# ការឃ្លាំមើលសេរីភាពមូលដ្ឋាន នៅកម្ពុជា

## របាយការណ៍ឆ្នាំ២០២៣

ខែមករា ដល់ខែធ្នូ
ឆ្នាំ២០២៣



### គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សមាគមអាដហុក
ADHOC

SOLIDARITY CENTER
AFL-CIO

ខែមេសា ឆ្នាំ២០២៤

គាំទ្រដោយ៖

ICNL
INTERNATIONAL CENTER FOR NOT-FOR-PROFIT LAW

# មាតិកា


មូលន័យសង្ខេប ........ 1
សេចក្តីផ្តើម ........ 5
ចំណុចគន្លឹះទី១ ៖ តើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ស្របតាមបទដ្ឋានច្បាប់អន្តរជាតិដែរឬទេ ? ........ 7
១១. អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ........ 9
១២. អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh អាចឱ្យរដ្ឋាភិបាលជ្រៀតជ្រែកបន្ថែមទៀតលើសិទ្ធិឯកជនភាព ........ 11
១៣. អនុក្រឹត្យលេខ ២១៧ ស្តីពីការរៀបចំ ការគ្រប់គ្រង និងបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ ........ 12
១៤. ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតកាន់តែរឹតត្បិតលើសិទ្ធិសេរីភាពខាងការបង្កើតសមាគម ........ 13
ចំណុចគន្លឹះទី២ ៖ តើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ត្រូវបានអនុវត្តនិងពង្រឹងការអនុវត្តបានត្រឹមត្រូវដែរឬទេ ? ........ 19
សេរីភាពខាងសមាគម ........ 24
សេរីភាពខាងការជួបប្រជុំ ........ 33
សេរីភាពខាងការបញ្ចេញមតិ ........ 38
ចំណុចគន្លឹះទី៣ ៖ តើបុគ្គលម្នាក់ៗយល់អំពីសេរីភាពមូលដ្ឋាន និងយល់ថាខ្លួនមានសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនេះដែរឬទេ ? ........ 47
៣.១ ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅតែបន្តធ្លាក់ចុះ ........ 48
៣.២ ពលរដ្ឋយល់ថាមិនសូវមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិជាពិសេសការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត និងការនិយាយទៅកាន់អ្នកសារព័ត៌មាន ........ 48
៣.៣ ចំនួនអ្នកដែលរឹតត្បិតសេរីភាពខ្លួនឯងជាញឹកញាប់មានការថយចុះចាប់តាំងពីឆ្នាំមុន ........ 50
៣.៤ ស្ត្រីយល់ថាមានសេរីភាពជាងបុរសក្នុងការបញ្ចេញមតិ ឬគំនិតមតិយោបល់ ........ 51
៣.៥ ពលរដ្ឋយល់ថាមិនសូវមានសេរីភាពក្នុងការចូលរួមជាមួយសមាគម ........ 52
៣.៦ ពលរដ្ឋយល់ថាមានសេរីភាពតិចតួចក្នុងការចូលរួមជីវភាពនយោបាយបើធៀបនឹងឆ្នាំមុន ........ 53
៣.៧ បុរសយល់ថាខ្លួនមានសេរីភាពជាងស្ត្រីក្នុងការចូលរួមនៅក្នុងជីវភាពនយោបាយ ........ 53
៣.៨ ការយល់របស់សាធារណជនអំពីច្បាប់ដែលពាក់ព័ន្ធសេរីភាពមូលដ្ឋាននៅតែទាប ........ 54
៣.៩ ពលរដ្ឋយល់ថាមិនសូវមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំតាមរយៈការធ្វើកូដកម្ម. 55
៣.១០ នៅឆ្នាំ២០២៣ ពលរដ្ឋវ័យផ្សេងៗគ្នាមានសេរីភាពចូលរួមការតវ៉ាដោយសន្តិវិធី ........ 56
៣.១១ ពលរដ្ឋម្នាក់ៗនៅតែមានការលំបាកក្នុងការរាយការណ៍អំពីការរំលោភសិទ្ធិមនុស្ស ........ 57
៣.១២ ពលរដ្ឋបន្តប្រឈមនៅពេលស្វែងរកដំណោះស្រាយចំពោះការរំលោភសិទ្ធិមនុស្ស ........ 58

ចំណុចគន្លឹះទី៤ ៖ តើអង្គការសង្គមស៊ីវិល និងសហជីព ត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាលបានដែរឬទេ?......59
៤.១ អង្គការសង្គមស៊ីវិលនិងសហជីព នៅមិនទាន់បានទទួលស្គាល់ពេញលេញថាជាដៃគូអភិវឌ្ឍន៍ស្របច្បាប់ និងមានសមត្ថភាព......60
៤.២ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពមានការលំបាកក្នុងការទទួលបានមូលនិធិពីរដ្ឋាភិបាល.61
៤.៣ ឱកាសក្នុងការចូលរួម និងសមាជិកភាពជាមួយរដ្ឋាភិបាលនៅតែជាបញ្ហាប្រឈមចម្បងសម្រាប់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព......61
៤.៤ អង្គការសង្គមស៊ីវិល និងសហជីព មិនទាន់អាចចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការតាក់តែងច្បាប់......62
៤.៥ កម្រិតកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល/សហជីព និងរដ្ឋាភិបាលមានការរីកចម្រើនគួរឱ្យកត់សម្គាល់......63
៤.៦ អង្គការសង្គមស៊ីវិល និងសហជីព ហាក់មានភាពងាយស្រួលក្នុងការទទួលបានព័ត៌មាន......64
សេចក្តីសន្និដ្ឋាន......66
ឧបសម្ព័ន្ធទី១ ៖ វិធីសាស្ត្រ និងការប្រមូលទិន្នន័យ......68
ឧបសម្ព័ន្ធទី ២ ៖ តារាងលទ្ធផលនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន......73
ឧបសម្ព័ន្ធទី៣ ៖ ការស្ទង់មតិជាសាធារណៈ......110
ឧបសម្ព័ន្ធទី៤៖ សំណួរ និងលទ្ធផលនៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព......122

# មូលន័យសង្ខេប

តួលេខទី១៖ ចំនួនហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពានសេរីភាពមូលដ្ឋានក្នុងឆ្នាំ២០២៣ តាមខេត្តនីមួយៗ




គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានពិនិត្យមើលទៅលើសេរីភាពមូលដ្ឋានចំនួន៣ គឺសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គម្រោងប្រើប្រាស់ឧបករណ៍ឃ្លាំមើលជាច្រើន ដោយផ្តល់នូវទិដ្ឋភាពបែបសត្យានុម័ត ថាតើសេរីភាពមូលដ្ឋានចែងនៅក្នុងច្បាប់នឹងអនុវត្តបែបណានៅទូទាំងប្រទេសកម្ពុជា។ ទិន្នន័យគម្រោងប្រមូលបាននៅចន្លោះថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បានបង្ហាញថាការអនុវត្តសេរីភាពមូលដ្ឋានដោយសន្តិវិធីបានជួបប្រទះការរឹតត្បិតកាន់តែខ្លាំងឡើងៗ ដូចជាការប្រែប្រួលផ្នែកច្បាប់នៅឆ្នាំ២០២៣ រួមមានច្បាប់បោះឆ្នោតដែលបានធ្វើវិសោធនកម្មបានធ្វើឱ្យថមថយដល់សំឡេងជំទាស់ ក្នុងអំឡុងពេលនៃការបោះឆ្នោតជាតិឆ្នាំ២០២៣។ ពលរដ្ឋបានរាយការណ៍ថាពួកគេមានអារម្មណ៍ថាមិនមានសេរីភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួននៅកម្រិតខ្ពស់ជាងឆ្នាំ២០២២ ហើយភាគរយនៃពលរដ្ឋដែលយល់ដឹងអំពីសេរីភាពមូលដ្ឋាននីមួយៗបានថយចុះកាន់តែតិចទៅៗ។ គួរកត់សម្គាល់ថា ខណៈដែលកិច្ចសហប្រតិបត្តិការរវាង អង្គការសង្គមស៊ីវិល/សហជីព និងរដ្ឋាភិបាលបានកើនឡើងគួរឱ្យកត់សម្គាល់ ក៏អង្គការសង្គមស៊ីវិល និងសហជីព កម្រត្រូវបានអនុញ្ញាតនៅក្នុងរបៀបវារៈធ្វើការសម្រេចចិត្តនោះដែរ។

តួលេខទី២៖ ចំនួនហេតុការណ៍ ការការពារ ការរឹតត្បិត ឬការរំលោភបំពានសេរីភាពមូលដ្ឋាន




គម្រោងបានកត់ត្រាហេតុការណ៍សរុបចំនួន ៦៣៣ ហេតុការណ៍ដែលជាប់ពាក់ព័ន្ធនឹងការអនុវត្តសេរីភាពមូលដ្ឋានក្នុងឆ្នាំ២០២៣។ ៣៧៧ នៃហេតុការណ៍សរុបមានការរំលោភបំពានយ៉ាងតិចមួយលើសេរីភាពមូលដ្ឋាន។

របកគំហើញសំខាន់ៗចំនួន៤ គាំទ្រដល់ការសន្និដ្ឋានរបស់គម្រោងថា លទ្ធភាពរបស់ពលរដ្ឋក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេមានកម្រិតទាបគួរឱ្យកត់សម្គាល់ក្នុងអំឡុងឆ្នាំ២០២៣។ ទី១ មាត្រា ១៤២ នៃវិសោធនកម្មច្បាប់បោះឆ្នោតកំណត់គោលដៅទៅលើអ្នកគាំទ្រនយោបាយជំទាស់ពីការអនុវត្តសេរីភាពខាងការបញ្ចេញមតិដោយសន្តិវិធី និងការមិនអនុវត្តស្របតាមរដ្ឋធម្មនុញ្ញ (របកគំហើញទីមួយ)។ ពលរដ្ឋកាន់តែច្រើនឡើងបង្ហាញពីការធ្លាក់ចុះការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន អ្នកសម្តែងមតិផ្នែកនយោបាយជំទាស់បានក្លាយជាគោលដៅរងគ្រោះ និងទទួលរងនូវការឃាយឃីតាមផ្លូវច្បាប់(របកគំហើញទីពីរ)។ ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋានបានថយចុះ ពលរដ្ឋបានកើនឡើងភាពភ័យ

ខ្លាចពីផលវិបាកនៅពេលអនុវត្តសេរីភាពទាំងនេះ(របកគំហើញទីបី)។ ជាចុងក្រោយ ទោះបីជាមានការបង្កើនកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលក៏ដោយ អង្គការសង្គមស៊ីវិល និងសហជីពនៅតែមិនត្រូវបានមើលឃើញថាជាភាគីពាក់ព័ន្ធដ៏មានសារៈសំខាន់(របកគំហើញទីបួន)។

**របកគំហើញទីមួយៈ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតមាត្រា១៤២ កំណត់មុខសញ្ញាអ្នកនយោបាយគណបក្សជំទាស់ក្នុងការអនុវត្តសេរីភាពខាងបញ្ចេញមតិ និងមិនស្របតាមរដ្ឋធម្មនុញ្ញ**

កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ព្រះមហាក្សត្របានប្រកាសដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត។ មាត្រា ១៤២ នៃច្បាប់បោះឆ្នោតដែលបានធ្វើវិសោធនកម្មនេះ បានរឹតត្បិតទៅលើសេរីភាពរបស់ពលរដ្ឋ និងអ្នកនយោបាយជំទាស់។

- មាត្រា ១៤២ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីដាក់ទោសព្រហ្មទណ្ឌទៅលើសកម្មភាពចំនួនពីរៈ ទី១) ការរារាំង ឬញុះញង់អ្នកបោះឆ្នោតឱ្យបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត និងទី២) ញុះញង់ឱ្យប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនទៅបោះឆ្នោត។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញបានចែងថា "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិផ្ទាល់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការជួបជុំ។" ការធ្វើឱ្យខូចសន្លឹកឆ្នោត គឺជាទម្រង់នៃការបញ្ចេញមតិមួយ។ អ្នកនយោបាយ អំពាវនាវឱ្យអ្នកគាំទ្ររបស់ខ្លួនធ្វើឱ្យខូចសន្លឹកឆ្នោត ឬមិនចូលរួមការបោះឆ្នោតបាន ក្នុងទម្រង់ជាការបង្ហាញអំពីការបញ្ចេញមតិរបស់ខ្លួនចំពោះដំណើរការបោះឆ្នោត។ ការកំណត់សកម្មភាពទាំងនេះជាបទល្មើសព្រហ្មទណ្ឌ ដូចមានក្នុងមាត្រា ១៤២ ផ្ទុយពីរដ្ឋធម្មនុញ្ញដែលអនុញ្ញាតឱ្យពលរដ្ឋអាចបញ្ចេញមតិយោបល់របស់ខ្លួនបាន។
- យោងតាមក្រមព្រហ្មទណ្ឌ ការញុះញង់ អាចចាត់ទុកបានថាជាសកម្មភាពបទល្មើសព្រហ្មទណ្ឌលុះត្រាតែវាជាការញុះញង់ឱ្យមានការធ្វើសកម្មភាពខុសច្បាប់ដូចជា ការប្រព្រឹត្តិបទឧក្រិដ្ឋជាដើម។ ដោយសារតែការមិនចូលរួមការបោះឆ្នោត និងការធ្វើឱ្យខូចសន្លឹកឆ្នោត មិនមែនជាអំពើព្រហ្មទណ្ឌដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនោះទេ ដូច្នេះការញុះញង់ឱ្យធ្វើសកម្មភាពទាំងនេះ មិនមានលក្ខណៈផ្ទុយនឹងច្បាប់។
- មាត្រា ១៤២ ដែលបានធ្វើវិសោធនកម្ម បានរំលោភបំពានសេរីភាពខាងការបញ្ចេញមតិរបស់អ្នកនយោបាយជំទាស់ព្រមទាំងរឹតត្បិតពួកគេមិនឱ្យចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចការសាធារណៈ។ មាត្រានេះ បានផ្តល់អំណាចក្នុងការចោទប្រកាន់ទៅលើគណបក្សនយោបាយជំទាស់ នៅក្នុងករណីដែលពួកគេលើកទឹកចិត្តឱ្យធ្វើខូចសន្លឹកឆ្នោត ក្នុងទម្រង់តាំមួយ ដែលអាចបង្កហានិភ័យដល់សិទ្ធិក្នុងការបញ្ចេញមតិ។

**របកគំហើញទីពីរៈ សេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋកាន់តែធ្លាក់ចុះ តាមរយៈអ្នកដែលមានទស្សនៈនយោបាយជំទាស់ត្រូវបានកំណត់មុខសញ្ញា**

តួលេខទី៣: ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌមកលើសមាជិកគណបក្សជំទាស់




ទិន្នន័យចំណុចគន្លឹះទីពីរ បង្ហាញថាពលរដ្ឋត្រូវបានទទួលរងសកម្មភាពរំលោភបំពាន ការរឹតត្បិត និងការឃ្លាំមើលនៅពេលអនុវត្តសេរីភាពមូលដ្ឋានរបស់របស់ខ្លួនក្នុងកម្រិតមួយខ្ពស់ជាងឆ្នាំមុនៗ។ នៅក្នុងចំណោមហេតុការណ៍ចំនួន ៦៣៣ ហេតុការណ៍ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានដែលបានកត់ត្រានៅក្នុងឆ្នាំ២០២៣ (កើនឡើង ១១% ធៀបនឹងឆ្នាំ២០២២) ក្នុងនោះមានហេតុការណ៍ចំនួន ២៥៥ ករណី ជាប់ពាក់ព័ន្ធនឹងការរឹតត្បិតយ៉ាងតិចមួយ និង ៣៧៧ ជាប់ពាក់ព័ន្ធករណីរំលោភបំពានមានយ៉ាងតិចមួយ។ ការកើនឡើងនៃហេតុការណ៍នេះ គឺពុំមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេ ពោលគឺកើតឡើងដោយសារតែការបង្ក្រាបទៅលើអ្នកនយោបាយជំទាស់ក្នុងអំឡុងពេលបោះឆ្នោតជាតិឆ្នាំ២០២៣។ ជាក់ស្តែង អ្នកការពារសិទ្ធិមនុស្ស អ្នកនយោបាយ និងអង្គការសង្គមស៊ីវិល ត្រូវបានក្លាយជាគោលដៅ។ ត្រឹមតែខែកក្កដា ឆ្នាំ២០២៣ មាត្រា ១៤២ នៃច្បាប់បោះឆ្នោត ត្រូវបានប្រើប្រាស់ ទៅលើសកម្មជន និងសមាជិកបក្សនយោបាយជំទាស់ចំនួន៤២នាក់។ ទន្ទឹមនឹងនេះ គម្រោងបានរកឃើញហេតុការណ៍ជាច្រើនដែលមានមនុស្សត្រូវរងការវាយប្រហារដោយសារតែជាប់ពាក់ព័ន្ធ ឬបង្ហាញអំពីការគាំទ្រគណបក្សជំទាស់។ ទន្ទឹមនឹងនេះ សមាជិកគណបក្សភ្លើងទៀនចំនួន ៣ រូប ត្រូវបានលុបឈ្មោះចេញពីមុខតំណែងមន្ត្រីរាជការនៅក្នុងឆ្នាំ២០២៣ នេះ ដោយសារតែជាប់ពាក់ព័ន្ធនឹងគណបក្សនយោបាយ ហើយមានសមាជិកយ៉ាងតិចចំនួន ១០ នាក់ផ្សេងទៀតបានរងការវាយដំរូបរាងកាយ។ មនុស្សម្នាក់រងការគំរាមសម្លាប់ និងប្រឈមនឹងការសួរនាំ បន្ទាប់ពីអនុញ្ញាតឱ្យមានការតម្លើងស្លាកគណបក្សភ្លើងទៀននៅខាងក្រៅផ្ទះរបស់ខ្លួន។ ការបង្ក្រាបទៅលើអ្នកដែលជំទាស់ផ្នែកនយោបាយក្នុងឆ្នាំ២០២៣ បង្ហាញថា សេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំរបស់ពលរដ្ឋ ត្រូវបានភ្ជាប់ទៅនឹងលក្ខខណ្ឌសច្ចភាព និងអនុលោមតាមគោលនយោបាយ ។

**របកគំហើញទីបី៖ ការយល់ដឹងអំពីសេរីភាពមូលដ្ឋានមានការធ្លាក់ចុះ ហើយពលរដ្ឋកាន់តែមានការភ័យខ្លាចចំពោះផលប៉ះពាល់នៅពេលអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន។**

ប្រជាធិបតេយ្យរីកចម្រើន គឺអាស្រ័យទៅលើចំណេះដឹងរបស់សាធារណជនអំពីសិទ្ធិ និងឆន្ទៈក្នុងការអនុវត្តសិទ្ធិទាំងនេះ។ ឆ្នាំ២០២៣ ត្រូវបានចាត់ទុកថាជាឆ្នាំដែលមានការដើរថយក្រោយពាក់ព័ន្ធនឹងការយល់ដឹងអំពីសេរីភាពមូលដ្ឋានរបស់ពលរដ្ឋ ហើយនៅក្នុងពេលមានបរិយាកាសនយោបាយមួយដែលសិទ្ធិរបស់ពលរដ្ឋត្រូវបានបដិសេធ នោះពលរដ្ឋម្នាក់ៗកាន់តែមានភាពស្ទាក់ស្ទើរក្នុងការអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួនថែមទៀត។ ភាគរយនៃអ្នកឆ្លើយតបដែលយល់ដឹងអំពីសេរីភាពមូលដ្ឋាននីមួយៗមានការធ្លាក់ចុះ ដោយក្នុងនោះអ្នកឆ្លើយតបចំនួន ៨% បានរាយការណ៍ថា ពួកគេយល់ដឹងច្បាស់អំពីសេរីភាពខាងការជួបប្រជុំ និងការបញ្ចេញមតិ

និង ៥% បានរាយការណ៍ថា ពួកគេយល់ដឹងយ៉ាងច្បាស់អំពីសេរីភាពខាងសមាគម។ លើសពីនេះទៀត នៅក្នុងឆ្នាំ២០២៣ ពលរដ្ឋហាក់មានអារម្មណ៍ថាមិនសូវមានសេរីភាពក្នុងការនិយាយជាមួយអ្នកសារព័ត៌មាន និយាយជាសាធារណៈ ឬនៅលើបណ្ដាញសង្គម។ បើមើលទៅលើចំណុចវិជ្ជមានវិញ បុគ្គលដែលកំណត់អត្តសញ្ញាណយេនឌ័រផ្សេងៗបានរាយការណ៍ថា ជានិច្ចកាល ឬជាប្រចាំ បានរីតត្បិតសេរីភាពខ្លួនឯង មានការថយចុះទាប បើធៀបទៅនឹងឆ្នាំ២០២២ (៤២%)។ ដោយឡែក បន្ទាប់ពីមានការកើនឡើងគួរឱ្យកត់សម្គាល់នូវទំនុកចិត្តរបស់ពលរដ្ឋនៅចន្លោះឆ្នាំ២០២០ និងឆ្នាំ២០២២ ដែលថារដ្ឋាភិបាលអាចនឹងផ្ដល់នូវដំណោះស្រាយទៅលើការរំលោភបំពានសិទ្ធិមនុស្ស ទំនុកចិត្តនេះ បានថយចុះមកត្រឹម ៣៤% នៅឆ្នាំ២០២៣។

**របកគំហើញទីបួន៖ ទោះបីជាមានកិច្ចសហប្រតិបត្តិការកើនឡើងជាមួយនឹងរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងសហជីព នៅតែមិនទាន់ត្រូវបានទទួលស្គាល់ថាជាភាគីពាក់ព័ន្ធដ៏មានសារៈសំខាន់**

តួលេខទី ៤៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលរាយការណ៍ថាចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងដំណើរការតាក់តែងច្បាប់ជាមួយរដ្ឋាភិបាល




នៅក្នុងឆ្នាំ២០២៣ ការស្ទង់មតិរបស់គម្រោងបានកត់ត្រាពីការកើនឡើងនៅក្នុងកិច្ចសហប្រតិបត្តិការផ្លូវការនិងក្រៅផ្លូវការ រវាងអង្គការសង្គមស៊ីវិល/សហជីព និងរដ្ឋាភិបាល។ ប៉ុន្តែ ភាគរយអ្នកដែលយល់ថា ពួកគេត្រូវបានទទួលស្គាល់ថាជាដៃគូស្របច្បាប់ គឺមានកម្រិតទាបបំផុត ចាប់តាំងពីការចាប់ផ្ដើមដំបូងរបស់គម្រោង។ ពុំមានភាពល្អប្រសើរណាមួយកើតឡើងគួរឱ្យកត់សម្គាល់នោះទេ ពាក់ព័ន្ធនឹងការចូលរួមរបស់អង្គការសង្គមស៊ីវិល និងសហជីពក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត និងដំណើរការតាក់តែងច្បាប់។ ភាគរយរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានដឹងអំពីឱកាសមូលនិធិរបស់រដ្ឋាភិបាលក៏នៅមានកម្រិតទាបផងដែរ។ ការមិនបញ្ចូលអង្គការសង្គមស៊ីវិល និងសហជីពទៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត និងមិនបានដឹងអំពីមូលនិធិ បានធ្វើឱ្យអង្គការសង្គមស៊ីវិល និងសហជីពខកខានក្នុងការតំណាងឱ្យទស្សនៈដ៏មានតម្លៃពីក្រុមជនងាយរងគ្រោះ និងសហគមន៍មូលដ្ឋាន ដែលអាចធ្វើឱ្យថយចុះនូវបរិយាប័ន្នដែលឈានទៅរកអភិបាលកិច្ចល្អ។

| ពណ៌កំណត់ចំណាំក្នុងរបាយការណ៍នេះ | |
|---|---|
| | សេរីភាពខាងសមាគម |
| | សេរីភាពខាងការបញ្ចេញមតិ |
| | សេរីភាពខាងការជួបប្រជុំ |
| | សេរីភាពទាំងបី |

# សេចក្ដីផ្ដើម

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានដែលបានចាប់ផ្ដើមអនុវត្តពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ គឺជាគម្រោងពិនិត្យតាមដាន និងវាយតម្លៃអំពីស្ថានភាពសេរីភាពមូលដ្ឋានចំនួនបី គឺសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ ("សេរីភាពមូលដ្ឋាន")[1] នៅក្នុងប្រទេសកម្ពុជា។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន តាមដានការអនុវត្តសេរីភាពមូលដ្ឋានដោយប្រើប្រាស់ឧបករណ៍តាមដានការឃ្លាំមើល។ នេះជារបាយការណ៍ប្រចាំឆ្នាំ២០២៣ គូសបញ្ជាក់ចំណុចគន្លឹះសំខាន់ៗ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានមានគោលបំណងបង្ហាញពីទិដ្ឋភាពបែបសត្យានុម័ត អំពីស្ថានភាពសេរីភាពមូលដ្ឋាននៅកម្ពុជានាពេលបច្ចុប្បន្ននេះដោយកំណត់និន្នាការដែលទាក់ទងទៅនឹងច្បាប់ និងការអនុវត្តសេរីភាពមូលដ្ឋាន។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រុមការងារគម្រោងបានបង្កើតនូវឧបករណ៍តាមដានការឃ្លាំមើលក្នុងការផ្ដល់ជាក្របខណ្ឌសត្យានុម័តនិងតុល្យភាព សម្រាប់ពិនិត្យអំពីស្ថានភាពសេរីភាពមូលដ្ឋាននៅកម្ពុជាដោយផ្ដោតលើការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងពលរដ្ឋ ព្រមទាំងភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល ជាមួយនឹងរដ្ឋាភិបាល។ ឧបករណ៍តាមដានឃ្លាំមើលវាយតម្លៃនេះ វាយតម្លៃជាលក្ខណៈប្រព័ន្ធថាតើសេរីភាពមូលដ្ឋានត្រូវបានធានា និងអនុវត្តនៅក្នុងប្រទេសកម្ពុជាដល់កម្រិតណា។

ឧបករណ៍តាមដានការឃ្លាំមើលមានធាតុផ្សំចំនួន ១៥២ ដែលឆ្លើយតបទៅនឹងចំណុចគន្លឹះសំខាន់ៗចំនួន ៤៖

**ចំណុចគន្លឹះទី១៖** ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិ

**ចំណុចគន្លឹះទី២៖** ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងប្រតិបត្តិតាម

**ចំណុចគន្លឹះទី៣៖** បុគ្គលយល់ដឹងអំពីសេរីភាពមូលដ្ឋាន និងសិទ្ធិដែលពាក់ព័ន្ធនិងយល់ថាខ្លួនអាចអនុវត្តសេរីភាពនេះដោយសេរី និង

**ចំណុចគន្លឹះទី៤៖** អង្គការសង្គមស៊ីវិលនិងសហជីពត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល។

[1] ក្នុងគោលបំណងនៃរបាយការណ៍នេះ សេរីភាពមូលដ្ឋានរួមមាន៖ សេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបជុំ។ គម្រោងប្រើប្រាស់និយមន័យនៃពាក្យសមាគម ដែលកំណត់ដោយអ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិខាងការជួបប្រជុំដោយសន្តិវិធី និងសមាគម។

នៅក្នុងរបាយការណ៍ឆ្នាំ២០២៣ វិធីសាស្ត្រប្រមូលទិន្នន័យចំនួន ៦ ត្រូវបានប្រើដើម្បីវាស់ចំណុចគន្លឹះទាំងនេះ ៖ ការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន[2] យន្តការរាយការណ៍ពីហេតុការណ៍ដែលបានកើតឡើង[3] ការពិនិត្យមើលទៅលើច្បាប់ដែលពាក់ព័ន្ធ ("ការពិនិត្យច្បាប់")[4] ឧបករណ៍វាយតម្លៃការចុះបញ្ជិកាសហជីព[5] ការស្ទង់មតិជាសាធារណៈ[6] និងការស្ទង់មតិជាមួយនឹងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ("ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព")[7]។ របាយការណ៍នេះបង្ហាញអំពីការវិភាគនៃចំណុចគន្លឹះនីមួយៗ និងរបស់ផ្សេងៗដោយផ្អែកលើទិន្នន័យដែលប្រមូលបាននៅក្នុងឆ្នាំ២០២៣។

[2] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាជាអ្នកតាមដានទៅលើការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាប្រចាំ ។ ការតាមដាននេះផ្តោតទៅលើការផ្សព្វផ្សាយរបស់សារព័ត៌មានពីសេរីភាពខាងសមាគមនិងសិទ្ធិទាក់ទិនដទៃទៀត និងត្រូវកំណត់ដោយគោលការណ៍ណែនាំអំពីការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដោយផ្អែកទៅលើឧបករណ៍តាមដានការឃ្លាំមើល។

[3] ការរាយការណ៍ពីហេតុការណ៍ត្រូវបានប្រមូលតាមរយៈទម្រង់មួយដែលត្រូវបានបង្កើតឡើងដើម្បីកត់ត្រានូវការរឹតត្បិតទៅលើសេរីភាពខាងសមាគមនិងសិទ្ធិដែលទាក់ទងដទៃទៀតជាមួយបុគ្គល និងសមាគម។

[4] ការពិនិត្យលើច្បាប់ត្រូវបានធ្វើឡើងដោយមានការវិភាគពីអ្នកជំនាញទៅលើខ្លឹមសារនៃច្បាប់ គោលនយោបាយ របាយការណ៍ និងឯកសារផ្លូវការដទៃទៀតដើម្បីធ្វើការវាយតម្លៃឱ្យដឹងថាតើមានការធានាដោយច្បាប់ប៉ុណ្ណា និងមានលក្ខខណ្ឌណាផ្សេងទៀតដែរឬទេដែលធានាដល់សេរីភាពមូលដ្ឋាន ។

[5] ឧបករណ៍វាយតម្លៃការចុះបញ្ជីសហជីពកត់ត្រាទុកនូវបទពិសោធន៍របស់តំណាងសហជីព ដែលព្យាយាមចុះបញ្ជីរបស់ពួកគេដែលតម្រូវតាមច្បាប់សហជីព។

[6] ការស្ទង់មតិជាសាធារណៈគឺដើម្បីស្វែងយល់ពីការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាន។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងជាភាសាខ្មែរចន្លោះពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

[7] ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវធ្វើឡើងជាប្រចាំឆ្នាំតាមរយៈប្រព័ន្ធអ៊ីនធឺណិត និងការសម្ភាសផ្ទាល់ដើម្បីស្វែងយល់ពីទស្សនៈ និងបទពិសោធន៍របស់ថ្នាក់ដឹកនាំពាក់ព័ន្ធនឹងលទ្ធភាពរបស់ពួកគេក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ នៅក្នុងឆ្នាំ២០២៣ ការស្ទង់មតិនេះត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១៤ ខែសីហា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

## ចំណុចគន្លឹះទី១ ៖ តើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ស្របតាមបទដ្ឋានច្បាប់អន្តរជាតិដែរឬទេ?

ចំណុចគន្លឹះទី១ ពិនិត្យវិសាលភាពក្របខណ្ឌច្បាប់កម្ពុជា ដែលអនុលោមតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ដែលពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន។[8] ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ រដ្ឋាភិបាលបានប្រកាសដាក់ឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត និងអនុក្រឹត្យចំនួនបីរួមមាន អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh អនុក្រឹត្យលេខ ២១៧ ស្តីពីការរៀបចំ ការគ្រប់គ្រង និងបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ។ អនុក្រឹត្យដែលបានអនុម័ត និងវិសោធនកម្មច្បាប់ទាំងនេះ បង្កឱ្យមានការព្រួយបារម្ភ ដល់ការការពារនិងអនុវត្តសេរីភាពមូលដ្ឋាន។

**របកគំហើញសំខាន់ៗ៖** អនុក្រឹត្យថ្មីចំនួនបី និងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត មិនអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន។ អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម អាចប្រើជាឧបករណ៍មួយដើម្បីឃ្លាំមើល និងរឹតត្បិតទូទៅ ទៅលើសិទ្ធិប្រជាពលរដ្ឋ។ អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh មានគោលបំណងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ ចំណេញពេលវេលា និងកាត់បន្ថយការចំណាយនានារបស់អ្នកប្រើប្រាស់។ ដោយឡែក ចាំបាច់ណាស់ត្រូវជានាថាថ្នាល និងការប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន (blockchain) នឹងមិនបង្កឱ្យមាន ហានិភ័យកាន់តែធ្ងន់ធ្ងរថែមទៀត ចំពោះការរំលោភបំពានសិទ្ធិមនុស្សនៅក្នុងប្រទេសនោះទេ។ អនុក្រឹត្យលេខ ២១៧ ស្តីពីការរៀបចំ ការគ្រប់គ្រង និងបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ មានបញ្ញត្តិដែលអាចយកមកប្រើជាឧបករណ៍មួយដើម្បីស្តាប់ការសន្ទនាផ្ទាល់ខ្លួន ដែលជាការរំលោភសិទ្ធិដោយមិនមានការអនុញ្ញាត

[8] របកគំហើញនៅក្នុងចំណុចគន្លឹះទី១ ផ្អែកចម្បងលើការពិនិត្យឯកសារច្បាប់។ ការពិនិត្យឯកសារនេះ ធ្វើការវិភាគលើវិសាលភាពដែលក្របខ័ណ្ឌច្បាប់ជាតិទាក់ទងនឹងសេរីភាពមូលដ្ឋានអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលកើតចេញពីសន្ធិសញ្ញាអន្តរជាតិ និងបទដ្ឋានអន្តរជាតិដូចដែលគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (អ.ស.ប) និងអ្នករាយការណ៍ពិសេសរបស់ អ.ស.ប បានបកស្រាយ។ នៅក្នុងរបាយការណ៍នេះ "ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" សំដៅដល់ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងសេរីភាពមូលដ្ឋាន រួមមានសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិដែលបានកើតចេញពីសន្ធិសញ្ញាអន្តរជាតិមានប្រទេសកម្ពុជាជារដ្ឋហត្ថលេខី។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាផ្តល់ធម្មនុញ្ញភាពដល់សិទ្ធិមនុស្សដែលមានចែងក្នុងធម្មនុញ្ញ អ.ស.ប សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងកតិកាសញ្ញា និងអនុសញ្ញាទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។ សេចក្តីសម្រេចចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបកស្រាយជាផ្លូវការនូវមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ថាសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន គឺអាចអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់ជាតិ។ សូមមើលសេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សន្ធិសញ្ញាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នរួមមាន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ បន្ថែមក្រៅពីសន្ធិសញ្ញាទាំងនេះ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ក៏ប្រើបទដ្ឋានអន្តរជាតិផ្សេងៗ ដែលគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប និងអ្នករាយការណ៍ពិសេសរបស់ អ.ស.ប បានបកស្រាយផងដែរ។

ដូចជាសិទ្ធិឯកជនភាព សិទ្ធិទទួលបានព័ត៌មាន និងសេរីភាពខាងការបញ្ចេញមតិ។ ជាងចុងក្រោយ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត កាន់តែរឹតត្បិតលើសិទ្ធិសេរីភាពខាងសមាគម ជាពិសេសចំពោះសមាជិកគណបក្សជំទាស់។ ច្បាប់ទាំងនេះបង្ហាញពីភាពរួមតូចចង្អៀតនៃសិទ្ធិពលរដ្ឋ និងនយោបាយ ព្រមទាំងបង្ក្រាបលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស និងសេរីភាពខាងការបញ្ចេញមតិ។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ដែលមានអានុភាពអនុវត្តនៅក្នុងច្បាប់កម្ពុជា យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ។[9] ចំពោះការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងការជួបប្រជុំ ឬសេរីភាពខាងការបង្កើតសមាគម ដែលត្រូវបានអនុញ្ញាតនៅក្រោមច្បាប់អន្តរជាតិ ការរឹតត្បិតត្រូវតែអនុវត្តតាមការវិនិច្ឆ័យលើជាតុផ្សំចំនួនបីដែលមានចែងក្នុងមាត្រា ១៩ [10] មាត្រា ២១ [11] និងមាត្រា ២២[12] នៃកតិកាសញ្ញា ក.អ.ស.ព.ន ។

**អនុញ្ញាតឱ្យមានការរឹតត្បិតណាមួយលើសេរីភាពខាងការបញ្ចេញមតិក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិបានលុះត្រាតែ៖**

១) មានចែងដោយច្បាប់មានភាពជាក់លាក់ និងច្បាស់លាស់។
២) គោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ និង
៣) មានភាពចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ និងសមាមាត្រទៅនឹងគោលបំណង។

*** ជាតុផ្សំចំនួនបីអនុវត្តចំពោះមាត្រា ២១ និង ២២ នៃកតិកាសញ្ញា ក.អ.ស.ព.ន។*

---

[9] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ ២, https://ccc.gov.kh/detail_info_en.php?_txtID=453។

[10] ក.អ.ស.ព.ន មាត្រា ១៩(៣); អនុសាសន៍ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប៖ មាត្រា ១៩៖ សេរីភាពខាងការបញ្ចេញយោបល់ និងមតិ CCPR/C/GC/៣៤ (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) វាក្យខណ្ឌ ២៥, https://www2.ohchr.org/english/bodies/hrc/docs/gc34.pdf។

[11] ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់ អ.ស.ប "របាយការណ៍រួមរបស់អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងសមាគម និងរបស់អ្នករាយការណ៍ពិសេស ស្តីពីការអនុវត្តដោយបង្ខំក្រៅប្រព័ន្ធតុលាការភ្លាមៗ ឬតាមអំពើចិត្តលើការគ្រប់គ្រងត្រឹមត្រូវនៃការជួបប្រជុំ A/HRC/៣១/៦៦ (ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦) វាក្យខណ្ឌ ៣០, https://undocs.org /A/HRC/31/66។

[12] ក.អ.ស.ព.ន មាត្រា ២២ ។

## ១.១. អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម បង្កឱ្យមានហានិភ័យដល់ការទទួលបានសេរីភាពមូលដ្ឋាន

អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម (អនុក្រឹត្យលេខ ៤១) ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន ១៥ ជំពូក និង ៤៣ មាត្រា។ ការចុះបញ្ជីឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ជាកាតព្វកិច្ច លើកលែងតែឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមរបស់អ្នកទេសចរ ឬអ្នកធ្វើដំណើរពីក្រៅប្រទេស ដែលស្នាក់ក្នុងព្រះរាជាណាចក្រកម្ពុជាមិនលើសរយៈពេលហុកសិបថ្ងៃ។ អនុក្រឹត្យនេះមានគោលបំណងទប់ស្កាត់ និងកាត់បន្ថយការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមក្លែងក្លាយ ឧបករណ៍ដែលជាផលចោរកម្ម និងឧបករណ៍ដែលនាំចូលខុសច្បាប់ ការពារសុខភាព សុវត្ថិភាព និងសិទ្ធិអ្នកប្រើប្រាស់ ធ្វើឱ្យប្រសើរឡើងគុណភាព សេវាទូរគមនាគមន៍ ជំរុញនិងលើកកម្ពស់ការប្រកួតប្រជែងដោយស្មោះត្រង់និងតម្លាភាព និងចូលរួមកៀរគរ ចំណូលជាតិប្រកបដោយប្រសិទ្ធភាព។

ដូច្នេះ គ្រប់ទូរសព្ទ និងប្រភេទកុំព្យូទ័រមួយចំនួន សៀវភៅអេឡិចត្រូនិក និងឧបករណ៍អេឡិចត្រូនិកផ្សេងទៀតដែលប្រើស៊ីមកាត ត្រូវចុះបញ្ជីតាមប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ចល័តអន្តរជាតិ (IMEI) នៅក្នុងប្រព័ន្ធទិន្នន័យរបស់រដ្ឋាភិបាល។ ក្នុងករណីខកខានមិនបានអនុវត្តតាម នឹងទទួលរងការដាក់ទណ្ឌកម្ម និងការពិន័យអន្តរការណ៍។ អនុក្រឹត្យប្រគល់អាណត្តិជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការដឹកនាំ និងគ្រប់គ្រងការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ព្រមទាំងប្រមូលកម្រៃពីការចុះបញ្ជីនេះ។ អនុក្រឹត្យនេះមានភាពមិនច្បាស់លាស់ក្នុងការកំណត់ពីដំណើរការនៃការចុះបញ្ជី ប្រភេទទិន្នន័យដែលត្រូវប្រមូល រក្សាទុក និងប្រើប្រាស់ និងរបៀបដែលរដ្ឋាភិបាលការពារឯកជនភាពរបស់អ្នកប្រើប្រាស់។ ការណែនាំ និងប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ត្រូវបានកំណត់តាមប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូចគ្នាដែរ បែបបទ និងនីតិវិធីនៃការដោះស្រាយវិវាទ ត្រូវបានកំណត់តាមប្រកាស ដែលនាំឱ្យមានភាពមិនច្បាស់លាស់ ជុំវិញការអនុលោមតាមដំណើរការត្រឹមត្រូវ។ លើសពីនេះ អនុក្រឹត្យត្រូវបានអនុម័តដោយមិនមានការចូលរួមពីក្រុមអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀតឡើយ។

អនុក្រឹត្យនេះមិនបានបញ្ជាក់ថា តើដំណើរការនៃការចុះបញ្ជីនឹងសម្រេចបាននូវគោលបំណងមិនច្បាស់លាស់ខាងលើដោយរបៀបណានោះទេ ហើយក៏មិនមានភាពសមាមាត្រ ឬចាំបាច់ ដើម្បីសម្រេចបាននូវគោលបំណងទាំងនោះដែរ។ មិនមានភស្តុតាងបញ្ជាក់ថាប្រព័ន្ធចុះបញ្ជីស៊ីមមានប្រសិទ្ធភាព ក្នុងការទប់ស្កាត់ការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមក្លែងក្លាយ ជាផលចោរកម្ម ឬដែលនាំចូលខុសច្បាប់ ឬ ឧបករណ៍ដែលជាផលចោរកម្ម និងឧបករណ៍ដែលនាំចូលខុសច្បាប់នោះទេ។ អនុក្រឹត្យនេះក៏មិនបានពន្យល់ថាតើដំណើរការនៃការចុះបញ្ជីនឹងការពារសុខភាព សុវត្ថិភាព និងសិទ្ធិពលរដ្ឋ និងលើកកម្ពស់ការប្រកួតប្រជែងដោយស្មោះត្រង់ និងតម្លាភាពដោយរបៀបណាដែរ។ ផ្ទុយទៅវិញ អនុក្រឹត្យនេះបាននាំមកនូវកង្វល់យ៉ាងធ្ងន់ធ្ងរដែលអនុញ្ញាតឱ្យ

រដ្ឋាភិបាលតាមដាន និងឃ្លាំមើលប្រជាពលរដ្ឋយ៉ាងងាយស្រួល ជាពិសេសក្រុមអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន សកម្មជនបរិស្ថាន និងសំឡេងជំទាស់ ម្យ៉ាងវិញទៀតដោយសារតែអនុក្រឹត្យនេះមិនបានចែងថា តើព័ត៌មានដែលទទួលបានពីដំណើរការនៃការចុះបញ្ជីនេះ នឹងត្រូវរក្សាជាការសម្ងាត់ដោយរបៀបណានោះទេ។ ដោយសារតែកង្វះក្របខណ្ឌការពារទិន្នន័យ ដូច្នេះហើយព័ត៌មានដែលមាននៅក្នុងស៊ីមកាតអាចត្រូវបានគេស្វែងរកយ៉ាងងាយស្រួល និងចែករំលែកជាមួយប្រព័ន្ធទិន្នន័យផ្សេងៗ និងភាគីទីបីផងដែរ។ ប្រការនេះអាចជាការរំលោភលើសិទ្ធិឯកជនភាព ដោយសារឧបករណ៍នេះអាចបង្កើនសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការបិទឧបករណ៍ ព្រមទាំងតាមដាន និងឃ្លាំមើលប្រជាពលរដ្ឋ។ ជាងនេះទៀត ច្បាប់នេះបានលុបបំបាត់ការការពារភាពអនាមិកនៅក្នុងវិស័យទូរគមនាគមន៍ ធ្វើឱ្យធ្លាក់ចុះនូវសិទ្ធិរបស់ពលរដ្ឋក្នុងការទទួលបានការទំនាក់ទំនងដោយសុវត្ថិភាព ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិសេរីភាពខាងសមាគម។

ទោះបីជាការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិអាចធ្វើឡើងតាមច្បាប់ក៏ដោយ ប៉ុន្តែការរឹតត្បិតនេះមានលក្ខណៈគតិយុត្តបានលុះត្រាតែលក្ខខណ្ឌទាំងបីនៃមាត្រា ១៩(៣) នៃកតិកាសញ្ញា ក.អ.ស.ព.ន ត្រូវបានបំពេញ៖ (១) ការរឹតត្បិតត្រូវបានបញ្ញត្តិដោយច្បាប់ស្របតាមបទដ្ឋាននៃភាពជាក់លាក់ និងច្បាស់លាស់ (២) ការរឹតត្បិតត្រូវធ្វើឡើងដោយមានការគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬការការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬសុខភាពសាធារណៈ ឬក្រមសីលធម៌ និង (៣) ការរឹតត្បិតត្រូវផ្អែកតាមភាពចាំបាច់ និងសមាមាត្រស្របតាមគោលបំណងជាក់លាក់។ គោលបំណងដែលបានកំណត់ក្នុងការបង្កើតអនុក្រឹត្យនេះ មិនបំពេញតាមលក្ខខណ្ឌគតិយុត្តនៃជាតុផ្សំទីមួយក្នុងចំណោមជាតុផ្សំទាំងបីក្នុងមាត្រានៃកតិកាសញ្ញា និង ដំណើរការខុសពីគោលការណ៍នៃភាពចាំបាច់ និងសមាមាត្រ ដែលតាមរយៈនេះ ការជ្រៀតជ្រែកលើសិទ្ធិត្រូវតែមានភាពចាំបាច់ស្របតាមគោលបំណងគតិយុត្ត និងជាមធ្យោបាយមួយក្នុងការសម្រេចបាននូវគោលបំណងនេះ ដោយមានផលរំខានតិចតួចបំផុត។ ភាពស្រពិចស្រពិលនៃខ្លឹមសារដែលមានចែងក្នុងបទប្បញ្ញត្តិទាំងនេះ អាចអនុញ្ញាតឱ្យអាជ្ញាធររំលោភលើសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ដែលភាគច្រើនផ្តន្ទាទោសចំពោះមាតិកាតាមប្រព័ន្ធអ៊ីនធឺណិត និងការបញ្ចេញមតិដែលរិះគន់រដ្ឋាភិបាល ព្រមទាំងមន្ត្រីសាធារណៈ។ ជាងនេះទៀត ការរឹតត្បិតមិនផ្អែកតាមគោលការណ៍នៃភាពចាំបាច់ ឬភាពសមាមាត្រនោះទេ នៅពេលដែលមានការរឹតត្បិតតិចតួច គឺត្រូវធ្វើឡើងក្នុងគោលបំណងដើម្បីទប់ស្កាត់ការប្រើប្រាស់ឧបករណ៍ក្លែងក្លាយ ឧបករណ៍ដែលជាផលចោរកម្ម ឬឧបករណ៍ដែលនាំចូលខុសច្បាប់។ បទប្បញ្ញត្តិទាំងនេះមិនស្របតាមមាត្រា១៩ នៃ ក.អ.ស.ព.ន ដែលរឹតត្បិតសេរីភាពខាងការបញ្ចេញមតិ និងទទួលបានព័ត៌មាន។

បទប្បញ្ញត្តិដូចបានពិភាក្សាខាងលើ មិនអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិស្តីពីសិទ្ធិឯកជនភាព ដូចក្នុងមាត្រា ១៧ នៃក.អ.ស.ព.ន។ សេចក្តីសម្រេចលេខ ៦៨/១៦៧ របស់ អ.ស.ប[13] បានអំពាវនាវឱ្យបណ្តារដ្ឋទាំងអស់គោរព និងការពារសិទ្ធិឯកជនភាព រួមទាំងក្នុងបរិបទនៃការប្រាស្រ័យទាក់ទងតាមប្រព័ន្ធឌីជីថល ក៏ដូចជាបង្កើតលក្ខខណ្ឌទប់ស្កាត់ការរំលោភសិទ្ធិនេះ រួមទាំងធានាបានថា ច្បាប់ជាតិដែលពាក់ព័ន្ធការគោរពតាមកាតព្វកិច្ចក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ពិតជាបញ្ជាក់ច្បាស់ណាស់ អនុក្រឹត្យនេះមានលក្ខណៈផ្ទុយនឹងសេចក្តីសម្រេចនេះ ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

### ១.២. បញ្ញត្តិមិនច្បាស់លាស់នៃអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh អាចឱ្យរដ្ឋាភិបាលជ្រៀតជ្រែកបន្ថែមទៀតលើសិទ្ធិឯកជនភាព

អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារឌីជីថល verify.gov.kh (អនុក្រឹត្យលេខ ០៥២) បានដាក់ឱ្យប្រើថ្នាលបង្កើតឡើងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីលុបបំបាត់ការក្លែងបន្លំឯកសារ ផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ ផ្តល់ទំនុកចិត្ត ចំណេញពេលវេលា និងកាត់បន្ថយការចំណាយនានា ព្រមទាំងជំរុញការធ្វើបរិវត្តកម្មឌីជីថលសេវាសាធារណៈ។ ការផ្ទៀងផ្ទាត់ឯកសារធ្វើឡើងដោយបញ្ចូល យូ.អ.កូដ ស្តង់ដា នៅលើឯកសារដែលអាចផ្ទៀងផ្ទាត់បាននៅក្នុងថ្នាល verify.gov.kh ។ ទោះបីជាអនុក្រឹត្យនេះមិនបានបញ្ជាក់ថា តើឯកសារអ្វីខ្លះអាចដាក់បញ្ចូល យូ.អ.កូដ ស្តង់ដាដែលអាចផ្ទៀងផ្ទាត់បានក៏ដោយ ក៏មាត្រា ៤ ចែងថា ក្រសួងរដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈត្រូវធ្វើផែនការដាក់បញ្ចូល យូ.អ.កូដ ស្តង់ដាដែលអាចផ្ទៀងផ្ទាត់បានតាមថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh លើឯកសាររបស់ខ្លួន។ ដូចគ្នាដែរ នីតិបុគ្គលឯកជនដែលមានបំណងដាក់បញ្ចូល យូ.អ.កូដ ស្តង់ដាលើឯកសាររបស់ខ្លួនតាមថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh អាចធ្វើការស្នើសុំមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

យោងតាមមាត្រា ៨ នៃអនុក្រឹត្យនេះចែងថា ក្រសួងរដ្ឋបាលថ្នាក់ក្រោមជាតិ នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជនដែលទទួលបានឯកសារដែលដាក់បញ្ចូល យូ.អ.កូដ ស្តង់ដា មានសិទ្ធិរក្សាទុកឯកសារក្នុង (១) ប្រព័ន្ធទិន្នន័យរបស់ខ្លួន (២) របស់មជ្ឈមណ្ឌលទិន្នន័យរបស់ប្រតិបត្តិករដែលទទួលបានអាជ្ញាបណ្ណពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬ (៣) ស្នើសុំឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រក្សាទុកទិន្នន័យក្នុងមជ្ឈមណ្ឌលទិន្នន័យជាតិ។

អនុក្រឹត្យមានភាពស្រពិចស្រពិលនៅត្រង់នីតិវិធីដែលអាជ្ញាធរពាក់ព័ន្ធ ត្រូវការពារទិន្នន័យទាំងឡាយដែលប្រមូលបានតាមរយៈ យូ.អ.កូដ។ ដំណើរការនេះក៏អាចរំខានដល់សិទ្ធិឯកជនភាពដែលត្រូវបានការពារ

[13] សេចក្តីសម្រេចលេខ ៦៨/១៦៧ របស់ អ.ស.ប។ អាចរកបាននៅលើ https://documents-dds-ny.un.org/doc/UNDOC/GEN/N13/449/47/PDF/N1344947.pdf?OpenElement ។

ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។[14] ជាការពិត ករណីដែលក្រសួង រដ្ឋបាលថ្នាក់ក្រោមជាតិ នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជនដែលទទួលបានឯកសារ រួមទាំង យ្យ.អ.កូដ ស្តង់ដា មានសិទ្ធិរក្សាទុកឯកសារលើប្រព័ន្ធទិន្នន័យរបស់ខ្លួន ឬរបស់មជ្ឈមណ្ឌលទិន្នន័យរបស់ប្រតិបត្តិករដែល ទទួលបានអាជ្ញាបណ្ណពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អាចអនុញ្ញាតឱ្យរដ្ឋាភិបាលទទួលបានព័ត៌មាន ឯកជនដែលជាប់ពាក់ព័ន្ធនឹងបុគ្គលម្នាក់ៗ ហើយអាចកំណត់មុខសញ្ញាលើក្រុមអ្នកការពារសិទ្ធិមនុស្ស សកម្ម ជន អ្នកសារព័ត៌មាន និងសមាជិកបក្សជំទាស់។

ដូចគ្នាដែរ ក្រសួងនានាអាចស្នើសុំមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យរក្សាទុកទិន្នន័យនៅ ក្នុងមជ្ឈមណ្ឌលទិន្នន័យជាតិដែលជាទីតាំងកណ្តាលសម្រាប់រក្សាទុកទិន្នន័យ ជាពិសេសសម្រាប់រដ្ឋាភិបាល ដែលគម្រោងនេះបានសាងសង់កាលពីខែកក្កដា ឆ្នាំ២០២៣ និងគ្រោងបញ្ចប់នៅឆ្នាំ២០២៥។ ការជ្រៀតជ្រែក លើឯកជនភាព និងភាពអនាមិករបស់ម្ចាស់សិទ្ធិក្នុងករណីបែបនេះ បង្កភាពងាយស្រួលដល់រដ្ឋក្នុងការឃ្លាំមើល ការទំនាក់ទំនង និងមានផលប៉ះពាល់ដែលបន្ទប់បង្អាក់ និងរារាំងដល់ការផ្សព្វផ្សាយព័ត៌មាន។ កង្វះច្បាប់ ការពារឯកជនភាព ជាបញ្ហាដែលគួរឱ្យព្រួយបារម្ភអំពីសុវត្ថិភាពព័ត៌មានឯកជន។

### ១.៣. បញ្ញត្តិមិនច្បាស់លាស់នៃអនុក្រឹត្យលេខ ២១៧ ស្តីពីការរៀបចំ ការគ្រប់គ្រង និងបែងចែក វិសាលគមន៍ប្រេកង់វិទ្យុ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិឯកជនភាពរបស់ម្ចាស់អាជ្ញាបណ្ណវិសាលគម ន៍ប្រេកង់វិទ្យុ

អនុក្រឹត្យនេះប្រគល់អាណត្តិដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាស្ថាប័នមានសមត្ថកិច្ច ទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធាន វិសាលគមន៍ប្រេកង់វិទ្យុ បន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណប និង គន្លងផ្កាយរណបនៅកម្ពុជា ហើយតម្រូវឱ្យបុគ្គលដែលមានបំណងប្រើប្រាស់វិសាលគមន៍ប្រេកង់វិទ្យុដើម្បី ចែកចាយសេវាផ្សព្វផ្សាយ មកដាក់ពាក្យសុំនៅក្រសួងព័ត៌មាន។

អនុក្រឹត្យនេះមានគោលបំណងពង្រឹងការគ្រប់គ្រង និងប្រើប្រាស់ធនធានកម្ររបស់ជាតិ (សំដៅទៅ លើធនធានធម្មជាតិ និងចំនួនវិសាលគមន៍ប្រេកង់វិទ្យុនៅក្នុងប្រទេសមានកម្រិត) ដោយជាផ្នែកមួយនៃការ ប្រកួតប្រជែងដោយស្មោះត្រង់ និងស្របច្បាប់ ព្រមទាំងការប្រមូលចំណូលជាតិ។ យោងតាមមាត្រា ១ នៃអនុ ក្រឹត្យនេះ បានកំណត់គោលការណ៍ វិធាន និងសមត្ថភាពនៃការគ្រប់គ្រងវិសាលគមន៍ប្រេកង់វិទ្យុ និងបន្ទារ ប្រេកង់វិទ្យុសម្រាប់ផ្កាយរណប ហើយគន្លងផ្កាយរណបដែលបានបង្កើតឡើងក្នុងគោលបំណងរៀបចំបែង ចែក និងប្រើប្រាស់វិសាលគមន៍ប្រេកង់វិទ្យុប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ យោងតាមមាត្រា ២ នៃអនុក្រឹត្យលេខ ២១៧ បានដាក់បញ្ចូលលក្ខខណ្ឌមិនច្បាស់លាស់នៃបញ្ហាសន្តិសុខ និងការពារជាតិ *ដោយ ចែងថា អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះតែវិសាលគមន៍ប្រេកង់វិទ្យុ និងបន្ទារប្រេកង់វិទ្យុ*

---
[14] ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញា ក.អ.ស.ព.ន កាលពីឆ្នាំ ១៩៩២។
https://tbinternet.ohchr.org/_layouts/15/TreatyBodyExternal/Treaty.aspx?Treaty=CCPR&Lang=en។

*សម្រាប់ផ្កាយរណប និងគន្លងផ្កាយរណបនៅកម្ពុជាប៉ុណ្ណោះ លើកលែងតែវិស័យសន្តិសុខ និងការពារជាតិ ដែលបានកំណត់វិសាលភាពទូលំទូលាយ។*

ដូចគ្នាដែរ យោងតាមមាត្រា ២៤ បានតម្រូវឱ្យម្ចាស់អាជ្ញាបណ្ណប្រេកង់វិទ្យុ *សហការផ្តល់ព័ត៌មានដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងករណីគ្រាអាសន្ន ឬការស្វែងរកជំនួយសង្គ្រោះបន្ទាន់ ក្នុងករណីដូចជា (ក) ការប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ។* ដោយអនុក្រឹត្យនេះមិនបានបញ្ជាក់ពីព័ត៌មានមួយចំនួនដែលត្រូវការពីម្ចាស់អាជ្ញាបណ្ណប្រេកង់វិទ្យុ និងមិនបានដាក់បញ្ចូលគោលការណ៍ការពារទិន្នន័យ បញ្ញត្តិនេះអាចត្រូវបានគេយកទៅប្រើប្រាស់ខុសទិសដៅ ដោយតម្រូវឱ្យបុគ្គលដែលជាម្ចាស់អាជ្ញាបណ្ណប្រេកង់វិទ្យុ(?) ផ្តល់ព័ត៌មានផ្ទាល់ខ្លួនដែលប៉ះពាល់សិទ្ធិឯកជនភាពរបស់ពួកគេ និងដើម្បីរួចផុតពីការជ្រៀតជ្រែកពីរដ្ឋ។ ដូច្នេះ អនុក្រឹត្យនេះមានបញ្ញត្តិមិនច្បាស់លាស់ ដែលបើកឱកាសដល់ការរំលោភបំពាន ព្រោះស្ទើរតែគ្រប់សកម្មភាពទាំងអស់ អាចត្រូវបានចាត់ទុកជាការគំរាមកំហែងដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ និងតម្រូវការក្នុងការផ្តល់ព័ត៌មាន។ ដូចគ្នាដែរ យោងតាមមាត្រា ៣៥ ចែងថា *ដើម្បីអនុវត្តផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុ សិទ្ធិប្រើប្រាស់បន្ទារប្រេកង់វិទ្យុមួយផ្នែក ឬទាំងស្រុងដែលត្រូវបានផ្តល់អាចត្រូវបានដកហូតដោយនិយ័តករទូរគមនាគមន៍កម្ពុជា ស្របតាមការសម្រេចរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្នុងករណីដែល៖ (ក) ប្រើប្រាស់ប្រេកង់វិទ្យុ ក្នុងគោលបំណងប្រព្រឹត្តបទល្មើសប្រឆាំងនឹងជាតិ (គ) ផ្តល់ព័ត៌មានក្លែងក្លាយ ដើម្បីទទួលបានអាជ្ញាបណ្ណប្រេកង់វិទ្យុ ដោយមិនបានបញ្ជាក់ច្បាស់លាស់ពីសកម្មភាពដែលចាត់ទុកថាជា "បទល្មើសប្រឆាំងនឹងជាតិ"។*

## ១.៤. ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត កាន់តែរឹតត្បិតលើសិទ្ធិសេរីភាពខាងការបង្កើតសមាគម និងបញ្ចេញមតិ ជាពិសេសសមាជិកគណបក្សជំទាស់

កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ព្រះមហាក្សត្រ នរោត្តម សីហមុនី បានប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត បន្ទាប់ពីបានឆ្លងការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភាក្នុងខែមិថុនា និងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ (ក.ប.ធ) បញ្ចប់ប្រញាប់ប្រញាល់បំផុត នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣។ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត បានកែប្រែបញ្ញត្តិមួយចំនួននៅក្នុងច្បាប់ជាធរមាន ដូចជាច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពាក់ព័ន្ធនឹងការបោះឆ្នោតថ្នាក់ជាតិ និងឃុំសង្កាត់ ដែលចូលជាធរមានក្នុងឆ្នាំ ២០១៧។

យោងតាមមាត្រា ២៣ (ចាស់) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានចែងអំពីលក្ខខណ្ឌ ៥ ចំណុចដែលប្រជាពលរដ្ឋកម្ពុជាត្រូវតែបំពេញ ដើម្បីអាចឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ រួមមាន ៖ '*(១) មានសញ្ជាតិខ្មែរពីកំណើត (២) មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត (៣) មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត (៤) មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា (៥) មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត។*'

- ***ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ[15] បានធ្វើវិសោធនកម្មមាត្រា ២៣, ១៤២ និង ១៤៣***

**មាត្រា ២៣** ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានធ្វើវិសោធនកម្មមាត្រា ២៣ ដោយដាក់ចេញលក្ខខណ្ឌថ្មីចំពោះបេក្ខជនតំណាងរាស្ត្រ៖ *"(៤)បានអនុវត្តសិទ្ធិបោះឆ្នោត ដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតសកលចំនួនពីរលើកចុងក្រោយជាប់គ្នា ដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត [គ.ជ.ប] លើកលែងករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្រប។"* ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក៏បានដាក់ចេញនូវបញ្ញត្តិចែងថា គ.ជ.ប ត្រូវរៀបចំ "បែបបទលក្ខខណ្ឌ និងនីតិវិធី" ដើម្បីវាយតម្លៃមូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធបោះឆ្នោតនេះបាន។ ការកែប្រែទាំងនេះស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា ក្នុងនោះមាត្រា ៣៤ ចែងថា បញ្ញត្តិដែលរឹតត្បិតលើសិទ្ធិឈរឈ្មោះបោះឆ្នោតត្រូវបានកំណត់តាមច្បាប់បោះឆ្នោត។ ទោះជាយ៉ាងណា បញ្ញត្តិទាំងនេះហាក់ដូចជាមិនស៊ីសង្វាក់គ្នានឹងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្រោមមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) នោះទេ ដែលចែងពីសិទ្ធិ និងឱកាសរបស់ប្រជាពលរដ្ឋគ្រប់រូបក្នុងការឈរឈ្មោះបោះឆ្នោតតាមកាលកំណត់ជាក់ស្ដែងដោយមិនមានការរឹតត្បិតមិនសមហេតុផល។

នៅក្នុងអនុសាសន៍ទូទៅលេខ ២៥ របស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប ស្ដីពីសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ សិទ្ធិបោះឆ្នោត និងសិទ្ធិស្មើគ្នាក្នុងការទទួលបានសេវាសាធារណៈ បានសង្កត់ធ្ងន់ថា ការអនុវត្តសិទ្ធិដែលត្រូវបានការពារតាមមាត្រា ២៥ មិនអាចព្យួរទុក ឬដកហូតបានឡើយ លើកលែងតែមានសំអាងហេតុ (១) តាមច្បាប់កំណត់ (២) មានលក្ខណៈសត្យានុម័ត និង (៣) មានហេតុផលត្រឹមត្រូវ។ ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវទីមួយ និងមិនមានការចូលរួមផ្ដល់មតិពហុភាគីពីអ្នកពាក់ព័ន្ធនានា។ មាត្រាដែលបានធ្វើវិសោធនកម្ម មិនបានកំណត់ពីមូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធបោះឆ្នោត ដែលមិនបានបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកសត្យានុម័ត។ លើសពីនេះការវាយតម្លៃលើមូលហេតុសមស្របជាសមត្ថកិច្ចរបស់ គ.ជ.ប ដែលនាំឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការអនុវត្តស្តង់ដាពីរចំពោះបញ្ញត្តិថ្មី។

**មាត្រា ១៤២** លើសពីនេះ ច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោត បានធ្វើវិសោធនកម្មមាត្រា ១៤២ ដោយផ្ដន្ទាទោសការប្រព្រឹត្តអំពើថ្មីៗចំនួនពីរ គឺការណែនាំ/ញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោតរបស់ខ្លួន និងញុះញង់អ្នកដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅចុះឈ្មោះបោះឆ្នោត។ បញ្ញត្តិបន្ថែមទាំងនេះរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិក្នុងន័យផ្ទុយនឹងច្បាប់ជាតិ និងអន្តរជាតិ ក្នុងនោះមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញចែងថា "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយ

[15] ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានចូលជាធរមានលើកដំបូងនៅអំឡុងខែមីនា ឆ្នាំ២០១៥ ។ ច្បាប់នេះត្រូវបានធ្វើវិសោធនកម្មលើកដំបូងកាលពីខែតុលា ឆ្នាំ២០១៧ ហើយបានធ្វើវិសោធនកម្មលើកទីពីរតាមរយៈច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោត ក្នុងឆ្នាំ២០២៣ ។

រំលោភបំពាន នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ"។ ទោះបីជាមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញចែងថា ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសេរីភាពខាងការបញ្ចេញមតិក៏ដោយ ក៏មានបញ្ញត្តិដែលអនុញ្ញាតឱ្យមានការរឹតត្បិត លើសិទ្ធិនេះតាមច្បាប់ដើម្បីការពារ *'សិទ្ធិអ្នកដទៃ' 'ទំនៀមទម្លាប់ល្អរបស់សង្គម' ឬ 'ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ។'* ក្នុងការអនុវត្តជាក់ស្តែង បញ្ញត្តិក្នុងន័យទូលាយទាំងនេះបានអនុញ្ញាតឱ្យរដ្ឋាភិបាលអនុម័តបទប្បញ្ញត្តិច្បាប់ ដែលរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិដោយអយុត្តិធម៌អស់រយៈពេលជាច្រើនឆ្នាំមកនេះ។

គួរកត់សម្គាល់ថា ក្រមព្រហ្មទណ្ឌគ្រាន់តែដាក់ទោសទណ្ឌលើការញុះញង់ឱ្យប្រព្រឹត្តអំពើខុសច្បាប់ប៉ុណ្ណោះ ដូចជាការបោះបង់ចោលកុមារ ប្រព្រឹត្តបទឧក្រិដ្ឋ ការរារាំងមន្ត្រីសាធារណៈ ឬ ការរើសអើងជាដើម។ ដោយការធ្វើពហិការមិនចូលរួមក្នុងការបោះឆ្នោត ឬការធ្វើឱ្យខូចបំផ្លាញសន្លឹកឆ្នោតរបស់ខ្លួន មិនមានលក្ខណៈផ្ទុយនឹងច្បាប់ ច្បាប់ថ្មីនេះមានអានុភាពដាក់ទោសទណ្ឌលើការញុះញង់ឱ្យប្រព្រឹត្តអំពើ ដែលមិនមានហេតុផលសមស្របនៅពីក្រោយការដាក់ទោសទណ្ឌចំពោះការញុះញង់។

បញ្ញត្តិនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ ការអនុវត្តប្រកបដោយអត្ថន័យនៃសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ ទាមទារឱ្យមានការទទួលបានសិទ្ធិផ្សេងៗដែលបានបង្កើតឡើង រួមទាំងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ យោបល់ និងព័ត៌មាន។ ការអនុម័តបញ្ញត្តិដែលនាំមកនូវបញ្ហាទាំងនេះ កំពុងរារាំងដល់ការបញ្ចេញមតិដោយសេរី និងបង្កការគំរាមកំហែងដល់សន្តិសុខ និងឯកជនភាពរបស់មេដឹកនាំគណបក្សជំទាស់។ ការណ៍នេះក៏អាចបង្កើននូវវប្បធម៌នៃការរឹតត្បិតសេរីភាពខ្លួនឯងផងដែរ ដែលកំហិតឱ្យអ្នកដែលអាជ្ញាធរចាត់ទុកថាជាអ្នកជំទាស់ កាន់តែមានការប្រុងប្រយ័ត្នបន្ថែមទៀតក្នុងការផលិតមាតិការិះគន់ ដើម្បីជៀសវាងការតបត។

**មាត្រា ១៤៣** យោងតាមមាត្រា ១៤៣ (ចាស់) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចែងថា គណបក្សនយោបាយណាដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១៤២ នឹងប្រឈមការដកហូតបេក្ខភាពរបស់ខ្លួន និង/ឬត្រូវបាន គ.ជ.ប ផាកពិន័យជាប្រាក់ពី ១០ លាន ទៅ ៣០ លានរៀល (ប្រហែល ២,៤២០-៧,២៧០ ដុល្លារ) ។ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត បានពង្រីកអំណាច គ.ជ.ប ក្នុងការដកហូតសិទ្ធិឈរឈ្មោះបោះឆ្នោតរបស់គណបក្សនោះយ៉ាងហោចណាស់ប្រាំឆ្នាំផងដែរ។ គណបក្សនយោបាយដែលមិនបានដកហូតបេក្ខជនដែលមិនមានសិទ្ធិ អាចរងការពិន័យជាប្រាក់ពី ១០ លាន ទៅ ៣០ លានរៀល ។ ការដាក់ទណ្ឌកម្មបែបនេះ (បើមាន) ជាការរឹតត្បិតមិនសមហេតុផលលើសិទ្ធិឈរឈ្មោះបោះឆ្នោត។

- ***ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ មាត្រា ៣៥-, ១៧១ និង ១៧២***

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ បានធ្វើវិសោធនកម្មមាត្រា ៣៥, ១៧១, និង ១៧២ ដូច្នេះលក្ខខណ្ឌអំពីសិទ្ធិចូលរួមសម្រាប់បេក្ខជន បទល្មើស និងការដាក់ទណ្ឌកម្មដូចបានពិភាក្សាខាងលើ ក៏អនុវត្តចំពោះការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ផងដែរ។

**មាត្រា ៣៥** យោងតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត អនាគតបេក្ខជនត្រូវតែបានបោះឆ្នោតយ៉ាងតិចពីរអាណត្តិ ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាបេក្ខជនក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ខណ្ឌ-ស្រុក ក្រុង រាជធានី-ខេត្ត និងថ្នាក់ជាតិ។ ថ្នាក់ដឹកនាំបក្សជំទាស់ដែលលេចធ្លោភាគច្រើនបាននិងកំពុងនិរទេសខ្លួនដោយបង្ខំ ដើម្បីជៀសវាងការជាប់ពន្ធនាគារពីបទចោទប្រកាន់ផ្សេងៗដែលខ្លួនអះអាងថាត្រូវបានបំភ្លៃ និងមិនយុត្តិធម៌ ហើយវិសោធនកម្មច្បាប់នេះ នឹងរារាំងពួកគេមិនឱ្យឈរឈ្មោះបោះឆ្នោតនាពេលអនាគតដោយមិនចាំបាច់មានវិធានការបន្ថែមទៀត ដើម្បីរាំងនោះទេ។ ច្បាប់ស្តីពីវិសោធនកម្មច្បាប់នេះ ក៏នឹងបន្ទច់បង្អាក់ដល់ការធ្វើមិនចូលរួមការបោះឆ្នោតផងដែរ ដោយថ្នាក់ដឹកនាំគណបក្សជំទាស់ដែលមានបំណងចូលរួមប្រកួតប្រជែងការបោះឆ្នោតនាពេលខាងមុខនឹងត្រូវបានដាក់ឱ្យស្ថិតក្នុងស្ថានភាពមិនល្អមួយដោយឡែក ប្រសិនបើពួកគេជំរុញឱ្យពលរដ្ឋមិនទៅបោះឆ្នោត ខណៈដែលខ្លួនទៅបោះឆ្នោត។

ដើម្បីអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រាល់ការរឹតត្បិតលើសេរីភាពខាងសមាគមត្រូវតែអនុវត្តតាមការវិនិច្ឆ័យលើជាតុផ្សំចំនួនបី ដូចមានចែងក្នុងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន)។ រាល់ការរឹតត្បិតលើសេរីភាពខាងសមាគមត្រូវតែ៖ (១) កំណត់ដោយច្បាប់ (២) មានគោលបំណងស្របច្បាប់ (សន្តិសុខជាតិ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬក្រមសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ) និង (៣) ជាមធ្យោបាយមួយក្នុងការសម្រេចគោលបំណងនោះដោយមានការរឹតត្បិតតិចតួចបំផុត។ ទាក់ទងនឹងបញ្ហានេះ វិសោធនកម្មច្បាប់ហាក់ដូចជា (១) មិនមានភាពចាំបាច់ទាំងស្រុង ដើម្បីជានាបុព្វហេតុសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ (២) ការរឹតត្បិតដូចមានចែងក្នុងច្បាប់ស្តីពីវិសោធនកម្មច្បាប់នេះ មិនមែនជាការរឹតត្បិតតិចតួចបំផុតក្នុងការធ្វើឱ្យសម្រេចនោះទេ ខណៈដែលការដាក់ទណ្ឌកម្មជាការពិន័យប្រាក់យ៉ាងច្រើន (១,២០០-៤,៨០០ ដុល្លារ) ដែលបង្អាក់ដល់ការអនុវត្តសិទ្ធិបោះឆ្នោត និងបំបិទសិទ្ធិរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតយ៉ាងហោចណាស់ប្រាំឆ្នាំ ខណៈដែលកាន់តែបង្ករការលំបាកកាន់តែខ្លាំងដល់សមាជិកគណបក្សជំទាស់ក្នុងការចូលរួមការបោះឆ្នោត។

- ***ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា***

**មាត្រា ៤ និង ៧** មាត្រា ៤ និង ៧ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ក៏បានធ្វើការកែប្រែលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដើម្បីអាចអនុវត្តលក្ខខណ្ឌទី ៤ នៃមាត្រា ២៣ ដែលបានធ្វើវិសោធនកម្មក្រោមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចំពោះបេក្ខជនព្រឹទ្ធសភាផងដែរ។[16] មិនមានលក្ខខណ្ឌតម្រូវថ្មីសម្រាប់បេក្ខជនព្រឹទ្ធសភា បើប្រៀបធៀបទៅនឹងបទប្បញ្ញត្តិមុនឡើយ។ ព្រោះថាសមាជិកព្រឹទ្ធសភាត្រូវបានជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ (៥៨រូប) ឬ ត្រូវតែងតាំងដោយព្រះមហាក្សត្រ និងរដ្ឋសភា (ពីរលើកក្នុងម្នាក់ៗ)។ ទោះជាយ៉ាងណា ក៏ មាត្រា៧ នៃ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះ

[16] សូមមើលបទវិភាគមាត្រា ២៣ (ថ្មី) ១៤២ (ថ្មី) និង ១៤៣ (ថ្មី) ខាងលើ។

ឆ្នោត ការជ្រើសរើសសមាជិកព្រឹទ្ធសភាឆ្នាំ២០២៤ បានបន្ថយឥទ្ធិពលសម្រាប់បេក្ខជនដែលមានសក្តានុពល។ តាមមាត្រា ២៣ ចាស់ ការបោះឆ្នោតនេះត្រូវតែជាការបោះឆ្នោតចុងក្រោយដែលរៀបចំដោយ គ.ជ.ប។ ដូច្នេះ សមាជិកព្រឹទ្ធិសភាចាំបាច់ត្រូវឆ្លងកាត់ការបោះឆ្នោតពីរលើក។ ទោះបីជាហេតុផលនៅពីក្រោយការវិសោធនកម្មនេះ នៅមិនទាន់ច្បាស់យ៉ាងណាក៏ដោយ ក៏អាចបន្ថែមនូវលក្ខខណ្ឌបោះឆ្នោតថ្មី សម្រាប់បេក្ខជនមួយចំនួនដែលអាចប៉ះពាល់ដល់ធ្ងន់ធ្ងរដល់សិទ្ធិក្នុងការចូលរួមកិច្ចការសាធារណៈ។

អនុក្រឹត្យថ្មីចំនួនបី និងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតនេះ មិនអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលទាក់ទងនឹងសេរីភាពមូលដ្ឋាន ហើយអាចត្រូវបានយកមកប្រើជាឧបករណ៍ដើម្បីឃ្លាំមើល និងរំលោភលើសិទ្ធិពលរដ្ឋកម្ពុជាដោយមិនមានការអនុញ្ញាត។ ទាក់ទងនឹងអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh បញ្ញត្តិនៃអនុក្រឹត្យនេះមិនបានកំណត់ច្បាស់លាស់អំពីនីតិវិធីដែលអាជ្ញាធរពាក់ព័ន្ធការពារសិទ្ធិឯកជនភាព រួមទាំងការធានាថារដ្ឋាភិបាលនឹងមិនចូលប្រើព័ត៌មានឯកជនរបស់បុគ្គល និងប្រើប្រាស់ព័ត៌មានទាំងនោះ ដើម្បីកំណត់មុខសញ្ញា និងឃ្លាំមើលក្រុមអ្នកការពារសិទ្ធិមនុស្ស សកម្មជន អ្នកសារព័ត៌មាន និងសមាជិកគណបក្សជំទាស់នោះទេ។ អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម មិនបានបញ្ជាក់ច្បាស់លាស់ថា តើដំណើរការនៃការចុះបញ្ជីនឹងសម្រេចបាននូវគោលបំណងដែលមិនច្បាស់លាស់និងមានភាពទូលាយ។ ជាពិសេសក្រុមអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន សកម្មជនបរិស្ថាន និងសំឡេងអ្នកជំទាស់។ អនុក្រឹត្យលេខ ២១៧ ស្តីពីការរៀបចំ ការគ្រប់គ្រង និងបែងចែកវិសាលគមន៍ហ្វ្រេកង់វិទ្យុដែលបង្កផលប៉ះពាល់ដល់សិទ្ធិឯកជនភាពរបស់ម្ចាស់អាជ្ញាបណ្ណវិសាលគមន៍ ហ្វ្រេកង់វិទ្យុ ដោយសារមានបញ្ញត្តិមិនច្បាស់លាស់ ដែលរដ្ឋាភិបាលអាចចូលទៅកាន់ព័ត៌មានឯកជនបានយ៉ាងងាយស្រួលក្រោមមូលហេតុសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ។

ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត បានកែប្រែដូចបានរៀបរាប់ខាងលើ ដើម្បីហាមឃាត់អ្នកដែលមិនបានចូលរួមការបោះឆ្នោតសកលចំនួនពីរអាណត្តិជាប់គ្នា (រដ្ឋសភា) ក្នុងការឈរឈ្មោះបេក្ខជន។ ក្នុងនោះក៏មានបទល្មើសថ្មីចំនួនពីរផងដែរ ត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់៖ ការញុះញង់អ្នកដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត និងណែនាំ/ញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោតរបស់ខ្លួន។ បទល្មើសថ្មីទាំងនេះត្រូវផ្តន្ទាទោសដោយការពិន័យជាប្រាក់ និងការព្យួរសិទ្ធិឈរឈ្មោះបោះឆ្នោត ដែលការហាមឃាត់នេះមិនស្របនឹងមាត្រា១៩នៃ ក.អ.ស.ព.ន និងមិនគ្រប់ធាតុផ្សំបទល្មើលការញុះញង់ក្នុងក្រមព្រហ្មទណ្ឌ។

ការរឹតត្បិតទាំងនេះក៏បង្កភាពងាយស្រួលដល់ការរំលោភសិទ្ធិសេរីភាពខាងសមាគម។ អាជ្ញាធរបានប្រើប្រាស់រួចហើយនូវបទប្បញ្ញត្តិច្បាប់ថ្មី ដើម្បីហាមឃាត់ថ្នាក់ដឹកនាំ និងសកម្មជនគណបក្សជំទាស់ចំនួន ៤២ រូប មិនឱ្យឈរឈ្មោះជាបេក្ខជនរយៈពេលយ៉ាងតិច ២០ ឆ្នាំ រួមទាំងលោក សម រង្ស៊ី អតីតមេដឹកនាំគណបក្សជំទាស់ផងដែរ។ នៅក្នុងបរិបទកម្ពុជាបច្ចុប្បន្ន គេកត់សម្គាល់ឃើញថាលំហសង្គមស៊ីវិល និងនយោបាយ កាន់តែមានភាពរួមតូចចង្អៀត ក៏ដូចជាការបង្ក្រាបឥតឈប់ឈរលើសេរីភាពខាងការបញ្ចេញមតិ អ្នកសារព័ត៌មាន និង

អ្នកការពារសិទ្ធិមនុស្ស ដែលការវិវត្តនេះនាំឱ្យមានការព្រួយបារម្ភរួចស្រាប់ហើយថាវិសោធនកម្មច្បាប់ និងគោលនយោបាយនឹងត្រូវប្រើជាមធ្យោបាយបង្ក្រាបនឹងសំឡេងជំទាស់។

## ចំណុចគន្លឹះទី២ ៖ តើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ត្រូវបានអនុវត្តនិងពង្រឹងការអនុវត្តបានត្រឹមត្រូវដែរឬទេ?

ចំណុចគន្លឹះទីពីរ ពិនិត្យមើលថា តើក្របខណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវកម្រិតណា។[17] ដើម្បីឱ្យបុគ្គលម្នាក់ៗទទួលបានសេរីភាពមូលដ្ឋានរបស់ខ្លួន មិនមែនគ្រាន់តែត្រូវមានក្របខណ្ឌច្បាប់ជាតិដែលអនុលោមតាមបទដ្ឋាន និងច្បាប់សិទ្ធិមនុស្សអន្តរជាតិប៉ុណ្ណោះទេ ថែមទាំងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ត្រូវធ្វើឡើងស្របតាមលិខិតគតិយុត្ត ដោយសង្គតិភាព និងមិនមែនតាមតែអំពើចិត្តផងដែរ។

របកគំហើញសំខាន់ៗ៖ យោងតាមទិន្នន័យចំណុចគន្លឹះទីពីរ សេរីភាពមូលដ្ឋាននៅទូទាំងកម្ពុជាបានធ្លាក់ចុះបន្តិចនៅឆ្នាំ២០២៣។ អាជ្ញាធរមិនត្រឹមតែបង្កើនការឃាំឃើទៅលើបុគ្គលដែលអនុវត្តសិទ្ធិទាំងនេះប៉ុណ្ណោះទេ តែថែមទាំងរឹតត្បិតការអនុវត្តសេរីភាពទាំងនោះ និងមិនគោរពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។[18] រាជរដ្ឋាភិបាលកម្ពុជា("រដ្ឋាភិបាល")ក៏បានកំណត់មុខសញ្ញាទៅលើសកម្មជនបក្សជំទាស់ អ្នកតស៊ូមតិដើម្បីលក្ខខណ្ឌការងារល្អប្រសើរ និងសម្តែងមតិរិះគន់តាមបណ្តាញសង្គម។ លើសពីនេះជនប្រព្រឹត្តអំពើរំលោភបំពានសេរីភាពទាំងនោះមិនត្រូវបាននាំខ្លួនមកទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួនឡើយ។

### ២.១ សេរីភាពមូលដ្ឋានបន្តទទួលរងការរឹតត្បិត និងការរំលោភបំពាននៅឆ្នាំ២០២៣ ដែលកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០២០

តួលេខទី ៥៖ ចំនួនហេតុការណ៍សរុបដែលបានកត់ត្រាពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២៣




ទោះបីជាសេរីភាពមូលដ្ឋានត្រូវបានការពារនៅក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ក៏ការរឹតត្បិត និងការរំលោភបំពានលើសេរីភាពមូលដ្ឋាននៅតែបន្តកើតឡើងជាប្រចាំ។ ការរឹតត្បិត និងការរំលោភបំពានទាំងនេះកើតចេញពីការអនុវត្តច្បាប់មិនត្រឹមត្រូវជាលក្ខណៈប្រព័ន្ធ។ គម្រោងបានកត់ត្រាការកើនឡើងនៃការរំលោភបំពានលើសេរីភាពមូលដ្ឋាន ១១ %នៅឆ្នាំ២០២៣ ដែលមានហេតុការណ៍ចំនួន ៦៣៣ ហេតុការណ៍នៅទូទាំង

[17] របកគំហើញនៅក្នុងចំណុចគន្លឹះនេះ ផ្អែកតាមទិន្នន័យដែលប្រមូលបានពីការឃ្លាំមើលតាមប្រព័ន្ធផ្សព្វផ្សាយ ការរាយការណ៍អំពីហេតុការណ៍ ការស្ទង់មតិសាធារណៈ ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព និងកិច្ចពិភាក្សាក្រុម។

[18]ការរឹតត្បិតលើសេរីភាពមូលដ្ឋាន អាចអនុវត្តបាននៅក្រោមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ប្រសិនបើការរឹតត្បិតទាំងនោះមានគោលបំណងការពារសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ សុខុមាលភាព ឬសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ទោះជាយ៉ាងនេះក្តី ច្បាប់សិទ្ធិមនុស្សអន្តរជាតិបានបញ្ជាក់ពីការរឹតត្បិត និងទំហំនៃការអនុញ្ញាតឱ្យមានការរឹត្បិត។ ហើយការរឹតត្បិតទាំងអស់នេះត្រូវតែធានាថាមិនបានបំពានដល់សិទ្ធិជាមូលដ្ឋាននោះទេ។ ការរឹតត្បិតសេរីភាពមូលដ្ឋានដែលហួសពីការកំណត់នឹងត្រូវបានចាត់ទុកថាជាការរំលោភបំពានបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ សូមអានការវិភាគលម្អិតក្នុងចំណុចគន្លឹះទី១។

ប្រទេស (តួលេខទី៥) ដែលក្នុងនោះសេរីភាពមូលដ្ឋានចំនួនមួយហេតុការណ៍ប៉ុណ្ណោះដែលត្រូវបានការពារជាជាងការរឹតត្បិត ឬការរំលោភបំពាន។




តារាងតួលេខនេះបង្ហាញការកើនឡើងយ៉ាងខ្លាំងពីឆ្នាំ២០២២ ដែលមានហេតុការណ៍ ចំនួន៥៦៦ហេតុការណ៍។ ក្នុងចំណោមហេតុការណ៍ទាំងនេះ ២៥៥ ហេតុការណ៍មានជាប់ពាក់ព័ន្ធនឹងការរឹតត្បិតយ៉ាងតិចមួយ ពាក់ព័ន្ធទៅនឹងសេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងការជួបប្រជុំ និងឬសេរីភាពខាងសមាគម (សូមមើលតួលេខទី៦)។




គួរកត់សម្គាល់ថា ចំនួននៃការរំលោភបំពានបានកើនឡើងយ៉ាងខ្លាំងនៅឆមាសទីមួយនៃឆ្នាំ២០២៣ ដែលបានកើនឡើងខ្ពស់រហូតដល់នៅខែកក្កដា ដែលជាខែមានការបោះឆ្នោតជាតិ មុនពេលមានការធ្លាក់ចុះហេតុការណ៍ជាបន្តបន្ទាប់ចាប់ពីខែសីហា ដល់ខែធ្នូ (តួលេខទី៧ និងទី៨)។

របត់នេះ បង្ហាញឱ្យឃើញពីការរឹតត្បិតគួរឱ្យព្រួយបារម្ភដែលរដ្ឋាភិបាលបានអនុវត្តទៅលើអ្នកនយោបាយ និងគណបក្សនយោបាយក៏ដូចជា ការរារាំងទៅលើសកម្មភាពនានារបស់អង្គការសង្គមស៊ីវិលផងដែរ។



តួលេខទី ៩៖ ចំនួនការថ្លែងរបស់រដ្ឋាភិបាលដែលបានកត់ត្រាអំពីការបេកស្រាយមិនត្រឹមត្រូវ ឬយល់ខុសអំពីសេរីភាពមូលដ្ឋាន




រដ្ឋាភិបាល បានបកស្រាយមិនត្រឹមត្រូវ ឬការភាន់ច្រលំអំពីសេរីភាពមូលដ្ឋានចំនួន២៤ ហេតុការណ៍ក្នុងអំឡុងរយៈពេលនៃការឃ្លាំមើលនេះ។[19] តួលេខនេះបង្ហាញពីការកើនឡើងពីការថ្លែងមិនត្រឹមត្រូវ ឬការភាន់ច្រលំអំពីសេរីភាពមូលដ្ឋានចំនួន១៤ ហេតុការណ៍នៅឆ្នាំ២០២២ ទៅ ២៤ ហេតុការណ៍នៅឆ្នាំ២០២៣។

តួលេខទី១០៖ ចំនួនហេតុការណ៍នៃការរឹតត្បិតឬការរំលោភបំពានសេរីភាពមូលដ្ឋាននៅឆ្នាំ២០២៣ បែងចែកតាមប្រភេទក្រុមមនុស្ស




នៅក្នុងឆ្នាំ២០២៣ បានកត់ត្រាអ្នកការពារសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិល និងអ្នកនយោបាយជំទាស់គឺជាអ្នកទទួលរងគ្រោះពីការរឹតត្បិតសេរីភាពមូលដ្ឋានច្រើនបំផុត។ និយោជិត និងសហជីពជាប្រភេទអ្នករងគ្រោះច្រើនបន្ទាប់ ដែលមានហេតុការណ៍ចំនួន ១១៤ (ថយចុះ ១៦%ពីឆ្នាំ២០២២ដែលមាន ១៣៥ហេតុការណ៍)។ ទោះជាយ៉ាងនេះក្ដី គម្រោងរកឃើញរបត់ដ៏គួរឱ្យព្រួយបារម្ភអំពីហេតុការណ៍កើតឡើងមកលើអ្នកសារព័ត៌មានដែលកើនឡើងដល់ ៧៨ ហេតុការណ៍នៅក្នុងឆ្នាំ២០២៣ កើនឡើង ៤១%។ ហេតុការណ៍ទាំងនោះរួមមាន ការដកហូតអាជ្ញាប័ណ្ណ[20] ការគំរាមកំហែង និងការរារាំងការធ្វើបទសម្ភាសន៍ក្នុងអំឡុងពេលបោះឆ្នោតជាតិ ត្រូវបានប្រើប្រាស់មកលើអ្នកសារព័ត៌មាន។ គួរកត់សម្គាល់ថា ហេតុការណ៍ចំនួន ១៩ ពាក់ព័ន្ធនឹងការឃាយឃីផ្លូវច្បាប់ដោយសារការរាយការណ៍អំពីបញ្ហារសើប អាជីវកម្មខុសច្បាប់ ឬអំពើពុករលួយ។

[19] ទិន្នន័យប្រមូលបានតាមរយៈការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់គម្រោង។

[20] នៅឆ្នាំ២០២៣ ស្ថាប័នផ្សព្វផ្សាយចំនួនប្រាំ ត្រូវបានដកហូតអាជ្ញាប័ណ្ណរួមទាំងវិទ្យុសំឡេងប្រជាធិបតេយ្យ (វីអូឌី) សារព័ត៌មានសមាគមអ្នកសារព័ត៌មានកម្ពុជា-អាស៊ាន សារព័ត៌មានរស្មីកំពង់ចាម សារព័ត៌មានដំណឹងក្នុងស្រុក និងសារព័ត៌មានខ្មែរខូវើជីវី។

## ២.២ នៅឆ្នាំ២០២៣ មានការកើនឡើងគួរឱ្យកត់សម្គាល់នូវការចោទប្រកាន់បទព្រហ្មទណ្ឌទៅលើបុគ្គលដែលបានអនុវត្តសេរីភាពមូលដ្ឋាន ដែលនាំឱ្យមានការកើនឡើងគួរឱ្យកត់សម្គាល់នូវការផ្តន្ទាទោស ការចោទប្រកាន់ និងការចាប់ខ្លួន



តួលេខទី១១៖ ចំនួនមនុស្សដែលទទួលរងទណ្ឌកម្មផ្នែកព្រហ្មទណ្ឌដោយការអនុវត្តសេរីភាពមូលដ្ឋាន ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣

នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រានូវនិន្នាការកើនឡើងស្រដៀងគ្នានៅឆ្នាំ២០២២ ទៅលើចំនួនបុគ្គល ដែលត្រូវបានកាត់ទោសចំពោះការអនុវត្តសិទ្ធិរបស់ខ្លួនដែលកើនឡើង ១៨ %ពី៧៦ នាក់ ទៅ៩៣ នាក់។ ក្នុងចំណោមអ្នកដែលត្រូវបានកាត់ទោស ៧១ នាក់ (៧៦%) ជាអ្នកនយោបាយ រួមមានមន្ត្រី សមាជិក និងសកម្មជនរបស់គណបក្សជំទាស់។[21] មនុស្សចំនួន៤២ នាក់ក្នុងចំណោម ៧១ នាក់នោះ ត្រូវបានកាត់ទោសនៅក្រោមមាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតដែលបានធ្វើវិសោធនកម្មថ្មី។ មនុស្សចំនួន២២ នាក់ផ្សេងទៀតគឺជាអ្នកការពារសិទ្ធិមនុស្សពាក់ព័ន្ធនឹងសិទ្ធិដីធ្លី[22] សិទ្ធិការងារ[23] អ្នកសារព័ត៌មាន[24] និងអ្នកប្រើប្រាស់បណ្តាញសង្គម។[25]ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌមកលើសកម្មជនសិទ្ធិដីធ្លីក៏មានកើនឡើងនៅក្នុងឆ្នាំ២០២៣ ផងដែរ។ គួរកត់សម្គាល់ថា មនុស្ស៥០ នាក់ក្នុងចំណោម ៩៧ នាក់ត្រូវអាជ្ញាធរកោះហៅ ជាសមាជិកសហគមន៍ដីធ្លី។ នៅឆ្នាំ២០២៣ ការកត់ត្រាកើនឡើងយ៉ាងច្រើនចំនួនបុគ្គលដែលទទួលរងការចោទប្រកាន់ ដែលកើនឡើង

---

[21] ក្នុងចំណោមនោះ មនុស្សចំនួន ៧១ នាក់ជាអ្នកនយោបាយ សមាជិក ឬសកម្មជនគណបក្សជំទាស់។

[22] មាស ដា "តុលាការខេត្តកោះកុង សម្រេចផ្តន្ទាទោសសកម្មជនដីធ្លី ១០ នាក់ឱ្យជាប់ពន្ធនាគារមួយឆ្នាំពីបទញុះញង់ (វីអូអេ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣) https://khmer.voanews.com/a/koh-kong-provincial-court-sentenced-ten-land-activists-to-one-year-in-prison-for-incitement/7227360.htmlនិង IR2023-263។

[23] លាស់ លីបលីប សាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមសំណុំរឿងកូដកម្មកាស៊ីណូណាហ្គាវើលដ៍ (វីអូអេ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣) https://khmer.voanews.com/a/phnom-penh-appeal-court-uphold-pp-court-over-naga-case/7317525.html

[24] IR2023-370។

[25] អាស៊ីសេរី "បុរសម្នាក់ត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារ ៣ ឆ្នាំ បន្ទាប់ពីផ្សព្វផ្សាយរិះគន់រដ្ឋាភិបាលនៅលើបណ្តាញសង្គមហ្វេសប៊ុក" (អាស៊ីសេរី ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣) https://www.rfa.org/english/news/cambodia/facebook-comments-sentence-11222023151550.html។

ដល់ ១០២ នាក់ បើធៀបទៅនឹង ២៧ នាក់កាលពីឆ្នាំមុន។ តួលេខការឃុំខ្លួននៅឆ្នាំ២០២២ គឺមានការកើនឡើងជាខ្លាំងដែលកើតឡើងចេញពីព្រឹត្តិការណ៍តែមួយគត់គឺកូដកម្មរបស់បុគ្គលិកក្រុមហ៊ុនណាហ្គាវើលដ៍ ដែលនាំឱ្យមានការឃុំខ្លួនមនុស្សរាប់ពាន់នាក់ ដែលនេះជារំលោភបំពានលើសេរីភាពមូលដ្ឋាន។ ការវិវឌ្ឍន៍នៅក្នុងឆ្នាំ ២០២៣ បង្ហាញអំពីការដើរថយក្រោយនៃការការពារសេរីភាពមូលដ្ឋាន ដោយមានការកើនឡើងជាខ្លាំងនូវចំនួនការចោទប្រកាន់បទព្រហ្មទណ្ឌ ការចាប់ខ្លួន និងការកាត់ទោសដែលកំណត់មុខសញ្ញាលើបុគ្គលដែលអនុវត្តសេរីភាពមូលដ្ឋាន ចាប់តាំងពីឆ្នាំ២០២២។

## ២.៣ ការចោទប្រកាន់ពីបទញុះញង់ឬធ្វើឱ្យខូចសន្លឹកឆ្នោតត្រូវបានចោទប្រកាន់ញឹកញាប់ នៅលើបុគ្គលដែលអនុវត្តសេរីភាពមូលដ្ឋាន

តួលេខទី១២ ៖ ចំនួនបុគ្គលដែលបានចោទប្រកាន់ចំពោះការអនុវត្តសេរីភាពមូលដ្ឋាន និងប្រភេទនៃបទចោទប្រកាន់




ទិន្នន័យក្នុងឆ្នាំ២០២៣ បង្ហាញឱ្យឃើញថាបុគ្គលដែលអនុវត្តសេរីភាពមូលដ្ឋាន ត្រូវបានចោទប្រកាន់ច្រើនបំផុតក្រោមមាត្រា១៤២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត មកលើសកម្មភាពញុះញង់ឱ្យអ្នកដទៃគូសខ្វែងសន្លឹកឆ្នោត ឬការធ្វើពហិការមិនទៅបោះឆ្នោត។ នៅខែកក្កដា ឆ្នាំ២០២៣ គម្រោងបានកត់ត្រាបុគ្គល អ្នកនយោបាយ សកម្មជន និងសមាជិកគណបក្សជំទាស់ចំនួន ៤២ នាក់ ត្រូវបានចោទប្រកាន់ ក្រោមមាត្រានេះ។ ការចោទប្រកាន់ទូទៅបំផុតទីពីរនៅឆ្នាំ២០២៣ គឺ" បទញុះញង់ "នៃក្រមព្រហ្មទណ្ឌ ក្នុងនោះកំណត់មុខសញ្ញាលើសកម្មជននយោបាយ អ្នកនយោបាយ និងសកម្មជនសិទ្ធិដីធ្លី។[26]

[26] មនុស្ស១១ នាក់ក្នុងចំណោម ៣៥ នាក់ ដែលត្រូវបានចោទប្រកាន់ពីបទ នៅឆ្នាំ២០២៣ "ញុះញង់"ជាសកម្មជនសិទ្ធិដីធ្លី ហើយមនុស្សចំនួន ២៤ នាក់ផ្សេងទៀតគឺជាអ្នកនយោបាយ និងសកម្មជនគណបក្សភ្លើងទៀន។

# សេរីភាពខាងសមាគម

តួលេខទី១៣៖ ចំនួននៃការរឹតត្បិត និងការរំលោភបំពានសេរីភាព ខាងសមាគមក្នុងឆ្នាំ២០២៣




នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រាហេតុការណ៍ ៣៤៤ ហេតុការណ៍។ ក្នុងចំណោមនេះ ហេតុការណ៍ចំនួន ១៨៣ (៥៣%) ពាក់ព័ន្ធនឹងការរឹតត្បិត និងហេតុការណ៍ចំនួន ១៦១ (៤៧%) ពាក់ព័ន្ធនឹងការរំលោភបំពានសេរីភាពសមាគមដោយរដ្ឋាភិបាល។[27] បើធៀបទៅនឹងឆ្នាំ២០២២ ហេតុការណ៍នៃការរឹតត្បិតបានកើនឡើង ៣០% (ពី១២៩ ដល់ ១៨៣ ហេតុការណ៍) និងហេតុការណ៍នៃការរំលោភបំពានបានកើន៨% (ពី១៤៨ ដល់ ១៦១ ហេតុការណ៍)។[28]

តួលេខទី ១៤៖ ចំនួនហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពាន ដោយអាជ្ញាធរ និងមិនមែនអាជ្ញាធរ បែងចែកតាមខែនីមួយៗ




តួលេខទី ១៥៖ ចំនួននៃការរឹតត្បិត ឬរំលោភបំពានសេរីភាព ខាងសមាគមដោយអាជ្ញាធរនិងមិនមែនអាជ្ញាធរ




ក្នុងអំឡុងពេលនេះ គម្រោងបានរាយការណ៍ពីការកើនឡើងហេតុការណ៍រឹតត្បិត ឬការរំលោភបំពានលើសេរីភាពខាងសមាគម (សូមមើលតួលេខទី១៤)។ គួរកត់សម្គាល់ថា អាជ្ញាធរមានសមត្ថកិច្ចគឺជាអ្នកទទួលខុសត្រូវភាគច្រើនចំពោះការហេតុការណ៍រំលោភបំពានទាំងនេះ (សូមមើលតួលេខទី១៥)។

---

[27] តួលេខទី១៥ បង្ហាញពីចំនួនហេតុការណ៍ដោយបែងចែកតាមតួអង្គ ហេតុការណ៍ខ្លះចាត់បញ្ចូលក្នុងតួអង្គលើសពីមួយ។

[28] ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព « របាយការណ៍ប្រចាំឆ្នាំ២០២២ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា » ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ (https://mail.cchrcambodia.org/en/publications/general-reports/cambodia-fundamental-freedoms-monitor-2022)។

តួលេខទី ១៦៖ ប្រភេទនៃជនរងគ្រោះតាមករណីនៃការរឹតត្បិត/ការរំលោភលើសេរីភាពខាងសមាគមនៅឆ្នាំ២០២៣




នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រាថា បុគ្គលយ៉ាងតិច ១៦.៩៧៤ ទទួលរងការរឹតត្បិតលើសិទ្ធិសេរីភាព ដែលមាន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្សគឺជាក្រុមមុខសញ្ញាធំបំផុត ដែលបន្ទាប់មកមានអ្នកនយោបាយ និងសហជីព(តួលេខទី១៦)។[29]

## ២.៤ ហេតុការណ៍ភាគច្រើនដែលបានកត់ត្រានៅឆ្នាំ២០២៣ បង្ហាញថារដ្ឋាភិបាលបានតាមដានច្រើនហួសហេតុ

ទិន្នន័យពីការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ និងការរាយការណ៍ពីហេតុការណ៍បានបង្ហាញថា ៣៥%(១៦១ ក្នុងចំណោម ៤៦២) នៃករណីទាំងអស់ដែលពាក់ព័ន្ធនឹងការអនុវត្តសេរីភាពខាងសមាគមពាក់ព័ន្ធនឹងការតាមដានត្រួតពិនិត្យច្រើនហួសហេតុពីរដ្ឋាភិបាល។ ករណីនេះ គឺត្រូវបានឃើញនៅក្នុងហេតុការណ៍នៃការឃាំឃើទៅលើអ្នកនយោបាយ/សកម្មជននយោបាយ និងការរារាំងសកម្មភាពរបស់អង្គការសង្គមស៊ីវិល រួមទាំងកម្មវិធីឯកជន និងសកម្មភាពសាធារណៈ។

## ២.៥ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានបន្តរាយការណ៍អំពីការជ្រៀតជ្រែកមកលើសកម្មភាពរបស់ពួកគេក្នុងការចងក្រងជាសម្ព័ន្ធ

[29] វិធីសាស្ត្រប្រមូលទិន្នន័យរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន រួមមាន ការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងរបាយការណ៍អំពីហេតុការណ៍នៅឆ្នាំ២០២៣។ ទិន្នន័យនេះជាចំនួនហេតុការណ៍ដែលបែងចែកតាមប្រភេទជនរងគ្រោះ។ ទោះយ៉ាងណាចំនួនបុគ្គលដែលរងការរឹតត្បិតឬរំលោភបំពានសេរីភាពខាងសមាគមមានចំនួនច្រើនដោយសារតែហេតុការណ៍១អាចប៉ះពាល់ដល់ប្រភេទជនរងគ្រោះលើសពី១។



តួលេខទី ១៧៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍អំពីការជ្រៀតជ្រែកលើការចងក្រងរបស់ពួកគេ ក្នុងការបង្កើតបណ្តាញ/សម្ព័ន្ធ នៅឆ្នាំ២០២៣



តួលេខទី ១៨៖ ចំនួនដងដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពបានរាយការណ៍អំពីការជ្រៀតជ្រែកលើការចងក្រងរបស់ពួកគេក្នុងការបង្កើតបណ្តាញ/សម្ព័ន្ធ នៅឆ្នាំ២០២៣

នៅក្នុងការស្ទង់មតិរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពឆ្នាំ២០២៣ គម្រោង បានកត់ត្រាការថយចុះ ៣ % លើការជ្រៀតជ្រែកដែលបានរាយការណ៍មកលើការចងក្រងបង្កើតបណ្តាញ/សម្ព័ន្ធរបស់ពួកគេ (តួលេខទី១៧)។ ទោះជាយ៉ាងនេះក្តី លើសពីពាក់កណ្តាលនៃថ្នាក់ដឹកនាំទាំងនោះបានរាយកាណ៍ពីការជ្រៀតជ្រែក។ ផ្ទុយពីការថយចុះបន្តិចពីឆ្នាំ២០២២ ទិន្នន័យនេះនៅតែមានកម្រិតខ្ពស់ជាងឆ្នាំ២០២០ និង ២០២១ ដែលជាពេលវេលាមានការរីករាលដាលជំងឺកូវីដ-១៩ រារាំងសកម្មភាព និងនាំឱ្យមានការថយចុះការរាយការណ៍អំពីការជ្រៀតជ្រែកនេះ។ ៤០% នៃអ្នកឆ្លើយតបបានរាយការណ៍ថាពួកគេទទួលរងការជ្រៀតជ្រែកចាប់ពី ១-៥ ដង អ្នកឆ្លើយតប ៥ %បានរាយការណ៍ថាជួបប្រទះការជ្រៀតជ្រែកចាប់ពី ៦-១០ ដង និង ៣ % បានរាយការណ៍ថាបានជួបប្រទះ លើសពី១០ ដង នៅក្នុងអំឡុងពេលមួយឆ្នាំពេញ។ គួរកត់សម្គាល់ថា ៥២ % នៃអ្នកឆ្លើយតប មិនបានចាំចំនួនដងដែលជួបប្រទះការជ្រៀតជ្រែកនោះទេ។

តួលេខទី ១៩៖ ភាគរយនៃហេតុការណ៍ដែលពាក់ព័ន្ធនឹងការរឹតត្បិតសេរីភាពខាងសមាគម ដោយសារតែការតាមដាន ឬការឃ្លាំមើលហួសហេតុពីសំណាក់រដ្ឋាភិបាល






ផ្ទុយទៅវិញ ការស្ទង់មតិបានបង្ហាញឱ្យឃើញថា មានការកើនឡើងភាគរយនៃហេតុការណ៍(៣៧%) ដែលរាយការណ៍ថាការតាមដាន ឬការឃ្លាំមើលមានលក្ខណៈហួសហេតុពីរាជរដ្ឋាភិបាល បើធៀបទៅនឹងឆ្នាំ២០២២ (តួលេខទី១៩)។ ចំនួនជាក់លាក់ ៣៤% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល (២៩ នាក់ក្នុងចំណោម ៨៦ នាក់) និង ៤៤% នៃថ្នាក់ដឹកនាំសហជីព (១៩ នាក់ក្នុងចំណោម ៤៣ នាក់) បានរាយការណ៍ថាបានជួបប្រទះការតាមដាន ឬការឃ្លាំមើលបែបនេះនៅឆ្នាំ២០២៣។



តួលេខទី ២០៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលយល់ថាការឃ្លាំមើលមានលក្ខណៈហួសហេតុ

ការស្ទង់មតិរយៈពេលបីឆ្នាំកន្លងមក បង្ហាញអំពីការបន្តធ្លាក់ចុះនៃភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលរាយការណ៍អំពីការតាមដានហួសហេតុ ដែលមាន ៥៨ %នៅឆ្នាំ២០២៣។ ទោះជាបែបនេះក្តី ភាគរយជារួមនៅតែមានកម្រិតខ្ពស់ដដែល ដែលក្នុងនោះលើសពីពាក់កណ្តាលនៃថ្នាក់ដឹកនាំបានរាយការណ៍អំពីការឃ្លាំមើលហួសហេតុ។ របត់នេះ បានកើតមាននៅក្នុងការស្ទង់មតិសាធារណៈនៅឆ្នាំ២០២៣ ដែល ៦៤ %នៃអ្នកឆ្លើយតបបាននិយាយថា ពួកគេបានចូលរួមនៅក្នុងសកម្មភាពសមាគម។ ទោះជាយ៉ាងនេះក្តី ២២% (អ្នកឆ្លើយតប ១៣៨ នាក់ក្នុងចំណោម ៦៤០ នាក់) បានរាយការណ៍ថាត្រូវបានកំណត់មុខសញ្ញាដោយសារតែការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពសមាគម ដែលតួលេខទីនេះគឺនៅតែមិនមានការប្រែប្រួលនោះទេអស់រយៈពេលបីឆ្នាំកន្លងមកនេះ (តួលេខទី២០) ។[30]

## ២.៦ រដ្ឋាភិបាលបន្តរឿតត្បិតលើសកម្មភាពរបស់គណបក្សប្រឆាំង សហជីព និងអង្គការសង្គមស៊ីវិល

តួលេខទី ២១៖ ចំនួនបុគ្គលដែលទទួលរងទណ្ឌកម្មព្រហ្មទណ្ឌចំពោះការអនុវត្តសេរីភាពខាងសមាគមនៅឆ្នាំ២០២៣




នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រាហេតុការណ៍ ៤៦២ ករណីពាក់ព័ន្ធនឹងសេរីភាពខាងសមាគម។ ហេតុការណ៍ទាំងនេះនាំឱ្យមនុស្សចំនួន ៥៦ នាក់ត្រូវបានកោះហៅដើម្បីបំភ្លឺ មនុស្សចំនួន ៦២នាក់ ត្រូវបានសាកសួរ ៧៦នាក់ ត្រូវបានឃុំខ្លួន ១៩ នាក់បានផ្តិតម្រាមដៃចុះកិច្ចសន្យា មនុស្សចំនួន ៧៨ នាក់ត្រូវបានចាប់ខ្លួន មនុស្សចំនួន៨៩នាក់ ត្រូវបានចោទកាត់ទោស និងមនុស្សចំនួន៣៧ នាក់ មានការតម្កល់កាត់ទោស (តួលេខទី២១)។ សកម្មជននយោបាយ និងអ្នកនយោបាយជារឿយៗ ត្រូវបានកំណត់មុខសញ្ញាទៅនឹងការចោទ

[30] ការស្ទង់មតិសាធារណៈ បានធ្វើឡើងចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ នៅទូទាំង២៥ រាជធានីខេត្ត និងបានស្ទង់មតិមនុស្សចំនួន ១,០០៥ នាក់។ សូមអានឧបសម្ព័ន្ធ៣ សំណួរ ៣.៤។

ប្រកាន់ដូចជា ការចេញមូលប្បទានបត្រមិនមានសាច់ប្រាក់ ការរំលោភមាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា(វិសោធនកម្មច្បាប់បោះឆ្នោត) ការក្លែងបន្លំឯកសារ ការញុះញង់ និងបទរួមគំនិតក្បត់។

តួលេខទី ២២៖ ចំនួនស្លាកគណបក្សដែលបានបំផ្លាញ ឬដកដោយមិនមានការអនុញ្ញាត




នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រាហេតុការណ៍ចំនួន ៤៦ នៃការបំផ្លាញ ឬការដកផ្ទាំងស្លាកគណបក្សនយោបាយដោយមិនមានការអនុញ្ញាត។ គណបក្សភ្លើងទៀន ត្រូវបានរាយការណ៍អំពីចំនួនហេតុការណ៍ទាំងនេះខ្ពស់បំផុត។ គួរកត់សម្គាល់ថា មានហេតុការណ៍តែមួយប៉ុណ្ណោះដែលពាក់ព័ន្ធនឹងគណបក្សប្រជាជនកម្ពុជា ដែលជនប្រព្រឹត្តបានទទួលរងវិធានការផ្លូវច្បាប់ (តួលេខទី ២២) ។ ហេតុការណ៍នេះ គួរផ្តល់ជាឧទាហរណ៍មួយសម្រាប់ការដោះស្រាយហេតុការណ៍ស្រដៀងគ្នា ដែលកើតមកលើគណបក្សជំទាស់ផ្សេងៗដែលនៅតែមិនទាន់ទទួលបានការដោះស្រាយនៅឡើយ។

### ២.៧ ការគំរាមសម្លាប់ និងការសាកសួរអ្នកគាំទ្រគណបក្សភ្លើងទៀនក្រោយពីការដំឡើងស្លាក

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ អ្នកស្រី សួន សុខឿន ជាអ្នកគាំទ្រគណបក្សភ្លើងទៀនបានបញ្ជាក់ថាមានការគំរាមសម្លាប់រូបគាត់ បន្ទាប់ពីអ្នកស្រីអនុញ្ញាតឱ្យដំឡើងស្លាកគណបក្សនៅក្រៅផ្ទះរបស់គាត់។ នៅថ្ងៃបន្ទាប់ អាជ្ញាធរបានចុះមកផ្ទះរបស់គាត់ និងបានសាកសួរគាត់ ដែលទាំងអស់នេះ អ្នកស្រីយល់ថាជាការកំណត់មុខសញ្ញាទៅលើរូបគាត់ ដោយសារតែការចូលរួមរបស់គាត់ជាមួយនឹងគណបក្សជំទាស់។[31]

[31] សុ ជីវី "សកម្មជនគណបក្សភ្លើងទៀនពីរនាក់នៅខេត្តព្រៃវែងត្រូវចាប់ខ្លួន និងម្នាក់ទៀតនៅខេត្តកណ្ដាលរងការគំរាមកំហែង" (អាស៊ីសេរី, ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣) https://www.rfa.org/khmer/news/politics/police-questions-candlelight-party-activist-for-raising-a-party-banner-in-front-of-her-house-04132023081509.html។

មន្ត្រីរាជការ ៣ រូបនៃគណបក្សភ្លើងទៀនត្រូវបានដកចេញពីតំណែង



សមាជិកគណបក្សភ្លើងទៀនបន្តទទួលរងការធ្វើទុក្ខបុកម្នេញពេញមួយឆ្នាំ២០២៣ ដោយសារតែសកម្មភាពនយោបាយរបស់ខ្លួន។ សមាជិកបីរូប លោក ផុន សុភា[32] លោក អ៊ី មុយលី[33] និងលោក ស៊ិន វត្ថា - ត្រូវបានដកចេញពីតំណែងជាមន្ត្រីរាជការដោយរងការចោទប្រកាន់ថារំលោភបំពានលក្ខន្តិកៈ។[34]



១០

សមាជិក ១០ នាក់នៃគណបក្សជំទាស់ត្រូវបានវាយដំ

តួលេខទី២៣: ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌមកលើសមាជិកគណបក្សជំទាស់




សមាជិកគណបក្សជំទាស់ជួប បញ្ហាប្រឈមខ្លាំងគួរឱ្យកត់សម្គាល់ នៅក្នុងការអនុវត្តសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយរបស់ពួកគេ ដែលជារឿយៗនាំឱ្យមានការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ទៅលើសកម្មភាពរបស់ពួកគេ។ នៅឆ្នាំ២០២៣ សមាជិកមកពីគណបក្សជំទាស់ បានរងវិធានការផ្លូវច្បាប់ជាច្រើន រួមទាំងការកោះហៅ មនុស្សចំនួន ៧ នាក់ ការសាកសួរ ៣០ នាក់ ការឃុំខ្លួន៤៥ នាក់ ផ្តិតម្រាមដៃធ្វើកិច្ចសន្យាចំនួន ១៨ នាក់ ចោទប្រកាន់ ៦៤ នាក់ ចាប់ខ្លួនចំនួន ៤៦ នាក់ កាត់ទោស ៧១ នាក់ និងតម្កល់ការកាត់ទោស ២២ នាក់ (តួលេខទី២៣)។

[32] យ៉ង ច័ន្ទដារ៉ា "មន្ត្រីគណបក្សភ្លើងទៀននៅខេត្តកណ្ដាលលើកឡើងថា ការលុបឈ្មោះរបស់លោកពីរដ្ឋ គឺជារឿងនយោបាយ" (អាស៊ីសេរី ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣) https://www.rfa.org/khmer/news/politics/kandal-provincial-governor-removes-names-of-senior-clp-officials-from-civil-service-04302023091229.html។

[33] មាន ឫទ្ធិ "មន្ត្រីគណបក្សភ្លើងទៀនមួយរូបទៀតត្រូវបានបណ្ដេញចេញដោយលោក ហេង សំរិន" (វិទ្យុអាស៊ីសេរី ថ្ងៃទី៨ ខែឧសភា ឆ្នាំ ២០២៣) https://www.rfa.org/khmer/news/politics/another-candlelight-party-official-fired-by-national-assembly-president-heng-samrin-05082023040859.html។

[34] ឃួន ណារីម "មន្ត្រីគណបក្សភ្លើងទៀន ត្រូវបានបណ្ដេញចេញពីក្របខណ្ឌបង្រៀនវិទ្យាល័យនៅក្រសួងអប់រំ" (សារព័ត៌មានខេមបូចា ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០២៣) https://cambojanews.com/candlelight-official-fired-from-high-school-teaching-job-with-education-ministry។

## ២.៨ វត្តមានអាជ្ញាធរនៅក្នុងសកម្មភាពឯកជនដែលរៀបចំឡើងដោយសមាគម

នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រាកម្មវិធីឯកជនចំនួន ៧៥ លើក ដែលអង្គការសង្គមស៊ីវិលរៀបចំឡើងត្រូវរងការជ្រៀតជ្រែក។ ទោះជាយ៉ាងនេះក្តី អាជ្ញាធរបានមកចូលស្តាប់ និងថតយកព័ត៌មានលំអិតយ៉ាងតិច ២៩ កម្មវិធី ក្នុងចំណោមកម្មវិធីទាំងនោះ (តួលេខទី២៤)។ នៅក្នុងនោះមាន ១៣ ហេតុការណ៍ អាជ្ញាធរទាមទារបង្ហាញភស្តុតាងការជូនដំណឹងជាមុន មុនពេលដែលអនុញ្ញាតឱ្យដំណើរការសកម្មភាពទាំងនេះ។ លើសពីនេះ អាជ្ញាធរបានផ្តិតយករូបភាពសកម្មភាពរបស់សមាគមនៅទីកន្លែងឯកជនចំនួន ៤៥ លើក។[35] មាត្រា ២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលការពារសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធីនៅក្នុងបរិវេណសាធារណៈ និងឯកជន។[36] លក្ខខណ្ឌតម្រូវឱ្យស្នើសុំការអនុញ្ញាតពីអាជ្ញាធរ ដើម្បីរៀបចំសកម្មភាពជួបប្រជុំ គឺរំលោភបំពានសិទ្ធិក្នុងការជួបប្រជុំ ដូចដែលបានបញ្ជាក់ដោយសេចក្តីពន្យល់ទូទៅលេខ ៣៧។

តួលេខទី២៤៖ អាជ្ញាធរបានជ្រៀតជ្រែកលើកិច្ចប្រជុំឬការបណ្តុះបណ្តាលឯកជនរបស់អង្គការសង្គមស៊ីវិលនៅឆ្នាំ២០២៣




នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣ អំឡុងពេលវគ្គបណ្តុះបណ្តាលសម្រាប់ក្រុមឃ្លាំមើលការបោះឆ្នោតរបស់អង្គការខុមហ្វ្រែលក្នុងនៅខេត្តព្រៃវែង មានមន្ត្រីមកពីគណៈកម្មាធិការបោះឆ្នោតឃុំសង្កាត់ម្នាក់បានណែនាំឱ្យបុគ្គលិកខុមហ្វ្រែលជូនដំណឹងដល់អាជ្ញាធរមុនពេលរៀបចំវគ្គបណ្តុះបណ្តាល សម្រាប់វគ្គបណ្តុះបណ្តាលក្រោយៗទៀតក្នុងមូលដ្ឋាននេះ។[37]

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ("សមាគមអាដហុក") ខេត្តមណ្ឌលគីរី បានគ្រោងបណ្តុះបណ្តាលពលរដ្ឋចំនួន ១៥ នាក់ ស្តីពីការទប់ស្កាត់ការរៀបការវ័យ

[35] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣៧ ស្តីពីមាត្រា ២១ (សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី) កថាខណ្ឌ ៦, ៧០, CCPR/C/GC/៣៧ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០២០។
https://documents.un.org/doc/undoc/gen/g20/232/15/pdf/g2023215.pdf?token=rUyXju3x2BKrkEISBa&fe=true/

[36] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣៧ ស្តីពីមាត្រា ២១ (២០២០) មាត្រា២១ (សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី) កថាខណ្ឌ១៣ (CCPR/C/GC/៣៧)។

[37] IR2023-202។

ក្មេង។ ប្រជាការពារភូមិម្នាក់បានរារាំងពលរដ្ឋទាំងនោះចូលរួមវគ្គបណ្តុះបណ្តាលដោយអះអាងថា សមាគមអាដហុក កំពុងតែរៀបចំសកម្មភាពខុសច្បាប់ ដោយសារតែការបណ្តុះបណ្តាលនេះមិនទទួលបានការយល់ព្រមពីមេប៉ុស្តិ៍។ បុគ្គលិកក៏បានជួបជាមួយលោក ចាន់ សុផារី នាយប៉ុស្តិ៍ឃុំចុងផ្លាស់ដើម្បីតវ៉ាអំពីការទាមទារឱ្យជូនដំណឹងជាមុន។ បន្ទាប់មក សមាគមអាដហុក ក៏បន្តរៀបចំការបណ្តុះបណ្តាលនោះ តែត្រូវប្តូរពេលវេលាបណ្តុះបណ្តាលទៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣ វិញ។[38]

## ២.៩ ថ្នាក់ដឹកនាំសហជីពអាចរក្សាទុកនិងដាក់ជូនរាល់ឯកសារចាំបាច់ទាំងអស់សម្រាប់ការចុះបញ្ជី



នៅឆ្នាំ២០២៣ សហជីពចំនួនប្រាំបួនបានចុះបញ្ជីដោយជោគជ័យ ដោយមិនចាំបាច់ត្រូវឆ្លងកាត់នីតិវិធីពិបាក ឬស្មុគស្មាញនោះទេ។ តួលេខនេះបង្ហាញឱ្យឃើញអំពីការរៀបចំនិងចំណេះដឹងកាន់តែល្អប្រសើរអំពីលក្ខខណ្ឌតម្រូវដាក់ពាក្យចុះបញ្ជី ដោយសារតែថ្នាក់ដឹកនាំសហជីព បានបង្ហាញអំពីការយល់ដឹងច្បាស់អំពីដំណើរការនីតិវិធី និងការយកចិត្តទុកដាក់លើឯកសារ។ ទោះបីជាយ៉ាងនេះក្តី ឧទាហរណ៍មួយចំនួនខាងក្រោមនេះបង្ហាញពីនិយោជិត និងសហជីពនៅតែបន្តប្រឈមនៅពេលចុះបញ្ជិការ ឬធ្វើសកម្មភាពសហជីព។

នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៣ កម្មករនិយោជិតជាង ១០០ នាក់មកពីរោងចក្រអឹមអិល និង រោងចក្រ យ័ន្តជា បានធ្វើការតវ៉ាដោយបានដាក់ញត្តិទៅក្រសួងការងារឱ្យជួយធ្វើអន្តរាគមន៍នៅក្នុងដំណើរការចុះបញ្ជីសហជីពរបស់ពួកគេ។ តំណាងសហជីព លោក កែវ វណ្ណៈ បានចែករំលែកអំពីបទពិសោធន៍លំបាករបស់លោកក្នុងការត្រូវកែអក្ខរាវិរុទ្ធម្តងហើយម្តងទៀតនៅក្នុងពាក្យស្នើសុំ ដែលនាំឱ្យមានការពន្យារពេល។[39]

នៅឆ្នាំ២០២៣ ថ្នាក់ដឹកនាំសហជីព បានរាយការណ៍ថាជួបបញ្ហាប្រឈមក្នុងអំឡុងពេលនៃដំណើរការបោះឆ្នោត និងចុះបញ្ជី ដោយមានករណីជាច្រើនជាប់ពាក់ព័ន្ធនឹងស្ថាបនិកលាឈប់ពីតំណែងនៅដំណាក់កាលដំបូងនៃការចុះបញ្ជី។[40]

---

[38] IR2023-264។

[39] មាន ឫទ្ធិ "កម្មករជិត ១០០នាក់ ចេញតវ៉ាស្នើក្រសួងការងារឱ្យឆាប់ការចុះបញ្ជិកាទទួលស្គាល់សហជីពនៅរោងចក្រ ML និង Yuan Jia" (អាស៊ីសេរី ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៣) https://www.rfa.org/khmer/news/human-rights/nearly-100-workers-asked-ministry-of-labor-to-expedite-the-registration-of-unions-03052023102509.html។

[40] កិច្ចពិភាក្សាក្រុមជាមួយសហជីពនៅខែសីហា ឆ្នាំ២០២៣។

## ២.១០ ការបន្ទុចបង្អាក់សកម្មភាពសហជីពនៅតែបន្តកើតមាននៅឆ្នាំ២០២៣ ទោះបីជាការជៀតជ្រែកនៅលើការបង្កើតបណ្តាញ/សម្ព័ន្ធមានការថយចុះ

តួលេខទី២៥៖ ចំនួនមនុស្សដែលទទួលរងទណ្ឌកម្មរដ្ឋបាលឬផ្លូវច្បាប់




ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព ក្នុងអំឡុងពេលរបាយការណ៍នេះ បានបង្ហាញអំពីការថយចុះការរាយការណ៍អំពីការជ្រៀតជ្រែកលើការប៉ុនប៉ងបង្កើតបណ្តាញ/សម្ព័ន្ធនៃសហជីព។ ទោះជាយ៉ាងនេះក្តី គម្រោងបានកត់ត្រាហេតុការណ៍ចំនួន ៥០ ពាក់ព័ន្ធនឹងការបន្ទុចបង្អាក់សកម្មភាពសហជីពនៅឆ្នាំ២០២៣។

ការបង្កើតសម្ព័ន្ធ និងបណ្តាញ នៅតែជាបញ្ហាប្រឈមចម្បងមួយសម្រាប់សហជីពនៅក្នុងប្រទេសកម្ពុជា។ ទិន្នន័យពីគម្រោង បង្ហាញថាការបន្ទុចបង្អាក់សកម្មភាពសហជីព[41] មាននិយោជិតចំនួន ១៥៦ នាក់ បានបញ្ឈប់ ឬបង្ខំលាលែងពីតួនាទីបន្ទាប់ពីបោះឆ្នោតឱ្យបង្កើតសហជីពមូលដ្ឋាន។ លើសពីនេះ និយោជិតចំនួន ២៣ នាក់បានទទួលប្រាក់បៀវត្សខ្ពស់ជាងមុន ឬតម្លើងតួនាទី និងនិយោជិតម្នាក់ត្រូវបានទម្លាក់តួនាទី។ និយោជិតយ៉ាងតិច ៦៦ នាក់បានទទួលរងការកោះហៅ ឬការគំរាមផ្លូវច្បាប់ ដោយសារតែការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពសហជីព។

នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ លោក ប៉ាវ ស៊ីណា ប្រធានសម្ព័ន្ធសហជីពចលនាកម្មករ បានចេញសេចក្តីប្រកាសព័ត៌មានដោយលើកឡើងថាសមាជិកសហជីពម្នាក់ ត្រូវបានបណ្តេញចេញ និងប្រាំបួននាក់ទៀតទទួលរងការគំរាមកំហែង បន្ទាប់ពីប៉ុនប៉ងបង្កើតសហជីពមូលដ្ឋានមួយនៅរោងចក្រកាត់ដេរសំលៀកបំពាក់ខាសវែល ស្ថិតនៅក្នុងខណ្ឌកំបូល រាជធានីភ្នំពេញ។[42]

[41] ការបន្ទុចបង្អាក់សកម្មភាពសហជីពគឺជាសកម្មភាពទាំងឡាយណាដែលបានអនុវត្តដើម្បីរារាំង ឬធ្វើឱ្យអំណាចរបស់សហជីពចុះខ្សោយ ឬរារាំងដល់ការប៉ុនប៉ងរបស់សហជីពក្នុងការពង្រីកសមាជិកនៅក្នុងកន្លែងធ្វើការ។

[42] សុវណ្ណ ស្រីពេជ្រ ផុន សុទ្ធីរ័ត្ន "កម្មករនិយោជិតរោងចក្រកាត់ដេរ និងស្បែកជើង ១៥ នាក់ត្រូវបានបណ្តេញពីការងារ បន្ទាប់ពីការបង្កើតសហជីព" (សារព័ត៌មានខេមបូចា ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣) https://khmer.cambojanews.com/15-factory-workers-fired-after-union-formation/។

# សេរីភាពខាងការជួបប្រជុំ

តួលេខទី ២៦៖ ចំនួនហេតុការណ៍រឹតត្បិត និងរំលោភបំពានសេរីភាពខាងជួបប្រជុំនៅឆ្នាំ២០២៣




នៅឆ្នាំ២០២៣ គម្រោង បានកត់ត្រាហេតុការណ៍ ១៣៤ ហេតុការណ៍ពាក់ព័ន្ធនឹងសេរីភាពខាងការជួបប្រជុំ។ ក្នុងចំណោមហេតុការណ៍ទាំងនេះ ហេតុការណ៍ចំនួន៩៩ (៧៤%) ត្រូវបានទុកជាការរឹតត្បិតលើសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងហេតុការណ៍ចំនួន ៣៤ (២៥%) ទុកជាការរំលោភបំពាន។ ហេតុការណ៍ចំនួនមួយ ត្រូវបានទុកជាកាការពារសេរីភាពខាងជួបប្រជុំដែលសិទ្ធិរបស់អ្នកចូលរួមការជួបប្រជុំត្រូវបានការពារ និងគោរពពីអាជ្ញាធរ។ ជាក់ស្តែង សមាជិកគណបក្សភ្លើងទៀនប្រមាណជា ៥០០ នាក់ បានប្រមូលផ្តុំគ្នានៅខាងមុខទីស្នាក់ការគណបក្សនៅរាជធានីភ្នំពេញ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ ទាមទារឱ្យមានការពន្យល់បកស្រាយពីថ្នាក់ដឹកនាំរបស់ខ្លួនចំពោះការដកមន្ត្រីមួយចំនួនចេញពីថ្នាក់ក្រោម។ អាជ្ញាធរមូលដ្ឋាន បានជួយសម្រួលដល់ការគ្រប់គ្រងចរាចរណ៍នៅទីតាំងជួបប្រជុំ។[43]

តួលេខ២៧៖ ចំនួនហេតុការណ៍ពាក់ព័ន្ធសេរីភាពខាងការជួបប្រជុំដោយបែងចែកតាមប្រភេទការជួបប្រជុំ




យោងតាមទិន្នន័យ ហេតុការណ៍កើតឡើងញឹកញាប់បំផុតទាក់ទងនឹងការជួបប្រជុំលើសិទ្ធិការងារ បន្ទាប់មកទៀតជាការជួបប្រជុំទាក់ទងនឹងសិទ្ធិដីធ្លី ការជួបប្រជុំរបស់អ្នកនយោបាយគណបក្សជំទាស់ និងផ្សេងៗទៀតដូចជា សកម្មជនបរិស្ថាន ក្រុមជនងាយរងគ្រោះ និងអ្នកលក់ដូរ (តួលេខទី២៧)។ គួរឱ្យកត់សម្គាល់ផងដែរ ទោះបីជាការបោះឆ្នោតជាតិ បានប្រព្រឹត្តទៅនៅក្នុងខែកក្កដា ឆ្នាំ២០២៣ ក៏ដោយ ក៏គណបក្សជំទាស់ចម្បង នៅតែមិនអាចចូលរួមបោះឆ្នោតបាន ដោយសារតែមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយសំអាងលើ

[43] ទិន ហ្សាការីយ៉ា "សមាជិកគណបក្សភ្លើងទៀនរាប់រយនាក់ចេញតវ៉ា និងទាមទារថ្នាក់ដឹកនាំបក្សឱ្យឈប់ដកតំណែងសមាជិកមូលដ្ឋានតាមអំពើចិត្ត" (អាស៊ីសេរី ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣) https://www.rfa.org/khmer/news/politics/hundred-activists-of-candlelight-party-protest-against-party-leaders-for-removing-local-members-12182023141142.html។

ការបាត់ឯកសារតម្រូវចាំបាច់ដោយគណៈកម្មការជាតិរៀបចំការបោះឆ្នោត។[44] រដ្ឋាភិបាលជាអ្នកទទួលខុសត្រូវចំពោះការរឹតត្បិត និងការរំលោភបំពានទៅលើសេរីភាពខាងការជួបប្រជុំនៅឆ្នាំ២០២៣ ភាគច្រើន។

## ២.១១ ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌលើបុគ្គលដែលអនុវត្តសេរីភាពខាងការជួបប្រជុំនៅឆ្នាំ២០២៣

តួលេខទី ២៨៖ ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌលើបុគ្គលដែលអនុវត្តសេរីភាពខាងការជួបប្រជុំ




គម្រោងបានកត់ត្រា មនុស្សយ៉ាងតិច ១៩ នាក់ត្រូវបានកោះហៅដោយ ១០ នាក់ក្នុងចំណោមនោះ គឺជាសមាជិក ឬអ្នកតំណាងសហគមន៍នៅតាមមូលដ្ឋាន។ បន្ថែមពីនេះ គម្រោងបានកត់ត្រាមនុស្សចំនួន ១០នាក់ ត្រូវបានកាត់ទោសដោយសារតែការអនុវត្តការជួបប្រជុំដោយសន្តិវិធីជាសមាជិកក្រុម ឬអ្នកតំណាងសហគមន៍ដីធ្លីផងដែរ។[45]

## ២.១២ការប៉ុនប៉ងរបស់សហគមន៍ដីធ្លីក្នុងការស្វែងរកដំណោះស្រាយ ជារឿយៗត្រូវបានបង្វៀតវាងពីរដ្ឋាភិបាលដែលអាចនាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការជួបប្រជុំ

សហគមន៍ដីធ្លីជាច្រើន ត្រូវបានរារាំងពីការចូលទៅកាន់ទីតាំងដែលអាចធ្វើឱ្យការជួបប្រជុំរបស់ពួកគេមានឥទ្ធិពល៖

សហគមន៍ដីធ្លីនៅក្នុងខេត្តកោះកុង កំពុងតវ៉ាពីការរំលោភដីធ្លីពីក្រុមហ៊ុនឯកជនដែលទទួលបានសម្បទានដីសេដ្ឋកិច្ច។ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ នគរបាលបានឃាត់សកម្មជនដីធ្លីមួយក្រុមមកពីខេត្តកោះកុងដែលគ្រោងធ្វើដំណើរទៅកាន់ក្រសួងយុត្តិធម៌ នៅរាជធានីភ្នំពេញ។ សកម្មជនបានកាន់ញត្តិស្នើសុំឱ្យមានការច្រានចោលនូវការចោទប្រកាន់ទៅលើសកម្មជនដីធ្លី ៣០ នាក់ផ្សេងទៀតមកពីសហគមន៍ចំនួនប្រាំ។ រថយន្តបួនគ្រឿងដែលដឹកសកម្មជន ត្រូវឃាត់នៅតាមផ្លូវ។ យោងតាមអង្គការលីកាដូ នគរបាលបានចាប់ខ្លួន

[44] សេដ្ឋ មីដេនស៍ "កម្ពុជាដកហូតសិទ្ធិគណបក្សជំទាស់នៅមុនការបោះឆ្នោត" (ញូយកថាម៍ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣) https://www.nytimes.com/2023/05/16/world/asia/cambodia-election-candlelight-party.html។

[45] មាន រិទ្ធី "តុលាការខេត្តកោះកុងសម្រេចផ្តន្ទាទោសលើសកម្មជិនដីធ្លី ១០ នាក់ឱ្យជាប់ពន្ធនាគារមួយឆ្នាំ និងពិន័យជាប្រាក់ ៤០ លានរៀល"(វិទ្យុអាស៊ីសេរី ខ្មែរ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣) https://www.rfa.org/khmer/news/land/koh-kong-provincial-court-sentences-10-land-activists-one-yesr-in-prison-for-incitement-08152023142708.html។

អ្នកភូមិចំនួន ១១ នាក់ ដោយក្នុងនោះ១០ នាក់ត្រូវបានចោទប្រកាន់ពីបទញុះញង់ព្រហ្មទណ្ឌតាមមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។[46]

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ជនជាតិដើមភាគតិចក្រោល និងមិលជាង ២០០ នាក់មកពីឃុំស្រែចាស់ និងឃុំល្វេសនៅក្នុងស្រុកសំបូរ បានធ្វើដំណើរឆ្ពោះទៅសាលាខេត្តក្រចេះ ដើម្បីស្វែងរកដំណោះស្រាយចំពោះ បញ្ហាដីធ្លីជាមួយមន្ទីរវុក្ខាប្រមាញ់ខេត្តពាក់ព័ន្ធនឹងចម្ការរិលជុំ។ ក្នុងអំឡុងពេលធ្វើដំណើរ អាជ្ញាធរស្រុកបានឃាត់ក្រុមពលរដ្ឋមិនឱ្យបន្តតវ៉ានិងបានស្នើសុំឱ្យពួកគាត់រង់ចាំដំណោះស្រាយនៅដើមឆ្នាំ២០២៤។[47]

នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ អ្នកស្រី មុំ សោភី តំណាងប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ បានអះអាងថា អាជ្ញាធរមូលដ្ឋានបានសួរនាំ និងរារាំងប្រជាពលរដ្ឋក្នុងការធ្វើដំណើរមកកាន់រាជធានីភ្នំពេញ ដើម្បីធ្វើការតវ៉ាឱ្យដោះលែងលោក ថេង សាវឿន និងសហការីពីររូបទៀត។ យោងតាមអ្នកស្រី មុំ សោភី អាជ្ញាធរមូលដ្ឋាន និងប្រជាការពារភូមិនៅក្នុងសហគមន៍កសិកម្មស្ទឹងសាមគ្គី ភូមិពាមរស់ ឃុំស្ទឹងសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បានមកផ្ទះរបស់ពួកគេ ដើម្បីរារាំងពលរដ្ឋមិនឱ្យចាកចេញពីលំនៅដ្ឋានដើម្បីចូលរួមការតវ៉ានៅរាជធានីភ្នំពេញ។[48]

## ២.១៣ ការជួបប្រជុំដោយសន្តិវិធីនៅបន្តជួបការរារាំង និងហាមឃាត់



តួលេខទី ២៩៖ ចំនួនហេតុការណ៍ពាក់ព័ន្ធនឹងសេរីភាពខាងការជួបប្រជុំនៅឆ្នាំ ២០២៣

បើធៀបទៅនឹងទិន្នន័យឆ្នាំ២០២២ គម្រោងបានកត់ត្រាការកើនឡើងលើហេតុការណ៍ដែលហាមឃាត់ និងជ្រៀតជ្រែកលើជួបប្រជុំដោយសន្តិវិធី។ នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រាហេតុការណ៍ការ

[46] អ៊ឹង ស៊ា "សកម្មជនដីធ្លីខេត្តកោះកុងយ៉ាងតិច ១០ នាក់ និងកុមារម្នាក់ត្រូវបានឃុំខ្លួន បន្ទាប់ពីប៉ុនប៉ងដាក់ញត្តិ" សារព័ត៌មាន ខេមបូចា (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣) https://cambojanews.com/at-least-10-koh-kong-land-activists-and-child-detained-attempting-to-deliver-petition/។

[47] សុ ជីវី "គ្រួសារជនជាតិដើមភាគតិចជាង ២០០ នាក់ តវ៉ាអាជ្ញាធរដែលបានរឹបអូសយកដីធ្លីរបស់ពួកគេ" (អាស៊ីសេរី ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០២៣) https://www.rfa.org/khmer/news/land/kratie-indigenous-families-protest-for-their-land-from-confiscation-01022024035754.html។

[48] អ៊ុក ដែន "អ្នកភូមិថា អាជ្ញាធរមូលដ្ឋានហាមពួកគាត់មិនឱ្យឡើងតវ៉ាទាមទារដោះលែង លោក ថេង សាវឿន និងមន្ត្រីសមាគម២រូប" ព័ត៌មានពលរដ្ឋ (ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣) https://cjkhmer.com/villagers-say-local-authorities-have-banned-them-from-protesting/។

កើនឡើងទ្វេដង ដែលការជួបប្រជុំត្រូវបានហាមឃាត់មានចំនួន៨ និងមានហេតុការណ៍ចំនួន ៩៨ នៃការជ្រៀតជ្រែកលើសេរីភាពនេះ ប្រៀបធៀបនឹងហេតុការណ៍ជ្រៀតជ្រៀកលើការជួបប្រជុំចំនួន៩៥ នៃហេតុការណ៍សរុបចំនួន១៦៩ នៅក្នុងឆ្នាំ២០២២។

នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ នគរបាលមូលដ្ឋានជាច្រើននៅក្នុងភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប បានឃាត់មនុស្សប្រមាណជា ១០០ នាក់ រួមទាំងព្រះសង្ឃ សមាជិកក្រុមសង្គមស៊ីវិល និងយុវជន ដែលបានធ្វើធម្មយាត្រាពីខេត្តសៀមរាបទៅកាន់រាជធានីភ្នំពេញ។ ធម្មយាត្រានេះមានគោលបំណងបួងសួងឱ្យមានការគោរពសិទ្ធិមនុស្ស និងប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិនៅរាជធានីភ្នំពេញ នៅថ្ងៃទី១០ ខែធ្នូ។ អាជ្ញាធរបានលើកឡើងអំពីការមិនជូនដំណឹង ជាមូលហេតុដើម្បីឃាត់ធម្មយាត្រានេះ ទោះបីជាអ្នកដើរក្បួនអះអាងថាបានដាក់ការជូនដំណឹងទៅកាន់រដ្ឋបាលខេត្តជាមុនរួចហើយក៏ដោយ។[49]

## ២.១៤ ការប្រើប្រាស់កម្លាំងមកលើការជួបប្រជុំដោយសន្តិវិធីនាំឱ្យមានរបួសដល់អ្នកចូលរួមការជួបប្រជុំ

នៅឆ្នាំ២០២៣ ទិន្នន័យបានបង្ហាញថា ហេតុការណ៍ចំនួន ៨ ដែលអាជ្ញាធរបានប្រើប្រាស់កម្លាំងទៅលើមនុស្សចំនួន ៦៧៥ នាក់ដែលអនុវត្តសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី ស្របពេលដែលស្វែងរកដំណោះស្រាយលើបញ្ហាដូចជា សិទ្ធិដីធ្លី បរិស្ថាន និងវិវាទការងារ។

នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ នគរបាលខណ្ឌដូនពេញ បានប្រើប្រាស់ហិង្សាមកលើលោក កែវ សុវណ្ណឫទ្ធិ ដែលជាគរុសិស្ស និងមនុស្សពីរនាក់ផ្សេងទៀតដែលធ្វើការតវ៉ាដោយសន្តិវិធី ដោយឈរកាន់ស្លាកមួយនៅខាងមុខក្រសួងអប់រំ ទាមទារឱ្យមានការផ្តល់ក្របខណ្ឌគរុកោសល្យដល់សិស្សដែលមានឈ្មោះក្នុងបញ្ជីវិញ ដែលពួកគាត់ រួមជាមួយគរុសិស្ស ១១ នាក់ទៀតត្រូវបានដកចេញពីក្របខណ្ឌ ដោយសារតែអះអាងថា "មិនបំពេញគ្រប់លក្ខខណ្ឌ"។ អាជ្ញាធរ និងសន្តិសុខប្រមាណ ១០ នាក់ បានវាយដំ និងចាប់បង្ខំពួកគេញាត់ចូលរថយន្តនគរបាល។ លោក សុវណ្ណឫទ្ធិ បានរាយការណ៍អំពីរបួសនៅដើមទ្រូង និងឆ្អឹងជំនីរ ស្របពេលដែលលោក លាភ ប្រាថ្នា ត្រូវបានរាយការណ៍ថាសន្លប់ បន្ទាប់ពីត្រូវបានវាយចំក្បាលនៅក្នុងអំឡុងពេលនៃការចុះបង្ក្រាប។[50]

## ២.១៥ ការកើនឡើងរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពមានសេរីភាពក្នុងការអនុវត្តសិទ្ធិក្នុងការជួបប្រជុំ

[49] វ៉ា សុភានុត "អាជ្ញាធរខេត្តសៀមរាបរាំងអ្នកការពារសិទ្ធិមនុស្ស" (សារព័ត៌មានខេមបូចា ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣) https://khmer.cambojanews.com/siem-reap-authorities-block-human-rights-defenders-pilgrimage/។

[50] ដឺ វីតា "អតីតគរុសិស្សនៃវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា គ្រោងនឹងដាក់ពាក្យបណ្ដឹងលើអាជ្ញាធរខណ្ឌដូនពេញ បន្ទាប់ពីប្រើប្រាស់ហិង្សាលើរូបគាត់ជាលើកទីពីរ" (អាស៊ីសេរី ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣) https://www.rfa.org/khmer/news/human-rights/daun-penh-authorities-use-violence-against-former-students-of-moeys-the-second-time-10092023053001.html។

តួលេខទី ៣០៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ តាមឆ្នាំនីមួយៗ




ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពឆ្នាំ២០២៣ បានបង្ហាញឱ្យឃើញអំពីការផ្លាស់ប្តូរជាវិជ្ជមានដែលថ្នាក់ដឹកនាំ ៦០% យល់ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ បើធៀបទៅនឹង ៥៤% នៅឆ្នាំ២០២២។ ប៉ុន្តែ ទោះបីជាយល់ថាមានភាពប្រសើរជាងមុនក្តី ក៏ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ត្រូវបានរឹតត្បិតក្នុងកម្មវិធីសាធារណៈមួយចំនួនតូចនៅឆ្នាំ២០២៣ ដូចជា ទិវាពលកម្មអន្តរជាតិ (បុណ្យជាតិដើម្បីអបអរសាទរសិទ្ធិរបស់កម្មករនិយោជិត)។ គួរឱ្យកត់សម្គាល់ផងដែរ សូម្បីតែកម្មវិធីទាំងនេះក៏ទាមទារឱ្យអង្គការសង្គមស៊ីវិល បំពេញតាមលក្ខខណ្ឌតម្រូវដែលមិនចាំបាច់ មុនពេលទទួលបានការអនុញ្ញាត។[51]

## ២.១៦ ពលរដ្ឋយល់ថាមិនសូវមានធំនោរក្នុងការអនុវត្តសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី

តួលេខទី ៣១៖ ចំនួនភាគរយនៃបុគ្គលដែលយល់ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី




ការស្ទង់មតិសាធារណៈឆ្នាំ២០២៣ បានបង្ហាញអំពីការធ្លាក់ចុះបន្តិចចំនួនអ្នកឆ្លើយតបដែលបានរាយការណ៍ថាមានសេរីភាពក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធីនៅទីសាធារណៈដោយ៥៩% យល់ថាមានសេរីភាព ដែលតួលេខនេះធ្លាក់ចុះពី៦២% នៅឆ្នាំ២០២២។ ការប្រែប្រួលនេះ អាចកើតចេញពីការបោះឆ្នោតជាតិនៅក្នុងខែកក្កដា ដែលជាអំឡុងពេលមានការចាត់វិធានការមកលើអ្នកនយោបាយគណបក្សជំទាស់។

[51] IR២០២៣-៣៧១ និង IR២០២៣-៣៧២។

# សេរីភាពខាងការបញ្ចេញមតិ

## ២.១៧ ទិន្នន័យថ្មីៗនេះ បង្ហាញអំពីការកើនឡើងនូវហេតុការណ៍ពាក់ព័ន្ធនឹងសេរីភាពខាងការបញ្ចេញមតិ បន្ទាប់ពីមានការធ្លាក់ចុះកាលពីឆ្នាំមុន




នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រានូវហេតុការណ៍ចំនួន ២៣៨ នៅទូទាំងប្រទេសពាក់ព័ន្ធនឹងការរឹតត្បិតយ៉ាងតិចមួយហេតុការណ៍ទៅលើសេរីភាពខាងការបញ្ចេញមតិ ដូចដែលមានក្នុងលក្ខខណ្ឌបីចំណុចក្នុងមាត្រា ១៩ នៃ ក.អ.ស.ព.ន។ តួលេខនេះបង្ហាញពីការកើនឡើង ៨៦% ពីឆ្នាំ២០២២ ដែលបានកត់ត្រាហេតុការណ៍ចំនួន១២៩ ប៉ុណ្ណោះ។[52] នៅឆ្នាំ២០១៨ និង២០២៣ ដែលសុទ្ធតែជាឆ្នាំបោះឆ្នោតជាតិ ការរឹតត្បិតមានការកើនឡើង តាមការវិភាគទិន្នន័យក៏បង្ហាញអំពីការកើនឡើងហេតុការណ៍យ៉ាងខ្លាំងនៅឆ្នាំ២០២១ ដែលទំនងជាបណ្តាលមកពីការកើនឡើងការពិភាក្សាជុំវិញបញ្ហានៃការរីករាលដាលនៃជំងឺកូវីដ-១៩។




នៅចន្លោះខែឧសភា និងខែកក្កដា ឆ្នាំ២០២៣ ហេតុការណ៍នៃការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិបានកើនឡើងយ៉ាងខ្លាំង ដោយសារតែជាអំឡុងពេលនៃការបោះឆ្នោត។ គួរកត់សម្គាល់ផងដែរ ការរឹតត្បិត និងការរំលោភបំពានទាំងនេះ ធ្វើឡើងជាច្រើនទម្រង់រួមទាំងការកំណត់មុខសញ្ញាជុំវិញការបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយ អ្នកសារព័ត៌មាន សកម្មជននិងសមាជិកគណបក្សជំទាស់ សហគមន៍ និងអ្នកប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម។

[52] មាត្រា ១៩ នៃ ក.អ.ស.ព.ន។

## ២. ១៨ ការរឹតត្បិតលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត បានបន្តកើនឡើងនៅឆ្នាំ២០២៣ ដែលប៉ះពាល់ដល់អ្នកប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម សកម្មជននយោបាយ និងអ្នកនយោបាយ

តួលេខទី ៣៤៖ ការរឹតត្បិត ឬការរំលោភលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតនៅឆ្នាំ២០២២

តួលេខទី ៣៥៖ ការរឹតត្បិត ឬការរំលោភលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតនៅឆ្នាំ២០២៣




ទោះបីជាចំនួននៃការរឹតត្បិតឬការរំលោភបំពាន ធៀបទៅនឹងចំនួនហេតុការណ៍សរុបដែលបានកត់ត្រានៅតែមានលក្ខណៈស្រដៀងគ្នារវាងឆ្នាំ២០២២ និងឆ្នាំ២០២៣ ក៏ដោយ ក៏នៅឆ្នាំ២០២៣ សង្កេតឃើញមានការកើនឡើងខ្ពស់នៃចំនួនការរឹតត្បិត ឬការរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិ ទាំងតាមប្រព័ន្ធអ៊ីនធឺណិត និងដោយផ្ទាល់។ នៅឆ្នាំ២០២៣ ហេតុការណ៍៤១% (៩៨ ក្នុងចំណោម ២៣៨ ហេតុការណ៍) នៃហេតុការណ៍ទាំងអស់ដែលបានកត់ត្រា ពាក់ព័ន្ធនឹងការរឹតត្បិតលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត (តួលេខទី ៣៥)។ ទិន្នន័យឆ្នាំ២០២៣ បង្ហាញថា ក្នុងចំណោមហេតុការណ៍នៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតទាំង ៩៨ ហេតុការណ៍នេះ ២៤ ហេតុការណ៍ជាកំណត់មុខសញ្ញាលើអ្នកសារព័ត៌មាន ២៤ ហេតុការណ៍ពាក់ព័ន្ធនឹងការចាត់វិធានការមកលើអ្នកប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម និង ១៩ ហេតុការណ៍ជាការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតរបស់សកម្មជននយោបាយឬអ្នកនយោបាយរបស់គណបក្សជំទាស់។

ឧទាហរណ៍ កាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ លោក ឌុច ភាស់ ប្រជាពលរដ្ឋរស់នៅក្នុងឃុំព្រៃរំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម បាននិយាយនៅក្នុងវីដេអូមួយក្នុងអំឡុងពេលប្រមូលផ្តុំគ្នាតវ៉ាការឈូសឆាយតំបន់បឹងចំណារដោយគ្រឿងចក្ររបស់ក្រុមហ៊ុន។ នៅក្នុងវីដេអូនេះ លោក ភាស់ បាននិយាយថា" ព្រៃឈើ ភ្នំ បឹងបួរ សុទ្ធតែត្រូវគេបំផ្លាញខ្ទេចខ្ទីអស់ហើយ។ សូម្បីតែឆ្កែក៏មិនអាចលក់ទ្រព្យសម្បត្តិទាំងអស់នេះបានដែរក្រៅពីអាជ្ញាធរពុករលួយ។" បន្ទាប់ពីការចុះផ្សាយការសម្ភាសន៍ជាវីដេអូនៅលើប្រព័ន្ធបណ្តាញសង្គម លោក

ភាស់ ត្រូវបានកោះហៅទៅប៉ុស្តិ៍នគរបាលនៅពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ និងបង្ខំឱ្យសុំទោសជាសាធារណៈចំពោះពាក្យសម្តីរបស់លោកដែលបានលើកឡើងកាលពីថ្ងៃទី៥នោះ។[53]

## ២. ១៩ ហ្វេសប៊ុក និងគេហទំព័រសារព័ត៌មានមួយចំនួន គឺស្ថិតក្នុងចំណោមវេទិកាដែលពាក់ព័ន្ធនឹងការរឹតត្បិតលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតខ្ពស់បំផុត នៅឆ្នាំ២០២៣

តួលេខទី ៣៦៖ ចំនួនការការរឹតត្បិត ឬការរំលោភលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតបែងចែកតាមមាតិកា




នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រានូវហេតុការណ៍ចំនួន ៩៨ នៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត (សូមមើលតួលេខទី៣៦)។ ក្នុងចំណោមហេតុការណ៍ទាំងនេះ៦៤%(៦៣ហេតុការណ៍) ជាហេតុការណ៍រំលោភបំពានសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធបណ្តាញសង្គមនានា។ ហ្វេសប៊ុកមានការរឹតត្បិត ឬការរំលោភបំពានច្រើនបំផុត ដែលបានកត់ត្រានូវហេតុការណ៍ចំនួន ៥៨។ មាតិកាដែលបានកំណត់មុខសញ្ញាបំផុតទីពីរគឺជា គេហទំព័រសារព័ត៌មាន ដែលបានកត់ត្រានូវហេតុការណ៍ចំនួន ២៤ នៅឆ្នាំ២០២៣ ដែលផ្តោតសំខាន់មកលើអ្នកសារព័ត៌មាន។

ឧទាហរណ៍បង្ហាញ៖ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានចេញសេចក្តីសម្រេចមួយឱ្យចាត់វិធានការវិន័យលើលោកមេធាវី ជួង ជូងី (វិធានការវិន័យជាលាយលក្ខណ៍អក្សរលេខ៣០០) តាមបញ្ញត្តិនៃមាត្រា ៦៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បន្ទាប់ពីបានផ្តល់បទសម្ភាសន៍ជាមួយវិទ្យុបារាំងអន្តរជាតិ(RFI) ពាក់ព័ន្ធនឹងសំណុំរឿងរបស់អនុប្រធានគណបក្សភ្លើងទៀន លោក ថាច់ សេដ្ឋា បានបំពានលើមាត្រា ៧ (សុចរិតភាព និងភាពស្មោះត្រង់ និងការរក្សាការសម្ងាត់វិជ្ជាជីវៈ) មាត្រា ១៧ (ការអន្តរាគមន៍ពីបណ្តាញផ្សព្វផ្សាយសាធារណៈ) មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងមាត្រា ១ និងមាត្រា ៣ នៃវិធាននីតិវិធីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។[54]

## ២.២០ ការកើនឡើងចំនួនមនុស្សទទួលរងទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ ដោយសារការបញ្ចេញមតិលើប្រព័ន្ធអ៊ីនធឺណិត នៅឆ្នាំ២០២៣

[53] វាយោ "លោក ឌុច ភាស់ ដែលបានចោទប្រកាន់អាជ្ញាធរថាឈូសឆាយដីបឹងចារ ត្រូវបានចាប់ខ្លួន និងបញ្ជូនខ្លួនទៅតុលាការ" (វាយោ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣) https://vayofm.com/news/detail/124841-435.html ។

[54] ឈឹម សុភទ្ទ "គណៈមេធាវី បានសម្រេចចាត់វិធានការវិន័យលើលោក ជួង ជូងី និងលោក សំ សុគង់" (វាយោថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២៣ ) https://vayofm.com/news/detail/122955-955.html។




ទិន្នន័យដែលប្រមូលបាននៅឆ្នាំ២០២៣ បង្ហាញថា មនុស្សយ៉ាងតិច ៨៥ នាក់ ត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌដោយសារតែការអនុវត្តសេរីភាពខាងការបញ្ចេញមតិ (ខ្ពស់ជាងឆ្នាំ២០២២ ដែលមានមនុស្ស ២៧ នាក់ត្រូវបានចោទប្រកាន់) នាំឱ្យមានការកាត់ទោសមនុស្ស ៦៨ នាក់។ ក្នុងចំណោមអ្នកដែលរងការចោទប្រកាន់បុគ្គល ៧៣% (៦២ នាក់ក្នុងចំណោម ៨៥ នាក់) ទទួលរងការចោទប្រកាន់ពាក់ព័ន្ធនឹងសកម្មភាពលើប្រព័ន្ធអ៊ីនធឺណិត។ ចំនួនទណ្ឌកម្មផ្នែកព្រហ្មទណ្ឌនេះបានធ្វើឱ្យមានផលប៉ះពាល់ ឈានដល់ការកម្រិតសេរីភាពខ្លួនឯង និងថយចុះមតិរិះគន់តាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។

## ២.២១ ការចោទប្រកាន់ចំនួនដប់ប្រភេទទៅលើការបញ្ចេញមតិ ដែលជាផ្នែកនៃការអនុវត្តសេរីភាពខាងការបញ្ចេញមតិ




គម្រោងបានកត់ត្រា[55] ការចោទប្រកាន់ ១០ ប្រភេទដែលបានប្តឹងទៅលើបុគ្គលនានាក្នុងអំឡុងរយៈពេលនៃរបាយការណ៍។ នៅក្រោមវិសោធនកម្មច្បាប់បោះឆ្នោត មនុស្សចំនួន ៤២ នាក់ ដែលសុទ្ធតែជាសមាជិក

---

[55] ចំនួនបុគ្គលដែលរងការចោទប្រកាន់នៅក្នុងតួលេខនេះ គឺខ្ពស់ជាងចំនួននៃការចោទប្រកាន់នៅក្នុងតួលេខទី៣៧ ដោយសារតែបុគ្គលម្នាក់ អាចរងការចោទប្រកាន់លើសពីមួយបទចោទ។

និងសកម្មជនគណបក្សជំទាស់ទទួលរងការចោទប្រកាន់។ គម្រោងក៏បានកត់ត្រាសមាជិកតំណាងសហគមន៍បឹងតាមោកចំនួន៩ នាក់ រងការចោទប្រកាន់ពីបទហិង្សាដោយចេតនាស្ថានទម្ងន់ទោស ពាក់ព័ន្ធនឹងសកម្មភាពរបស់ពួកគេតវ៉ានឹងវិធានការរបស់រដ្ឋាភិបាល។ បន្ថែមពីនេះ បុគ្គល ២៦ នាក់ រួមមានអ្នកសារព័ត៌មាន សមាជិក/តំណាងសហគមន៍ដីធ្លី អ្នកប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម និងអ្នកនយោបាយ/សកម្មជននយោបាយ ទទួលរងការចោទប្រកាន់តាមមាត្រា ៤៩៤ និង ៤៩៥ នៃ ក្រមព្រហ្មទណ្ឌ។[56]

## ២.២២ ពាក្យសម្ដីរើសអើងកំណត់មុខសញ្ញាលើបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ អាចបង្កើតឱ្យមានបរិយាកាសការងារមិនមានផាសុកភាព និងមិនមានសុវត្ថិភាព

ទោះបីជាសេរីភាពខាងការបញ្ចេញមតិ គឺជាសិទ្ធិមនុស្សជាមូលដ្ឋានក៏ដោយ ក៏ពាក្យសម្ដីនាំឱ្យមានការរើសអើងគំរាមកំហែងដល់សិទ្ធិនេះផងដែរ។ ពាក្យសម្ដីទាំងនេះ អាចធ្វើឱ្យពលរដ្ឋជួបការលំបាកមិនហ៊ានបញ្ចេញមតិ ប៉ះពាល់ដល់សិទ្ធិរបស់ពួកគេក្នុងការបញ្ចេញមតិដោយសេរី និងបង្កើតឱ្យមានបរិយាកាសបំភិតបំភ័យ និងបំបិទមតិ។ នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រានូវហេតុការណ៍ចំនួនបួនដែលមានប្រើប្រាស់ពាក្យសម្ដីនាំឱ្យមានការរើសអើងដែលហេតុការណ៍ចំនួនបីកំណត់មុខសញ្ញាលើអ្នកសារព័ត៌មាន និងហេតុការណ៍មួយកំណត់មុខសញ្ញាលើអ្នកនយោបាយ។[57]

## ២.២៣ កម្រិតនៃសេរីភាពខាងការបញ្ចេញមតិរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព បានបង្ហាញអំពីការកើនឡើងប្រសើរបន្តិចនៅឆ្នាំ២០២៣ ប៉ុន្តែនៅតែក្នុងកម្រិតទាបគួរឱ្យព្រួយបារម្ភ

តួលេខទី ៣៨៖ ចំនួនភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងចំនួនភាគរយនៃអ្នកដែលបានរឹតត្បិតសេរីភាពខ្លួនឯងក្នុងឆ្នាំ២០២៣




នៅឆ្នាំ២០២៣ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ បានកើនឡើង ៤ %ពី ៥៤ %នៅឆ្នាំ២០២២ ទៅ ៥៨ %នៅឆ្នាំ២០២៣។ ជាមួយនឹងការកើនឡើងល្អប្រសើរនេះ គឺជាការថយចុះជាវិជ្ជមានគួរឱ្យកត់សម្គាល់ទៅលើកម្រិត

[56] យ៉ង ចាន់ដារ៉ា "តុលាការបើកការស៊ើបអង្កេតលើសកម្មជនដីធ្លីបឹងតាមោកពីរនាក់ ពាក់ព័ន្ធនឹងសកម្មភាពអំពើហិង្សាព្រាងទុកជាមុន" (អាស៊ីសេរី ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣) https://www.rfa.org/khmer/news/land/beoung-ta-mok-community-testify-at-pp-court-09072023045404.html។

[57] ការរាយការណ៍អំពីការរាយការណ៍ចំនួនបីពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យសម្ដីនាំឱ្យមានរើសអើងមកលើអ្នកសារព័ត៌មានឯករាជ្យនៅក្នុងថ្នាក់រៀន និងនៅលើបណ្តាញសង្គម។

នៃការរឹតត្បិតសេរីភាពខ្លួនឯង ដែលបានរាយការណ៍ពីថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលថយចុះពី ៨៦ %នៅឆ្នាំ២០២២ ដល់ ៨០ %នៅឆ្នាំ២០២៣។ ទោះបីជាលទ្ធផលទាំងនេះបង្ហាញអំពីរបត់ជាវិជ្ជមានក៏ដោយ ទោះជាយ៉ាងណានៅមានការព្រួយបារម្ភជាខ្លាំងថា ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព បានរាយការណ៍ថាបានរឹតត្បិតសេរីភាពខ្លួនឯងក្នុងកម្រិតខ្ពស់ក្នុងរយៈពេលមួយឆ្នាំនេះ។ លើសពីនេះទៅទៀត កម្រិតនៃសេរីភាពខាងការបញ្ចេញមតិ គឺនៅមិនប្រសើរនៅឡើយទេបើមើលទៅភាគរយនៅឆ្នាំ២០១៦ និងឆ្នាំ២០១៧ ដែលមាន ៧៤% និង ៧៧% រៀងគ្នានៃអ្នកឆ្លើយតបបានរាយការណ៍ថាមានសេរីភាពក្នុងការបញ្ចេញមតិ។ តួលេខនេះបង្ហាញឱ្យឃើញថា ថ្នាក់ដឹកនាំសង្គមស៊ីវិលនៅតែមានការប្រុងប្រយ័ត្នខ្ពស់នៅពេលបញ្ចេញមតិ និងទស្សនៈរបស់អ្នកដែលពួកគេតំណាងឱ្យជាសាធារណៈ។

## ២.២៤ អ្នកសារព័ត៌មានទទួលរងបទពិសោធន៍រឹតត្បិតនៅឆ្នាំ២០២៣

តួលេខទី៣៩៖ ចំនួនអ្នកសារព័ត៌មានដែលរងទណ្ឌកម្មផ្លូវច្បាប់ដោយសារតែការអនុវត្តសេរីភាពខាងការបញ្ចេញមតិនៅឆ្នាំ២០២៣




អំឡុងពេលកត់ត្រានេះ គម្រោងបានកត់ត្រាអ្នកសារព័ត៌មានចំនួន ២៦ នាក់ដែលបានទទួលរងការរឹតត្បិត ឬទណ្ឌកម្មដោយសារការបំពេញការងាររបស់ពួកគេ។ អ្នកសារព័ត៌មានត្រូវបាននាំខ្លួនទៅសាកសួរបន្ទាប់ពីការស៊ើបអង្កេតឬការរាយការណ៍អំពីបញ្ហានានា ដូចជា សកម្មភាពអាជីវកម្មខុសច្បាប់[58] អំពើពុករលួយ[59] និងវិវាទដីធ្លី[60]។

ឧទាហរណ៍៖ កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ តុលាការកំពូលបានតម្កល់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ខេត្តបាត់ដំបង ក្នុងការផ្តន្ទាទោសអ្នកសារព័ត៌មានលោក កៅ ពិសិដ្ឋ ឱ្យជាប់ពន្ធនាគារពីរឆ្នាំ និងពិន័យជាប្រាក់ ៣ លានរៀល ពីបទញុះញង់ បន្ទាប់ពីលោកបានរិះគន់រដ្ឋាភិបាលតាមប្រព័ន្ធបណ្តាញសង្គម និងវ៉ាក់សាំងកូវីដ-១៩ ដែលផលិតនៅ

[58] IR២០២៣-០១៦។

[59] IR២០២៣-០០៩។

[60] យុត សុគុណ "សង្គមស៊ីវិលនិយាយថា អាជ្ញាធរខេត្តកំពង់ឆ្នាំងបានឃុំខ្លួនអ្នកសារព័ត៌មានជាការគំរាមកំហែង និងជាការបំបិទសិទ្ធិ" វីអូឌី (ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣) https://www.vodkhmer.news/2023/01/20/civil-society-says-kampong-chhnang-authorities-detained-citizen-journalists-as-a-threat-and-blocked-rights/

ប្រទេសចិន ។ តុលាការកំពូល បានចាត់ទុកការបញ្ចេញមតិនេះ ថាបំពានលើ *ច្បាប់ស្តីពីការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត*។[61]

តួលេខទី៤០ ៖ អ្នកសារព័ត៌មានទទួលរងការបំភិតបំភ័យ/ការឃាឃី នៅពេលបំពេញការងារនៅក្នុងឆ្នាំ២០២៣




នៅឆ្នាំ២០២៣ គម្រោងបានបន្តកត់ត្រាការបំភិតបំភ័យ និងឃាឃីដែលអ្នកសារព័ត៌មានទទួលរងបទពិសោធន៍ទាំងនេះនៅពេលដែលពួកគេស៊ើបអង្កេត ឬរាយការណ៍ព័ត៌មាន។ នៅក្នុងហេតុការណ៍ចំនួន ៥ បណ្តាញផ្សព្វផ្សាយ ឬអ្នកសារព័ត៌មានបានទទួលរងការគំរាមកំហែងផ្លូវច្បាប់ និងត្រូវបានបង្គាប់ឱ្យកែឡើងវិញ ឬរារាំងពីការចុះផ្សាយអត្ថបទរបស់ពួកគេ។[62] មាន ៦ ករណីដែលអ្នកសារព័ត៌មាន ដែលបម្រើការងារនៅបណ្តាញផ្សព្វផ្សាយទទួលរងការវាយប្រហារ ឬការបង្កបួសស្នាមដោយជនដែលមិនស្គាល់អត្តសញ្ញាណ។[63] នៅក្នុងហេតុការណ៍ចំនួន ៤ សម្ភារៈរបស់អ្នកសារព័ត៌មានត្រូវបានចាប់យកពីម្ចាស់អាជីវកម្ម ឬអាជ្ញាធរ នៅ

[61] ម៉េង គ្រុយពន្លក "តុលាការកំពូលផ្តន្ទាទោសអ្នកសារព័ត៌មានឱ្យជាប់ពន្ធនាគារពីរឆ្នាំពីបទផ្សព្វផ្សាយសារលើបណ្តាញហ្វេសប៊ុកដែលរិះគន់ដល់រដ្ឋាភិបាល" វីអូឌី (ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣) https://www.vodkhmer.news/2023/02/01/supreme-court-sentences-journalist-to-two-years-in-prison/។

[62] វិទ្យុអាស៊ីសេរី "បណ្តាញសារព័ត៌មានកម្ពុជា បានលុបឈ្មោះរដ្ឋមន្ត្រីចេញបន្ទាប់ពីការគំរាមកំហែងផ្លូវច្បាប់" (វិទ្យុអាស៊ីសេរី ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣) https://www.rfa.org/english/news/cambodia/news-outlet-legal-threat-09192023164628.html។

[63] ធុំ ពិសម័យ "អ្នកសារព័ត៌មានត្រូវបានជនមិនស្គាល់មុខវាយប្រហារ" សារព័ត៌មានកោះសន្តិភាព (ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣) https://kohsantepheapdaily.com.kh/article/1679217.html ។

ពេលស៊ើបអង្កេត ផ្សាយផ្ទាល់ ឬថតយករូបភាព។[64] ការជ្រៀតជ្រែកហួសហេតុបែបនេះទៅលើសកម្មភាពរបស់អ្នកសារព័ត៌មាន ជារឿងគួរឱ្យព្រួយបារម្ភជាខ្លាំងដោយសារ តែមិនមានករណីណាមួយក្នុងចំណោមករណីទាំងនេះ រកឃើញជនប្រព្រឹត្តអំពើនោះឱ្យមកទទួលខុសត្រូវនៅឡើយ។

### ២.២៥ ក្នុងអំឡុងពេលនៃការបោះឆ្នោតជាតិឆ្នាំ២០២៣ មានការដកហូតអាជ្ញាប័ណ្ណបណ្តាញផ្សព្វផ្សាយ

តួលេខទី៤២៖ ចំនួននៃការដកហូត ការដាក់ទណ្ឌកម្ម ឬការផ្អាកបណ្តាញផ្សព្វផ្សាយឯករាជ្យពេញមួយឆ្នាំ




រដ្ឋាភិបាលបន្តរឹតត្បិតសេរីភាពសារព័ត៌មាននៅមុនការបោះឆ្នោតជាតិឆ្នាំ២០២៣ តាមរយៈការបិទបណ្តាញផ្សព្វផ្សាយចំនួនប្រាំដែលចុះផ្សាយព័ត៌មានរសើបឬរិះគន់អំពីអំពើពុករលួយនៅក្នុងប្រទេស។[65] បណ្តាញផ្សព្វផ្សាយទាំងនោះសុទ្ធតែត្រូវបានប្រានចោលលទ្ធភាពក្នុងការដាក់បណ្តឹងឧបាស្រ័យជំទាស់នឹងសេចក្តីសម្រេចនេះ។

**ឧទាហរណ៍៖** កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៣ វិទ្យុសំឡេងប្រជាធិបតេយ្យ (វីអូឌី) ជាបណ្តាញផ្សព្វផ្សាយឯករាជ្យមួយចុងក្រោយនៃបណ្តាញផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា បានចុះផ្សាយអត្ថបទមួយដែលស្រង់សម្តីរបស់អ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន ដែលបានលើកឡើងថា លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ដែលពីមុនជាមេបញ្ជាការកងទ័ពជើងគោកបានចុះហត្ថលេខាលើកញ្ចប់ជំនួយសង្គ្រោះដែលមានទឹកប្រាក់ ១០០.០០០ ដុល្លារទៅឱ្យប្រទេសទួរគី ជំនួសមុខឱ្យឪពុករបស់លោក អតីតនាយករដ្ឋមន្ត្រី។ នៅថ្ងៃទី១១ ខែកុម្ភៈ លោក ហ៊ុន សែន បានទាមទារតាមរយៈប្រព័ន្ធបណ្តាញសង្គមឱ្យ វីអូឌី ចេញលិខិតសុំទោសនៅក្នុងរយៈពេល ៧២ ម៉ោង។ នៅថ្ងៃបន្ទាប់ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បានចេញលិខិតមួយដែលបង្ហាញអំពីការសោកស្តាយចំពោះការភាន់ច្រលំណាមួយទៅលើអត្ថបទនេះ និងស្នើសុំឱ្យមានការយោគយល់ពីអតីតនាយករដ្ឋមន្ត្រី។ អតីតនាយករដ្ឋមន្ត្រី បានចាត់ទុកការឆ្លើយតបនោះថា" មិនអាចទទួលយកបាន "និងបានបង្គាប់ឱ្យក្រសួងព័ត៌មានដកហូតអាជ្ញាប័ណ្ណចុះផ្សាយ និងផ្សព្វផ្សាយរបស់ វីអូឌី នៅថ្ងៃទី១៣ ខែកុម្ភៈ។[66]

---

[64] IR2023-011។

[65] វិទ្យុសំឡេងប្រជាធិបតេយ្យ (វីអូឌី) សារព័ត៌មានសមាគមអ្នកសារព័ត៌មានកម្ពុជា-អាស៊ាន សារព័ត៌មានរស្មីកំពង់ចាម សារព័ត៌មានដំណឹងក្នុងស្រុក និងសារព័ត៌មានខ្មែរខូរ៉េធីវី។

[66] ឃ្លារ៍ បលវីន ហ្យូ ឡសិន "លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បិទបណ្តាញសារព័ត៌មានឯករាជ្យក្នុងស្រុក" សារព័ត៌មាន Reuters (ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣) https://www.reuters.com/world/asia-pacific/cambodias-hun-sen-orders-shutdown-last-independent-local-news-outlet-2023-02-12/។

ឧទាហរណ៍៖ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ក្រសួងព័ត៌មានបានដកហូតអាជ្ញាប័ណ្ណរបស់បណ្តាញផ្សព្វផ្សាយភាសាខ្មែរលើប្រព័ន្ធអ៊ីនធឺណិតចំនួនបី៖ សមាគមអ្នកសារព័ត៌មានកម្ពុជា-អាស៊ាន សារព័ត៌មានស្មើកំពង់ចាម និងសារព័ត៌មានដំណឹងក្នុងស្រុក ដោយសារតែ" បំពានធ្ងន់ធ្ងរលើក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន"។ បណ្តាញផ្សព្វផ្សាយទាំងបី កន្លងមកបានរាយការណ៍អំពីការអះអាងការចូលរួមពាក់ព័ន្ធរបស់ព្រះរាជអាជ្ញារងខេត្តតាកែវនៅក្នុងសំណុំរឿងដំរិត។ បណ្តាញផ្សព្វផ្សាយទាំងនេះ ក៏បានចុះផ្សាយអត្ថបទមួយដែលបង្ហាញថា លោក សរ ចំរុង សមាជិករដ្ឋសភាជាន់ខ្ពស់នៃកាន់អំណាច ត្រូវបានគេរាយការណ៍ថាបានក្លែងបន្លំឯកសារ ដើម្បីទទួលបានដីធ្លីនៅក្នុងខេត្តបន្ទាយមានជ័យ។[67]

ការវិភាគទិន្នន័យពីចំណុចគន្លឹះទី ២ បង្ហាញថារដ្ឋាភិបាលនៅតែមិនបានអនុវត្តតាមច្បាប់ និងបទដ្ឋានស្តីពីសិទ្ធិមនុស្សអន្តរជាតិ។ គម្រោងបានកត់ត្រាការកើនឡើងនៃហេតុការណ៍ពាក់ព័ន្ធនឹងការរំលោភបំពានលើសេរីភាពមូលដ្ឋានជារៀងរាល់ឆ្នាំ។ ច្បាប់នានាដូចជា ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត បានបន្តប្រើប្រាស់ដើម្បីបន្ថយឥទ្ធិពលពលរដ្ឋ និងបន្ថយសំឡេងជំទាស់ ជាពិសេសក្នុងអំឡុងពេលនៃការបោះឆ្នោតជាតិឆ្នាំ២០២៣។ ជាលទ្ធផលមនុស្សចំនួន៤២ នាក់ ដែលជាសមាជិក ឬសកម្មជននៃគណបក្សជំទាស់ ត្រូវបានចោទប្រកាន់នៅក្រោមច្បាប់ស្តីពីការបោះឆ្នោតដែលបានធ្វើវិសោធនកម្ម។ អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សកម្មជនសិទ្ធិការងារ និងសកម្មជនបរិស្ថាន ក៏នៅតែបន្តទទួលរងការឃាយី និងការវាយប្រហារ ដោយសារតែភាពសកម្មរបស់ពួកគេ។

[67] ឃួន ណារីម អ៊ឹង ស៊ា"ក្រសួងព័ត៌មានដកហូតអាជ្ញាប័ណ្ណរបស់បណ្តាញផ្សព្វផ្សាយចំនួនបី បន្ទាប់ពីការរាយការណ៍អំពីការពាក់ព័ន្ធរបស់មន្ត្រីជាន់ខ្ពស់នៅក្នុងការក្លែងបន្លំដីធ្លី" (សារព័ត៌មាន ខេមបូចា ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣) https://cambojanews.com/information-ministry-revokes-three-media-licenses-following-reports-on-senior-officials-role-in-land-fraud/។

## ចំណុចគន្លឹះទី៣ ៖ តើបុគ្គលម្នាក់ៗយល់អំពីសេរីភាពមូលដ្ឋាន និងយល់ថាខ្លួនមានសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនេះដែរឬទេ?

ចំណុចគន្លឹះទី៣ វាយតម្លៃពីកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា អំពីសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ និងកម្រិតដែលពលរដ្ឋយល់ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនោះ។ ទិន្នន័យចំណុចគន្លឹះទី៣ ត្រូវបានប្រមូលតាមរយៈការស្ទង់មតិជាសាធារណៈជាមួយពលរដ្ឋចំនួន ១,០០៥[68] នាក់ នៅទូទាំង២៥ រាជធានី-ខេត្ត (តួលេខទី៤២) ដែលធ្វើឡើងចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ វិធីសាស្ត្រជ្រើសរើសសំណាកងាយៗត្រូវបានប្រើប្រាស់សម្រាប់ការស្ទង់មតិនេះ។



តួលេខទី ៤២ ចំនួនអ្នកឆ្លើយតបការស្ទង់មតិសាធារណៈពីចន្លោះឆ្នាំ២០១៦ និង ឆ្នាំ២០២៣

**របកគំហើញសំខាន់ៗ៖** ខណៈពេលដែលការដាក់សម្ពាធផ្នែកនយោបាយ និងវិធានការហិង្សាតាមអំពើចិត្តមានការកើនឡើងនៅក្នុងអំឡុងពេលនៃការបោះឆ្នោតជាសកលនៅកម្ពុជាឆ្នាំ២០២៣ ការយល់ដឹងរបស់ប្រជាពលរដ្ឋសេរីភាពមូលដ្ឋាន និងក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសិទ្ធិទាំងនេះ មានការថយចុះចាប់តាំងពីឆ្នាំ២០២២ មក។ នៅឆ្នាំ២០២៣ ពលរដ្ឋជាច្រើនបានរាយការណ៍ថាបានរឹតត្បិតសេរីភាពខ្លួនឯង ឬមិនបញ្ចេញគំនិតនិងមតិយោបល់របស់ខ្លួនដោយសារតែភ័យខ្លាចការសងសឹក។ ទោះជាយ៉ាងនេះក្ដី ទិន្នន័យបង្ហាញថារឹតត្បិតសេរីភាពខ្លួនឯងរបស់ស្ត្រី និងបុគ្គលដែលមានអត្តសញ្ញាណភេទផ្សេងៗនៅកម្រិតទាបជាងបុរស បើធៀបទៅនឹងឆ្នាំមុន។ ដោយឡែក ស្ត្រីយល់ថាមិនសូវមានសេរីភាពដូចបុរសក្នុងការចូលរួមនៅក្នុងជីវភាពនយោបាយប៉ុន្មានទេ។ នៅពេលដែលពលរដ្ឋមិនមានជំនឿមកលើយន្តការដោះស្រាយ ដើម្បីការពារសេរីភាពមូលដ្ឋាន ដោយយល់ថាពួកគាត់កាន់តែមានភាពលំបាកក្នុងការដាក់ពាក្យប្ដឹង និងមានទំនុកចិត្តតិចតួចចំពោះការដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស ពីស្ថាប័នរដ្ឋាភិបាល ឬតុលាការ ។ កង្វះទំនុកចិត្តលើតុលាការ និងរដ្ឋាភិបាលនៅតែមានកម្រិតខ្ពស់ចាប់តាំងពីការចាប់ផ្ដើមកត់ត្រារបស់គម្រោង។

---

[68] ការបន្ថែមសំណាកគំរូសម្រាប់ការស្ទង់មតិក្នុងឆ្នាំ២០២២ ដោយសារតែការកើនឡើងធនធានមួយផ្នែក។

## ៣.១ ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅតែបន្តធ្លាក់ចុះ




តួលេខទី ៤៣៖ ភាគរយនៃសាធារណជនដែលបានរាយការណ៍ថាយល់ដឹងច្បាស់អំពីធាតុផ្សំនៃសេរីភាពមូលដ្ឋាននីមួយៗ

ភាគរយនៃអ្នកឆ្លើយតបដែលបានឆ្លើយ ថាខ្លួនបានដឹង "ច្បាស់ណាស់" អំពីអត្ថន័យ នៃសេរីភាពនីមួយៗបន្តស្ថិតនៅកម្រិតទាប (៨% ចំពោះសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ និង៥% ប៉ុណ្ណោះចំពោះសេរីភាពខាងសមាគម)។ នេះមានន័យថាតិចជាង១០ភាគរយនៃពលរដ្ឋកម្ពុជាអាចដឹងច្បាស់ពីសេរីភាពមូលដ្ឋាននីមួយៗ។ ភាគរយនៃអ្នកឆ្លើយតបដែលបានឆ្លើយថាខ្លួនបាន "ដឹងច្បាស់ណាស់" អំពីធាតុផ្សំនៃសេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ គឺមានការថយចុះ បើធៀបនឹងឆ្នាំ២០២២ ពោលគឺថយចុះពី១២% (សេរីភាពខាងការបញ្ចេញមតិ) និង១០% (សេរីភាពខាងការជួបប្រជុំ) មកត្រឹម៨% សម្រាប់សេរីភាពមូលដ្ឋានទាំងពីរនេះនៅឆ្នាំ២០២៣។ ភាគរយនៃអ្នកឆ្លើយតបដែលបានឆ្លើយថាខ្លួន "ដឹងច្បាស់ណាស់" អំពីធាតុផ្សំនៃសេរីភាពខាងសមាគម គឺពុំមានការប្រែប្រួលខុសពីឆ្នាំមុនទេ ដែលមានត្រឹម៥%។

ការណ៍ដែលមានពលរដ្ឋមួយចំនួនតូចប៉ុណ្ណោះដឹងច្បាស់អំពីសេរីភាពមូលដ្ឋាន និងធាតុផ្សំនៃសិទ្ធិទាំងនេះ គឺអាចដោយសារតែការរារាំងពលរដ្ឋក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនឱ្យបានពេញលេញ ឬការមិនទទួលស្គាល់នូវការរំលោភសិទ្ធិទាំងនេះ។ នេះជាការព្រួយបារម្ភ បន្ទាប់ពីការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋានមានការកើនឡើងបន្តិចពីឆ្នាំ២០២០ ហើយបានធ្លាក់ចុះជាថ្មីម្តងទៀត។

## ៣.២ ពលរដ្ឋយល់ថាមិនសូវមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ជាពិសេសការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត និងការនិយាយទៅកាន់អ្នកសារព័ត៌មាន

តួលេខទី ៤៤៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការនិយាយទៅកាន់អ្នកសារព័ត៌មាន




នៅក្នុងឆ្នាំ២០២០ ភាគរយនៃអ្នកឆ្លើយតប ដែលយល់ថា មានសេរីភាពក្នុងការនិយាយទៅកាន់អ្នកសារព័ត៌មាន គឺបានធ្លាក់ដល់កម្រិតទាប ពោលគឺ ២៧%។ ចាប់តាំងពីពេលនោះមក តួលេខនេះនៅបន្តកើនឡើងបន្តិច។ ទោះជាយ៉ាងនេះក្តី នៅឆ្នាំ២០២៣ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាខ្លួនមានសេរីភាពក្នុងការនិយាយទៅកាន់អ្នកសារព័ត៌មានគឺមានត្រឹម ៣៨% ពោលគឺថយចុះ ១១% ពីឆ្នាំ២០២១ (ពី

៤៩%) និង ថយចុះ ៧% ពីឆ្នាំ២០២២ (ពី៤៥%)។ ហេតុដូច្នេះ មានន័យថា លើសពីពាក់កណ្តាល ៦២% នៃអ្នកឆ្លើយតបមិនបានយល់ថាខ្លួនមានសេរីភាពក្នុងការនិយាយទៅកាន់អ្នកសារព័ត៌មាននោះទេ ឧទាហរណ៍រួមមាន ករណីមួយចំនួនដែលបុគ្គលបានស្នើសុំឱ្យរក្សាអត្តសញ្ញាណរបស់ខ្លួនជាជនអនាមិកនៅពេលផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយ ដោយសារតែពួកគេភ័យខ្លាចការសងសឹកពីអាជ្ញាធរ ដែលនេះបង្ហាញថាពលរដ្ឋជាច្រើននៅតែយល់ថា ខ្លួនមិនអាចបញ្ចេញការយល់ឃើញរបស់ខ្លួនបានដោយសេរីឡើយ និងឆ្លុះបញ្ចាំងអំពីការរឹតត្បិតយ៉ាងធ្ងន់ធ្ងរជាបន្តបន្ទាប់មកលើសេរីភាពខាងការបញ្ចេញមតិ។

តួលេខទី៤៥៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈ




ភាគរយនៃអ្នកឆ្លើយតបដែលយល់ថា ខ្លួនមានសេរីភាពក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈ បានបន្តកើនឡើងនៅឆ្នាំ២០២២ (ពី ៥៥% នៅឆ្នាំ២០២២ ទៅ ៥៣% នៅឆ្នាំ២០២៣) ចំណុចគួរកត់សម្គាល់គឺពលរដ្ឋអាចជជែកគ្នាបានកាន់តែច្រើនពីប្រធានបទផ្សេងៗនៅទីសាធារណៈក្នុងរយៈពេល ៤ ឆ្នាំកន្លងមក ពី ២៩% នៅឆ្នាំ២០២០ ដល់ ៥៥% និង ៥៣% នៅឆ្នាំ២០២២ និងឆ្នាំ២០២៣ បន្តបន្ទាប់គ្នា។ ទោះជាយ៉ាងនេះក្តី ជាការព្រួយបារម្ភដែលពលរដ្ឋ ៤៧% ផ្សេងទៀតមិនបានយល់ថាខ្លួនមានសេរីភាពក្នុងការនិយាយនៅទីសាធារណៈនោះទេ ភាពភ័យខ្លាចអាចកើតមាន ប្រសិនបើពួកគាត់បញ្ចេញមតិដែលអាចជាការរិះគន់ ឬការដាក់សម្ពាធទៅលើអ្នកកាន់អាជ្ញាធរ។ ទិន្នន័យនេះបង្ហាញថាពលរដ្ឋនៅតែបន្តរឹតត្បិតការបញ្ចេញមតិរបស់ខ្លួន។

តួលេខទី ៤៦៖ ភាគរយនៃអ្នកឆ្លើយតបយល់ថាមានសេរីភាពក្នុងការនិយាយដោយបើកចំហនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម




ភាគរយនៃអ្នកឆ្លើយតបដែលយល់ថា មានសេរីភាពក្នុងការនិយាយដោយបើកចំហគ្រប់ប្រធានបទទាំងអស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម បានថយចុះនៅចន្លោះឆ្នាំ២០២២ និងឆ្នាំ២០២៣ ធ្លាក់ចុះពី ៤៤% មក ៣៦%។ ទោះបីជាកម្រិតនេះមានការកើនឡើងលើសពីឆ្នាំ២០២០ (២៨%) ក៏ដោយ ក៏ភាគរយជារួមគឺនៅតែមានកម្រិតទាបដដែល មានការវិវឌ្ឍវិជ្ជមានខ្លះដែរនៅឆ្នាំ២០២១ ដែល ៤៧% នៃអ្នកឆ្លើយតបយល់ថាខ្លួនមានសេរីភាពក្នុងការនិយាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម តែបានថយចុះមកវិញផងដែរ។ ភាគរយទាបនៅឆ្នាំ២០២៣ អាចឆ្លុះបញ្ចាំងអំពីភាពភ័យខ្លាចនឹងការឃ្លាំមើល និងការ

ចាត់វិធានការចំពោះមតិគាំទ្រគណបក្សជំទាស់ ឬការរិះគន់គណបក្សកាន់អំណាចក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ ២០២៣ តាមប្រព័ន្ធផ្សព្វផ្សាយសង្គម។

ការស្ទង់មតិបានបង្ហាញថា ពីមួយពេលទៅមួយពេល ភាគរយនៃពលរដ្ឋដែលយល់ថាខ្លួនមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិបានឈានទៅរកលំនាំដដែលៗ៖ ការរឹតត្បិតលើការបញ្ចេញមតិ គឺមានការកើនឡើងខ្ពស់បំផុតក្នុងអំឡុងពេលបោះឆ្នោត។ យោងតាមតួលេខទី៤៤ តួលេខទី៤៥ និងតួលេខទី៤៦ អ្នកឆ្លើយតបយល់ថាខ្លួនមានសេរីភាពខ្លាំងណាស់ក្នុងការនិយាយដោយបើកចំហគឺនៅមុនពេលការបោះឆ្នោតពេលនៅឆ្នាំ២០១៧ បើធៀបទៅនឹងឆ្នាំបន្តបន្ទាប់។ កម្រិតសេរីភាពក្នុងការនិយាយដោយបើកចំហមានការធ្លាក់ចុះនៅឆ្នាំ២០១៨ អាចដោយសារតែការកើនឡើងនៃការរឹតត្បិត និងករណីរំលោភបំពានសេរីភាពមូលដ្ឋានជុំវិញការបោះឆ្នោត បន្តថយចុះបន្ថែមទៀតនៅឆ្នាំ២០២០ អាចដោយសារតែការរឹតត្បិត និងការរំលោភបំពានកើនឡើងក្នុងអំឡុងពេលរាតត្បាតជំងឺកូវីដ-១៩។ ការធ្លាក់ចុះនេះបានកើនឡើងជាបន្តបន្ទាប់វិញនៅក្នុងរយៈពេលពីរឆ្នាំបន្ទាប់មកនេះ។ ក្នុងអំឡុងពេលបោះឆ្នោតជាតិនៅឆ្នាំ២០២៣ ភាគរយនេះបានធ្លាក់ចុះម្តងទៀតទំនងជាដោយសារតែភាពភ័យខ្លាច នៅមុននិងអំឡុងពេលបោះឆ្នោតជាតិកាលពីពេលថ្មីៗកន្លងទៅនេះ ដែលកើតមានមកលើសកម្មជនគណបក្សជំទាស់។ នេះជាបញ្ហាគួរឱ្យបារម្ភក្នុងអំឡុងពេលដែលជិតពាក់កណ្តាលនៃពលរដ្ឋមិនហ៊ានបញ្ចេញមតិរបស់ខ្លួនតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។ ជាការចាំបាច់ណាស់ដែលគួរបង្កើតបរិយាកាសឱ្យពលរដ្ឋអាចអនុវត្តនូវសិទ្ធិសេរីភាពមូលដ្ឋានរបស់ខ្លួន ដោយមិនបារម្ភពីការទទួលរងនូវផលវិបាក និងរក្សាបរិយាកាសនេះក្នុងអំឡុងពេលអស្ថិរភាពនយោបាយ ឬក្នុងអន្តរកាលនៃការផ្លាស់ប្តូរ។

## ៣.៣ ចំនួនអ្នកដែលរឹតត្បិតសេរីភាពខ្លួនឯងជាញឹកញាប់មានការថយចុះចាប់តាំងពីឆ្នាំមុន ប៉ុន្តែចំនួននេះនៅតែមានកម្រិតខ្ពស់ដដែល

តួលេខទី ៤៧៖ ចំនួនភាគរយនៃសាធារណជនដែលបានរាយការណ៍អំពីការរឹតត្បិតសេរីភាពខ្លួនឯង




នៅចន្លោះឆ្នាំ២០២១ និងឆ្នាំ២០២៣ ពលរដ្ឋមួយចំនួនធំបានរាយការណ៍ថាបានរឹតត្បិតសេរីភាពខ្លួនឯង ដោយលើកឡើងថាពួកគាត់ភ័យខ្លាចពីផលប៉ះពាល់ចំពោះការធ្វើសកម្មភាពទាំងនេះ។ ភាគរយនៃអ្នកដែលបានរាយការណ៍ថា "ជានិច្ចកាល" រឹតត្បិតសេរីភាពខ្លួនឯង គឺមាន ១០% នៅឆ្នាំ២០២១ និងឆ្នាំ២០២២ និងថយមកត្រឹម ៩% ក្នុងឆ្នាំ២០២៣។ នៅឆ្នាំ២០២៣ ១៤% នៃអ្នកឆ្លើយតបបានឆ្លើយថារឹតត្បិតសេរីភាពខ្លួនឯង "ជាប្រចាំ" និង ៤០% ឆ្លើយថាបានរឹតត្បិតសេរីភាពខ្លួនឯង "នៅពេលខ្លះ" អ្នកឆ្លើយតបចំនួន ១៣% ឆ្លើយថា "កម្រណាស់" និងអ្នកឆ្លើយតបត្រឹមតែ ១១% ប៉ុណ្ណោះ ឆ្លើយថា "មិនដែលសោះ"។ ទោះបីជាមានការធ្លាក់ចុះ ៥% នៃភាគរយអ្នកឆ្លើយតបថាបានរឹតត្បិតខ្លួនឯង "នៅពេលខ្លះ" ពីឆ្នាំ២០២២ ក៏ការពិតនៃភាគរយអ្នកឆ្លើយ

តប (៤០%) បានរាយការណ៍ថាបានរឹតត្បិតសេរីភាពខ្លួនឯង "នៅពេលខ្លះ" ព្រមទាំងការប្រែប្រួលភាគរយនៃអ្នកឆ្លើយតបថា "ជានិច្ចកាល"ឬ "ជាប្រចាំ" បានរឹត្បិតសេរីភាពខ្លួនឯង នេះអាចបញ្ជាក់ថាពលរដ្ឋភ័យខ្លាចពីផលវិបាកដែលអាចកើតមានឡើង នៅពេលបញ្ចេញមតិ ឬចែករំលែកគំនិតរបស់ពួកគាត់តាមប្រព័ន្ធអ៊ីនធឺណិត និងនៅទីសាធារណៈ។ ពលរដ្ឋនៅតែបន្តភ័យខ្លាចក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ បើទោះបីជាច្បាប់ជាតិធានានូវសិទ្ធិនេះចំពោះពលរដ្ឋគ្រប់រូបក៏ដោយ។

## ៣.៤ ស្ត្រីយល់ថាមានសេរីភាពជាងបុរសក្នុងការបញ្ចេញមតិ ឬគំនិតមតិយោបល់ ដោយឡែកបុគ្គលដែលមាននិន្នាការភេទផ្សេងៗបានរាយការណ៍ថាបានរឹតត្បិតសេរីភាពខ្លួនឯងក្នុងកម្រិតទាបជាងបុរសនិងស្ត្រីនៅឡើត



តួលេខទី៤៨៖ ភាគរយនៃសាធារណជនដែលបានរាយការណ៍អំពីការរឹតត្បិតសេរីភាពខ្លួនឯងដោយបែងចែកតាមយេនឌ័រ

ជាប្រវត្តិនៅក្នុងការស្ទង់មតិបង្ហាញពីភាពខុសគ្នារវាងយេនឌ័រនីមួយៗ ដែលជាទូទៅស្ត្រី តែងតែមានកម្រិតខ្ពស់ជាងបុរសក្នុងការរឹតត្បិតសេរីភាពខ្លួនឯង ទោះបីជាយ៉ាងណាតួលេខបានធ្លាក់ចុះនៅក្នុងឆ្នាំ២០២២។ នៅឆ្នាំ២០២៣ របត់បែបនេះនៅបន្តដដែល កម្រិតនៃការរឹតត្បិតសេរីភាពខ្លួនឯងក្នុងចំណោមបុរសខ្ពស់ជាងកម្រិតរឹតត្បិតសេរីភាពខ្លួនឯងក្នុងចំណោមស្ត្រី។ ១០% នៃអ្នកឆ្លើយតបជាបុរសបានរាយការណ៍ថា "ជានិច្ចកាល" តែងរឹតត្បិតសេរីភាពខ្លួនឯង ១៧% បានរឹតត្បិតសេរីភាពខ្លួនឯង "ជាប្រចាំ" ៣៩% បានរឹតត្បិតសេរីភាពខ្លួនឯង "នៅពេលខ្លះ" ១២% ឆ្លើយថា "កម្រណាស់" និង ១០% ឆ្លើយថា "មិនដែលសោះ"។ បើធៀបជាមួយស្ត្រីវិញ ៨% នៃអ្នកឆ្លើយតបជាស្ត្រីបានរាយការណ៍ថា "ជានិច្ចកាល" តែងរឹតត្បិតសេរីភាពខ្លួនឯង ១១% បានរឹតត្បិតសេរីភាពខ្លួនឯង "ជាប្រចាំ" ៤០% បានរឹតត្បិតសេរីភាពខ្លួនឯង "នៅពេលខ្លះ" ១៤% ឆ្លើយថា "កម្រណាស់" និង ១២% ឆ្លើយថា "មិនដែលសោះ"។ បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រផ្សេងៗ បានរាយការណ៍ពីការរឹតត្បិតសេរីភាពខ្លួនឯង "ជានិច្ចកាល" និង "ជាប្រចាំ" នៅកម្រិត ០% និង ៥% ដូចគ្នា[៦៩] ដែលជាតួលេខល្អប្រសើរមួយពីឆ្នាំមុន ដែល ២១% បានរាយការណ៍ថាបានរឹតត្បិតសេរីភាពខ្លួនឯង "ជានិច្ចកាល" និង ២៦% បានរាយការណ៍ថារឹតត្បិតសេរីភាពខ្លួនឯង "ជាប្រចាំ"។ គួរកត់សម្គាល់ថា លើសពីពាក់កណ្ដាលនៃបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រផ្សេងៗបានរាយការណ៍ថាបានរឹតត្បិតសេរីភាពខ្លួនឯងនៅ "នៅពេលខ្លះ" (៥៣%) នេះបង្ហាញឱ្យឃើញថាពលរដ្ឋដែលមានយេនឌ័រផ្សេងៗយល់ថាមានសេរីភាពជាងគេក្នុងការបញ្ចេញមតិក៏ដោយ ក៏ពួកគេនៅតែយល់ថាមានភាពភ័យខ្លាចពីផលប៉ះពាល់ក្រោយការបញ្ចេញមតិនោះផងដែរ ។

[៦៩] នៅឆ្នាំ២០២៣ អ្នកឆ្លើយតបចំនួន១៩ នាក់បានបញ្ជាក់ថាមានអត្តសញ្ញាណយេនឌ័រផ្សេងៗ។

## ៣.៥ ពលរដ្ឋយល់ថាមិនសូវមានសេរីភាពក្នុងការចូលរួមជាមួយសមាគម ឬសហជីព ប៉ុន្តែយល់ថាមានសេរីភាពក្នុងការចាកចេញពីសមាគម ឬសហជីពខ្លាំងជាង




ចាប់តាំងពីឆ្នាំ២០១៧ អ្នកឆ្លើយតបដែលជាបុគ្គលិកឬកម្មករនិយោជិតត្រូវបានសួរសំណួរអំពីការយល់ឃើញរបស់ពួកគាត់អំពីសេរីភាព ឬមិនមានសេរីភាពក្នុងការចូលរួម និង/ឬចាកចេញពីសហជីព ឬសមាគម។ តួលេខទី៤៩ បង្ហាញថាពលរដ្ឋ ៣៤% យល់ថាពួកគាត់អាចអនុវត្តសេរីភាពខាងសមាគមបានតាមរយៈការចូលរួមជាមួយសហជីព (ក្នុងនោះមាន "មានសេរីភាពខ្លាំងណាស់" និង "មានសេរីភាពខ្លះដែរ")។ នេះបង្ហាញថា ៣០% នៃអ្នកឆ្លើយតបយល់ថាមានការកម្រិតសេរីភាពនេះ (មិនមានសេរីភាពតិចតួចឬ មិនមានសេរីភាពទាល់តែសោះ)ក្នុងការចូលរួមសកម្មភាពជាមួយសហជីព ដែលនេះជាការកើនឡើងភាពភ័យខ្លាចបើប្រៀបធៀបនឹងឆ្នាំ២០២២ និងបង្ហាញថាពលរដ្ឋជាច្រើនបន្តភ័យខ្លាចក្នុងការចូលរួមសកម្មភាពជាមួយសមាគម។




តួលេខទី៥០ បង្ហាញថា ១៨% នៃអ្នកឆ្លើយតបយល់ថាខ្លួន "មានសេរីភាពខ្លាំងណាស់" និង ៣៩% ឆ្លើយថា "មានសេរីភាពខ្លះដែរ" ក្នុងការចូលរួមជាមួយសមាគមដែលតួលេខនេះបង្ហាញអំពីការធ្លាក់ចុះពីឆ្នាំ២០២២។




ការវិវឌ្ឍន៍នេះ ស្រដៀងគ្នាទៅនឹងករណីសេរីភាពសហជីព ដែលអ្នកឆ្លើយតបត្រឹមតែ ៤% ប៉ុណ្ណោះយល់ថាខ្លួន "មិនមានសេរីភាពទាល់តែសោះ" ក្នុងការចូលរួមសមាគម ជាភាគរយមួយដែលនៅតែទាបដដែលចាប់តាំងពីគម្រោងបានចាប់ផ្តើម។

តួលេខទី៥២ បង្ហាញថា ពលរដ្ឋយល់ថាកាន់តែមានសេរីភាពក្នុងការចាកចេញពីសមាគម (ដោយ ២៥% នៃអ្នកឆ្លើយតបបានរាយការណ៍ថា "មានសេរីភាពខ្លាំងណាស់" ក្នុងការចាកចេញ បើធៀបទៅនឹង ២០% នៅឆ្នាំ២០២២ និង ត្រឹមតែ ១៧% នៅឆ្នាំ២០២១)។ ទោះជាយ៉ាងនេះក្តី គួរកត់សម្គាល់ថា ភាគរយនៃពលរដ្ឋដែលយល់ថាខ្លួន "មិនមានសេរីភាពទាល់តែសោះ" ក្នុងការចាកចេញពីសមាគម បានកើនឡើង ៣% នៅឆ្នាំ២០២៣ (ពី ១% ទៅ ៤%)។ ជាលទ្ធផលតួលេខទី៤៩ និងទី៥០ មិនមានការការប្រែប្រួលប្រសើរនោះទេ តែបែរជាមានការថយចុះឆន្ទៈរបស់ពលរដ្ឋក្នុងការចូលរួមសមាគមឬសហជីព។ ទោះជាយ៉ាងនេះក្តី តួលេខទី៥១ បង្ហាញអំពីការកើនឡើងឆន្ទៈរបស់ពលរដ្ឋក្នុងការចាកចេញពីសមាគម។

## ៣.៦ ពលរដ្ឋយល់ថាមានសេរីភាពតិចតួចក្នុងការចូលរួមជីវភាពនយោបាយ បើធៀបនឹងឆ្នាំមុន




ទិន្នន័យពីឆ្នាំ២០២៣ បង្ហាញអំពីការធ្លាក់ចុះ ៤% នៃបុគ្គលដែលយល់ថាខ្លួនមានសេរីភាពក្នុងការចូលរួមក្នុងជីវភាពនយោបាយ នេះបើធៀបទៅនឹងឆ្នាំ២០២២។ តួលេខនេះ បង្ហាញអំពីការធ្លាក់ចុះនៃកំណើនគួរឱ្យកត់សម្គាល់នៅក្នុងការចូលរួមក្នុងជីវភាពនយោបាយដែលបានកត់ត្រានៅឆ្នាំ២០២២ នៅពេលដែលភាគរយនៃពលរដ្ឋដែលយល់ថាខ្លួនមានសេរីភាពក្នុងការចូលរួមក្នុងជីវភាពនយោបាយបានកើនឡើង១៥%។ សូម្បីតែនៅក្នុងឆ្នាំបោះឆ្នោត មានត្រឹមតែ៤០% ប៉ុណ្ណោះនៃពលរដ្ឋដែលយល់ថាមានសេរីភាពក្នុងការធ្វើសកម្មភាពនយោបាយ ដែលបង្កជាបញ្ហាគួរឱ្យបារម្ភថាតើបរិយាកាសបែបនេះ អាចនាំឱ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌។

## ៣.៧ បុរសយល់ថាខ្លួនមានសេរីភាពជាងស្ត្រីក្នុងការចូលរួមនៅក្នុងជីវភាពនយោបាយ




៤៥% នៃអ្នកឆ្លើយតបជាបុរស និង ៣៦% នៃអ្នកឆ្លើយតបជាស្ត្រី មានអារម្មណ៍ថា "មានសេរីភាពខ្លាំងណាស់" ឬ "មានសេរីភាពខ្លះដែរ" ក្នុងការចូលរួមនៅក្នុងជីវភាពនយោបាយ។ តួលេខនេះគឺថយចុះបន្តិចពីឆ្នាំ២០២២ ដែល ៤៧% នៃបុរស និង ៤២% នៃស្ត្រីយល់ថាខ្លួនមានសេរីភាពក្នុងការចូលរួមនៅក្នុងជីវភាពនយោ

បាយ។[70] តួលេខនេះក៏បង្ហាញពីបញ្ហានៃភាពខុសគ្នាផ្នែកយេនឌ័រនាពេលបច្ចុប្បន្ននៅក្នុងបរិបទនយោបាយ ដោយភាគរយនៃស្ត្រីដែលយល់ថាខ្លួនមានសេរីភាពចូលរួមក្នុងជីវភាពនយោបាយទាបជាងបុរស ៩% បើធៀបទៅនឹងឆ្នាំ២០២២ ដែលភាពខុសគ្នានេះមានត្រឹមតែ ៥%។ ជារួម ភាគរយទាំងបុរស និងស្ត្រីដែលយល់ថាខ្លួនមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយ គឺខ្ពស់ជាងតួលេខដែលបានកត់ត្រាពីឆ្នាំ២០១៨ ដល់ ២០២១។ ទោះជាយ៉ាងនេះក្តី មានការព្រួយបារម្ភថា ភាពខុសគ្នានៃយេនឌ័រ គឺមានកម្រិតខ្ពស់បំផុតចាប់តាំងពីគម្រោងបានចាប់ផ្តើម។

## ៣.៨ ការយល់របស់សាធារណជនអំពីច្បាប់ដែលពាក់ព័ន្ធសេរីភាពមូលដ្ឋាននៅតែទាប

ការស្ទង់មតិសាធារណជន ពិនិត្យទៅលើកម្រិតនៃការយល់ដឹងអំពីច្បាប់ជាតិដែលគ្រប់ដណ្តប់លើសេរីភាពមូលដ្ឋាន បានសួរនាំទៅកាន់អ្នកចូលរួមការស្ទង់មតិអំពីសកម្មភាពជាក់លាក់ណាមួយ ថាតើសកម្មភាពនោះស្របច្បាប់ ឬ ខុសច្បាប់។ នៅឆ្នាំ២០២៣ អ្នកចូលរួម ត្រូវបានសួរសំណួរចំនួនដប់ សំណួរចំនួនបួនទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ សំណួរចំនួនបីទាក់ទងនឹងសេរីភាពខាងសមាគម និងចំនួនបីទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ។ សេរីភាពខាងការបញ្ចេញមតិ នៅតែជាសេរីភាពមួយដែលមានការយល់ដឹងច្រើនបំផុតក្នុងចំណោមពលរដ្ឋ។ ផ្ទុយទៅវិញសេរីភាពខាងការជួបប្រជុំនៅតែមានការយល់ដឹងតិចជាងគេក្នុងចំណោមសេរីភាពទាំងអស់។

តួលេខទី ៥៤៖ ភាគរយនៃសាធារណជនដែលបានឆ្លើយត្រឹមត្រូវចំពោះសំណួរដែលវាស់ស្ទង់អំពីសេរីភាពមូលដ្ឋាននីមួយៗ




នៅឆ្នាំ២០២៣ ៥០% នៃអ្នកឆ្លើយតបបានឆ្លើយត្រឹមត្រូវមកកាន់សំណួរទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ។ ដោយមានតែ ៣៣% នៃអ្នកឆ្លើយតបប៉ុណ្ណោះដែលឆ្លើយបានត្រឹមត្រូវថា ការធ្វើកូដកម្ម ដោយមិនចាំបាច់មានការអនុញ្ញាត គឺជារឿងស្របច្បាប់ និងអ្នកឆ្លើយតប ៥៤% បានដឹងអំពីសិទ្ធិរបស់ពួកគាត់ក្នុងការចូលរួមក្នុងការតវ៉ាដោយសន្តិវិធី។ ៦៤% នៃអ្នកឆ្លើយតប បានឆ្លើយថា ជារឿងខុសច្បាប់ដែល អាជ្ញាធរប្រើកម្លាំងដើម្បីបំបែកការជួបប្រជុំដោយសន្តិវិធី។ ទោះបីជាតួលេខនេះខ្ពស់ជាងតួលេខសំណួរមុនៗក៏ដោយ ក៏

[70] នៅក្នុងរបាយការណ៍ឃ្លាំមើលសេរីភាពមូលដ្ឋានពីមុន តួលេខឆ្នាំ២០២២ ការគណនាភាគរយនៃបុរសឬស្ត្រី ដែលយល់ថាខ្លួនមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយ បានប្រើចំនួននៃអ្នកឆ្លើយតបសរុបធ្វើជាភាគបែង។ តួលេខនេះត្រូវបានកែតម្រូវឡើងវិញដើម្បីឱ្យត្រូវគ្នាជាមួយនឹងនីតិវិធីគណនាដែលប្រើប្រាស់នៅគ្រប់ឆ្នាំផ្សេងទៀត ដែលយកតួលេខអ្នកឆ្លើយតបតាមយេនឌ័រនីមួយៗដែលយល់ថាខ្លួនមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយជាភាគបែង។

មានការព្រួយបារម្ភជាខ្លាំងថា ៣៦% ឬ អ្នកចូលរួម ៣៦២ នាក់នៃការស្ទង់មតិនេះមិនបានដឹងថាការប្រើកងកម្លាំងដើម្បីបំបែកការជួបប្រជុំដោយសន្តិវិធីគឺជាសកម្មភាពខុសច្បាប់នោះទេ។

អ្នកឆ្លើយតបចំនួន ៥១% បានឆ្លើយត្រឹមត្រូវមកកាន់សំណួរដែលប្រើសម្រាប់វាស់ស្ទង់កម្រិតយល់ដឹងអំពីសេរីភាពខាងសមាគម។ តាមការបង្ហាញ មានតែ ២៧% ប៉ុណ្ណោះដែលបានឆ្លើយថា ជារឿងស្របច្បាប់ដែលសមាគមធ្វើសកម្មភាព ដោយមិនចាំបាច់ធ្វើការជូនដំណឹងដល់អាជ្ញាធរ ដែលអ្នកឆ្លើយតប ៤៧% បានឆ្លើយត្រឹមត្រូវថាការបង្កើតក្រុមសន្សំដោយមិនមានការអនុញ្ញាត គឺខុសច្បាប់។ ៧៩% នៃអ្នកឆ្លើយតប ដែលជាភាគរយខ្ពស់ជាងគេបំផុតនៅក្នុងផ្នែកនេះ បានឆ្លើយត្រឹមត្រូវថា ជារឿងខុសច្បាប់ក្នុងការបង្កើតអង្គការមិនមែន រដ្ឋាភិបាលដោយមិនចាំបាច់ចុះបញ្ជី។ ក្រោមច្បាប់អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលអាចប្រតិបត្តិការបានដោយមិនចាំបាច់ចុះបញ្ជី។ ភាគរយដ៏ច្រើននៃចម្លើយត្រឹមត្រូវចំពោះសំណួរនេះ បង្ហាញថាអ្នកដែលបានស្ទង់មតិគឺបានដឹងច្រើនអំពីឧបសគ្គ ឬការរឹតត្បិតផ្លូវច្បាប់ដែលបានដាក់បន្ទុកមកលើសេរីភាពខាងសមាគម ជាជាងច្បាប់ដែលការពារសេរីភាពនេះ។

៧៥% នៃអ្នកឆ្លើយតបបានឆ្លើយត្រឹមត្រូវមកកាន់សំណួរទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ។ ៦៧% នៃអ្នកឆ្លើយតបបានឆ្លើយតបត្រឹមត្រូវថា ការជជែកពីរឿងនយោបាយនៅទីសាធារណៈគឺជារឿងស្របច្បាប់ ៨៥% បានឆ្លើយត្រឹមត្រូវថា ការនិយាយនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ/សង្កាត់ គឺជារឿងស្របច្បាប់ ៨៩% បានឆ្លើយត្រឹមត្រូវថា ការប្រមាថមើលងាយបុគ្គលសាធារណៈគឺជារឿងខុសច្បាប់ និង ៥៧% នៃអ្នកចូលរួមបាននិយាយថា ការរិះគន់គោលនយោបាយរបស់រដ្ឋាភិបាលគឺជារឿងស្របច្បាប់។

## ៣.៩ ពលរដ្ឋយល់ថាមិនសូវមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំតាមរយៈការធ្វើកូដកម្ម

តួលេខទី ៥៥៖ ភាគរយនៃអ្នកដែលយល់ថាមានសេរីភាពក្នុងការធ្វើកូដកម្មប្រឆាំងនឹងនិយោជករបស់ខ្លួន




ទិន្នន័យឆ្នាំក្នុង២០២២ បានបង្ហាញអំពីការរីកចម្រើនជាវិជ្ជមានចំពោះភាគរយនៃពលរដ្ឋដែលយល់ថាខ្លួនមានសេរីភាពក្នុងការធ្វើកូដកម្ម បើធៀបទៅនឹងឆ្នាំ២០២១។ ទិន្នន័យនេះគឺជាសញ្ញាណប្រសើរមួយដែរដែលពលរដ្ឋយល់ថាខ្លួនមានសេរីភាពជាងមុនក្នុងការអនុវត្តសិទ្ធិក្នុងការជួបប្រជុំ។ ទោះជាយ៉ាងនេះក្តី ការវិវឌ្ឍនេះមិនបានបន្តកើនឡើងទៀតនោះទេនៅឆ្នាំ២០២៣។

អ្នកឆ្លើយតបតែ ៨% ប៉ុណ្ណោះយល់ថាខ្លួន "មានសេរីភាពខ្លាំងណាស់" ក្នុងការធ្វើកូដកម្មប្រឆាំងនឹងនិយោជករបស់ខ្លួន ដែលធ្លាក់ចុះពី ១៣% នៅឆ្នាំ២០២២ និង ២២% យល់ថាខ្លួន "មានសេរីភាពខ្លះដែរ" ក្នុងការធ្វើបែបនេះ បើប្រៀបធៀបនឹង ២៩% ក្នុងឆ្នាំ ២០២២។

តួលេខទី ៥៦៖ ភាគរយនៃអ្នកដែលយល់ថាមានសេរីភាពក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី




មានការធ្លាក់ចុះតិចតួចបានកត់សម្គាល់ក្នុងការចូលរួមរបស់ពលរដ្ឋនៅក្នុងការអនុវត្តសេរីភាពជួបប្រជុំដោយសន្តិវិធីដែល ១៥% យល់ថាខ្លួន "មានសេរីភាពខ្លាំងណាស់ក្នុងការធ្វើបែបនេះ ដែលជាការធ្លាក់ចុះ ៦% ពីឆ្នាំ២០២២ និង ៤៤% យល់ថាខ្លួន "មានសេរីភាពខ្លះដែរ"។ នៅក្នុងឆ្នាំ២០២៣ ការប្រើប្រាស់បណ្តាញសង្គមដើម្បីគៀងគរសំឡេងគាំទ្ររបស់គណបក្សនយោបាយធំទាស់ត្រូវរងវិធានការយ៉ាងធ្ងន់ធ្ងរ បុគ្គលដែលបង្ហោះសារបែបនោះបានប្រឈមនឹងវិធានការតបត។ ហេតុការណ៍ទាំងនេះបង្ហាញឱ្យឃើញពីការដាក់សម្ពាធលើការតវ៉ាដោយសន្តិវិធី ដែលជាទូទៅធ្វើឡើងតាមរយៈប្រព័ន្ធអ៊ីនធឺណិត ហើយនាំឱ្យមានការថយចុះរបស់ពលរដ្ឋក្នុងការឆ្លើយតបថា "មានសេរីភាពខ្លះណាស់" ក្នុងការចូលរួមការតវ៉ាដោយសន្តិវិធី។

## ៣.១០ នៅឆ្នាំ២០២៣ ពលរដ្ឋវ័យផ្សេងៗគ្នាមានសេរីភាពចូលរួមការតវ៉ាដោយសន្តិវិធី

តួលេខទី ៥៧៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី
ដោយបែងចែកតាមអាយុ




នៅឆ្នាំ២០២៣ ១៦% នៃអ្នកឆ្លើយតបទាំងអស់មានអាយុ ១៥ ទៅ ២៥ ឆ្នាំ យល់ថាខ្លួន "មានសេរីភាពខ្លះដែរ" ឬ "មានសេរីភាពខ្លាំងណាស់" ក្នុងការចូលរួមក្នុងការតវ៉ាដោយសន្តិវិធី។ ពលរដ្ឋអាយុចាប់ពី១៥ ទៅ ២៥ ឆ្នាំ បានរាយការណ៍ថាមានសេរីភាពជាងពលរដ្ឋដែលមានវ័យចំណាស់ក្នុងការចូលរួមការតវ៉ា។ ភាគរយនេះ

មានការធ្លាក់ចុះទៅតាមក្រុមអាយុផ្សេងៗ។ លើសពីនេះទៅទៀត ភាគរយតិចតួចនៃអ្នកឆ្លើយតបគ្រប់វ័យ បានឆ្លើយថា "មានសេរីភាពខ្លាំងណាស់" ក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី។ កាលពីឆ្នាំមុន យុវជនអាយុពី ១៥ ដល់ ២៥ ឆ្នាំ យល់ថាខ្លួនមានសេរីភាពខ្លាំងណាស់ក្នុងការចូលរួមនៅក្នុងការតវ៉ាដោយសន្តិវិធី។ នៅក្នុងឆ្នាំ ២០២៣ ពលរដ្ឋអាយុចាប់ពី៣៦ ទៅ ៤៥ ឆ្នាំ និងអាយុចាប់ពី៤៦ ទៅ៥៥ បានរាយការណ៍ថា មានសេរីភាពក្នុងការចូលរួមសកម្មភាពបែបនេះ កើនឡើង (៤% ពលរដ្ឋអាយុចាប់ពី៣៦ ទៅ៤៥ ឆ្នាំ និងកើនឡើង២% ពលរដ្ឋអាយុចាប់ពី ៤៦ ទៅ៥៥ឆ្នាំ)។ ភាគរយនេះមានការធ្លាក់ចុះទៅតាមក្រុមអាយុផ្សេងៗ ដែលការពិត អ្នកឆ្លើយតប ១៥% ប៉ុណ្ណោះដែលយល់ថា "មានសេរីភាពខ្លាំងណាស់" ក្នុងការចូលរួមការជួបប្រជុំ ដែលនេះជាបញ្ហា (តួលេខទី៥៦)។

## ៣.១១ ពលរដ្ឋម្នាក់ៗនៅតែមានការលំបាកក្នុងការរាយការណ៍អំពីការរំលោភសិទ្ធិមនុស្ស




តួលេខទី៥៨៖ ភាគរយនៃសាធារណជនដែលរាយការណ៍ថាមានការលំបាកខ្លះដែរក្នុងការដាក់ពាក្យបណ្ដឹងនៅចំពោះមុខអាជ្ញាធរ




តួលេខទី៥៩៖ ភាគរយនៃសាធារណជនដែលរាយការណ៍ថាមានការលំបាកច្រើនក្នុងការដាក់ពាក្យបណ្ដឹងនៅចំពោះមុខអាជ្ញាធរ

ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាខ្លួនមានការ "លំបាកខ្លះដែរ" និង "មានការលំបាកច្រើន" ក្នុងការដាក់ពាក្យបណ្ដឹងនៅចំពោះមុខអាជ្ញាធរ នៅតែមានកម្រិតថេរដដែលនៅគ្រប់ពេលនៃការធ្វើរបាយការណ៍។ មានការធ្លាក់ចុះបន្តិចចំពោះអ្នកដែលរាយការណ៍ថាមានការ "លំបាកខ្លះដែរ" ក្នុងការដាក់ពាក្យបណ្ដឹង ពី ៤០% នៅឆ្នាំ២០២០ មកត្រឹម ២៩% នៅឆ្នាំ២០២៣ ទោះជាយ៉ាងនេះក្ដី ភាគរយនៃអ្នកដែលយល់ថាខ្លួន "មានការលំបាកច្រើន" ក្នុងការដាក់ពាក្យបណ្ដឹងនៅចំពោះមុខអាជ្ញាធរទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស បានកើនឡើង ៦% នៅចន្លោះឆ្នាំ២០២២ និងឆ្នាំ២០២៣ (ពី៣៦% រហូតដល់ ៤២%)។ ជារួម ៧១% នៃសាធារណជនយល់ថាខ្លួនមានការ "លំបាកខ្លះដែរ" ឬ "លំបាកច្រើន" ក្នុងការដាក់ពាក្យបណ្ដឹង។ លទ្ធផលទាំងនេះ ជាការគួរព្រួយបារម្ភ ដោយសារតែ២ភាគ៣ នៃសាធារណជនយល់ថាដំណើរការនោះមានភាពលំបាក ហើយនៅពេលដែលមនុស្សយល់បែបនេះ ពួកគេមិនសូវមានទំនោរក្នុងការដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរអំពីករណីរំលោភសិទ្ធិមនុស្សនោះទេ។

## ៣.១២ ពលរដ្ឋបន្តប្រឈមនៅពេលស្វែងរកដំណោះស្រាយចំពោះការរំលោភសិទ្ធិមនុស្ស




សាធារណជនមានជំនឿចិត្តកាន់តែច្រើនចាប់តាំងពីគម្រោងបានចាប់ផ្តើមដោយជឿថារដ្ឋាភិបាល ឬតុលាការ នឹងផ្តល់យុត្តិធម៌ចំពោះការរំលោភសិទ្ធិមនុស្សដែល ៣៤% បានរាយការណ៍ថា ពួកគាត់មានទំនុកចិត្ត បើធៀបទៅនឹងតិចជាង ៣០% ដែលបានរាយការណ៍នៅចន្លោះឆ្នាំ២០១៧ និងឆ្នាំ២០២១។ ទោះជាយ៉ាងនេះក្តី តួលេខនេះបង្ហាញពីការថយចុះ៥% ពីឆ្នាំ២០២២ ហើយពលរដ្ឋ៦៦% យល់ថាមិនមានជំនឿចិត្តពីរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស។ នេះបង្ហាញថា ភាគច្រើននៃពលរដ្ឋមិនមានទំនុកចិត្តលើសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការដោះស្រាយដែលចាំបាច់ត្រូវមានការប្រឹងប្រែងដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនុកចិត្តរបស់សាធារណជនមកលើយន្តការនានាក្នុងការការពារសិទ្ធិមនុស្ស។ ដូចគ្នានេះដែរ អាជ្ញាធរត្រូវតែរំឭកឡើងវិញអំពីកាតព្វកិច្ចបន្ថែមរបស់ខ្លួនក្នុងការធានានូវការគោរពសិទ្ធិមនុស្សឱ្យបានពេញលេញ។

ទិន្នន័យពីចំណុចគន្លឹះទី៣ នៅក្នុងឆ្នាំ២០២៣ បង្ហាញថា ពលរដ្ឋនៅតែបន្តមានការលំបាកក្នុងការកំណត់រកជាតុសំខាន់ៗនៃសេរីភាពមូលដ្ឋាន ដែលនាំឱ្យធ្លាក់ចុះធន្ទៈ និងកើនឡើងភាពភ័យខ្លាចនៅក្នុងការអនុវត្តសិទ្ធិរបស់ពួកគាត់។ ជារឿងវិជ្ជមានមួយដែលបានកត់សម្គាល់ឃើញថាទាំងស្ត្រី និងអ្នកមានអត្តសញ្ញាណយេនឌ័រផ្សេងៗ បានរាយការណ៍អំពីកម្រិតនៃការរឹតត្បិតសេរីភាពខ្លួនឯងទាបជាងបុរស ដែលគូសបញ្ជាក់អំពីការរីកចម្រើនក្នុងការជំរុញឱ្យមានសមភាពយេនឌ័រនៅក្នុងវិស័យសាធារណៈ។ ស្របពេលដែលឆ្នាំ២០២២ មានការរីកចម្រើនខ្លះៗអំពីការយល់ដឹងរបស់សាធារណជនពីការអនុវត្តសិទ្ធិសេរីភាពមូលដ្ឋាន ការវិវត្តនេះគឺស្ទើរតែមិនអាចបន្តនៅឆ្នាំ២០២៣។ ជាការពិតណាស់ ទំនងហាក់បីដូចជាតាំងពីនៅមុនរហូតដល់ការបោះឆ្នោតជាតិនៅខែកក្កដា ឆ្នាំ២០២៣ បានបង្ហាញអំពីចេតនារបស់គណបក្សកាន់អំណាចក្នុងការធ្វើទុក្ខបុកម្នេញលើសកម្មជនគណបក្សជំទាស់ ដែលទំនងជាបង្អាក់ទឹកចិត្តដល់ពលរដ្ឋក្នុងការអនុវត្តសេរីភាពមូលដ្ឋានដែលផ្ទុយគោលការណ៍ច្បាប់អន្តរជាតិ។

## ចំណុចគន្លឹះទី ៤ ៖ តើអង្គការសង្គមស៊ីវិល និងសហជីព ត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងនាមជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជាបានដែរឬទេ?

ចំណុចគន្លឹះទី ៤ ពិនិត្យទៅលើវិសាលភាពដែលអង្គការសង្គមស៊ីវិល និងសហជីព អាចធ្វើការជាមួយរាជរដ្ឋាភិបាលក្នុងនាមជាដៃគូនៅក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ ទិន្នន័យសម្រាប់ចំណុចគន្លឹះទី ៤ ដកស្រង់ចេញពីការស្ទង់មតិប្រចាំឆ្នាំជាមួយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានធ្វើឡើងចាប់ពីថ្ងៃទី ១៤ ខែសីហា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។[71] នៅឆ្នាំ២០២៣ នេះ មានអ្នកឆ្លើយតបចំនួន ១៥៩ នាក់ តំណាងឱ្យអង្គការស្ថាប័នចំនួន ១៥៩ ក្នុងនោះ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលមានចំនួន១០៤ នាក់ (អង្គការសង្គមស៊ីវិលក្នុងស្រុកចំនួន ៨៩ និងអង្គការអន្តរជាតិចំនួន ១៥) និង (ថ្នាក់ដឹកនាំសហជីពចំនួន ៥៥ នាក់) មកពីរាជធានី-ខេត្តចំនួន ២៥ បានឆ្លើយតបទៅនឹងការស្ទង់មតិនេះ។

**របកគំហើញសំខាន់ៗ៖** ទិន្នន័យដែលប្រមូលបាននៅក្នុងឆ្នាំ២០២៣ បានបង្ហាញថា អង្គការសង្គមស៊ីវិល និងសហជីព នៅមិនទាន់ត្រូវបានរដ្ឋាភិបាលទទួលស្គាល់ថាជាអ្នកពាក់ព័ន្ធដ៏សំខាន់នៅឡើយ។ អង្គការសង្គមស៊ីវិល និងសហជីព មិនបានដឹងអំពីឱកាសដាក់ពាក្យស្នើសុំមូលនិធិ និងធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាលនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនានានោះទេ។ ស្រដៀងគ្នានេះដែរ អ្នកឆ្លើយតបយល់ថាមានលំហតូចចង្អៀតសម្រាប់ការធ្វើអន្តរកម្ម និងចូលរួមដោយសារតែឱកាសក្នុងការធ្វើការងារជាមួយអាជ្ញាធរគឺមិនច្បាស់លាស់ មិនមានតម្លាភាព និងមិនបើកចំហនោះទេ។ ទោះជាយ៉ាងនេះក្តី ទិន្នន័យដែលប្រមូលបាននៅឆ្នាំ២០២៣ ពិតជាបានបង្ហាញថាអង្គការសង្គមស៊ីវិល និងសហជីពបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសហការជាមួយរដ្ឋាភិបាលទាំងផ្លូវការ និងក្រៅផ្លូវការ ដើម្បីធានាបាននូវអភិបាលកិច្ចបែបពហុភាគី និងមានតុល្យភាព។ ការណ៍នេះបង្ហាញឱ្យឃើញថាត្រូវមានកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការលុបបំបាត់គម្លាត និងបង្កើនកិច្ចសហការរវាងស្ថាប័នអង្គការសង្គមស៊ីវិលទាំងនេះ និងរដ្ឋាភិបាល ។

[71] ទិន្នន័យសម្រាប់ចំណុចគន្លឹះទី ៤ ដកស្រង់ចេញពីការស្ទង់មតិប្រចាំឆ្នាំជាមួយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ដែលបានធ្វើឡើងនៅខែធ្នូ ឆ្នាំ២០១៦ (ឆ្នាំ២០១៦) ខែធ្នូ ឆ្នាំ២០១៧ (ឆ្នាំ២០១៧) ខែមករា ឆ្នាំ២០១៩ (ឆ្នាំ២០១៨) ខែមករា ឆ្នាំ២០២០ (ឆ្នាំ២០១៩) ខែតុលា ឆ្នាំ២០២០ (ឆ្នាំ២០២០) ខែកញ្ញា ឆ្នាំ២០២១ (ឆ្នាំ២០២១) ខែកញ្ញា ឆ្នាំ២០២២ (ឆ្នាំ២០២២) ខែសីហា ឆ្នាំ២០២៣ (ឆ្នាំ២០២៣)។

## ៤.១ អង្គការសង្គមស៊ីវិល និងសហជីព នៅមិនទាន់បានទទួលស្គាល់ពេញលេញថាជាដៃគូអភិវឌ្ឍន៍ស្របច្បាប់ និងមានសមត្ថភាព

តួលេខទី ៦១ ៖ អង្គការសង្គមស៊ីវិល និងសហជីព បានរាយការណ៍ថាត្រូវបានរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ជាដៃគូស្របច្បាប់ និងពេញសមត្ថភាព







គម្រោងពិនិត្យទៅលើភាគរយនៃអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថាខ្លួនយល់ថាត្រូវបានទទួលស្គាល់ជាដៃគូអភិវឌ្ឍន៍ស្របច្បាប់ និងមានសមត្ថភាព។ ៥០ %នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលដែលបានចូលរួមនៅក្នុងការស្ទង់មតិ បានរាយការណ៍ថា ស្ថាប័នរបស់ពួកគាត់ត្រូវបានរដ្ឋាភិបាលចាត់ទុកថាជាដៃគូអភិវឌ្ឍន៍ដែលមានសមត្ថភាព[72] ស្របពេលដែលត្រឹមតែ ៥៤ %នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលដែលបានចូលរួមនៅក្នុងការស្ទង់មតិ បានរាយការណ៍ថា ស្ថាប័នរបស់ពួកគេត្រូវបានរដ្ឋាភិបាលចាត់ទុកថាជាដៃគូស្របច្បាប់ទាំងស្រុងនៅឡើយ[73]នៅឆ្នាំ២០២៣។ ដូចគ្នានឹងឆ្នាំកន្លងទៅដែរ លទ្ធផលទាំងនេះបង្ហាញឱ្យឃើញថា រដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធនៅមានកម្រិតក្នុងការរួមបញ្ចូល ឬផ្តល់តម្លៃនៃភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល ទៅលើការដោះស្រាយបញ្ហាផ្សេងៗក្នុងសង្គម ឬការចូលរួមនៅក្នុងការរៀបចំគោលនយោបាយ។ កង្វះការរួមបញ្ចូលនេះអាចនាំឱ្យមានការយល់ឃើញថា អង្គការសង្គមស៊ីវិល ឬសហជីពមិនមែនជាតួអង្គសំខាន់ និងពាក់ព័ន្ធដែលដើរតួយ៉ាងសំខាន់នៅក្នុងលំហសង្គមស៊ីវិលនោះទេ។

[72] ដើម្បីមានការទទួលស្គាល់ជាដៃគូអភិវឌ្ឍន៍ដែលមានសមត្ថភាព គឺត្រូវមានការវាយតម្លៃថាមានជំនាញ ចំណេះដឹង និងសមត្ថភាពពាក់ព័ន្ធ ដើម្បីអាចក្លាយជាដៃគូអភិវឌ្ឍន៍ដែលមានប្រយោជន៍ដល់រាជរដ្ឋាភិបាល។

[73] ដើម្បីមានការទទួលស្គាល់ជាដៃគូអភិវឌ្ឍន៍ស្របច្បាប់ គឺត្រូវតែមានការទទួលស្គាល់ថាជាស្ថាប័នស្របតាមគតិយុត្ត ផ្លូវការ និងស្របច្បាប់។

## ៤.២ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពមានការលំបាកក្នុងការទទួលបានហិរញ្ញប្បទានពីរដ្ឋាភិបាល

តួលេខទី ៦២៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថាបានដឹងព័ត៌មានអំពីឱកាសហិរញ្ញប្បទានពីរាជរដ្ឋាភិបាល




តួលេខទី ៦៣៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែល បានរាយការណ៍ថាមិនអាចទទួលបានហិរញ្ញប្បទានដើម្បីកសាងសមត្ថភាពពីរាជរដ្ឋាភិបាល




គម្រោងពិនិត្យទៅលើភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលរាយការណ៍ថាមានលទ្ធភាពទទួលបានឱកាសហិរញ្ញប្បទាន ឬមូលនិធិសម្រាប់គាំទ្រដល់សកម្មភាពរបស់ខ្លួន។ ការបានដឹងពីឱកាសមានការកើនឡើងបន្តិច បើធៀបជាមួយនឹងឆ្នាំមុន ដោយមានថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ៨% បានរាយការណ៍ថា ពួកគាត់បានដឹងអំពីឱកាសហិរញ្ញប្បទាននៅឆ្នាំ២០២៣ (តួលេខទី៦២) បើធៀបទៅនឹង ៦% ក្នុងឆ្នាំ២០២២។ ទោះជាយ៉ាងនេះក្តី ភាគរយនៃថ្នាក់ដឹកនាំដែលបានដឹងអំពីឱកាសហិរញ្ញប្បទាននេះ គឺមានមិនលើសពី ១០% នោះទេចាប់តាំងពីឆ្នាំ២០១៧ ដែលសំណួរនេះត្រូវបានសួរជាលើកដំបូងចាប់ពីឆ្នាំ២០១៧ រៀងមក។[74] លើសពីនេះទៅទៀត តួលេខទី ៦៣ បង្ហាញឱ្យឃើញថា ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ភាគច្រើន (៥៧%) បានរាយការណ៍ថាពួកគាត់មិនមានលទ្ធភាពទទួលបានហិរញ្ញប្បទានពីរដ្ឋាភិបាលសម្រាប់ការកសាងសមត្ថភាព។ ការណ៍នេះបង្ហាញឱ្យឃើញអំពីបញ្ហាប្រឈម ឬឧបសគ្គរាំងដែលអាចកើតមានឡើង ដែលរាំងស្ថាប័នទាំងនេះក្នុងការទទួលបានមូលនិធិចាំបាច់ ហើយអាចមានកម្រិតដល់អង្គការសង្គមស៊ីវិល និងសហជីពពីការប្រើប្រាស់ជំនាញរបស់ពួកគាត់ដើម្បីរួមចំណែកដល់សង្គមជាតិ។

## ៤.៣ ឱកាសក្នុងការចូលរួម និងសមាជិកភាពជាមួយរដ្ឋាភិបាលនៅតែជាបញ្ហាប្រឈមចម្បងសម្រាប់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព

តួលេខទី៦៤៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថាបានដឹងអំពីឱកាសចូលរួមក្នុងការពិគ្រោះយោបល់ ក្រុមប្រឹក្សា និង/ឬគណៈកម្មាធិការជាមួយរដ្ឋាភិបាល




[74] សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិថ្នាក់ឆ្នាំ២០១៦ នោះទេ។

ការស្ទង់មតិនេះ ពិនិត្យទៅលើភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថាឱកាសសម្រាប់ការចូលរួម និងការចូលរួមជាសមាជិកនៅក្នុងគណៈកម្មាធិការ វេទិកាពិភាក្សា ក្រុមការងារក្រុមប្រឹក្សាជាមួយរដ្ឋាភិបាល គឺមានភាពច្បាស់លាស់ បើកចំហ និងតម្លាភាព។

នៅឆ្នាំ២០២៣ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព បានរាយការណ៍អំពីការកើនឡើងអំពីការបានដឹងឱកាសក្នុងការចូលរួមក្នុងនាមជាអ្នកពិគ្រោះយោបល់ ទីប្រឹក្សា និង/ឬគណៈកម្មាធិការជាមួយស្ថាប័នពាក់ព័ន្ធ (រដ្ឋាភិបាល) (៣៨% បើធៀបទៅនឹង ២៩% កាលពីឆ្នាំមុន សូមមើលតួលេខទី៦៤)។ ទោះបីជាការយល់ដឹងមានការកើនឡើងក៏ដោយ ក៏ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពជាង ៧០% នៅតែយល់ថាឱកាសក្នុងការចូលរួមក្នុងនាមជាអ្នកពិគ្រោះយោបល់ ទីប្រឹក្សា និង/ឬគណៈកម្មាធិការ មិនមានភាពច្បាស់លាស់ មិនបើកចំហ និងមិនមានតម្លាភាពនោះទេ (សូមមើលតួលេខទី ៦៥)។ នៅក្នុងសង្គមពហុនិយម ជាការសំខាន់ណាស់ដែលស្ថាប័ននានា និងរដ្ឋាភិបាលប្រឹងប្រែងសម្រេចឱ្យបាននូវតម្លាភាព និងភាពបើកចំហ ព្រមទាំងធ្វើយ៉ាងណាធានាថាអ្នកពាក់ព័ន្ធចម្រុះបែបអាចរួមចំណែកដល់ការធ្វើសេចក្តីសម្រេចសំខាន់ៗ។

តួលេខទី ៦៥៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថា ឱកាសនៃការចូលរួមមានភាពច្បាស់លាស់ បើកចំហ និងតម្លាភាព




នេះបង្ហាញឱ្យឃើញថា អង្គការសង្គមស៊ីវិល និងសហជីពមួយភាគធំ យល់ថាខ្លួនត្រូវបានផាត់ចេញ ឬមានឱកាសតិចតួចក្នុងការចូលរួមនៅក្នុងសកម្មភាពសំខាន់ៗទាំងនេះ។ កង្វះការចូលរួមពីអង្គការសង្គមស៊ីវិល និងសហជីពតាមរយៈលទ្ធផលទាំងនេះ បង្ហាញថារដ្ឋាភិបាលបានប្រឈមក្នុងការប្រមូល និងប្រើប្រាស់ធនធាន និងជំនាញដែលមានស្រាប់មកពិគ្រោះយោបល់ និង លើកកម្ពស់ផលប្រយោជន៍សង្គម។

## ៤.៤ អង្គការសង្គមស៊ីវិល និងសហជីព មិនទាន់អាចចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការតាក់តែងច្បាប់

តួលេខទី ៦៦៖ នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថា % ជាអ្នកចូលរួមសកម្មនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងតាក់តែងច្បាប់ជាមួយរដ្ឋាភិបាល






នៅឆ្នាំ២០២៣ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ៣៤%[75] ដែលបានស្ទង់មតិបានរាយការណ៍ថាបានចូលរួមសកម្មនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការតាក់តែងច្បាប់ជាមួយរដ្ឋាភិបាល ថយចុះពីឆ្នាំ២០២២ ដែលមានអ្នកឆ្លើយតប ៤០ %។ ជាក់ស្តែង គម្រោងមិនទទួលបានព័ត៌មានថា អង្គការសង្គមស៊ីវិល ត្រូវបានពិគ្រោះយោបល់ក្នុងអំឡុងពេលនៃដំណើរការធ្វើសេចក្តីព្រាងវិសោធនកម្មសំខាន់ៗទៅលើច្បាប់បោះឆ្នោត ដែលត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា កាលពីខែមិថុនា ឆ្នាំ២០២៣ និងបានទទួលការអនុញ្ញាតឱ្យពន្លឿនដំណើរការនេះឱ្យបានលឿនបំផុតពីក្រុមប្រឹក្សាធម្មនុញ្ញ(កបធ)។[76]

## ៤.៥ កម្រិតកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល/សហជីព និងរដ្ឋាភិបាលមានការកែលម្អគួរឱ្យកត់សម្គាល់

តួលេខទី ៦៧៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានរាយការណ៍ពីភាពជាដៃគូផ្លូវការ ឬក្រៅផ្លូវការជាមួយរដ្ឋាភិបាល




ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានធ្វើការស្ទង់មតិបានរាយការណ៍ថា បានចូលរួមជាផ្លូវការនៅក្នុងកិច្ចសហការជាមួយរដ្ឋាភិបាល នៅក្នុងគម្រោងសំខាន់ៗ ដែលផ្តល់ផលប្រយោជន៍ដល់ការអនុវត្តសកម្មភាពតាមសហគមន៍ បានកើនឡើងដល់កម្រិតខ្ពស់បំផុតមិនធ្លាប់មានគឺ ៤៦ %នៅក្នុងឆ្នាំ២០២៣ ដោយកើនពី ៤១ %នៅឆ្នាំ២០២២។ ទន្ទឹមនឹងនេះដែរ ភាគរយនៃថ្នាក់ដឹកនាំ ដែលបានរាយការណ៍ថា កិច្ចសហការក្រៅផ្លូវការបានកើនឡើងលើស ៥០ % ជាលើកដំបូង ចាប់តាំងពីពេលចាប់ផ្តើមអនុវត្តគម្រោងមក ពោលគឺបានកើនដល់ ៦៣%។[77] ការណ៍នេះបង្ហាញឱ្យឃើញថា រដ្ឋាភិបាលកំពុងតែសហការកាន់តែច្រើនជាមួយអង្គការសង្គមស៊ីវិល និងសហជីពជាងពេលកន្លងទៅ ទោះជាយ៉ាងនេះក្តី ត្រូវបង្កើនវឌ្ឍនភាពបន្ថែម តាមរយៈការបន្តផ្សព្វផ្សាយអំពាវនាវស្វែងរកកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល។

---

[75] ភាគរយនៅត្រង់ចំណុចនេះ គឺជាចំនួនសរុបនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថាបានចូលរួមសកម្មនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការតាក់តែងច្បាប់ជាមួយរដ្ឋាភិបាល"ញឹកញាប់ណាស់" "ញឹកញាប់" ឬ "នៅពេលខ្លះ"។ សម្រាប់ការប្រៀបធៀបលទ្ធផលពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២ សូមអានតួលេខទី ៥៧ ទំព័រ ៣៧ នៃរបាយការណ៍ឆ្នាំ២០២២ នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅ https://cchrcambodia.org/en/publications/general-reports/cambodia-fundamental-freedoms-monitor-២០២២ ។

[76] អង្គការសង្គមស៊ីវិលបានចេញសេចក្តីថ្លែងការណ៍រួមស្នើពន្យាពេលធ្វើវិសោធនកម្មច្បាប់បោះឆ្នោត។ អាចរកបានតាមរយៈតំណរនេះ https://comfrel.org/english/joint-statement-request-for-postponement-of-election-law-amendment/ ។

[77] ពាក់ព័ន្ធនឹងកិច្ចសហការក្រៅផ្លូវការបង្ហាញឱ្យឃើញថា ភាគរយនៃអង្គការសង្គមស៊ីវិល និងសហជីពដែលបានរាយការណ៍ថាបានសហការក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំកន្លងទៅ" ញឹកញាប់ណាស់" "ញឹកញាប់ "និង" នៅពេលខ្លះ"។

## ៤.៦ អង្គការសង្គមស៊ីវិល និងសហជីព ហាក់មានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានពីរដ្ឋាភិបាល

តួលេខទី ៦៨៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានរាយការណ៍ថាមានសេរីភាពក្នុងការទទួលបាន ព័ត៌មានពីរដ្ឋាភិបាល




តួលេខទី៦៩៖ % នៃអង្គការសង្គមស៊ីវិល/សហជីព ដែលត្រូវបានបដិសេធការចូលប្រើប្រាស់ព័ត៌មានផ្លូវការ ដែលមិនមែនជាព័ត៌មានសម្ងាត់ និង/ឬរសើប




គម្រោងនេះក៏បានពិនិត្យទៅលើភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថា មានលទ្ធភាពទទួលបានព័ត៌មានពីរដ្ឋាភិបាលបានដោយងាយស្រួលផងដែរ។ នៅឆ្នាំ២០២៣ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថា មានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានពីរដ្ឋាភិបាល បានកើនឡើងដល់ ៣៤% (២៨%បានរាយការណ៍ថា "មានភាពងាយស្រួលខ្លះដែរ" និង៦% បានរាយការណ៍ថា "មានភាពងាយស្រួលខ្លាំងណាស់") ដោយកើនពី ២៦% នៅឆ្នាំ២០២២។ ភាពប្រសើរឡើងនៃលទ្ធភាពក្នុងការទទួលបានព័ត៌មានរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព គឺមានសារៈសំខាន់ខ្លាំងណាស់ ដោយសារតែការណ៍នេះអនុញ្ញាតឱ្យពួកគេទទួលបានព័ត៌មានបច្ចុប្បន្នភាពថ្មីៗជានិច្ចអំពីគោលនយោបាយ សេចក្តីសម្រេចចិត្ត និងគំនិតផ្តួចផ្តើមនានារបស់រដ្ឋាភិបាល ដែលអាចមានឥទ្ធិពលមកលើស្ថាប័ន ឬសហគមន៍ដែលពួកគេតំណាង។

តួលេខទី៧០៖ ប្រភេទព័ត៌មានដែលអង្គការសង្គមស៊ីវិល/សហជីពបានរាយការណ៍ថាកំពុងព្យាយាមទទួលបានពីរដ្ឋាភិបាល



នៅឆ្នាំ២០២៣ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ២១% ដែលបានធ្វើការស្ទង់មតិ បានរាយការណ៍ថា បានព្យាយាមចូលប្រើប្រាស់ព័ត៌មានអំពីការវិនិយោគពីរដ្ឋាភិបាលច្រើនជាងព័ត៌មានប្រភេទផ្សេងទៀត។ ផ្ទុយមកវិញ នៅឆ្នាំ២០២២ បញ្ហាច្បាប់ (២៨%) និងបញ្ហាការងារ (២៧%) គឺជាប្រធានបទដែលត្រូវបានចាប់អារម្មណ៍ជាងគេ។[78] ព័ត៌មានប្រភេទផ្សេងទៀតដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានព្យាយាមស្វែងរកនៅឆ្នាំ២០២៣ រួមមាន ព័ត៌មានអំពីសេចក្តីព្រាងច្បាប់ បញ្ហាការងារ ថវិកាជាតិ និងគោលនយោបាយ (១៤%ដូចគ្នា)។

ទិន្នន័យដែលបានប្រមូលពីចំណុចគន្លឹះទីបួនបង្ហាញថា ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពនៅតែយល់ថាពួកគាត់មិនត្រូវបានចាត់ទុកជាដៃគូអភិវឌ្ឍន៍មានសមត្ថភាពពីសំណាក់រដ្ឋាភិបាលនោះ ទោះបីជាមានកិច្ចសហការច្រើនជាងពីមុនក៏ដោយ។ លើសពីនេះ កម្រិតនៃការចូលរួមរបស់អង្គការសង្គមស៊ីវិល និងសហជីពនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដំណើរការតាក់តែងច្បាប់ ការពិគ្រោះយោបល់ ការប្រឹក្សា និងគណៈកម្មាធិការជាមួយរដ្ឋាភិបាលគឺមិនមានការកើនឡើងគួរឱ្យកត់សម្គាល់ឡើយ។ អង្គការសង្គមស៊ីវិលនិងសហជីព ដើរតួនាទីជាតួអង្គដ៏សំខាន់ដែលមានជំនាញ និងបទពិសោធន៍អាចចូលរួមចំណែកយ៉ាងធំធេងនៅក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ ស្ថាប័នទាំងនេះតំណាងឱ្យទស្សនៈដ៏មានតម្លៃពី ក្រុមជនងាយរងគ្រោះនិងសហគមន៍មូលដ្ឋាន។ ការចូលរួមរបស់អង្គការសង្គមស៊ីវិល និងសហជីពនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត អាចជាវិធីសាស្ត្រជំរុញការចូលរួមប្រកបដោយបរិយាប័ន្នដែលឈានទៅរកអភិបាលកិច្ចល្អ និងនីតិរដ្ឋ។

[78] សូមអានរបាយការណ៍ប្រចាំឆ្នាំ២០២២ តួលេខទី ៦៣ ទំព័រ ៣៩។

# សេចក្តីសន្និដ្ឋាន

ក្នុងអំឡុងឆ្នាំ២០២៣ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានបន្តចងក្រងឯកសារអំពីព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងការរឹតត្បិតលើការអនុវត្តសេរីភាពជាមូលដ្ឋាន (សេរីភាពខាងការបញ្ចេញមតិ សមាគម និងការជួបប្រជុំ) ដែលបានកើនឡើងក្នុងអំឡុងពេលបោះឆ្នោតជាតិឆ្នាំ២០២៣។ រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ដែលអនុញ្ញាតឱ្យមានការតាមដាន និងកំណត់មុខសញ្ញាអ្នកមាននិន្នាការផ្ទុយបានយ៉ាងងាយស្រួល មិនស្របតាមកាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់ជាតិនិងច្បាប់អន្តរជាតិ។ ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត មាត្រា១៤២ បានហាមឃាត់សមាជិករដ្ឋសភាពីការណែនាំអ្នកបោះឆ្នោតឱ្យបំផ្លាញសន្លឹកឆ្នោត ឬមិនទៅបោះឆ្នោត។ តាមរយៈការដាក់ទោសផ្នែកព្រហ្មទណ្ឌចំពោះសកម្មភាពញុះញង់ អាចរារាំងសមាជិកគណបក្សជំទាស់ពីការចូលរួមផ្នែកនយោបាយដោយមិនមានមូលដ្ឋាន។ អនុក្រឹត្យថ្មីៗនេះក៏បានបង្កប់នូវសមត្ថកិច្ចឃ្លាំមើលរបស់រដ្ឋាភិបាលផងដែរ។ ជារួម ការវិវឌ្ឍផ្នែកគតិយុត្តិនេះបានកម្រិតការបញ្ចេញមតិរបស់ពលរដ្ឋដោយផ្ទុយទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិ។

អំឡុងការបោះឆ្នោតជាតិឆ្នាំ២០២៣ ការចាត់វិធានការខុសច្បាប់មកលើបុគ្គលមាននិន្នាការផ្ទុយមានការកើនឡើងគួរកត់សម្គាល់ដែលទំនងបណ្តាលមកពីការវិវឌ្ឍគតិយុត្តិដូចក្នុងចំណុចគន្លឹះទី១។ អ្នកនយោបាយ អង្គការសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្ស ទទួលរងការប៉ះពាល់ ដោយគម្រោងបានកត់ត្រាហេតុការណ៍ចំនួន៣៧៧ ករណីដែលចាត់ទុកជាការរំលោភបំពានសេរីភាពមូលដ្ឋាន។ គួរកត់សម្គាល់ដែរថា ៤២ ករណីជាប់ពាក់ព័ន្ធនឹងការឃាយឃីតាមផ្លូវច្បាប់មកលើសមាជិក និងសកម្មជនគណបក្សជំទាស់ ដែលប្រាប់អ្នកគាំទ្ររបស់ខ្លួនទាក់ទងនឹងការគូសសន្លឹកឆ្នោត។ យុទ្ធសាស្ត្រផ្សេងទៀតរួមមានដូចជាការ បំផ្លាញស្លាកសញ្ញាគណបក្សនយោបាយ និងការវាយប្រហារលើរូបរាងកាយសមាជិកគណបក្សជំទាស់។ ជាលទ្ធផលការអនុវត្តសេរីភាពមូលដ្ឋាន ជាពិសេស ការបញ្ចេញមតិ និង ចងក្រងសមាគម នៅតែជាគ្រោះថ្នាក់ដល់ពលរដ្ឋ។

នៅឆ្នាំ២០២៣ ក៏បានមើលឃើញពីការធ្លាក់ចុះការយល់ដឹងរបស់ពលរដ្ឋអំពីសេរីភាពមូលដ្ឋានដែលគួរឱ្យព្រួយបារម្ភ។ គម្លាតដ៏គំហុកនេះឆ្លុះបញ្ចាំងពីការអនុវត្តដែលមិនអនុលោមតាមច្បាប់អន្តរជាតិ និងបទដ្ឋានក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សដែលកម្ពុជារដ្ឋហត្ថលេខី ហើយនេះក៏ឆ្លុះបញ្ចាំងពីនីតិរដ្ឋផងដែរ។ ការបង្ក្រាបមកលើការអនុវត្តសេរីភាពមូលដ្ឋាន ធ្វើឱ្យមានការធ្លាក់ចុះការយល់ដឹង និងទំនុកចិត្តរបស់ពលរដ្ឋក្នុងការអនុវត្តសិទ្ធិរបស់ពួកគេក្នុងការជួបប្រជុំដោយសន្តិវិធី បង្កើតសមាគម និងបញ្ចេញមតិ។ ពលរដ្ឋភាគច្រើនមានអារម្មណ៍ថា មានសេរីភាពតិចតួចក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈ តាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងទៅកាន់អ្នកសារព័ត៌មាន ដោយភ័យខ្លាចការសងសឹក។ ភាពភ័យខ្លាចទាំងនេះមានផលជះដល់យន្តការការពារសិទ្ធិមនុស្សផងដែរ ដោយសាធារណជនបានថយចុះទំនុកចិត្ត អំពីលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស។ ពលរដ្ឋខ្មែរក៏បានថយចុះការយល់ដឹង និងទំនុកចិត្តអំពីសេរីភាពមូលដ្ឋាន តាមរយៈការបង្កើនការរឹតត្បិតខ្លួនឯង និងធ្លាក់ចុះការចូលរួមរបស់ពលរដ្ឋ។

ខណៈពេលដែលអង្គការសង្គមស៊ីវិលបានរាយការណ៍ពីការកើនឡើងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលទាំងកិច្ចសហការផ្លូវការនិងក្រៅផ្លូវការ ពួកគេមិនត្រូវបានទទួលស្គាល់ជាដៃគូពិតប្រាកដក្នុងកិច្ចការ

នយោបាយ និងសេដ្ឋកិច្ចនៅឡើយ។ គួរបញ្ជាក់ថា មិនមានការកើនឡើងគួរឱ្យកត់សម្គាល់នូវភាពសកម្មរបស់អង្គការសង្គមស៊ីវិលក្នុងការចូលរួមធ្វើសេចក្ដីសម្រេចចិត្តនោះទេ ដែលនេះបង្ហាញថាការរាយការណ៍អំពីកិច្ចសហប្រតិបត្តិការគ្រាន់តែជារូបភាព ជាជាងវឌ្ឍភាពពិតប្រាកដ។ នៅឆ្នាំ២០២៣ ក៏បានបង្ហាញឱ្យឃើញថា ភាគរយនៃអង្គការសង្គមស៊ីវិលនិងសហជីពដែលយល់ថា ខ្លួនត្រូវបានទទួលស្គាល់ជាដៃគូស្របច្បាប់ពីរដ្ឋាភិបាលមានចំនួនតិចតួចបំផុត។

តាមរយៈការផ្ដល់ទឡ្ហីករណ៍អំពីស្ថានភាពនៃសេរីភាពមូលដ្ឋាននៅប្រទេសកម្ពុជា គម្រោងមានបំណងផ្ដល់នូវព័ត៌មានដែលជាមូលដ្ឋានគ្រឹះសម្រាប់ពិចារណាក្នុងការពិភាក្សាក្នុងន័យស្ថាបនាពិតប្រាកដដែលអាចធ្វើឱ្យច្បាប់ជាតិកម្ពុជាស្របជាមួយច្បាប់អន្តរជាតិ។ គម្រោងស្នើឱ្យមានវិធានការជាក់លាក់ប្រកបដោយអត្ថន័យឆ្ពោះទៅរកការបង្កើតបរិយាកាសអំណោយផល និងលក្ខខណ្ឌចាំបាច់នានាសម្រាប់សង្គមស៊ីវិលធ្វើប្រតិបត្តិការដើម្បីឱ្យដំណើរការលទ្ធិប្រជាធិបតេយ្យប្រព្រឹត្តទៅប្រសើរឡើង៕

# ឧបសម្ព័ន្ធទី១ ៖ វិធីសាស្ត្រ និងការប្រមូលទិន្នន័យ

ឧបសម្ព័ន្ធនេះ បង្ហាញអំពីវិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ ដែលបានប្រើប្រាស់ដើម្បីប្រមូលនិងវិភាគទិន្នន័យរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន។

**វិធីសាស្ត្រ**

ក្រុមការងារគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានប្រើប្រាស់ឧបករណ៍តាមដានការឃ្លាំមើលផ្សេងៗដើម្បីឃ្លាំមើលស្ថានភាពសេរីភាពមូលដ្ឋាននេះ។ ទិន្នន័យទាំងនេះត្រូវបានប្រមូលចងក្រងរៀបចំជាប្រព័ន្ធនិងវាយតម្លៃយ៉ាងត្រឹមត្រូវស្របតាមគោលការណ៍នៃឧបករណ៍តាមដានការឃ្លាំមើល ដែលមានគោលបំណងផ្តល់នូវតុល្យភាព និងសត្យានុម័តជាក់លាក់មួយ សម្រាប់ត្រួតពិនិត្យតាមដានអំពីសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសរីភាពខាងការបញ្ចេញមតិ ("សេរីភាពមូលដ្ឋាន") នៅក្នុងប្រទេសកម្ពុជា។ ទិន្នន័យនេះក៏ផ្តោតសំខាន់ទៅលើការចូលរួមរបស់ពលរដ្ឋផងដែរ។

ការឃ្លាំមើលសេរីភាពមូលដ្ឋាននៅឆ្នាំ២០២៣ គឺរាប់ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ លទ្ធផលដែលបានពីការឃ្លាំមើលនេះត្រូវបានយកមកប្រៀបធៀប និងពិនិត្យឡើងវិញជារៀងរាល់ត្រីមាស៖ ត្រីមាសទី១ ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣, ត្រីមាសទី២ ចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣, ត្រីមាសទី៣ ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣, និងត្រីមាសទី៤ ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

ឧបករណ៍តាមដានការឃ្លាំមើលនេះមានសូចនាករ ១៥២ ដែលឆ្លើយតបចំពោះចំណុចគន្លឹះចំនួន៤[79]៖

**ចំណុចគន្លឹះទី១ ៖** ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិ

**ចំណុចគន្លឹះទី២ ៖** ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្តនិងប្រតិបត្តិតាមត្រឹមត្រូវ

**ចំណុចគន្លឹះទី៣ ៖** បុគ្គលយល់ដឹងអំពីសេរីភាពមូលដ្ឋាននិងសិទ្ធិដែលពាក់ព័ន្ធនិងយល់ថាខ្លួនអាចអនុវត្តសេរីភាពនេះដោយសេរី និង

**ចំណុចគន្លឹះទី៤ ៖** អង្គការសង្គមស៊ីវិលនិងសហជីពត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល។

ឧបករណ៍តាមដានការឃ្លាំមើល បានគូសបញ្ជាក់អំពីសកម្មភាពសំខាន់ៗជាលម្អិតសម្រាប់ក្រុមការងារអនុវត្តផងដែរ។ ឧបករណ៍នេះបង្កើតនិយមន័យដើម្បីជានាទូវការអនុវត្តស៊ីសង្វាក់គ្នានូវគោលគំនិតជាគន្លឹះ ព្រមទាំងបង្ហាញយ៉ាងច្បាស់នូវធាតុទាំងឡាយនៃចំណុចគន្លឹះទាំង៤។ ឧបករណ៍តាមដានការឃ្លាំមើលនេះលម្អិត

[79] ព័ត៌មានបន្ថែមទាក់ទងនឹងវិធីសាស្ត្រ សូមមើល៖ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ 'គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបាយការណ៍ឆ្នាំទី៣'(ខែកក្កដា ឆ្នាំ២០១៩) ឧបសម្ព័ន្ធទី១ <https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=130&id=5>។

អំពីសូចនាករនិងមានតារាងវិភាគដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃនូវការផ្លាស់ប្ដូរធៀបជាមួយធាតុនីមួយៗ និងចំណុចគន្លឹះទាំងនោះ ក៏ដូចជាធ្វើការប្រៀបធៀបជាមួយប្រភពទិន្នន័យ បុគ្គលទទួលខុសត្រូវចំពោះការប្រមូលទិន្នន័យ និងភាពញឹកញាប់នៃការប្រមូលទិន្នន័យផងដែរ។[80]

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ក្រុមការងារអនុវត្តគម្រោងបានប្រើប្រាស់នូវវិធីសាស្ត្រប្រមូលទិន្នន័យចំនួន ៦ យ៉ាងដើម្បីវាស់វែងសូចនាករពាក់ព័ន្ធនឹងធាតុនីមួយៗនៅក្រោមចំណុចគន្លឹះទាំងនោះ។




ចាប់តាំងពីការអនុវត្តគម្រោងដំបូងនៅឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០២៣ គម្រោងបានកត់ត្រាទិន្នន័យដូចខាងក្រោម៖

| ឆ្នាំ | Media Monitoring ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | Incidents Report ការរាយការណ៍ពីហេតុការណ៍ | CSO/TU Leader Survey ការស្ទង់មតិថ្នាក់ដឹកនាំអង្គការនិងសហជីព | Public Poll ការស្ទង់មតិសាធារណជន | Desk review ការវិភាគឡើងវិញលើច្បាប់ | CSO and TU Registration Monitoring ការវាយតម្លៃការចុះបញ្ជិការ |
|---|---|---|---|---|---|---|
| ២០១៦ | ៦១២ | ១៣២ | ២០៩ | ៩០៨ | ៨ | វិធីសាស្ត្រនេះមិនបានអនុវត្តនៅឆ្នាំ២០១៦ |
| ២០១៧ | ៦៦៩ | ១៤៧ | ១៦៩ | ៩៩៦ | ៤ | សហជីពចំនួន៧២ បានព្យាយាមចុះបញ្ជី |
| ២០១៨ | ៦៥៨ | ១៦៧ | ២០២ | ៩៩២ | ៦ | សហជីពចំនួន៤៦ បានព្យាយាមចុះបញ្ជី |
| ២០១៩ | ៥៣៧ | ១១៩ | ១៤២ | ៣៧៩ | ២ | សហជីពចំនួន២៩ បានព្យាយាមចុះបញ្ជី |
| ២០២០ | ២៩២ | ៩២ | ១៣៨ | ៣៩០ | ១ | សហជីពចំនួន៦ បានព្យាយាមចុះបញ្ជី |

[80] សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងវិធីសាស្ត្រនៃឧបករណ៍តាមដានការឃ្លាំមើលអាចរកបានតាមការស្នើសុំ។

| | | | | | | |
|---|---|---|---|---|---|---|
| ២០២១ | ៣៥១ | ១០៣ | ១៧១ | ៩២៥ | ៣ | សហជីពចំនួន៣ បានព្យាយាមចុះបញ្ជី |
| ២០២២ | ៣២៩ | ២៣៧ | ១៥០ | ១,៤២៤ | ១ | សហជីពចំនួន២ បានព្យាយាមចុះបញ្ជី |
| ២០២៣ | ២៦២ | ៣៧១ | ១៥៩ | ១,០០៥ | ៤ | អង្គការនិងសហជីពចំនួន១០ បានចុះបញ្ជី |

**ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន**

ការតាមដានប្រព័ន្ធផ្សព្វផ្សាយផ្ដោតលើការផ្សព្វផ្សាយព័ត៌មានអំពីសេរីភាពមូលដ្ឋាន។ វិធីសាស្ត្រនេះត្រូវបានប្រើជាពីរវិធី៖ ទីមួយប្រើដើម្បីប្រមូលទិន្នន័យ សម្រាប់សូចនាករដែលវាស់វែងការផ្លាស់ប្ដូរ នៅក្នុងការអនុវត្តរបស់រដ្ឋាភិបាលឬការបកស្រាយច្បាប់ដែលជះឥទ្ធិពលដល់សេរីភាពមូលដ្ឋាន។ ទីពីរផ្ដល់នូវមធ្យោបាយនៃការតាមដានចំនួន និងប្រភេទនៃហេតុការណ៍ដែលសេរីភាពមូលដ្ឋានត្រូវបានរំលោភឬរឹតត្បិត។

ក្រុមការងារគម្រោងបានអនុវត្តជាប្រចាំថ្ងៃក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ភាគច្រើនជាសារព័ត៌មានក្នុងស្រុក និងប្រភពបណ្ដាញផ្សព្វផ្សាយដទៃទៀតត្រូវបានតាមដានឃ្លាំមើលដើម្បីរកនូវអត្ថបទរឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ ។[81]

ក្រុមការងារបានកំណត់និងត្រួតពិនិត្យទៅលើអត្ថបទរឿងដែលពាក់ព័ន្ធនានា ហើយបញ្ចូលព័ត៌មានសំខាន់ៗទាំងនោះចូលទៅក្នុងប្រព័ន្ធទិន្នន័យ។ ប្រព័ន្ធទិន្នន័យនេះក៏បានធ្វើចំណាត់ថ្នាក់អត្ថបទរឿងនីមួយៗទៅតាមប្រភេទដែលឆ្លើយតបជាមួយសូចនាករនីមួយៗ និងធាតុទាំងឡាយដែលមាននៅក្នុងឧបករណ៍តាមដានការឃ្លាំមើល។ ប្រព័ន្ធទិន្នន័យនេះត្រូវបានពិនិត្យមើលជារៀងរាល់ត្រីមាសនីមួយៗ។

**យន្តការរាយការណ៍អំពីហេតុការណ៍**

ការរាយការណ៍អំពីហេតុការណ៍ កត់ត្រាអំពីហេតុការណ៍នៃការរឹតត្បិត និងការរំលោភបំពានលើសេរីភាពមូលដ្ឋានដែលមិនមានចុះផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ការរាយការណ៍អំពីហេតុការណ៍ត្រូវបានប្រមូលតាមរយៈទម្រង់រាយការណ៍អំពីហេតុការណ៍ដែលរាយការណ៍ទៅក្រុមការងាររបស់គម្រោង។ ទម្រង់រាយការណ៍ហេតុការណ៍នេះផ្ដល់ជាមធ្យោបាយសម្រាប់បុគ្គលឬសមាគមដែលជឿថាសេរីភាពមូលដ្ឋានរបស់ខ្លួនត្រូវបានរំលោភបំពាន។

---

[81] ប្រភពព័ត៌មានរួមបញ្ចូល៖ កាសែតភ្នំពេញប៉ុស្តិ៍ (ខ្មែរ និងអង់គ្លេស) កាសែតខ្មែរថាមស៍ វិទ្យុអាស៊ីសេរី វិទ្យុបារាំងអន្តរជាតិ កាសែតដើមអម្ពិល វិទ្យុសំឡេងប្រជាធិបតេយ្យ (ខ្មែរ និងអង់គ្លេស) វិទ្យុសំឡេងសហរដ្ឋអាមេរិកវីអូអេ វិទ្យុវាយោ សារព័ត៌មានកោះសន្តិភាព កាសែតរស្មីកម្ពុជា កាសែតថ្មីថ្មី កាសែតកម្ពុជាថ្មី, សារព័ត៌មានហ្វ្រេសញូវ, មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា, ស្វីហ្វ៍ញូវដេលី, TVFB, ខ្លីខ្លី, ស៊ីអ៊ីអិន, ខេមញូវ, ខេមបូចារ, Cambodia Peace Channel, ខេមបូណូមីស, ខេមបូឌៀននីស ស៊ីជេខ្មែរ ខ្មែរណាស់ ញូវរ៉ូម ខេធីដេលី ខ្មែរវីផត និងនគរវត្ត។ គួរកត់សម្គាល់ថា ការថយចុះចំនួនប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យអាចធ្វើឱ្យការរាយការណ៍អាចមានភាពលំអៀង។ ព្រមទាំងប្រភពព័ត៌មានអន្តរជាតិរួមមាន៖ Al Jazeera, The Diplomat, UCA News, The Star and Reuters ។

ទម្រង់រាយការណ៍អំពីហេតុការណ៍នេះត្រូវបានបំពេញនៅពេលដែលជនរងគ្រោះទៅជួបជាមួយក្រុមការងារគម្រោង ហើយក្រុមការងារនឹងស្វែងយល់ពីបញ្ហានេះ ព្រមទាំងធ្វើការសាកសួរព័ត៌មានលម្អិតជាមួយជនរងគ្រោះបន្ថែមទៀត។ ទម្រង់រាយការណ៍ពីហេតុការណ៍កត់ត្រានូវទិន្នន័យទាំងបែបគុណភាព និងបរិមាណ រួមមានព័ត៌មានអំពីហេតុការណ៍ ទីតាំង មនុស្សដែលពាក់ព័ន្ធរួមទាំងប្រភេទនៃសមាគម (ប្រសិនបើពាក់ព័ន្ធ) និងប្រភេទនៃការរំលោភបំពានផងដែរ។ ព័ត៌មានសំខាន់ៗ ដែលមាននៅក្នុងទម្រង់រាយការណ៍អំពីហេតុការណ៍នឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យនៃយន្តការរាយការណ៍អំពីហេតុការណ៍ដែលនឹងវិភាគដោយក្រុមការងារ។

នៅក្នុងឆ្នាំ២០២៣ គម្រោងបានកត់ត្រានូវហេតុការណ៍ជាក់លាក់ចំនួន ៣៧១ ករណីតាមរយៈការរាយការណ៍អំពីហេតុការណ៍។

**ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព**

ការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីព គឺជាការស្ទង់មតិប្រចាំឆ្នាំដែលត្រូវបានរៀបចំឡើងដើម្បីបង្ហាញពីទស្សនៈនិងបទពិសោធន៍របស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពអំពីលទ្ធភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវបានជ្រើសរើសដោយចៃដន្យដើម្បីចូលរួមក្នុងការស្ទង់មតិនេះ តាមរយៈការប្រើប្រាស់នូវសំណាកបច្ចេកទេស ដោយផ្អែកលើព័ត៌មានពីសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលនិងសហព័ន្ធសហជីព។

នៅក្នុងឆ្នាំ២០២៣ នេះ ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១៤ ខែសីហា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។ ការស្ទង់មតិគឺត្រូវបានធ្វើតាមអនឡាញ ដែលមានអ្នកឆ្លើយតបសរុបចំនួន ១៥៩ នាក់។ លទ្ធផលនៃស្ទង់មតិនេះត្រូវបានវិភាគដើម្បីកំណត់ការវិវត្តផ្សេងៗគ្នារបស់អង្គការសង្គមស៊ីវិល ឬសហជីពដែលបានចូលរួមនៅក្នុងការស្ទង់មតិ រួមទាំងនៅក្នុងសូចនាករនៃឧបករណ៍តាមដានការឃ្លាំមើល។

**ការស្ទង់មតិជាសាធារណៈ**

ការស្ទង់មតិជាសាធារណៈត្រូវបានធ្វើឡើងរៀងរាល់ឆ្នាំក្នុងគោលបំណងយល់ដឹងអំពីការយល់ឃើញរបស់សាធារណៈជនទូទៅទាក់ទងនឹងការអនុវត្តសេរីភាពមូលដ្ឋាន។ ការជ្រើសរើសសំណាកដែលមានលក្ខណៈងាយៗ ត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងលើដំណើរការស្ទង់មតិនេះ។ ការស្ទង់មតិនេះធ្វើឡើងនៅទីតាំងសាធារណៈទូទាំងប្រទេសកម្ពុជា។ ក្រុមការងារគម្រោងបានចុះទៅទីតាំងដែលប្រជាពលរដ្ឋ ធ្វើដំណើរទៅមក និងជ្រើសរើសដោយចៃដន្យនូវប្រជាពលរដ្ឋយល់ព្រមចូលរួមនៅក្នុងការស្ទង់មតិនេះ។

ការស្ទង់មតិជាសាធារណៈនៅឆ្នាំ២០២៣ នេះ បានចាប់ផ្ដើមធ្វើឡើងចន្លោះថ្ងៃទី១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ទូទាំង ២៥ ខេត្ត/ក្រុង និងមានអ្នកចូលរួមឆ្លើយចំនួន ១០០៥ នាក់។ លទ្ធផលនៃការស្ទង់មតិត្រូវបានវិភាគដើម្បីកំណត់ពីនិន្នាការរបស់អ្នកឆ្លើយតបផ្សេងៗគ្នា ដូចជាសូចនាករនៃឧបករណ៍តាមដានការឃ្លាំមើល។

**ការពិនិត្យឡើងវិញទៅលើច្បាប់**

ការពិនិត្យឡើងវិញទៅលើច្បាប់ គឺជាការវិភាគទៅលើច្បាប់ ប្រកាស សារាចរ សេចក្តីណែនាំ គោលនយោបាយ របាយការណ៍ និងបទប្បញ្ញត្តិផ្សេងទៀតដែលប៉ះពាល់ដល់ការអនុវត្តសេរីភាពមូលដ្ឋាន។ ការពិនិត្យ និងសិក្សាឯកសារច្បាប់ដើម្បីវាយតម្លៃអំពីកម្រិតដែលក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជា អាចធានាបាននូវសេរីភាពមូលដ្ឋានដូចដែលបានតម្រូវនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ដូចនេះការពិនិត្យទៅលើច្បាប់គឺផ្តោតសំខាន់ទៅលើខ្លឹមសារដែលចែងនៅច្បាប់ ជាជាងការអនុវត្តច្បាប់។[82]

របាយការណ៍ចេញពីការសិក្សាលើការពិនិត្យច្បាប់ពាក់ព័ន្ធនេះនឹងធ្វើឡើងជាប្រចាំត្រីមាស ដើម្បីធ្វើបច្ចុប្បន្នភាពនៃការវិភាគច្បាប់និងលិខិតបទដ្ឋានគតិយុត្តិដែលត្រូវបានធ្វើវិសោធនកម្ម ក៏ដូចជាការបញ្ចូលការវិភាគទៅលើច្បាប់ថ្មី ឬលិខិតបទដ្ឋានគតិយុត្តិទាំងឡាយណាដែលបានពិនិត្យឡើងវិញថ្មីៗនេះផងដែរ ។[83]

**ការវាយតម្លៃការចុះបញ្ជីអង្គការ សមាគម និង សហជីព**

ការចុះបញ្ជីអង្គការ និង សហជីព គឺជាដំណើរការចាំបាច់មួយដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និង ច្បាប់ស្តីពីសហជីព តម្រូវឱ្យអនុវត្ត។ ដំណើរការចុះបញ្ជីនេះ ក៏ជាឱកាសមួយសម្រាប់រដ្ឋាភិបាលបដិសេធតាមអំពើចិត្ត ក្នុងការបង្កើតសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហជីពផងដែរ។ ការត្រួតពិនិត្យប្រសិទ្ធភាពនៃដំណើរការចុះបញ្ជីបង្ហាញឱ្យឃើញថាតើសិទ្ធិក្នុងការបង្កើតសមាគម និងសហជីពត្រូវបានការពារ និងអនុវត្តដោយរបៀបណា។ ក្រុមការងារអនុវត្តគម្រោងបានកត់ត្រាទិន្នន័យទាំងនេះ តាមរយៈការអនុវត្តដោយ "សាកសួរព័ត៌មានពីដំណើរការចុះបញ្ជី"។ ចំពោះសមាគម និង សហជីពដែលបានជ្រើសរើស និងវាយតម្លៃពីបទពិសោធន៍នៃការចុះបញ្ជីតាមច្បាប់ស្តីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព ដោយប្រើប្រាស់ទម្រង់វាយតម្លៃរបស់ក្រុមការងារគម្រោង។ ទម្រង់វាយតម្លៃ ដែលរៀបចំដោយក្រុមការងារប្រើប្រាស់ដើម្បីផ្ទៀងផ្ទាត់ភាពខុសគ្នារវាងការចុះបញ្ជីសមាគម និងសហជីពនៅពេលដែលកំពុងដំណើរការនៃការចុះបញ្ជី។

នៅក្នុងឆ្នាំ២០២៣ ឧបករណ៍វាយតម្លៃបានកត់ត្រាបទពិសាធន៍ការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល ចំនួន១ និងសហជីពមូលដ្ឋានចំនួន៩ បានចុះបញ្ជីដោយជោគជ័យតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព។

---

[82] ឧបសម្ព័ន្ធទី ២។

[83] ព័ត៌មានបន្ថែមទាក់ទងនឹងការពិនិត្យច្បាប់គឺអាចរកបានតាមការស្នើសុំ។

## ឧបសម្ព័ន្ធទី ២ ៖ តារាងលទ្ធផលនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន

តារាងខាងក្រោមនេះ ផ្តល់នូវទិន្នន័យសង្ខេបដែលគម្រោងបានប្រមូលចងក្រងក្នុងអំឡុងពេល"ឆ្នាំ២០២៣" (ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣) ។ សូចនាករទាំងនេះសុទ្ធតែពឹងផ្អែកទៅលើប្រភពទិន្នន័យផ្សេងៗ ដូចមាននៅក្នុងឧបសម្ព័ន្ធទី១ ។

ការពិនិត្យមើលទៅលើច្បាប់ដែលពាក់ព័ន្ធ៖ នៅពេលបញ្ចប់ការវិភាគច្បាប់ឬលិខិតបទដ្ឋានពាក់ព័ន្ធពិន្ទុ ៥ នឹងត្រូវវាស់ទៅលើក្របខ័ណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានដែលស្របតាមបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ (ពិន្ទុ ១= ស្ថិតក្នុងកម្រិតខ្សោយ, ពិន្ទុ៣= កម្រិតពិន្ទុមធ្យម, ៥= កម្រិតពិន្ទុខ្ពស់)។ គម្រោងឱ្យពិន្ទុដោយមិនលំអៀងទៅលើកម្មវត្ថុនិងសូចនាករ ផ្អែកលើច្បាប់និងលិខិតបទដ្ឋានដែលមានស្រាប់។ ចំពោះច្បាប់ឬលិខិតបទដ្ឋានដែលលំបាកនឹងរកបាន សូចនាករនេះត្រូវបានបញ្ជាក់ថាមិនអាចវាស់វែងបាន។

ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយនិងការរាយការណ៍ពីហេតុការណ៍៖ ទិន្នន័យត្រូវបានកត់ត្រារយៈពេលពេញ ១ឆ្នាំ និងជាត្រីមាសដែលត្រូវបានប្រើប្រាស់សម្រាប់ការវិភាគ។

ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ការស្ទង់មតិជាសាធារណៈ ការវាយតម្លៃការចុះបញ្ជីអង្គការសង្គមស៊ីវិល ៖ ការឆ្លើយតបរបស់អ្នកចូលរួមទៅលើការស្ទង់មតិ និងការវាយតម្លៃ ការចុះបញ្ជីត្រូវបានរួមបញ្ចូលនិងវិភាគ។ ចំនួនតួលេខនិងភាគរយដែលបង្ហាញទាំងអស់ត្រូវបានយកចេញពីការវិភាគចម្លើយរបស់អ្នកឆ្លើយតប។

លទ្ធផលរបាយការណ៍ប្រចាំឆ្នាំត្រូវរួមបញ្ចូលគ្នានូវសូចនាករទាំងអស់ ហើយត្រូវបានឱ្យពិន្ទុតាមលេខកូដពណ៌ដូចខាងក្រោម៖

| | |
|---|---|
| (បៃតង) | កម្រិតពិន្ទុខ្ពស់ |
| (លឿង) | កម្រិតពិន្ទុមធ្យម |
| (ក្រហម) | ស្ថិតក្នុងកម្រិតខ្សោយ |
| | មិនអាចឱ្យពិន្ទុបាន |

ការវាយតម្លៃលើឧបករណ៍តាមដានវាយតម្លៃធ្វើឡើងនៅចុងបញ្ចប់ឆ្នាំទី៤ ដែលនាំឱ្យមានការពិនិត្យឡើងវិញសូចនាករមួយចំនួនរួមទាំងការបន្ថែមសូចនាករថ្មីចំនួន១១ ទៀត ។ សូចនាករត្រូវបានសម្គាល់ថា "មិនមានចម្លើយ" សម្រាប់ឆ្នាំផ្សេងៗមុនឆ្នាំ២០២០។ សម្រាប់ព័ត៌មានលំអិតអំពីឧបសម្ព័ន្ធនេះ (២០១៦ ដល់ ២០២២ សូមអានរបាយការណ៍ឃ្លាំមើលសេរីភាពមូលដ្ឋានឆ្នាំ២០២២។[84]

[84] ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ.ស៊ី.អិន.អិល "របាយការណ៍ប្រចាំឆ្នាំ២០២២ នៃកាឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" (https://www.cchrcambodia.org/en/publications/general-reports/cambodia-fundamental-freedoms-monitor-2022) ។

| ចំណុចគន្លឹះទី១ ៖ ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធសេរីភាពខាងការបង្កើតសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ ស្របតាមបទដ្ឋានអន្តរជាតិ | | | | |
|---|---|---|---|---|
| **ជាតុផ្សំ** | **សូចនាករ** | **ប្រភពទិន្នន័យ** | **២០២៣** | **កំណត់សម្គាល់** |
| សេរីភាពខាងការបង្កើតសមាគម | កម្រិតនៃច្បាប់ជាតិ ឬគោលនយោបាយ បានគោរពដល់សេរីភាពខាង ការបង្កើតសមាគមសេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២,៥ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញនៅឡើយទេ។ សិទ្ធិសេរីភាពខាងសមាគម ការជួបប្រជុំ និងការបញ្ចេញមតិត្រូវបានធានាក្នុងមាត្រា៤២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា[85]។ ទោះជាយ៉ាងណាមាត្រា៤២ នេះ អនុវត្តចំពោះប្រជាពលរដ្ឋកម្ពុជា ដោយមិនមានវិសាលភាពសម្រាប់ជនជាតិផ្សេងទៀតដែលកំពុងរស់នៅកម្ពុជានោះឡើយ[86]។ ប៉ុន្តែ ការធានាទាំងនេះត្រូវបានធ្វើឱ្យខ្សោយចុះគួរឱ្យកត់សម្គាល់ដោយសារការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិមួយចំនួននៃរដ្ឋធម្មនុញ្ញ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨។[87] ម្យ៉ាងទៀត ច្បាប់ជាតិដែលគ្រប់គ្រងមកលើសេរីភាពខាងសមាគមដូចជាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពក៏មានបទប្បញ្ញត្តិមួយចំនួនរឹតត្បិតលើសេរីភាពមូលដ្ឋានផងដែរ[88]។ វិសោធនកម្មច្បាប់ស្តីពីសហជីពឆ្នាំ២០២០ មានការរឹតត្បិតតិចជាងមុនទៅលើសេរីភាពខាងសមាគម[89]។ សេរីភាពខាងការបញ្ចេញមតិត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនៅក្នុងច្បាប់មួយចំនួនដូចជាច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពី ការអប់រំក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ និងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ខណៈបញ្ញត្តិខ្លះស្របនឹងបទដ្ឋានអន្តរជាតិនោះ ក៏មានបទប្បញ្ញត្តិមួយចំនួនមានខ្លឹមសារមិនច្បាស់លាស់ដែលអាចធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងការជួបប្រជុំ។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន (ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្ន) បានកាត់បន្ថយលទ្ធភាពក្នុងការអនុវត្តសេរីភាពខាងការសមាគម ជួបប្រជុំ និងបញ្ចេញមតិក្នុងកំឡុងពេលអាសន្ន។ នៅឆ្នាំ២០២១ ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានអនុម័តឡើងដោយផ្តល់អំណាចយ៉ាងខ្លាំងដល់អាជ្ញាធរ ដើម្បីរឹតត្បិតសិទ្ធិសេរីភាពខាងសមាគម និងសេរីភាពខាងការជួបប្រជុំ ក្រោមហេតុផលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ការអនុម័តអនុក្រឹត្យស្តីពី ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិក៏ប៉ះពាល់យ៉ាងខ្លាំងលើ សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំតាមអនឡាញ។ ចំណែកឯសង្ឃប្រកាស ដែលបានចេញផ្សាយកាលពីឆ្នាំ២០២១ ប៉ះពាល់ធ្ងន់ធ្ងរទៅលើសេរីភាពខាងការជួបប្រជុំផងដែរ។[90] នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ រដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធឺណិត ដែលរឹតត្បិតសេរីភាពខាងការបញ្ចេញមតិ និងមិនអនុលោមតាមច្បាប់អន្តរជាតិ[91]។ ការប្រើប្រាស់ភាសា និងខ្លឹមសារមិនច្បាស់លាស់នៃអនុក្រឹត្យនេះ គឺបើកចំហចំពោះការបកស្រាយផ្សេងៗ និងងាយរងគ្រោះចំពោះការអនុវត្តតាមតែអំពើចិត្ត ឬមិនសមាមាត្រដោយអាជ្ញាធរ ដោយការចុះបញ្ជីដែនឈ្មោះអាចត្រូវបានកំណត់ដោយរដ្ឋាភិបាលតែប៉ុណ្ណោះ ដែលអាចឱ្យអង្គភាពបាត់បង់ឈ្មោះដែនរបស់ខ្លួន ដែលបានចុះបញ្ជី។ ហើយអាចឈានដល់ការបិទខ្ទប់ ការរឹតត្បិត ឬសេរីភាពនិយាយតាមប្រព័ន្ធអ៊ីនធឺណិត និងការបង្រួមលំហសង្គម ស៊ីវិល ជាវិធានការមិនសមាមាត្រ ដែលរំលោភលើកាតព្វកិច្ចរបស់កម្ពុជា ក្នុងនាមជារដ្ឋភាគី។ |
| **សេរីភាពខាងការបង្កើតសមាគម** | | | | |
| ១.២ ដំណើរការចុះបញ្ជីអង្គការ សមាគម មានភាពត្រឹមត្រូវ និងតម្លាភាព | កម្រិតនៃដំណើរការនៃការចុះបញ្ជី និងតារាងតម្លៃសម្រាប់ការចុះបញ្ជីសមាគម ត្រូវបាន ផ្សព្វផ្សាយជាសាធារណៈ និងចែងយ៉ាងច្បាស់លាស់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះ។ លក្ខខណ្ឌនៃការចុះបញ្ជីសម្រាប់អង្គការសង្គមស៊ីវិល និងសហជីពក្រោមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព មានខ្លឹមសារស្រពេចស្រពិល លំបាក និងមានបន្ទុកច្រើន ព្រមទាំងមិនស្របជាមួយបទដ្ឋានអន្តរជាតិ[92]។ ជាពិសេស មាត្រា ៥ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបានរារាំងបុគ្គលមួយចំនួនដូចជា បុគ្គលដែលពុំមែនជាសញ្ជាតិខ្មែរ និងបុគ្គលដែលមានអាយុក្រោម១៨ ឆ្នាំពីការបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ មាត្រានេះមិនស៊ីសង្វាក់គ្នានឹងមាត្រា ១១ ដែលអនុញ្ញាតឱ្យក្រសួងមហាផ្ទៃត្រូវកំណត់ ដោយប្រកាស ទៅលើនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគមដោយអនីតិជន។ ព្រមទាំង កង្វះវិធានផ្នែកនីតិវិធីការពារក្នុងដំណើរការចុះបញ្ជីដែលកំណត់ក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល[93] ក្នុងនោះរួមទាំងការចែងពុំច្បាស់លាស់ពីមូលហេតុនៃការបដិសេធសំណើសុំចុះបញ្ជីជាដើម ដែលប្រការនេះទុកចន្លោះប្រហោងសម្រាប់ការបដិសេធតាមតែអំពើចិត្ត។ ផ្ទុយពីនេះ វិសោធនកម្មច្បាប់ស្តីពីសហជីពឆ្នាំ២០២០ បានលុបចោលការរឹតត្បិត២ ចំណុចមកលើសហជីព ប៉ុន្តែនៅតែមានភាពលំបាកក្នុងការចុះបញ្ជីដដែល។ មាត្រា ២០ បានរឹតត្បិតលទ្ធភាពក្នុងការអនុវត្តសកម្មភាព ដោយតម្រូវឱ្យថ្នាក់ដឹកនាំមានអាយុចាប់១៨ ឆ្នាំ មានសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅដែលទាំងនេះមិនស្របតាមការអនុវត្តអន្តរជាតិល្អបំផុតនោះទេ និងមិនស្របតាមសិទ្ធិក្នុងការជ្រើសរើសតំណាងរបស់ពួកគេដោយសេរី[94]។ ជាចុងក្រោយច្បាប់ស្តីពីសហជីពបង្កើតគ្រាន់តែជានីតិវិធីសម្រាប់សហជីពដែលតម្រូវឱ្យមានការយល់ព្រមពីរដ្ឋាភិបាលផ្ទុយពីច្បាប់សិទ្ធិមនុស្សអន្តរជាតិតែប៉ុណ្ណោះ[95]។<br><br>ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត រឹតត្បិតបន្ថែមទៀតលើសិទ្ធិសេរីភាពខាងសមាគម ជាពិសេសសមាជិកបក្សជំទាស់ ដោយសារច្បាប់នេះចែងការរឹតត្បិតមិនសមហេតុផលសម្រាប់ការឈរឈ្មោះបោះឆ្នោត ដែលតម្រូវឱ្យប្រជាពលរដ្ឋ *"បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតក្នុងការបោះឆ្នោតសកលពីរអាណត្តិជាប់គ្នាចុងក្រោយដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត)គ.ជ.ប) លើកលែងតែក្នុងករណីដែលសិទ្ធិបោះឆ្នោតមិនត្រូវបានអនុវត្តដោយមានហេតុផលសមស្របប៉ុណ្ណោះ។"* តម្រូវការបែបនេះគឺកម្ពុជាបំពានលើកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនក្រោម ក.ស.ព.ន។ |
| ១.៣ ពុំមានការរឹតត្បិតលើចំនួនសមាគមដែលមាន គោលបំណងប្រហាក់ប្រហែលគ្នា | កម្រិតនៃច្បាប់ រឹតត្បិតមិនឱ្យ បង្កើតសមាគមដែលមានគោល បំណងប្រហាក់ប្រហែលគ្នា | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ៥ | ប្រទេសកម្ពុជាបង្ហាញពីការបានបំពេញចំណុចនេះ ព្រោះថា ទាំងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឬក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធផ្សេងទៀតមិនបានដាក់កម្រិតលើចំនួនសមាគមដែលប្រតិបត្តិការដោយមាន គោលបំណងស្រដៀងគ្នានោះទេ។ មាត្រា៧ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល គូសបញ្ជាក់ការរឹតត្បិតតែ ឈ្មោះ អក្សរកាត់ និងនិមិត្តសញ្ញារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលមិនអាចចម្លងពីអង្គការដែលបានចុះបញ្ជីផ្សេងមុនរួចហើយ ឬកាកបាទក្រហម អឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិបានទេ។ ការរឹតត្បិនេះត្រូវបានចាប់ទុកថាសមហេតុផល និងសមាមាត្រ ប្រសិនបើច្បាប់នេះត្រូវបានអនុវត្តដោយយុត្តិធម៌ តម្លាភាព និងសង្គតិភាព។ |
| ១.៤ សមាគមអាចបង្កើតបណ្តាញនៃអង្គការសម្ព័ន្ធ សហព័ន្ធ ឬ | កម្រិតនៃច្បាប់ ឬគោល នយោបាយអនុញ្ញាត ឱ្យសមាគម | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ៣ | កម្ពុជាបានបំពេញផ្នែកខ្លះលើចំណុចនេះ។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលកំណត់ថា សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបង្កើតឡើងដោយ "រូបវន្តបុ្គ/និងនីតិបុគ្គល" ដែលនេះបង្ហាញថាទោះជាបណ្តាញរបស់អង្គការមិនមែនរដ្ឋាភិបាល ឬសម្ព័ន្ធនៃអង្គការដើម នឹងទទួលបានការអនុញ្ញាត។ ទន្ទឹមនេះច្បាប់ស្តីពីសហជីព ទទួលស្គាល់ដាក់លាក់នូវសិទ្ធិរបស់សហជីព និងសមាគមនិយោជកក្នុងការប្រឹក្សាយោបល់គ្នាដោយសេរី និងចូលជាសមាជិកជាមួយសហជីព និងសមាគមនិយោជកដទៃទៀត ច្បាប់ស្តីពីសហជីព ក៏ចែងផងដែរពីលក្ខខណ្ឌរឹតត្បិតដែលពុំអនុលោមតាមច្បាប់ ដែលបង្កជាឧបសគ្គពុំសមហេតុផលចំពោះការបង្កើតបណ្តាញនេះ។[96] |

| | | | | |
|---|---|---|---|---|
| សហជីពប្រភេទផ្សេងទៀតដោយសេរី | | | | |
| ១.៥<br>ការចុះបញ្ជីសមាគមគឺជាការស្ម័គ្រចិត្ត | កម្រិតនៃ ច្បាប់ ឬគោលនយោបាយ អនុញ្ញាតដល់ការចុះបញ្ជីសមាគមដោយស្ម័គ្រចិត្ត | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះ ពីព្រោះថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីគណបក្សនយោបាយ ហើយនិងច្បាប់ស្តីពីសហគមន៍កសិកម្មតម្រូវឱ្យចុះបញ្ជីតាមលក្ខន្តិកៈច្បាប់។ និយមន័យនៃពាក្យសមាគមក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានអត្ថន័យទូលំទូលាយពេកដែលអាចអនុវត្តទៅលើក្រុមក្នុងវិស័យក្រៅប្រព័ន្ធនៅកម្ពុជា[97]។ នៅក្រោមច្បាប់ទាំងនេះ ការខកខានមិនបានចុះបញ្ជីការធ្វើឱ្យសមាគមក្លាយជាសមាគមដែលខុសច្បាប់។ ការបដិសេធលើសមត្ថភាពផ្លូវច្បាប់និងការហាមប្រាម ស្ថាប័ននានាដែលពុំបានចុះបញ្ជីពីការអនុវត្តសកម្មភាពណាមួយគឺពុំស្របជា មួយសិទ្ធិសេរីភាពខាងសមាគម ដែលសមាគមទាំងនោះ គួរតែត្រូវបានចាត់ទុកថាកំពុងធ្វើប្រតិបត្តិការដោយស្របច្បាប់ លើកលែងតែបានបង្ហាញសកម្មភាពផ្ទុយពីនោះ។ ការចុះបញ្ជីគួរតែត្រូវបានធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយផ្អែកលើប្រព័ន្ធនៃការជូនដំណឹង ជាជាងសុំការអនុញ្ញាត និងក្នុងគោលបំណង ទទួលបានសមត្ថភាពផ្លូវច្បាប់តែប៉ុណ្ណោះ ដែលនេះពុំគួរតម្រូវឱ្យមានការស្នើសុំការអនុញ្ញាតជាមុន ចំពោះការអនុវត្តសកម្មភាពស្របច្បាប់ឡើយ។ |
| ១.៦<br>បទប្បញ្ញត្តិដែលមានការត្រួតត្រាលើសមាគមអនុលោមតាមបទដ្ឋានអន្តរជាតិ | កម្រិតនៃច្បាប់ ឬគោលនយោបាយដែលត្រួតត្រាមកលើសមាគមដែលស្របទៅតាមបទដ្ឋានអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ១,៥ | កម្ពុជាពុំបានបំពេញចំណុចនេះទេ ដោយសារតែមាត្រាខ្លះនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ផ្ទុយនឹងស្តង់ដារអន្តរជាតិ ស្តីពីសិទ្ធិសេរីភាពខាងការបង្កើតសមាគម និងខាងការបញ្ចេញមតិ ដែលជាប់កាតព្វកិច្ចចំពោះរដ្ឋភាគី។ ការអនុវត្តល្អប្រសើរជាអន្តរជាតិបង្ហាញពីតម្រូវការតិចតួចក្នុងការតាមដាន ព្រមទាំងការប៉ុនប៉ងត្រួតពិនិត្យយ៉ាងជិតដល់ដើម្បីរារាំងសមាគម និងសមាជិកក្នុងការបង្កើតជម្រើសសម្រាប់អង្គការនិងការងាររបស់អង្គការ។ ច្បាប់ស្តីពី សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល តម្រូវឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជូនដំណឹងជាមុន អំពីសកម្មភាពជាក់លាក់ដែលធ្វើឡើងក្នុងដែនសមត្ថកិច្ចរដ្ឋបាលរាជធានី ឬ ខេត្តណាមួយត្រូវជូនដំណឹងដោយផ្ទាល់ទៅរដ្ឋបាលរាជធានី ខេត្តនោះ និងទាមទារឱ្យអង្គការអន្តរជាតិនៅកម្ពុជាធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល។ ច្បាប់ស្តីពីសហជីពបញ្ជាក់ពីខ្លឹមសារនៃលក្ខន្តិកៈរបស់សហជីពកំណត់ចំនួននៃសមាជិក និងអាណត្តិសម្រាប់អ្នកដឹកនាំគ្រប់គ្រង។ យន្តការត្រួតពិនិត្យច្បាប់នេះនៅមិនបានធ្វើឱ្យថមថយនៅក្នុងវិសោធនកម្មច្បាប់ស្តីពីសហជីពនោះទេ។ ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងមួយនៅក្នុងខែតុលា ឆ្នាំ២០១៧ ជាការអនុវត្តលើការជូនដំណឹងជាមុន សម្រាប់សកម្មភាពរបស់អង្គការសង្គមស៊ីវិលទាំងអស់ ដែលសេចក្តីប្រកាសនេះផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ ព្រោះជាការគ្រប់គ្រងលើសកម្មភាពសមាគម។ នេះនាំឱ្យពិន្ទុទាក់ទងនឹងការគោរពសេរីភាពមូលដ្ឋានធ្លាក់ចុះរហូតមកដល់ ១ ក្នុងរបាយការណ៍អង្កេតនៅក្នុងឆ្នាំទី២ ប៉ុន្តែរបៀបរបបនៃការជូនដំណឹងជាមុននេះ ត្រូវបាននិរាករណ៍វិញ តាមរយៈ សេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។ វិសាលភាពនៃសេចក្តីជូនដំណឹងឆ្នាំ២០១៨ នោះ បានកំណត់លើ |

[85] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី១០ កក្កដា ឆ្នាំ២០០៧ បានបកស្រាយតាមសមត្ថកិច្ចលើមាត្រា៣១ នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងអត្ថន័យសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ក្នុងនោះរួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលត្រូវអនុវត្តដោយផ្ទាល់ក្នុងច្បាប់កម្ពុជា។ សូមមើលសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ កក្កដា ឆ្នាំ២០០៧) ។

[86] អនុក្រឹត្យលេខ១៤៨ ស្តីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសបានពង្រីកវិសាលភាពមកលើកម្មករនិយោជិតដែលធ្វើការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

[87] ការប្រើពាក្យពេចន៍មានអត្ថន័យទូលំទូលាយខ្លាំងពេក តម្រូវឱ្យបុគ្គលនិងគណបក្សនយោបាយ "តម្កល់ផលប្រយោជន៍ជាតិ" និងហាមប្រាមការធ្វើសកម្មភាពណាមួយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋ ទោះដោយផ្ទាល់ឬដោយប្រយោលក្តី"។ ហ្វ្រេសញូវ 'សេចក្តីព្រាងវិសោធនកម្មក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងការប្រមាថព្រះមហាក្សត្រ និងវិសោធនកម្មបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ (ហ្វ្រេសញូវ, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨) <https://bit.ly/2DZYnKM>

[88] ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី (មាត្រា៦) ចែងលក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីមានបន្ទុកច្រើន លំបាក និងមិនច្បាស់លាស់ (ជំពូក២ និងជំពូក៣) ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលព្រមទាំងចែងបែបទូលាយពីការត្រួតពិនិត្យរបស់រដ្ឋាភិបាលក្នុងការបដិសេធលើការចុះបញ្ជី(មាត្រា៨) និងកំណត់នូវសកម្មភាពលំបាក និងលក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ហិរញ្ញវត្ថុ (មាត្រា២៥) ព្រមទាំងកំណត់ទោសទណ្ឌដោយពុំសមាមាត្រ (មាត្រា៣០)។ ច្បាប់ស្តីពីសហជីពកំណត់លក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីមានបន្ទុកច្រើននិងស្មុគស្មាញនិងមូលហេតុទូលំទូលាយសម្រាប់ការបដិសេធលើការចុះបញ្ជី (មាត្រា១៥ និងប្រកាសលេខ២៤៩) និងលក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍មានបន្ទុកច្រើន (មាត្រា១៧)។

[89] វិសោធនកម្មបានបន្ថយវិសាលភាពរបស់ច្បាប់ដែលមិនរួមបញ្ចូលការធ្វើដំណើរតាមអាកាសនិងការធ្វើដំណើរទៅបរទេស ហើយបានដកចេញចំណុចដែលតម្រូវឱ្យថ្នាក់ដឹកនាំសហជីពមិនធ្លាប់ត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌពីមុនមក ហើយការតម្រូវឱ្យបង់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងទៀតត្រូវធ្វើមុនពេលការរំលាយសហជីព និងដកចេញចំណុចដែលសហជីពត្រូវរំលាយនៅពេលមានថ្នាក់ដឹកនាំឬគណៈគ្រប់គ្រងត្រូវបានកាត់ទោសពីបទល្មើសព្រហ្មទណ្ឌ។ សូមមើលចំណុចគន្លឹះទី១ ។

[90] សូមមើលចំណុចគន្លឹះទី១។

[91] នយ័តករទូរគមនាគមន៍កម្ពុជា 'ការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធឺណិត' (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១) <https://trc.gov.kh/sub-decree/>។

[92] សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីពីរស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង អាយ.ស៊ី.អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ៤-៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf.។

[93] មាត្រា៨ ក្រសួងមហាផ្ទៃអាចបដិសេធការស្នើសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលបានរកឃើញថាមាន "គោលបំណង និងទិសដៅ" ដែលអាចធ្វើឱ្យ "ប៉ះពាល់ដល់សន្តិសុខស្ថិរភាពនិងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា"។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលទុកចន្លោះនូវនីតិវិធីចុះបញ្ជីជាក់ស្តែង សម្រាប់ការកំណត់របស់ក្រសួងមហាផ្ទៃ តាមរយៈបញ្ញារដ្ឋបាល ឬ ប្រកាស។

[94] អនុសញ្ញាលេខ៨៧ នៃអង្គការពលកម្មអន្តរជាតិ ស្តីពីសេរីភាពខាងសមាគម និងការការពារការរៀបចំ អនុម័តថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៤៨, មានសុពលភាពអនុវត្តថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៥០) <http://www.refworld.org/docid/425bc1914.html>

[95] មាត្រា៨ នៃអនុសញ្ញាសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មានសុពលភាពអនុវត្តថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦)។

[96] មាត្រា១០ នៃច្បាប់ស្តីពីសហជីពអំពីលក្ខខណ្ឌសមាជិកសហជីពបង្កការលំបាក សំរាប់វិស័យក្រៅប្រព័ន្ធ ឬក្រុមតូចៗ។

[97] លិខិតរបស់ ម.ស.ម.ក ស្នើក្រសួងមហាផ្ទៃបញ្ជាក់នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ និងលិខិតឆ្លើយតបដែលម.ស.ម.កបានទទួលនៅថ្ងៃទី២២ ខែកញ្ញា។ ជាការលើកទឹកចិត្ត លិខិតឆ្លើយតបពីក្រសួងមហាផ្ទៃបានចង្អុលបង្ហាញថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនឹងមិនអនុវត្តចំពោះសហគមន៍មូលដ្ឋានទេ។ ទោះយ៉ាងណាក៏ដោយ នៅតែមានវិសាលភាពគួរឱ្យកត់សំគាល់សម្រាប់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីក្នុងការអនុវត្តផ្ទុយ ដោយសារតែពាក្យដែលមិនច្បាស់លាស់នៃច្បាប់៖ សូមអាន ម.ស.ម.ក លិខិតរបស់ ម.ស.ម.ក ស្នើក្រសួងមហាផ្ទៃបញ្ជាក់ពីការប្រើប្រាស់ពាក្យ)ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ (<https://cchrcambodia.org/index_old.php?title=CCHR-Open-Letter-Seeks-Clarification-Regarding-Application-of-the-LANGO-to-CBOs-and-Informal-Groups&url=media/media.php&p=press_detail.php&prid=569&id=5>។

| | | | | |
|---|---|---|---|---|
| | | | | ក្រុមសង្គមស៊ីវិលដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃដែលនោះជាការទុកចន្លោះប្រហោង អាចឱ្យអាជ្ញាធរមូលដ្ឋានរារាំងសកម្មភាពនានារបស់ក្រុម ឬសហគមន៍តូចៗដែលពុំបានចុះបញ្ជី។ |
| ១.៧<br><br>លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ទៅរដ្ឋាភិបាលអនុលោមតាមបទដ្ឋានអន្តរជាតិ | ក្បឹទនៃលក្ខខណ្ឌធ្វើរបាយការណ៍អនុលោម តាមបទដ្ឋានអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | ២ | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍សម្រាប់អង្គការសង្គមស៊ីវិល និងសហជីពក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពគឺជាលក្ខខណ្ឌលំបាកនិងមិនអនុលោមតាមបទដ្ឋានអន្តរជាតិ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ អនុញ្ញាតរដ្ឋអាចតម្រូវឱ្យសមាគមរាយការណ៍ ប្រសិនបើពួកគេបង្កើតឡើងក្នុងគោលបំណងស្របច្បាប់ តម្លាភាព និងគណនេយ្យភាព[98]។ ទោះជាយ៉ាងណាក៏ដោយបទដ្ឋានអន្តរជាតិតម្រូវឱ្យមាន កាតព្វកិច្ចរាយការណ៍ដោយមិនតាមទំនើងចិត្ត[99]ឬជាបន្ទុក[100]។ អង្គការតូចៗ ឬក្រុមនៅតាមមូលដ្ឋានអាចរងការប៉ះពាល់ដោយពុំសមាមាត្រ ព្រោះពួកគេមានធនធានតិចតួច ក្នុងការគោរពតាមលក្ខខណ្ឌតម្រូវជាច្រើនទាំងនោះ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពតម្រូវឱ្យអង្គការសង្គមស៊ីវិល ឬសហជីពផ្ញើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុទៅក្រសួងមហាផ្ទៃ[101]។ នៅឆ្នាំ២០១៩ មាត្រា១៧ នៃច្បាប់ស្តីពីសហជីពត្រូវបានកែសម្រួលឡើងវិញពីប្រើពាក្យថា "រៀបចំ" ជំនួសឱ្យ "ដាក់ជូន" នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពសម្រាប់សវនករ តាមសំណើរបស់ម្ចាស់ជំនួយឬសំណើរបស់សមាជិកសរុបយ៉ាងតិច១០% សម្រាប់សហជីពមូលដ្ឋាន ឬ ៥% នៃសមាជិកសរុបសម្រាប់សហព័ន្ធឬសហភាព។ មាត្រា១៧ ដដែលនេះក៏នៅតែបន្តតែត្បិតនៃដល់កិច្ចការផ្ទៃក្នុងរបស់សមាគមដដែល។<br><br>លើសពីនេះមាត្រា២៥ នៃច្បាប់ស្តីពីសមាគម ផ្តល់សិទ្ធិអំណាចដល់ក្រសួងមហាផ្ទៃដើម្បីទាមទារឱ្យសមាគមផ្តល់ជូននូវច្បាប់ចម្លងរបស់សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុរបស់សមាគមដើម្បីពិនិត្យ និងធ្វើសវនកម្មដោយរដ្ឋាភិបាល "ប្រសិនបើចាំបាច់"។ បទប្បញ្ញត្តិនេះផ្តល់អំណាចដ៏ទូលំទូលាយ ព្រមទាំងឆន្ទានុសិទ្ធិចំពោះក្រសួងមហាផ្ទៃ ក្នុងការកំណត់ថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណាខ្លះដែលមានកាតព្វកិច្ចបង្ហាញរបាយការណ៍របស់ខ្លួន និងឆ្លងកាត់សវនកម្មរបស់រដ្ឋាភិបាល។ ការអនុវត្តនេះធ្វើឱ្យប៉ះពាល់ដល់ឯកជនភាពនៃសមាគម និងអាចបង្កហានិភ័យដល់សុវត្ថិភាពនៃសមាជិកភាពរបស់សមាគមទាំងនោះ។ ដូច្នេះហើយ ក្របខណ្ឌច្បាប់បច្ចុប្បន្នរបស់កម្ពុជាដែលទាមទារការរាយការណ៍ពីអង្គការសង្គមស៊ីវិលនិងសហជីព គឺបំពានលើស្តង់ដាអន្តរជាតិដោយសារតែការចែងមិនមានភាពច្បាស់លាស់ មានលក្ខណៈដាក់បន្ទុក និងបំពានទាំងស្រុងលើឯកជនភាព និងសុវត្ថិភាពនិងស្ថាប័នទាំងនេះ។ |
| ១.៨<br><br>ទណ្ឌកម្មមក លើសមាគម ត្រូវបានចែងដោយច្បាប់សមាមាត្រ ផ្សព្វផ្សាយជាសាធារណៈ មាននិយមន័យច្បាស់លាស់ មានតម្លាភាព និងងាយស្រួលយល់ | ក្បឹទនៃ ទណ្ឌកម្មមកលើសមាគមដែលត្រូវបានកំណត់ដោយច្បាប់ ដែលមានលក្ខណៈសមាមាត្រ ផ្សព្វផ្សាយជាសាធារណៈ មាននិយមន័យច្បាស់លាស់ មានតម្លាភាព និងងាយស្រួលយល់ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ ទោសទណ្ឌចំពោះអង្គការសង្គមស៊ីវិលនិងគណបក្សនយោបាយក្រោមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីពនិងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ពុំសមាមាត្រ និងពុំស្របតាមបទដ្ឋានអន្តរជាតិ[102]។ ទោសទណ្ឌជាច្រើនក្រោមច្បាប់ស្តីពីសហជីព ហើយនិងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក៏ពុំបានឲ្យន័យឱ្យបានល្អិតល្អន់ ងាយយល់ និងតម្លាភាព។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់ទោសទណ្ឌជាច្រើន រួមទាំងការលែងសហជីព និងការលុបបញ្ជិកា ដែលមានខ្លឹមសារស្រពេចស្រពិល និយមន័យមិនច្បាស់លាស់ ហើយពិបាកយល់ពីចំណាត់ការទាំងនោះដូចជា "ពាក្យអញ្ញត្រឹតផ្នែកនយោបាយ" ជា ដើម។ ខណៈដែលវិសោធនកម្មច្បាប់ស្តីពីសហជីពនៅក្នុងឆ្នាំ២០១៩ បានដកចេញការលែងដោយស្វ័យប្រវត្តិ ប្រសិនបើថ្នាក់ដឹកនាំឬគណៈគ្រប់គ្រងណាម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋ[103] ច្បាប់ស្តីពីសហជីពក៏ចែងចំណាត់ការដែលនាំទៅកេការដាក់ទោសទណ្ឌដោយស្រដៀងគ្នានេះដែរពីនិយមន័យមិនច្បាស់ លាស់និងចំណាត់ការដូចជាការហាមប្រាមការក្នុងការរៀបចំទាំងឡាយណាក្នុងគោលបំណងបំរើនិន្នាការនយោបាយ ឬមហិច្ឆតាផ្ទាល់ខ្លួនជាដើម។ ម្យ៉ាងវិញទៀត ក្រមព្រហ្មទណ្ឌពិពណ៌នាអំពីទោសទណ្ឌក្នុងអត្ថន័យមិនច្បាស់លាស់ និងពុំសមាមាត្រដែលអាចអនុវត្តទៅលើសមាគមនិងអ្នកដឹកនាំដូចជា "ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស "ការប្រមាថ" "ការរិះគន់លើសេចក្តីបង្គាប់របស់តុលាការ" និងបទបរិហារកេរ្តិ៍។ ច្បាប់ស្តីពីទូរគមនាគមន៍[104] ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម[105] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏មានចែងពីទោសទណ្ឌនានា ចំពោះចំណាត់ការដែលពុំសមាមាត្រ ទូលំទូលាយនិងមិនច្បាស់លាស់នេះផងដែរ[106]។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្នបង្កើតការដាក់ទោសទណ្ឌមកលើអង្គការនិងអាជីវករដែលមិនគោរពតាមវិធានការពេលប្រទេសជាតិជួបប្រទះភាពអាសន្ន។ នីតិបុគ្គលដែលប្រព្រឹត្តិទោសព្រហ្មទណ្ឌដោយចេតនា "ការប៉ុនប៉ងប្រព្រឹត្តអំពើរាំងដល់កិច្ចប្រត្តិការ ពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន"[107] និង "ការប៉ុនប៉ងមិនគោរពតាមវិធានដែលដាក់ចេញដោយរាជរដ្ឋាភិបាល"[108]។ ទោសទណ្ឌក្រោមបញ្ញត្តិច្បាប់រួមបញ្ចូលទាំង |

[98] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌទី៦៥) <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

[99] ដូចយោងខាងលើ។

[100] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិឡើកឡើងថាកាតព្វកិច្ចរាយការណ៍មិនត្រូវរារាំងដល់ស្វយ័តភាពរបស់សមាគម។ UN Doc A/HRC/២២/L.១៣ (ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១៣ កថាខណ្ឌទី៩) <https://documents-dds-ny.un.org/doc/RESOLUTION/LTD/G13/120/26/PDF/G1312026.pdf?OpenElement>

[101] សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ផលិតរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង ICNL (ខែសីហា ឆ្នាំ២០១៨) ទំព័រ ៤ - ៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

[102] សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង ICNL (ខែសីហា ឆ្នាំ ២០១៨) ទំព័រ៤ - ៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/ admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

[103] មាត្រា២៩ នៃច្បាប់ស្តីពីសហជីព។

[104] មាត្រា១០៧ នៃច្បាប់ស្តីពីទូរគមនាគមន៍។

[105] មាត្រា៧ មាត្រា ៧៦ មាត្រា៧៧ និងមាត្រា៧៨ នៃច្បាប់ស្តីពីប្រឆាំងនឹងអំពើភេរវកម្ម។

[106] មាត្រា៧៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់។

[107] មាត្រា៧ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។

[108] មាត្រា៨ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។

| | | | | |
|---|---|---|---|---|
| | | | | ការពិន័យដ៏ធំរហូតដល់១លានរៀល បន្ថែមពីលើ “ទោសមួយឬច្រើនដូចមានចែងក្នុងមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌ”។ មាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌផ្ដល់អំណាចក្នុងការរំលាយឬបង្ខំឱ្យបិទស្ថាប័ន។ ការរំលាយឬបិទស្ថាប័នអង្គការសង្គមស៊ីវិលជាការរំលោភបំពានច្បាប់មួយផ្នែកដែលមិនស្របនឹងសេរីភាពខាងការបង្កើតសមាគម[109]។ មាត្រា៥ នៃច្បាប់កូវីដ-១៩ អាជ្ញាធរអាចផ្អាកឬដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្ម និងអាចបិទអាជីវកម្មដែលជាទណ្ឌកម្មប្រឆាំងនឹងជនដែលមិនអនុវត្តតាមបទបញ្ញត្តិ វិធានការសុខភាព និងវិធានការរដ្ឋបាលនេះ”។<br><br>ដូចគ្នាដែរ ក្នុងការលើកឡើងកន្លងមកមាត្រា ១៤៣ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានកំណត់វិធីសាស្ត្រពីរយ៉ាងសម្រាប់ការដោះស្រាយការបំពានដែលមានចែងក្នុងមាត្រា១៤២។ ការឆ្លើយតបនេះរួមបញ្ចូលទាំងការដកបេក្ខភាពគណបក្សនយោបាយដោយបំពាន និងការផាកពិន័យជាប្រាក់ពី ១០លាន ទៅ ៣០លានរៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។(ប.ជ.គ) ទោះជាយ៉ាងណាក៏ដោយ វិសោធនកម្មបន្តបន្ទាប់ដែលចុះក្រោយគឺច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានបង្កើនការផាកពិន័យកាន់តែធ្ងន់ធ្ងរចំពោះមាត្រា១៤២នេះ។ វិសោធនកម្មនេះបានកំណត់ឱ្យ គប ដ.ជ.កហូតសិទ្ធិចូលរួមបោះឆ្នោតណាមួយបន្ថែមទៀតសម្រាប់រយៈពេលយ៉ាងតិច ៥ឆ្នាំ។ គណបក្សនយោបាយណាដែលមិនគោរពតាមការណែនាំ ក្នុងការដកបេក្ខជនដែលមិនមានសិទ្ធិឈរឈ្មោះចេញពីបញ្ជីបោះឆ្នោតត្រូវទទួលរងការផាកពិន័យដូចគ្នាពី ១០លាន ទៅ ៣០លាន ដែលស្មើនឹងប្រមាណ ២៤២០ . ២៧០ ដុល្លារ។.ដុល្លារ ទៅ ៧ ការដាក់ទណ្ឌកម្មបែបនេះប្រសិនបើត្រូវបានអនុវត្ត និងបង្កើតការរឹតត្បិតមិនសមហេតុផលលើសិទ្ធិឈរឈ្មោះបោះឆ្នោត។ ការរឹតត្បិតនេះបានពន្យល់លម្អិតនៅកថាខណ្ឌខាងលើ ដោយបង្ហាញពីភាពមិនស្មើគ្នាដោយហាមឃាត់ការបោះឆ្នោតរយៈពេល៥ឆ្នាំ។<br><br>ក្របខណ្ឌច្បាប់បច្ចុប្បន្នរបស់កម្ពុជាដែលគ្រប់គ្រងការដាក់ទណ្ឌកម្មសម្រាប់អង្គការសង្គមស៊ីវិល សហជីព និងគណបក្សនយោបាយបង្ហាញពីភាពមិនស៊ីចង្វាក់គ្នាជាច្រើនរវាងស្តង់ដារអន្តរជាតិ។ ភាពមិនច្បាស់លាស់ កង្វះតម្លាភាព និងភាពមិនសមាមាត្រដែលកើតមាននៃទណ្ឌកម្មទាំងនេះ បង្កជាការប្រឈមយ៉ាងខ្លាំងចំពោះស្ថាប័នទាំងនេះ ចំពោះលទ្ធភាពក្នុងការប្រតិបត្តការដោយសេរី និងស្វ័យភាព<br><br>របស់ខ្លួន។ |
| ១.៩<br><br>ការការពារផ្នែកនីតិវិធីត្រូវបានដាក់ឱ្យអនុវត្តសម្រាប់សមាគមដែលប្រឈមនឹងទណ្ឌកម្ម | កម្រិតនៃការការពារត្រូវបានដាក់ឱ្យអនុវត្តសម្រាប់សមាគមដែលប្រឈមនឹងទណ្ឌកម្ម | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | | កម្ពុជាមិនបំពេញចំណុចនេះទេ។ មានកិច្ចការពារមួយចំនួនត្រូវបានបញ្ចូលក្នុងច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដូចជាការបង្កើនទោស និងសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងករណីលុបឈ្មោះចេញពីបញ្ជី ប៉ុន្តែកិច្ចការពាររួមទាំងនេះពុំទាន់គ្រប់គ្រាន់នៅឡើយ។ ច្បាប់ស្ដីពីសហជីពពុំមានចែងពីសិទ្ធិប្ដឹងទាស់ទៅសាលាឧទ្ធរណ៍ចំពោះការពិន័យផ្នែករដ្ឋបាល ឡើយ ទោះបីជាប្រកាសលេខ ២៥១ នៃក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានបង្កើតសិទ្ធិមានដែនកំណត់ទាក់ទងនឹងបណ្ដឹងទាស់ផ្នែករដ្ឋបាលទៅក្រសួងការងារនៅពេលទទួលបានលិខិតព្រមាន ឬការផាកពិន័យក៏ដោយ។<br><br>ទោសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ មានចែងសិទ្ធិប្ដឹងឧទ្ធរណ៍។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ស្ដីពីគណបក្សនយោបាយ ផ្ដល់ការការពារតិចតួចចំពោះការដាក់ទោស បើទោះបីជាបានផ្ដល់អំណាចជាការសម្រេចចិត្តយ៉ាងសំខាន់ដល់ស្ថាប័ននីតិប្រតិបត្តិក្នុងការដាក់ទណ្ឌកម្មដែលបានកំណត់យ៉ាងទូលំទូលាយ និងច្បាស់លាស់ក៏ដោយ។ ដូច្នេះក្របខណ្ឌច្បាប់បច្ចុប្បន្នបង្ហាញពីការប្រឈមក្នុងការធានានូវដំណើរការត្រឹមត្រូវ និងការអនុវតប្រកបដោយយុត្តិធម៌ នៃទោសដែលមានកំណត់ក្នុងក្របខណ្ឌច្បាប់ផ្សេងៗ ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធក្នុងដំណើរការទាំងនេះ។ |
| ១.១០<br><br>សិទ្ធិក្នុងការរំលាយដោយស្ម័គ្រចិត្តត្រូវបានការពារដោយច្បាប់ | កម្រិតនៃការរំលាយដោយស្ម័គ្រចិត្តត្រូវបានការពារដោយច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | ៤ | ជាទូទៅកម្ពុជាបានបំពេញចំណុចនេះ។ មាត្រា២៦ នៃច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក "អាចផ្អាកសកម្មភាពរបស់ខ្លួនដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ ក្រសួងមហាផ្ទៃ ហើយមុននឹងផ្អាកសកម្មភាពត្រូវធ្វើរបាយការណ៍សកម្មភាពការងារនិងរបាយការណ៍ហិរញ្ញវត្ថុ"។ ប៉ុន្តែបទប្បញ្ញត្តិមិនច្បាស់លាស់នៃមាត្រា ២៦ (២) អាចបង្កើតជាឧបសគ្គដល់ការរំលាយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដោយស្ម័គ្រចិត្ត ព្រោះបទប្បញ្ញត្តិទាំងនោះតម្រូវថា "សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមុននឹងរំលាយត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន"។ ជាងនេះទៅទៀត អត្ថបទនេះផ្ទុយនឹងកថាខណ្ឌទី ១ នៃមាត្រា ២៥ ដែលសំដៅតែលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មិនមែនទៅលើសមាគមក្នុងស្រុក ដោយមាត្រានេះមិនបានពន្យល់បន្ថែមអំពីភាពខុសគ្នាចំពោះតម្រូវការរវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុង ស្រុក។ ក្រមរដ្ឋប្បវេណីធានាដល់ការរំលាយស្ថាប័ននីតិបុគ្គលដោយស្ម័គ្រចិត្តមាត្រា៦៤។ តាមមាត្រា៦៤(១) "ដោយមូលហេតុនៃការរំលាយដែលបានកំណត់នៅក្នុងលក្ខន្តិកៈ"។ សមាគមឬអង្គការមិនមែនរដ្ឋាភិបាលអាចរំលាយតាមសេចក្ដីសម្រេចនៃមហាសន្និបាតសមាជិក ដោយទទួលបានការគាំទ្រភាគច្រើនពីសមាជិកទាំងអស់ត្រូវមានការយល់ព្រមពីសមាជិកចាប់ពីពាក់កណ្ដាលឡើងទៅ ដោយមានសំឡេងចាប់ទី ៣ ភាគ ៤ ឡើងទៅ នៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ មាត្រា ៦៤ (២) និង (៣)។ |
| ១.១១<br><br>ការរំលាយអាចធ្វើទៅបានបន្ទាប់ពីបានប្រើប្រាស់ច្បាប់ដទៃទៀតអស់លទ្ធភាពនិង | កម្រិតនៃ ដំណើរការរំលាយសមាគមត្រូវបានដាក់ឱ្យអនុវត្ត | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | ១ | កម្ពុជាខកខានបំពេញចំណុចនេះ។ ការរំលាយសមាគមឬអង្គការមិនមែនរដ្ឋាភិបាលអាចធ្វើទៅបានក្រោមក្រមព្រហ្មទណ្ឌ ច្បាប់ស្ដីពីការប្រឆាំងនឹងអំពើភេរវកម្ម ច្បាប់ស្ដីពីគណបក្សនយោបាយ និងច្បាប់ស្ដីពីសហជីព និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ក្នុងករណីនីមួយៗ ការរំលាយអាចត្រូវបានគេកំណត់ថាជាវិធានការវិន័យតែប៉ុណ្ណោះ ពុំមែនជាការឆ្លើយតបដោយសមាមាត្រ និងជាដំណោះស្រាយចុងក្រោយចំពោះគ្រោះថ្នាក់លើការបន្តប្រតិបត្តិការ របស់សមាគម ឬអង្គការមិនមែន រដ្ឋាភិបាលឡើយ។ ជាពិសេស វិធានការនៃការផ្អាក ឬការរំលាយសហជីពតាមអំណាចផ្នែករដ្ឋបាលបង្កការប៉ះពាល់ធ្ងន់ធ្ងរលើគោលការណ៍សេរីភាពខាងសមាគម[110]។ មាត្រា ២៤ និង ២៥ អាចជាហេតុផល ក្នុងមាត្រា ៣០ ដើម្បីផ្អាក ឬលុបឈ្មោះចេញពីបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ លើសពីនេះ ពាក្យកំពុងប្រើក្នុងមាត្រា៣០ នឹងអនុញ្ញាតឱ្យក្រសួងមហាផ្ទៃផ្អាក ឬលុបឈ្មោះចេញពីបញ្ជីសមាគម និងអង្គការមិន |

[109] ការរំលាយដោយមិនស្ម័គ្រចិត្តគឺជាវិធីចុងក្រោយដែលគួរប្រើប្រាស់តែចំពោះការបំពានធ្ងន់ធ្ងរនិងគួរតែធ្វើបន្ទាប់ពីបានជូនដំណឹងនិងឱកាសក្នុងការតវ៉ា។ សូមអាន គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ A/HRC/20/27, ‘របាយការណ៍អ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសេរីភាពខាងសមាគម’, Maina Kiai’ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២, កថាខណ្ឌទី៧៥ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>។

[110] អត្ថបទស្ដីពីសេរីភាពខាងសមាគមរបស់អង្គការពលកម្មអន្តរជាតិឆ្នាំ២០១៦ កថាខ័ណ្ឌ៦៨៣ <http://www.ilo.org/wcmsp5/groups/public/@ed_norm/@normes/documents/publication/wcms_090632.pdf>។

| | | | | |
|---|---|---|---|---|
| បង្ហាញថាសមាគម អាចបង្កគ្រោះថ្នាក់ | | | | មែនរដ្ឋាភិបាលក្នុងស្រុក ដោយសារតែមិនគោរពតាមលក្ខន្តិកៈរបស់ខ្លួន ទោះបជាការមិនគោរពតាមលក្ខន្តិកៈនេះមិនមែនជាបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់ជាតិក៏ដោយ។<br><br>បទប្បញ្ញត្តិដ៏ទូលំទូលាយដែលមានចែងក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានផ្តល់អំណាចដល់ក្រសួងក្នុងការសម្រេចចិត្តហួសហេតុ និងបើកឱកាសសម្រាប់ការរំលាយស្ថាប័នតាមអំពើចិត្ត ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងសមាគមបន្ថែមទៀត។ ជាពេសនោះគឺ កថាខណ្ឌចុងក្រោយនៃមាត្រា ៣០ ដែលចែងថាក្រសួងមហាផ្ទៃនឹងសម្រេចដកបញ្ជីចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណាដែលបង្កគ្រោះថ្នាក់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ផ្អែកលើលក្ខណៈវិនិច្ឆ័យមិនច្បាស់លាស់ដែលប៉ះពាល់ដល់សេរីភាពខាងសមាគម។ ក្របខណ្ឌច្បាប់របស់កម្ពុជា ដែលមានលក្ខណៈគ្រប់គ្រងការរំលាយសមាគម ដែលមិនសមស្របនឹងស្តង់ដារអន្តរជាតិ អនុញ្ញាតឱ្យមានវិធានការមិនសមាមាត្រ និងការដាក់ទណ្ឌកម្មដែលជារឿយៗហួសពីគោលការណ៍នៃភាពចាំបាច់បំផុតដោយបំពានសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងសមាគម។ |
| ១.១២<br><br>សមាគមត្រូវបាន អនុញ្ញាតឱ្យធ្វើ សកម្មភាពសេដ្ឋកិច្ច | កម្រិតនៃច្បាប់ ឬគោលនយោបាយ អនុញ្ញាតឱ្យសមាគមធ្វើ សកម្មភាពសេដ្ឋកិច្ច | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | ៤ | ប្រទេសកម្ពុជាបានបំពេញចំណុចនេះ ដែលទាក់ទងនឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច។ ទោះបីជាគ្មានច្បាប់ជាក់លាក់ណាមួយគ្រប់គ្រងដោយផ្ទាល់លើការចូលរួមអង្គការមិនមែនរដ្ឋាភិបាលក្នុងសកម្មភាពសេដ្ឋកិច្ចក៏ដោយ ក៏សិទ្ធិនេះមិនត្រូវបានការពារ ឬហាមឃាត់ជាក់លាក់ក្នុងក្របខណ្ឌច្បាប់បច្ចុប្បន្នដែរ។ ការខ្វះភាពជាក់លាក់ និងការណែនាំ ធ្វើឱ្យមាននូវបរិយាកាសមិនច្បាស់លាស់។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពីសហជីព បានដាក់កម្រិតលើសិទ្ធិនេះដោយហាមឃាត់សហជីពមិនឱ្យដំណើរការអាជីវកម្ម ដោយអនុញ្ញាតករណីលើកលែងតែមួយគត់គឺផ្តល់ឱកាសឱ្យសហជីពកាន់កាប់ភាពជាតំណាងបំផុតនៅកន្លែងដែលខ្លួនធ្វើការ។ ការកំណត់ជាក់លាក់បែបនេះចំពោះសហជីពគឺមានលក្ខណៈផ្ទុយនឹងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ ដោយក្នុងនោះរួមមានសិទ្ធិខាងការជួបប្រជុំដោយសន្តិវិធី ការតស៊ូមតិសម្រាប់ការផ្តល់សិទ្ធិអំណាចដល់បុគ្គល និងក្រុមផ្សេងៗដើម្បីចូលរួមសកម្មភាពចម្រុះ រួមមានអក្ខរកម្ម ការស្វែងយល់ពីសិល្បៈ និងផ្នែកវប្បធម៌ សេដ្ឋកិច្ច និងសង្គមផ្សេងៗទៀត។<br><br>ក្នុងខណៈដែលកម្ពុជាមិនបានហាមឃាត់អង្គការមិនមែនរដ្ឋាភិបាលឱ្យចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចជាក់លាក់នោះ ការអវត្តមាននៃការទទួលស្គាល់ផ្លូវច្បាប់ និងបទប្បញ្ញត្តិរឹតត្បិតនៃច្បាប់សហជីព បង្កើតបរិយាកាសប្រឈមផ្សេងៗក្នុងការអនុលោមតាមគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ។ |
| ១.១៣<br><br>ការទទួលមូលនិធិ បរទេស ត្រូវបាន អនុញ្ញាត នៅក្រោមច្បាប់ | កម្រិតនៃការទទួលបានមូលនិធិបរទេសត្រូវ បានអនុញ្ញាតដោយច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ៤ | កម្ពុជាបានបំពេញចំណុចនេះ ទាក់ទងនឹងសម្ថភាពរបស់សមាគមក្នុងការទទួលបានមូលនិធិពីបរទេស។ ខណៈដែលក្របខណ្ឌច្បាប់មិនចែងពីការហាមឃាត់ច្បាស់លាស់លើការទទួលមូលនិធិពីបរទេសរបស់សមាគមក៏ដោយ ក៏បទប្បញ្ញត្តិមួយចំនួននៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បង្កឱ្យមានការព្រួយបារម្ភផងដែរ។ ជាពិសេសមាត្រា២៧ នៃច្បាប់ស្តីពីសមាគមបានកំណត់តម្រូវការណ៍បន្ថែម និងតឹងរ៉ឹងលើអង្គការមិនមែនរដ្ឋាភិបាលដែលស្វែងរក និងឬទទួលមូនិធិពីបរទេស។ កាតព្វកិច្ចក្នុងការរាយការណ៍កើនឡើង/ទាំងនេះអាចបង្កើតបន្ទុករដ្ឋបាល និងរារាំងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនពីមូលនិធិបរទេស។<br><br>លើសពីនេះ មាត្រា ២៥ នៃច្បាប់ស្តីសមាគម កំណត់ថាសមាគមជាតិ និងអន្តរជាតិដែលទទួលបានបានការគាំទ្រពីម្ចាស់ជំនួយត្រូវបញ្ជូនឯកសារផ្សេងៗជាច្រើនទៅក្រសួងពាក់ព័ន្ធក្នុងរយៈពេលកំណត់ជាក់លាក់។ តម្រូវការទាំងនោះរួមមាន១ការបញ្ជូនច្បាប់ចម្លងនៃ . ការទំនាកទំនងម្ចាស់ជំនួយក្នុងរយៈពេល៣០ ដើម្បីដាក់ ២បញ្ជូនច្បាប់ចម្លងនៃឯកសារគម្រោង និងកិច្ចព្រមព្រៀងផ្តល់មូលនិធិក្នុងរយៈ . ពេល៣០ ថ្ងៃបន្ទាប់ពីការបំណើរការគម្រោងថ្មី ឬកិច្ចព្រមព្រៀង។ ខណៈដែលហាក់ដូចជាចែងជាក់លាក់ តែនិតិវិធីក្នុងការរាយការណ៍នូវតម្រូវការទាំងនេះក្នុងការអនុវត្តជាក់ស្តែងគឺអាចជាឧបសគ្គក្នុងការទទួលបានមូលនិធិបរទេស ជាពិសេសសម្រាប់អង្គការតូចៗ។ ឧបសគ្គដូចជាពេលវេលា និងភាពស្មុគស្មាញដែលអាចកើតមាននៃការបំពេញតម្រូវការទាំងនេះជះឥទ្ធិពលមិនសមាមាត្រដល់អង្គការមិនមែនមែនរដ្ឋាភិបាលតូចៗដែលមានធនធានមានកម្រិត ដោយរារាំងលទ្ធភាពរបស់ស្ថាប័នទាំងនេះក្នុងការទទួលបានមូលនិធិពីដ៏សំខាន់ពីបរទេស។ ទោះបីជាមិនមានការហាមឃាត់ជាក់លាក់តាមផ្លូវច្បាប់ក៏ដោយ ក៏តម្រូវការរាយការណ៍ដ៏តឹងរ៉ឹងដែលមានចែងក្នុងច្បាប់ស្តីពីសមាគម អាចបង្កជាឧបសគ្គសម្រាប់សមាគមមួយចំនួន ជាពិសេសសមាគមតូចៗដែលកំពុងស្វែងរកការទទួលបានមូលនិធិពីបរទេស។ |
| ១.១៤<br><br>សមាគមមិនប្រឈម នឹងការរឹតត្បិតមិន សមហេតុផលពី ទទួល មូលនិធិឯកជន (ក្នុងស្រុក) | កម្រិតនៃ ច្បាប់ ឬគោលនយោបាយអនុញ្ញាតឱ្យ សមាគមទទួលមូលនិធិពី ប្រភពឯកជនដោយគ្មានការរឹតត្បិតមិនសមហេតុផល | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ៤ | កម្ពុជាបានបំពេញចំណុចនេះ។ កម្ពុជាពុំមានច្បាប់ហាមប្រាមក្នុងការទទួលមូលនិធិពីប្រភពឯកជនក្នុងស្រុកឡើយ។ ប៉ុន្តែការទទួលការគាំទ្រពីម្ចាស់ជំនួយ ទោះក្រៅប្រទេស ឬ ក្នុងប្រទេសនឹងនាំឱ្យមានលក្ខខណ្ឌធ្វើរបាយការណ៍ ដែលតាមការអនុវត្តជាក់ ស្តែងអាចបង្កជាឧបសគ្គមួយ ជាពិសេសចំពោះអង្គការតូចៗ។ ជាងនេះទៅទៀត មាត្រា ២៥ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល តម្រូវថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលទទួលការគាំទ្រពីម្ចាស់ជំនួយត្រូវបញ្ជូនច្បាប់ថតចម្លងនៃឯកសារដើមដែលបានបញ្ជូនទៅម្ចាស់ជំនួយមកក្រសួងមហាផ្ទៃ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេសឱ្យបានក្នុងអំឡុងពេល៣០ ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។<br><br>ថ្វីត្បិតតែមើលទៅហាក់បីដូចជាមិនច្បាស់លាស់ក៏ដោយ នីតិវិធីជាកំហិតទាំងនេះអាចអនុវត្តជាការរារាំង ជាពិសេសសម្រាប់អង្គការតូចៗដែលមានធនធានមានកម្រិត។ ឧបសគ្គពេលវេលា និងបន្ទុករដ្ឋបាលដែលអាចកើតមានទាក់ទងនឹងការបំពេញតម្រូវការទាំងនេះអាចប៉ះពាល់ដល់អង្គភាពតូចៗ ដែលមានសមត្ថភាព និងធនធានតិចជាង ដូច្នេះរារាំងសមត្ថភាពរបស់ស្ថាប័នទាំងនេះក្នុងការទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុសំខាន់ៗពីប្រភពឯកជននៅក្នុងស្រុក។ ដូច្នេះ ទោះបីជាមិនមានរបាំងផ្លូវច្បាប់ច្បាស់លាស់ក៏ដោយ ក៏កាតព្វកិច្ចរាយការណ៍ដ៏តឹងរ៉ឹងដែលមានចែងនៅក្នុងច្បាប់ស្តីពីសមាគម អាចមានសក្តានុពលបង្កនូវឧបសគ្គសម្រាប់សមាគមមួយចំនួន ជាពិសេសក្រុមតូចៗក្នុងការស្វែងរកមូលនិធិពីប្រភព ឯកជនក្នុងស្រុក។ |
| ១.១៥<br><br>កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ មិនមានលក្ខណៈស្មុគស្មាញ | កម្រិតនៃ លក្ខខណ្ឌតម្រូវសម្រាប់ការ របាយការណ៍ហិរញ្ញវត្ថុ ស្របទៅតាម បទដ្ឋានអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ២ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញទេ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិ បាលកំណត់កាតព្វកិច្ចក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុក្នុងនោះរួមទាំងបទប្បញ្ញត្តិទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងព័ត៌មានលម្អិតអំពីការទទួលមូលនិធិផងដែរ។ ការកំណត់លក្ខខណ្ឌតម្រូវក្នុងការធ្វើរបាយការណ៍ផ្នែកហិរញ្ញវត្ថុនេះក៏មានចែងក្នុងច្បាប់ស្តីពីសហជីពផងដែរ និងជាកម្មវត្ថុអាចត្រូវកែប្រែពីក្រសួងការងារនៅពេលណាមួយក៏បាន។ មាត្រា១៧ នៃវិសោធនកម្មច្បាប់ស្តីពីសហជីពត្រូវបានកែសម្រួលឡើងវិញពីប្រើពាក្យថា "រៀបចំ" ជំនួសឱ្យ "ដាក់ជូន" នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍សកម្មភាពសម្រាប់សវនករតាមសំណើររបស់ម្ចាស់ជំនួយ ឬសំណើររបស់សមាជិកសរុបយ៉ាងតិច១០% សម្រាប់សហជីពមូលដ្ឋាន ឬ៥%នៃសមាជិកសរុបសម្រាប់សហព័ន្ធឬសហភាព។ មាត្រា១៧ ដដែលនេះក៏នៅបន្តរឹតត្បិតនៃដល់កិច្ចការផ្ទៃក្នុងរបស់សមាគម ដដែល។ ទាំងអង្គការសង្គមស៊ីវិលនិងសហជីពឱ្យយោបល់ដែលពួកគេបាន |

| | | | | |
|---|---|---|---|---|
| | | | | ប្រឹងប្រែងគោរពតាមតម្រូវការរបាយការណ៍របស់រាជរដ្ឋាភិបាលក្រោមច្បាប់អង្គការសមាគម និងច្បាប់ស្តីពីសហជីព។ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយក៏ចែងពីកាតព្វកិច្ចថ្មីមួយក្នុងការប្រកាសទ្រព្យសម្បត្តិ និងទំនួលខុសត្រូវចំពោះអង្គភាពប្រឆាំងអំពើពុករលួយ។ ជាចុងក្រោយ លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ ក៏មានចែងក្នុងសេចក្តីប្រកាសស្តីពីគោលការណ៍ណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធ របស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលចាត់ទុកជាបន្ទុកការងារបន្ថែមទៀតលើលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលអាចរឹតត្បិតលើសេរីភាពខាងសមាគមដែលពុំអនុលោមតាមច្បាប់។ |
| ១.១៦<br><br>យន្តការសម្រាប់ការដោះស្រាយការរំលោភទៅលើសេរីភាពខាងការបង្កើតសមាគមត្រូវបានអនុវត្ត | កម្រិតនៃប្រព័ន្ធដោះស្រាយសម្រាប់ការរំលោភលើសេរីភាពខាងការបង្កើតសមាគម ត្រូវបានធានាដោយច្បាប់ និងគោលនយោបាយ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២,៥ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញនៅឡើយទេ។ រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋឱ្យតតាំង នឹងការរំលោភបំពានណាមួយលើសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែ នីតិវិធីត្រួតពិនិត្យផ្នែកតុលាការពុំត្រូវបានពន្យល់ឱ្យបានច្បាស់ លាស់ ដែលធ្វើឱ្យការធានានេះមានប្រសិទ្ធភាពតិចតួច។ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញអនុញ្ញាតឱ្យពលរដ្ឋតតាំងចំពោះច្បាប់ឬសេចក្តីសម្រេចដែលបង្កឱ្យមានការរំលោភលើសិទ្ធិក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែច្បាប់នេះត្រូវបានធ្វើវិសោធនកម្មក្នុងខែកុម្ភៈ ឆ្នាំ២០១៨ លុបចេញបញ្ញត្តិដែលអនុញ្ញាតឱ្យគណបក្សនយោបាយអាចប្តឹងទាស់ទៅនឹងសេចក្តីសម្រេច របស់ក្រសួងមហាផ្ទៃដែលបដិសេធលើសំណើសុំចុះបញ្ជី។ ក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមិនមានយន្តការដាក់ទោសរដ្ឋបាលមកលើការបដិសេធការចុះបញ្ជីសមាគមនោះទេ។ សម្រាប់សមាគមក្នុងស្រុកមានវិធានការមួយប៉ុណ្ណោះសម្រាប់តវ៉ាមកលើការបដិសេធការចុះបញ្ជីរបស់ពួកគេដែលត្រូវតវ៉ា ចំពោះការបដិសេធតាមប្រព័ន្ធតុលាការ។ សម្រាប់សមាគមបរទេសឬអង្គការអន្តរជាតិ ពួកគេអាចតវ៉ាពីការសម្រេចនេះទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ប្រកាសលេខ២៥០ និង២៥១ ពង្រីកវិសាលភាពដល់ច្បាប់ស្តីពីសហជីព ដែលកម្រិតការតវ៉ាត្រឹមតែក្រសួងបណ្តុះបណ្តាលការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែមិនបានផ្តល់សិទ្ធិឱ្យពួកគេតវ៉ាពីការសម្រេចនេះដល់តុលាការនោះទេ។ ហើយទាំងនេះគឺមិនស្របតាមការអនុវត្តល្អបំផុតជាអន្តរជាតិដែលអនុញ្ញាតឱ្យ "សមាគមអាចតវ៉ាអំពីការបដិសេធមិនចុះបញ្ជីដោយមិនលំអៀង និងឯករាជ្យ"[111]។ |
| ១.១៧<br><br>សមាជិកភាពនៅក្នុងអង្គការ សមាគម សម្ព័ន្ធឬសហព័ន្ធមិនមែនជាកាតព្វកិច្ចឡើយ | កម្រិតនៃសមាជិកភាពនិងការដកខ្លួនពីសមាជិកភាពដោយស្ម័គ្រចិត្តក្រោមការកំណត់របស់ច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៤ | កម្ពុជាបំពេញបានផ្នែកខ្លះនៃធាតុផ្សំនេះ។ ទាំងច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីសហជីពធានា សេរីភាពក្នុងការមិនចូលរួមនិងចាកចេញពីសហជីពកម្មករឬសមាគមនិយោជក[112]។ ច្បាប់ស្តីពីសហជីពតម្រូវឱ្យបុគ្គលនីមួយៗដាក់លិខិតជាមួយហត្ថលេខាឬក៏ស្នាមមេដៃរបស់ពួកគេទៅសហជីពនិងនិយោជក ដើម្បីប្រាប់ពីការចាកចេញពីសមាជិកភាពនោះ។ ច្បាប់នោះក៏បានសង្កត់ធ្ងន់ថា "គ្មាននរណាម្នាក់អាចជ្រៀតជ្រែកសិទ្ធិរបស់កម្មករនិយោជិតក្នុងការចូលរួមឬចាកចេញពីសហជីពឡើយ"[113]។ ស្រដៀងគ្នានេះ ច្បាប់ស្តីពីគណបក្សនយោ បាយបានចែងថា "ការចូលជាសមាជិកភាពនៃគណបក្សនយោបាយគឺជាការស្ម័គ្រចិត្ត"។ សមាជិកនៃគណបក្សនយោបាយអាចលាឈប់ពីសមាជិកភាពបានគ្រប់ពេលវេលា ដោយមិនតម្រូវឱ្យមានបង្ហាញពីមូលហេតុ។ [114] ច្បាប់ស្តីពីអង្គការសមាគមនៅតែបន្តស្ងៀមស្ងាត់ អំពីការដកខ្លួនចេញពីសមាជិកភាពដោយស្ម័គ្រចិត្ត។ ផ្នែកមួយនៃសមាគមទាំងបីប្រភេទរួមមាន សហជីព សមាគមនិយោជក និងគណបក្សនយោបាយ សិទ្ធិក្នុងការចាកចេញពីសមាជិកភាព គឺមិនត្រូវបានការពារនៅក្នុងច្បាប់នោះទេ។ ទោះជាបែបនេះក្តីសូចនាករមួយនេះបានឱ្យពិន្ទុចំនួន៤។ មាត្រា៤២ នៃរដ្ឋធម្មនុញ្ញធានានិងការពារប្រជាជនខ្មែរក្នុងការបង្កើតសមាគម និងគណបក្សនយោបាយ ប៉ុន្តែមិនបាននិយាយពីការដកខ្លួនចេញពីសមាជិកភាពរបស់សមាគមនោះទេ។<br><br>ដូច្នេះ ខណៈពេលដែលការធានាដាក់លាក់មានសម្រាប់ប្រភេទសមាគមមួយចំនួន ក្របខ័ណ្ឌច្បាប់របស់កម្ពុជាបង្ហាញនូវចន្លោះប្រហោងក្នុងការការពារយ៉ាងទូលំទូលាយនូវសិទ្ធិចូលរួមដោយសេរី ឬដកខ្លួនចេញពីសមាគមផ្សេងៗ។ ការដោះស្រាយបញ្ហាខ្វះខាតទាំងនេះដោយការអនុម័តបទប្បញ្ញត្តិច្បាប់ច្បាស់លាស់ដែលការពារសិទ្ធិក្នុងការដកខ្លួនចេញពីសមាគមណាមួយនឹងលើកកម្ពស់ការអនុលោមតាមស្តង់ដារអន្តរជាតិនៅក្នុងចន្លោះខ្វះខាតនេះ។ |
| ១.១៨<br><br>ការសន្មតមុនដែលគាំទ្រដល់ការរៀបចំការប្រមូលផ្តុំដោយសន្តិវិធី គឺត្រូវបានកំណត់យ៉ាងច្បាស់លាស់ | កម្រិតនៃក្របខ័ណ្ឌច្បាប់កំណត់នូវការសន្មតមុនដែលគាំទ្រចំពោះការប្រមូលផ្តុំដោយសន្តិវិធីដែលត្រូវបានអនុញ្ញាត | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | កម្ពុជាខកខានក្នុងការគោរពចំណុចនេះឱ្យបានពេញលេញ។ ច្បាប់កម្ពុជាចែងពុំច្បាស់លាស់ពីការសន្មតជាមុនក្នុងការគាំទ្រដល់ការរៀបចំបាតុកម្មដោយសន្តិវិធី។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងពីការសន្មត់ទុកជាមុនក្នុងការគាំទ្រដល់ការរៀបចំបាតុកម្មដោយសន្តិវិធីដែលចែងថា អាជ្ញាធរមានសមត្ថកិច្ច "ត្រូវឆ្លើយតបជាវិជ្ជមានជាលាយលក្ខណ៍អក្សរ"[115]។ ប៉ុន្តែការសន្មតទុកជាមុននេះមិនអនុវត្ត ទោះការប្រមូលផ្តុំដោយសន្តិវិធីធ្វើឡើងនៅក្នុងអំឡុងពេលថ្ងៃឈប់សម្រាក (ពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ពិធីឡើងគ្រងរាជ បុណ្យឯករាជ្យជាតិ បុណ្យចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌ)[116]។ ម្យ៉ាងទៀត ច្បាប់នេះមានវិសាលភាពតូចចង្អៀតពេក ដែលមិនរាប់បញ្ចូលការជួបប្រជុំក្នុងយុទ្ធនាការបោះឆ្នោត ឬការជួបប្រជុំទាក់ទងនឹងវិវាទការងារជាដើមដែលផ្ទុយទៅនឹងគោលការណ៍សន្មត់ទុកជាមុនដែលបានលើកឡើងខាងលើ។[117] |

[111] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២(, កថាខណ្ឌ៩៥ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

[112] " សេរីភាពសហជីពរបស់បុគ្គលម្នាក់ៗក៏បង្ហាញពីសេរីភាពនៃការមិនចូលរួមជាមួយសហជីពកម្មករឬនិយោជក និងសេរីភាពក្នុងការចាកចេញពីសមាគមបានគ្រប់ពេល" មាត្រា២៧៣ នៃច្បាប់ស្តីពីការងារ និង" សេរីភាពរបស់បុគ្គលម្នាក់ក្នុងមាត្រា៥ (សិទ្ធិក្នុងការបង្កើតនិងចូលរួមជាមួយសហជីពឬសមាគមនិយោជក) នៃច្បាប់នេះហើយក៏បង្កប់នូវសេរីភាពក្នុងការមិនចូលរួមជាមួយសហជីពកម្មករឬសមាគមនិយោជកនិងសេរីភាពក្នុងការដកខ្លួនចេញពីសហជីពឬសមាគមនិយោជកនោះបានគ្រប់ពេលទាំងអស់" មាត្រា៧ នៃច្បាប់ស្តីពីសហជីព។

[113] មាត្រា១៣ នៃច្បាប់ស្តីពីសហជីព។

[114] មាត្រា៧ នៃច្បាប់ស្តីពីគណបក្សនយោបាយ។

[115] មាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[116] ក្នុងករណីនេះ ក្រោមមាត្រា ១១ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថាអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដីរាជធានី ឬខេត្ត ត្រូវធ្វើការឆ្លើយតបដោយជូនដំណឹង "ជាបន្ទាន់" ទៅអ្នកដែលបានដាក់លិខិតជូនដំណឹង "ដើម្បីឱ្យពួកគេអាចមានពេលជួបជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ធ្វើការពិចារណាដើម្បីពិភាក្សាគ្នាដោះស្រាយ" ។ ប្រសិនបើពុំមានការឯកភាពគ្នាទេ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវផ្តល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលយ៉ាងយូរត្រឹមម្ភៃបួន (២៤) ម៉ោងមុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី (មាត្រា១២)។

[117] មាត្រា ៣ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

| | | | | |
|---|---|---|---|---|
| | | | | ស្រដៀងគ្នានេះច្បាប់ការងារ ក៏មិនរាប់បញ្ចូលនូវសកម្មភាពមួយចំនួនក្រៅពីវិសាលភាពនៃកិច្ចការពារដែលមានចែងក្នុងច្បាប់នេះដែរ[118]។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន បន្ថែមពីលើនូវការសន្មតនៃការអនុញ្ញាតឱ្យមានការប្រជុំដោយសន្តិវិធីដោយកំណត់អំណាចយ៉ាងទូលាយនិងគ្មាន “ហាមឃាត់ឬរឹតត្បិតសិទ្ធិជួបប្រជុំនិងជាក្រុម" នៅក្នុងពេលប្រទេសជាតិភាពអាសន្ន[119]។ ការវិវឌ្ឍបទបញ្ញតិនៅឆ្នាំ ២០២១ បង្កើតបានជាមូលដ្ឋានបន្ថែមសម្រាប់ជំទាស់នឹងអ្នករិះគន់។ មាត្រា៤ នៃច្បាប់កូវីដ-១៩ ផ្តល់អំណាចដ៏សម្បើមដល់អាជ្ញាធរក្នុងការរឹតត្បិតឬហាមឃាត់ “ការប្រជុំ និងការប្រមូលផ្តុំរបស់មនុស្ស ដែលសកម្មភាពនេះអាច បណ្តាលឱ្យមានការរីករាលដាលជំងឺកូវីដ-១៩” ។ បន្ថែមពីនេះមានត្រា ៦ នៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ រដ្ឋាភិបាលអាចប្រើប្រាស់ ក្នុងការបិទអ៊ីនធឺណិតឬបិទការផ្តល់សេវាដែលប្រើប្រាស់សម្រាប់អនុវត្តការជួបប្រជុំ។ ហើយជាចុងក្រោយ សង្ឃប្រកាស បានហាមឃាត់ព្រះសង្ឃពីការចូលរួមក្នុងការតវ៉ាផ្សេងៗ។ ដោយសារមូលហេតុនេះ ពិន្ទុត្រូវបានធ្លាក់ចុះមកត្រឹម ២ ដែលបង្ហាញពីការប្រើអំណាចខ្លាំងក្នុងការរឹតត្បិតនិងហាមឃាត់ដល់ការជួបប្រជុំដោយសសន្តិវិធី។ ដូច្នេះ ទោះបីជាមានការសន្មត់មានកម្រិតនៅក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីក៏ដោយ ការកំណត់យ៉ាងទូលំទូលាយ ការដកចេញ និងការវិវឌ្ឍនីតិបញ្ញត្តិថ្មីៗនៅក្នុងក្របខ័ណ្ឌច្បាប់របស់កម្ពុជា បង្ហាញពីការបរាជ័យក្នុងការរក្សាសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធីយ៉ាងទូលំទូលាយ និងជាប់លាប់។ |
| ១ .១៩<br>ការរឹតត្បិត តម្រូវឱ្យមានហេតុផលច្បាស់លាស់ និងទាន់ពេលវេលា | កម្រិតនៃ ក្របខ័ណ្ឌច្បាប់តម្រូវឱ្យមានហេតុផលច្បាស់លាស់ទាន់ពេលវេលាចំពោះការរឹតត្បិតលើការជួបប្រជុំ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | កម្ពុជាខកខានក្នុងការបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី[120] ច្បាប់ស្តីពីការងារ[121] និងច្បាប់ស្តីពីការបោះឆ្នោតបង្ហាញពីនីតិវិធីនៃការជូនដំណឹងមុនសម្រាប់ការជួបប្រជុំ[122] ដែលស្របតាមច្បាប់អន្តរជាតិអំពីនីតិវិធីនៃការជូនដំណឹងមុន។ ទោះជាបែបនេះក្តីការអនុវត្តល្អជាអន្តរជាតិបានផ្តល់អនុសាសន៍ អំពីការជូនដំណឹងមុនចំពោះការជួបប្រជុំដែលមានចំនួនអ្នកចូលរួមច្រើន ឬការជួបប្រជុំដែលអ្នករៀបចំរំពឹងថាមានការរំខានតែប៉ុណ្ណោះ[123]។ ខណៈដែលច្បាប់ជាតិមិនបានអនុវត្តការអនុញ្ញាតជាមុន ការពិតដែលថាការជួបប្រជុំដោយសន្តិវិធី អាចត្រូវបានបញ្ឈប់ដោយអាជ្ញាធរ ប្រសិនបើមានការជូនដំណឹងត្រឹមត្រូវមិនបានដាក់ស្នើ មិនស្របតាមច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ[124]។ ច្បាប់ស្តីពីការបោះឆ្នោតរឹតត្បិតមកលើការជួបប្រជុំដោយមិនសមាមាត្រ ដូចជាតម្រូវឱ្យជូនដំណឹងមុនដែលនេះមិនមែនជាការតម្រូវផ្លូវការដែលទាមទារឱ្យមានការជូនដំណឹងគ្រប់ការជួបប្រជុំ ដូចជាការជួបប្រជុំដែលមានអ្នកចូលរួមតិចតួចដោយមិនមានការវិនិច្ឆ័យត្រឹមត្រូវ[125]។ ទោះជាបែបនេះក្តីច្បាប់ស្តីពីគណបក្សនយោបាយទាមទារឱ្យបង្ហាញអត្តសញ្ញាណអ្នកដឹកនាំចំនួន៣នាក់បាតុកម្មដោយសន្តិវិធីក៏តម្រូវឱ្យមានព័ត៌មានលំអិត នៃអត្តសញ្ញាណរបស់ថ្នាក់ដឹកនាំទាំងបីដែលជាតម្រូវការមួយដែលហាក់ដូចជាមិនសមាមាត្រនិងមិនចាំបាច់[126]។ នេះដូចមិនច្បាស់ថាហេតុអ្វីបានជាព័ត៌មានលម្អិតអំពីបុគ្គលចំនួន ៣ នាក់ចាំបាច់ត្រូវទាមទារ សម្រាប់ការជួបប្រជុំតូចៗ អាចមិនពាក់ព័ន្ធឬជាបន្ទុក ដូច្នេះវាជាឧបសគ្គដល់សេរីភាពខាងការជួបប្រជុំ។ លើសពីនេះទៀត ច្បាប់តម្រូវឱ្យមានការជូនដំណឹងជាមុនត្រូវធ្វើយ៉ាងហោចណាស់ប្រាំថ្ងៃនៃថ្ងៃធ្វើការមុនពេលព្រឹត្តិការណ៍កើតឡើង[127]។ ការកំណត់រយៈពេលបែបនេះគឺជាសកម្មភាពនៃការរឹតត្បិតសេរីភាពខាងការជួបប្រជុំដែលរារាំងអ្នករៀបចំក្នុងការទទួលបានការឆ្លើយតបមកលើព្រឹត្តិការណ៍ដែលពួកគេបានរៀបចំ។ ខណៈដែលច្បាប់ជាតិក្រោមសូចនាករនេះមិនមានការផ្លាស់ប្តូរឡើយនៅក្នុងឆ្នាំទី៥ នេះ ហើយពិន្ទុបានផ្តល់ឱ្យនៅក្នុងកម្រិតពិន្ទុទាប ៣ ការវាយតម្លៃឡើងវិញនូវច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធីនិងការឆ្លើយតបតាមបទដ្ឋានអន្តរជាតិ។ |
| ១.២០<br>ការហាមឃាត់ការប្រមូលផ្តុំត្រូវបានកំណត់ថាជាវិធានការចុងក្រោយចាំបាច់ និងសមាមាត្រទៅនឹងគោលបំណង | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលហាមឃាត់ក្នុងលក្ខខណ្ឌដែលបានកំណត់ថាជាជម្រើសចុងក្រោយសមាមាត្រទៅនឹងគោលបំណង | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | កម្ពុជាពុំបានគោរពចំណុចនេះឱ្យបានពេញលេញ។ មាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងនូវលក្ខខណ្ឌចំនួនពីរដែលការជូនដំណឹងពីការប្រមូលផ្តុំអាចត្រូវបានបដិសេធដែលលក្ខខណ្ឌទាំងពីរនោះមានខ្លឹមសារស្រពិចស្រពិល[128]។ សៀវភៅណែនាំការអនុវត្តច្បាប់ស្តីពី ការធ្វើបាតុកម្មដោយសន្តិវិធីកំណត់ពីស្តង់ដារ អនុវត្តលើប្រភេទព័ត៌មានដែលអាចនាំទៅរកការហាមប្រាម ហើយបើមានសំណើរដែលមិនស្ថិតក្នុងការហាមប្រាមត្រូវពិភាក្សាជាមុន[129]។ នៅក្នុងផ្នែកទាក់ទងនឹងការណែនាំការអនុវត្តនេះក៏គូសបញ្ជាក់ផងដែរថា ប្រសិនបើអាជ្ញាធរជឿថាមានព័ត៌មានដូចបានបញ្ជាក់ក្នុងមាត្រា៩ (២) អាជ្ញាធរត្រូវ “ពិចារណា និងវាយតម្លៃលើព័ត៌មាននោះដើម្បីកំណត់ថាតើព័ត៌មាននោះមានភ័ស្តុដែរឬយ៉ាងណា” ហើយអាជ្ញាធរត្រូវជូនដំណឹងនិងផ្តល់កិច្ចសហប្រតិបត្តិការតាមការបង្កើត “ដំណោះស្រាយដែលលុបបំបាត់គ្រោះថ្នាក់ដែលអាចកើតឡើង ធ្វើយ៉ាងណាឱ្យបាតុកម្មនោះអាចដំណើរការទៅបាន”[130]។ ផ្ទុយទៅវិញ ប្រសិនបើមានការអនុវត្តតាមមាត្រា៩ (២) នេះក៏ពុំមានបទប្បញ្ញត្តិដើម្បីអាចឱ្យអាជ្ញាធរឆ្លើយតបវិញឡើយ។ ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នផ្តល់អំណាចដ៏ធំក្នុងការហាមឃាត់ការជួបប្រជុំក្នុងពេលដែលប្រទេសជួបភាពសន្ទផ្ទុយពីច្បាប់អន្តរជាតិ។ ច្បាប់នេះមិនបានពិចារណាទៅលើពីភាពចាំបាច់ឬសមាមាត្រ ដែលអាចឱ្យអាជ្ញាធរមានសិទ្ធិហាមឃាត់មិនឱ្យមានការជួបប្រជុំ នៅពេលដែលការជួបប្រជុំមិនមែនជាវិធានការចុងក្រោយឬរឹតត្បិតតិចតួចបំផុត។ មាត្រា៤ នៃច្បាប់ស្តីពីកូវីដ-១៩ អនុញ្ញាតឱ្យរដ្ឋាភិបាលមានអំណាចក្នុងការហាមឃាត់បណ្តោះអាសន្ន “ការប្រជុំ |

[118] ទន្ទឹមនេះ ច្បាប់ការងារចែងក្នុងមាត្រា៣២០ ថា សិទ្ធិធ្វើកូដកម្ម ត្រូវបាន "ធានា" សិទ្ធិនេះក៏ត្រូវបានអនុវត្តដែរ នៅពេលដែលសហជីពជាតំណាងកម្មករនិយោជិតយល់ឃើញថាត្រូវយកសិទ្ធិនេះ មកប្រើដើម្បីបង្ខំឱ្យមានការគោរពតាមអនុសញ្ញារួម ឬតាមច្បាប់។ ជាពិសេស សិទ្ធិធ្វើកូដកម្មអាចអនុវត្តទៅបាន លុះត្រាតែបានប្រើប្រាស់អស់លទ្ធភាពក្នុងការដោះស្រាយជម្លោះដោយមធ្យោបាយសន្តិវិធីជាមួយនិយោជក។

[119] មាត្រា ១៥ នៃច្បាប់ពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន (២០២០)។

[120] មាត្រា៦,៧,១០,១៤,២០ និង២៨ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[121] មាត្រា៣២៤ និង៣២៧ នៃច្បាប់ស្តីពីសហជីព។

[122] មាត្រា៧៨, ៧៩ និង៨១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា។ មាត្រា៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់។

[123] OSCE-ODIHR and Venice Commission, 'គោលការណ៍ណែនាំអំពីសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី', (បោះពុម្ពលើកទី២ ២០១០), កថាខណ្ឌ១១៥។ <https://www.osce.org/odihr/73405?download=true> គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍លើកទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai' (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣) UN Doc A/HRC/23/39 កថាខណ្ឌ៥២។

[124] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍លើកទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai' (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២) UN Doc A/HRC/20/27, កថាខណ្ឌ២៩ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf> ។

[125] មាត្រា៦,៧,១០,១៤,២០ និង២៨ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[126] មាត្រា៦ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[127] មាត្រា៧ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[128] មាត្រា ៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចែងថាអាជ្ញាធរដែនដីរាជធានី ឬខេត្ត មានសមត្ថកិច្ចត្រូវឆ្លើយតបជាវិជ្ជមាន ចំពោះលិខិតជូនដំណឹងនោះជាលាយលក្ខណ៍អក្សរ លើកលែងតែ៖ ១) ការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវចំលើថ្ងៃប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក ពិធីបុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ ២) មានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

[129] ផ្នែក៣ មាត្រា ២ មាត្រា៤ មាត្រា៧ នៃសៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[130] ផ្នែក៣ មាត្រា ២ មាត្រា៤ មាត្រា៧ នៃសៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

| | | | | |
|---|---|---|---|---|
| | | | | និងការប្រមូលផ្តុំមនុស្ស ដែលសកម្មភាពនោះនាំឱ្យមានការរីករាលដាលជំងឺកូវីដ-១៩”។ កង្វះខាតនៃការពន្យល់អំពីមូលហេតុដែលហាមឃាត់ការជួបប្រជុំ ដែលអាចបណ្តាលឱ្យមានការរីករាលដាលជំងឺកូវីដ-១៩ គួបផ្សំនឹងអំណាចដែលផ្តល់ឱ្យអាជ្ញាធរក្នុងការហាមឃាត់ការជួបប្រជុំ។ ទោះបីជាវិធានការកាត់បន្ថយការរីករាលដាល ក៏បង្កើតជាលក្ខខណ្ឌហាមឃាត់ការប្រមូលផ្តុំ។[131] បន្ថែមពីនេះ ការហាមឃាត់ព្រះសង្ឃក្នុងការចូលរួមការជួបប្រជុំតាមរយៈសង្ឃប្រកាស គឺមិនសមាមាត្រនិងមិនស្របតាមគោលបំណងស្របច្បាប់នោះទេ។ នេះបង្ហាញថាបទបញ្ញាតិទាំង២នេះ ទទួលបានពិន្ទុមកត្រឹមតែ ២ ប៉ុណ្ណោះ ។ |
| ១.២១<br>ការរឹតត្បិតតម្រូវឱ្យមានហេតុផលច្បាស់លាស់និងទាន់ពេលវេលា | កម្រិតនៃ ក្របខ័ណ្ឌច្បាប់តម្រូវឱ្យមាន ហេតុផលច្បាស់លាស់ទាន់ពេលវេលា ចំពោះការរឹតត្បិតលើការជួបប្រជុំ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ២,៥ | កម្ពុជាបានបំពេញតាមចំណុចនេះបានខ្លះ។ ក្របខ័ណ្ឌច្បាប់ដែលមានស្រាប់តម្រូវឱ្យមានការឆ្លើយតបពីអាជ្ញាធរមកលើការជូនដំណឹងអំពីការជួបប្រជុំ។ ការឆ្លើយតបចាំបាច់ត្រូវប្រាប់ពីមូលហេតុដែលអាជ្ញាធររឹតត្បិត ទោះជាបែបនេះក្តីក៏នៅតែមិនមានចែងជាក់លាក់នោះទេ។ ច្បាប់ជាតិបានសន្មត់ថាបានផ្តល់សិទ្ធិប្រសិនបើមិនទទួលបានការឆ្លើយតបពីការជូនដំណឹងនោះទេ[132]។ នៅក្នុងមាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរដែនដីរាជធានី ឬខេត្ត មានសមត្ថកិច្ចត្រូវតែឆ្លើយតបនូវលិខិត ជូនដំណឹងយ៉ាងយូរត្រឹម៣ថ្ងៃនៃការងារដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានដាក់ជូន។ ប្រសិនបើអាជ្ញាធរដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចខកខានក្នុងការឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុ កម្មដោយសន្តិវិធី “មានន័យថាអាជ្ញាធ ដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចបានព្រមព្រៀងហើយ”[133]។ លើសពីនេះទៀត ក្នុងករណីដែលចែងនៅក្នុងមាត្រា៩ (២) ប្រសិនបើមិនមានការព្រមពៀងគ្នា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងជាបុគ្គលម្នាក់គត់ដែលជាអ្នកធ្វើសេចក្តីសម្រេចចុងក្រោយ ជាលាយលក្ខណ៍អក្សរនិងយ៉ាងយូរបំផុតម្ភៃបួន (២៤) ម៉ោងមុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី[134]។ សេចក្តីសម្រេចនេះមិនបានអនុញ្ញាតឱ្យមានការតវ៉ា នៅមុខតុលាការមិនលំអៀងដូចមានចែងក្នុងច្បាប់អន្តរជាតិនោះទេ[135]។ ច្បាប់គ្រប់ គ្រងប្រទេសក្នុងភាពអាសន្នខកខានក្នុងការរាប់បញ្ចូលការទទួលខុសត្រូវ ឬតម្លាភាពរបស់អាជ្ញាធរដែលកំណត់ថាតើត្រូវដាក់កម្រិតលើការជួបប្រជុំគ្នាទេច្បាប់មិនតម្រូវឱ្យអាជ្ញាធរផ្តល់ហេតុផលណាមួយ ឡើយ។ មិនខុសពីការពន្យល់ខាងលើ ច្បាប់កូវីដ-១៩ បានអនុញ្ញាតឱ្យអាជ្ញាធររឹត្បិត “ការប្រជុំ និងការប្រមូលផ្តុំមនុស្សដែលនាំឱ្យមានរីករាលដាលជំងឺកូវីដ-១៩”។ កង្វះខាតនៃការពន្យល់អំពីមូលហេតុដែលហាមឃាត់ការជួបប្រជុំ ដែលអាចបណ្តាលឱ្យមានការរីករាលដាលជំងឺកូវីដ-១៩ ប៉ុន្តែមិនបានផ្តល់មូលហេតុគ្រប់គ្រាន់ពីក្រោយការហាមឃាត់ដោយអាជ្ញាធរនោះទេ។[136]ពិន្ទុនេះត្រូវបានបន្ថយត្រឹម២ពិន្ទុ។ |
| ១.២២<br>ការរឹតត្បិតលើពេលវេលា និង ទីកន្លែងមិនមែនជាកាតព្វកិច្ចនោះទេ | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលរឹតត្បិតមក លើពេលវេលា និង/ឬទីកន្លែង ត្រូវបាន ចែងនៅក្នុងក្របខ័ណ្ឌច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ២,៥ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ មាត្រា៩(១) នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបង្ហាញពីការហាមឃាត់ ទៅលើការធ្វើបាតុកម្មដោយសន្តិវិធីនៅថ្ងៃបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក បុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ ការហាមឃាត់ទាំងអស់នេះមិនមាននៅក្នុងគោលបំណងណាមួយដែលមាននៅក្នុងមាត្រា២១ ក.អ.ស.ព.ន ប៉ុន្តែនៅតែអាចធ្វើ បាន។ ករណីខ្លះទៀត ការហាមឃាត់ទៅលើការធ្វើបាតុកម្មដោយសន្តិវិធីទាំងអស់នៃថ្ងៃទាំងនោះ មិនបំពេញតាមតម្រូវការចាំបាច់និងសមាមាត្រនៃផ្នែកទី៣ នៃលក្ខខ័ណ្ឌទាំងបីចំណុច វាអាចមានការជំទាស់គំនិតគ្នាក្នុងការពិចារណាអំពីកាលៈទេសៈជាក់លាក់នៃការប្រមូលផ្តុំនីមួយៗហើយដូច្នេះនឹងមានវិសមភាពនិងការរើសអើង (វាប៉ះពាល់ដល់ពលរដ្ឋដែលមានបំណងអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំ)[137]។ អំណាចក្នុងការរឹតត្បិតនិងហាមឃាត់ការជួបប្រជុំទាំងអស់នេះដែលមានចែងក្នុងមាត្រា៥ (២) នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន អាចដំណើរការជារបាំង ក្នុងការហាមឃាត់ការជួបប្រជុំទាំងអស់ក្នុងពេលមានអាសន្ន។ ពាក្យពេចន៍នៃច្បាប់នេះមាន លក្ខណៈទូលំទូលាយនិង ត្រូវបានគេមើលឃើញថារាល់ការជួបប្រជុំមួយចំនួន ឬទាំងអស់អាចត្រូវបានហាមឃាត់ដោយសេរីនៅក្នុងមាត្រា៥ (២)។ ស្រដៀងគ្នានេះ មាត្រា៤ នៃច្បាប់កូវីដ-១៩ ផ្តល់ឱ្យអាជ្ញាធរនូវ “អំណាចបណ្តោះអាសន្ន” ក្នុងការហាមឃាត់ការជួបប្រជុំដែលអាចបណ្តាលឱ្យមានការរីករាលដាលកូវីដ-១៩ ហាក់ដូចជាអនុញ្ញាតឱ្យមានការហាមឃាត់ដាច់ខាត ប៉ុន្តែមិនបានកំណត់ជាក់លាក់អំពីពេលណាដែលការហាមឃាត់នេះនឹងត្រូវបញ្ចប់នោះទេ។ ហើយនេះ អាជ្ញាធរអាចហាមឃាត់ការជួបប្រជុំគ្នាដោយប្រើរយៈពេលយូរតាមទំនើងចិត្ត។[138] ពិន្ទុនេះត្រូវបានធ្លាក់មកត្រឹម ២,៥ ។ កង្វះលក្ខណៈវិនិច្ឆ័យច្បាស់លាស់នេះបង្កើតហានិភ័យនៃការរឹតត្បិតតាមអំពើចិត្ត និងមានសក្តានុពលលើសលប់លើសិទ្ធិជាមូលដ្ឋាននេះ។ ភាពមិនស៊ីសង្វាក់គ្នាដ៏សំខាន់ទាំងនេះជាមួយនឹងស្តង់ដារអន្តរជាតិ និងការអនុវត្តល្អបំផុតទាក់ទងនឹងបទប្បញ្ញត្តិនៃការជួបប្រជុំក្នុងកំឡុងពេលជាក់លាក់ ឬព្រឹត្តិការណ៍នានាបង្ហាញការដាក់ទាបគឺ ២៥ សម្រាប់.ចំណុចនេះ។ |
| ១.២៣<br>ការជួបប្រជុំស្របពេលគ្នានៅទីតាំងនិងពេលវេលាតែមួយត្រូវបានអនុញ្ញាត | កម្រិតនៃ ក្របខ័ណ្ឌច្បាប់ដែល អនុញ្ញាតឱ្យមានការជួបប្រជុំ ស្របពេលគ្នា | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ គ្មានច្បាប់ការហាមឃាត់ទៅលើការជួបប្រជុំដែលបានធ្វើក្នុងពេលជាមួយគ្នានោះទេ។ មាត្រា១៤ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបានចែងថា ការធ្វើបាតុកម្មដោយសន្តិវិធីមានពីរក្រុមផ្សេងគ្នាហើយធ្វើនៅកន្លែងតែមួយនិងពេលវេលាតែមួយ អាជ្ញាធរដែនដីរាជធានីឬខេត្ត មានសមត្ថកិច្ចត្រូវសម្រេចឱ្យក្រុមអ្នកដែលបានដាក់សេចក្តីជូនដំណឹងមុនទទួលបានសិទ្ធិធ្វើមុន ឬអាចអនុញ្ញាតឱ្យធ្វើនៅកន្លែងមួយផ្សេងទៀតដែលមានចម្ងាយយ៉ាងតិចប្រាំរយ (៥០០) ម៉ែត្រពីគ្នា។ ការផ្តល់ជូននេះគឺជាផ្នែកមួយនៃមាត្រា១៤ ដែលទាក់ទងនឹងករណីបាតុកម្មជាក់ស្តែងនៅ “កន្លែងមញ្ចេញមតិជាសាធារណៈ” ឬនៅកន្លែងឯកជន។ ប៉ុន្តែ នៅក្នុងផ្នែកទី២ នៃមាត្រា២.៤.៥ នៃការណែនាំការអនុវត្តបានបង្ហាញច្បាស់លាស់ថាអាជ្ញាធរគួរតែ “ប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងដ៏ល្អបំផុតរបស់ពួកគេ” ដើម្បីធានាថាក្រុមដែលចង់ធ្វើបាតុកម្មទាំងអស់អាចធ្វើបាតុកម្មបាន "ក្នុងកម្រិតដែលអាចធ្វើទៅបាន" ដែលពួកគេអាចធ្វើដូច្នោះក្នុងលក្ខណៈ ពេលវេលា និងទីតាំងដែលពួកគេបានស្នើសុំ។ |

[131] សូមមើលចំណុចគន្លឹះទី១។

[132] សូមមើលមាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[133] មាត្រា១០ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[134] មាត្រា១២ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[135] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១) , កថាខណ្ឌ ៤២ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

[136] មាត្រា១២ នៃច្បាប់ស្តីកូវីដ-១៩។

[137] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍រួមគ្នារបស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម និងការដោះស្រាយក្រៅប្រព័ន្ធច្បាប់ដោយ សង្ខេប ឬតាមទំនើងចិត្តដើម្បីគ្រប់គ្រងការប្រមូលផ្តុំ, ( ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦( , UN Doc. A/HRC/៣១/៦៦ កថាខណ្ឌ៣០។ សូមអានគណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ, 'របាយការណ៍ជុំទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai,' UN Doc. A/HRC/២៣/៣៩, ( ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣, កថាខណ្ឌ៦៣ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session23/A.HRC.23.39_EN.pdf>

[138] សូមមើលចំណុចគន្លឹះទី១។

| | | | | |
|---|---|---|---|---|
| ១.២៤<br><br>នីតិវិធីប្ដឹងជំទាស់ មុនពេលមាន ស្ថាប័នឯករាជ្យ និងមិនលម្អៀងត្រូវបានបង្កើតឡើងសម្រាប់ការដាក់កំហិតលើការប្រមូលផ្ដុំ | កម្រិតនៃនីតិវិធីដែលវែងឆ្ងាយពេក កំណត់នៅក្នុងក្របខណ្ឌច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២,៥ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ នៅក្នុងច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរដែនដីរាជធានីឬខេត្តមានសមត្ថកិច្ចត្រូវតែឆ្លើយតបទៅនឹងលិខិតជូនដំណឹងយ៉ាងយូរត្រឹមបី (៣)ថ្ងៃនៃថ្ងៃការងារដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានគេដាក់ជូន[139]។<br>អាជ្ញាធរដែនដីរាជធានីឬខេត្តមានសមត្ថកិច្ចខកខានក្នុងការឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី "មានន័យថាអាជ្ញាធរដែនដីរាជធានីឬខេត្តមានសមត្ថកិច្ចបានព្រមព្រៀងហើយ"[140]។ បើកន្លែងណាមានព័ត៌មានច្បាស់ថាការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ។ អាជ្ញាធរ ដែនដីរាជធានីឬខេត្តត្រូវតែជូនដំណឹងទៅអ្នករៀបចំកម្មវិធី"ភ្លាមៗ" ហើយមានរយៈពេលបីថ្ងៃដើម្បីជួបជាមួយអ្នកដឹកនាំបាតុកម្មដើម្បីឈានទៅរកកិច្ចព្រមព្រៀងមួយ។ បើសិនមិនមានការព្រមព្រៀងគ្នានោះទេ មានត្រា១២ បានចែងថារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងជាបុគ្គលម្នាក់ដែលជាអ្នកសម្រេចចុងក្រោយជាលាយលក្ខណ៍អក្សរនិងយ៉ាងយូរបំផុតម្ភៃបួនម៉ោង (២៤) មុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនអាចត្រូវបានចាត់ទុកថាជា "ស្ថាប័នឯករាជ្យ និងមិនលំអៀងឡើយ"។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គឺជាសមាជិកនៃអង្គនីតិប្រតិបត្តិមិនមែនជា "ស្ថាប័នឯករាជ្យ"។ មិនអាចប្ដឹងទៅស្ថាប័នតុលាការបន្ថែមទៀតបានទេ។ ដូច្នេះមិនមាននីតិវិធីបណ្ដឹងឧទ្ធរណ៍ស្រ័យឯករាជ្យឬមិនលំអៀងត្រូវបានកំណត់ដោយច្បាប់ទេ។ នៅលើការវាយតម្លៃឡើងវិញនៃចំណុចនេះពិន្ទុនេះត្រូវបានទម្លាក់មកត្រឹម ២,៥ ។ លើសពីនេះទៅទៀតច្បាប់ស្ដីពីកូវីដ-១៩ មិនមាននីតិវិធីបណ្ដឹងឧទ្ធរណ៍ស្រ័យណាមួយត្រូវបានផ្ដល់មកលើការដាក់កម្រិតការជួបប្រជុំទេ ចំណុចនេះមិនច្បាស់ថាតើនីតិវិធីបណ្ដឹងឧទ្ធរណ៍ស្រ័យធម្មតាក្រោមច្បាប់បាតុកម្មដោយសន្តិវិធីឬយ៉ាងណា[141]។ |
| ១.២៥<br><br>អ្នករៀបចំមិនប្រឈមនឹងទោសព្រហ្មទណ្ឌ ឬទណ្ឌកម្ម រដ្ឋបាលការខកខានមិនបានជូនដំណឹងដល់អាជ្ញាធរ | កម្រិតនៃ ក្របខណ្ឌច្បាប់ដែលកំណត់អំពីការដាក់ទោសព្រហ្មទណ្ឌនិង/ឬ រដ្ឋបាលចំពោះអ្នករៀបចំដែលខកខានមិនបានជូនដំណឹងអាជ្ញាធរ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី ផ្ដល់នូវការព្រមានដល់អ្នករៀបចំបាតុកម្មដែលមិនផ្ដល់នូវការជូនដំណឹង[142]។ ច្បាប់ស្ដីពីសហជីពនិងច្បាប់ស្ដីពីការងារបានចែងថាការធ្វើកូដកម្មដែលមិនស្របតាមបទប្បញ្ញត្តិរបស់ខ្លួនរួមទាំងតម្រូវឱ្យជូនដំណឹងជាមុនត្រូវចាត់ទុកថាខុសច្បាប់[143]។ ប៉ុន្តែមានតែស្ថាប័នតុលាការតែមួយគត់អាចកំណត់ពីភាពស្របច្បាប់និងមិនស្របច្បាប់នៃការធ្វើកូដកម្ម[144]។ យ៉ាងណាក៏ដោយ ច្បាប់ស្ដីពីសហជីពចែងថា ប្រសិនបើអ្នកធ្វើកូដកម្មបន្តធ្វើកូដកម្ម ត្រូវបានតុលាការការងារប្រកាសថាខុសច្បាប់និងមិនបានអនុវត្តតាមការព្រមាន ពួកគេនឹងត្រូវទទួលរងការផាកពិន័យជាអន្តរការណ៍ ជាទឹកប្រាក់មិនលើសពី៥លានរៀល (ប្រមាណ ១២០០ ដុល្លាសហរដ្ឋអាមេរិក)[145]។ នៅពេលដែលការពិន័យគឺជាជម្រើសចុងក្រោយទៅតាមការព្រមានពីបើ ដងចំនួនការផាកពិន័យបង្កើតឱ្យមានការដាក់កំហិតដោយមិនសមហេតុផលទៅលើសិទ្ធិសេរីភាពកម្មករ ក្នុងការប្រើប្រាស់សេរីភាពខាងសមាគម។ ដូច្នេះ ទោះបីជាច្បាប់ជាតិផ្ដល់ការការពារមួយចំនួនប្រឆាំងនឹងការពិន័យលើសកម្រិតក៏ដោយ ការដាក់ទណ្ឌកម្មដ៏ច្រើនសន្ធឹកសន្ធាប់ចំពោះការមិនគោរពតាមលក្ខខណ្ឌនៃការជូនដំណឹងសម្រាប់កូដកម្ម បង្កើតការរឹតត្បិតមិនសមាមាត្រលើសិទ្ធិសេរីភាពខាងការបង្កើតសមាគមរបស់កម្មករ ដោយត្រូវការការត្រួតពិនិត្យ និងការកែសម្រួលលក្ខខណ្ឌទាំងនេះ ដើម្បីធានាបាននូវដំណើរការប្រកបដោយសមតុល្យ និងសមាមាត្រ។ |
| ១.២៦<br><br>នគរបាលមានកាតព្វកិច្ចសម្របសម្រួលដល់ការជួបប្រជុំដោយសន្តិវិធី | កម្រិតនៃអនុវត្តច្បាប់និងគោលនយោបាយ គាំទ្រដល់ ការជួបប្រជុំដោយសន្តិវិធី | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថា អាជ្ញាធរដែនដីរាជធានីឬខេត្ត មានសមត្ថកិច្ចត្រូវតែទទួលខុសត្រូវក្នុងការការពារនៅបាតុកម្មដោយសន្តិវិធី និងមិនជ្រៀតជ្រែកនៅការធ្វើបាតុកម្មដោយសន្តិវិធីនេះ[146]។<br><br>ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងអំពីការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចទាក់ទងនឹងការជួបប្រជុំដោយសន្តិវិធី។ ដែលណត់ឱ្យ៖<br><br>• ការពារបាតុកម្មដោយសន្តិវិធី<br><br>• បដិសេធពីការជ្រៀតជ្រែកក្នុងការធ្វើបាតុកម្មដោយសន្តិវិធី<br><br>•ឆ្លើយតបទៅនឹងសំណើសុំជំនួយពីអ្នករៀបចំ ដោយធានានូវសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបញ្ចេញមតិជាសាធារណៈ<br><br>លើសពីនេះ គោលការណ៍ណែនាំសម្រាប់ការអនុវត្តច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធីផ្ដល់នូវភាពច្បាស់លាស់បន្ថែម ដោយសង្កត់ធ្ងន់ថា៖<br><br>• ការបំបែកការជួបប្រជុំគ្នាត្រូវបានអនុញ្ញាតតែជាមធ្យោបាយចុងក្រោយ នៅពេលដែលមិនមានជម្រើសផ្សេងទៀត។<br><br>អាជ្ញាធរមានសមត្ថកិច្ចឆ្លើយតបទៅនឹងសំណើសម្រាប់ជំនួយដល់អ្នករៀបចំបាតុកម្មដើម្បីធានាថា "សិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធីនិងការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈរបស់ពួកគេដោយមានសេចក្ដីថ្លៃថ្នូរ"[147]។ ក្នុងករណីមានអំពើ |

[139] មាត្រា១២ នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[140] មាត្រា១០ នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[141] មាត្រា៥(២) នៃច្បាប់ស្ដីពីគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។ មាត្រា ៤ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

[142] មាត្រា២១ នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី, សូមមើលផ្នែកទី៣ មាត្រា៤-៤-១ នៃសេចក្ដីណែនាំឱ្យអនុវត្ត។

[143] មាត្រា៩២ នៃច្បាប់ស្ដីពីសហជីព។

[144] មាត្រា៣៣៧ នៃច្បាប់ស្ដីពីការងារ។

[145] មាត្រា៩២ នៃច្បាប់ស្ដីពីសហជីព។

[146] មាត្រា១៧ នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[147] មាត្រា១៨ នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី។

| | | | | |
|---|---|---|---|---|
| | | | | ហឹង្សា សេចក្តីណែនាំឱ្យមានការអនុវត្តចែងយ៉ាងច្បាស់ថាបាតុកម្មអាចត្រូវបានបំបែកនៅពេលដែលគ្មានជម្រើសផ្សេងទៀត[148] បន្ថែមទៀតថារាល់សកម្មភាពរបស់នគរបាលត្រូវតែមានសមាមាត្រទៅនឹងស្ថានភាព ហើយត្រូវបានប្រើក្នុងករណីចាំបាច់[149]។ |
| ១.២៧<br>អ្នករៀបចំ ការប្រមូលផ្តុំមិនទទួលខុសត្រូវលើបន្ទុកហិរញ្ញវត្ថុសម្រាប់ការផ្តល់សេវាសាធារណៈ | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលការពារអ្នករៀបចំ មិនឱ្យទទួលខុសត្រូវលើផ្នែកហិរញ្ញវត្ថុចំពោះការផ្តល់សេវាសាធារណៈ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៥ | ប្រទេសកម្ពុជាបង្ហាញពីការអនុលោមតាមជាតុនេះទាក់ទងនឹងអវត្តមាននៃក្របខ័ណ្ឌច្បាប់នៃបទប្បញ្ញត្តិដែលកំណត់អ្នករៀបចំការជួបប្រជុំទទួលខុសត្រូវចំពោះថ្លៃសេវាសាធារណៈក្នុងអំឡុងពេលជួបប្រជុំ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី មិនរួមបញ្ចូលបទប្បញ្ញត្តិណាមួយដែលតម្រូវឱ្យអ្នករៀបចំការជួបប្រជុំទទួលបន្ទុកផ្នែកហិរញ្ញវត្ថុសម្រាប់សេវាសាធារណៈដែលបានផ្តល់ក្នុងអំឡុងពេលព្រឹត្តិការណ៍នោះទេ។ ដោយចំណុចនេះស្របតាមការអនុវត្តល្អបំផុតអន្តរជាតិ ដែលទទួលស្គាល់សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងជៀសវាងការដាក់បន្ទុកហិរញ្ញវត្ថុមិនសមរម្យលើអ្នករៀបចំ។ ដូច្នេះ ក្របខណ្ឌច្បាប់របស់កម្ពុជាធានានូវចំណុចនេះ ដោយមិនដាក់បន្ទុកផ្នែកហិរញ្ញវត្ថុលើអ្នករៀបចំការជួបប្រជុំ ដោយធានាថាការអនុវត្តសិទ្ធិជាមូលដ្ឋាននេះដោយគ្មានឧបសគ្គដែលមិនចាំបាច់។ |
| ១.២៨<br>អ្នករៀបចំការប្រមូលផ្តុំ និងអ្នកចូលរួមមិនទទួលខុសត្រូវចំពោះ ទង្វើខុសច្បាប់របស់អ្នកដទៃ ឬចំពោះការថែរក្សាសណ្តាប់ធ្នាប់សាធារណៈឡើយ | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលអ្នករៀបចំ និងអ្នកចូលរួមមិនទទួលខុសត្រូវស្របច្បាប់ចំពោះទង្វើខុសច្បាប់របស់អ្នកដទៃនិង/ឬ ចំពោះការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៤ | កម្ពុជាបានបំពេញតាមចំណុចនេះ។ អ្នករៀបចំការជួបជុំមិនត្រូវមានទំនួលខុសត្រូវចំពោះការខូចខាតទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍មួយដែលបានប្រែជាអំពើហិង្សានោះឡើយ។ ក្នុងករណីមានការប្រជុំដោយសន្តិវិធីប្រែជាហិង្សាដូចដែលមានចែងក្នុងមាត្រា២០ (២) នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី អ្នករៀបបាតុកម្ម ត្រូវទទួលការព្រមានជាលាយ លក្ខណ៍អក្សរ។ មាត្រា ២៣ ដល់ ២៧ ចែងទាក់ទងនឹងការកាន់អាវុធ ឬសារធាតុគ្រោះថ្នាក់ ការខូចខាតទ្រព្យសម្បត្តិឯកជនឬសាធារណៈអំពើហិង្សាដែល បណ្តាលឱ្យមានរបួសឬស្លាប់។ ក្នុងករណីទាំងអស់នេះច្បាប់ចែងយ៉ាងច្បាស់ថា បុគ្គលដែលជាអ្នកធ្វើសកម្មភាពនោះជាអ្នកត្រូវទទួលខុសត្រូវ។ នេះមិនអាចចាត់ទុកថាជាការទទួលខុសត្រូវរបស់អ្នករៀបចំនិងអ្នកចូលរួមដ៏ទៃទៀតនោះទេ។ |
| ១.២៩<br>ការប្រើប្រាស់កម្លាំងរបស់រដ្ឋអាចធ្វើទៅបានលុះត្រាតែចាំបាច់ដើម្បីគ្រប់គ្រងស្ថានភាពក្នុងលក្ខណៈ សមហេតុផល និង សមាមាត្រ | កម្រិតនៃក្របខ័ណ្ឌច្បាប់កំណត់ពីការប្រើប្រាស់កម្លាំងរបស់រដ្ឋនៅក្នុងស្ថានភាពដែលចាំបាច់ដើម្បីគ្រប់គ្រងស្ថានភាពក្នុងលក្ខណៈសមហេតុផល និងសមាមាត្រ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៤ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ប្រសិនបើការជួបប្រជុំដោយសន្តិវិធីប្រែជាហិង្សាអាជ្ញាធរត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់និងបញ្ឈប់ការធ្វើបាតុកម្មភ្លាមៗ[150]។ មាត្រា ២៣-២៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបង្ហាញពីរបៀបដែលអាជ្ញាធរគួរតែឆ្លើយតបប្រសិនបើបាតុកម្មប្រែទៅជាអំពើហិង្សាឬបាតុករប្រព្រឹត្តិបទឧក្រិដ្ឋ។ ការឆ្លើយតបរួមមានការរឹបអូសយកអាវុធ ផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ។ ការអន្តរាគមន៍ណាមួយរបស់ប៉ូលីសត្រូវតែសមាមាត្រទៅនឹងស្ថានភាព ហើយត្រូវបានប្រើតែក្នុងកម្រិតចាំបាច់ដើម្បីស្តារសណ្តាប់ធ្នាប់ភ្លាមៗ[151]។ ហេតុដូច្នេះហើយ ខណៈពេលដែលកម្ពុជាបង្ហាញពីកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់ការគ្រប់គ្រងការជួបប្រជុំដោយហិង្សា ការខ្វះខាតភាពច្បាស់លាស់ទាក់ទងនឹង "វិធានការត្រឹមត្រូវ" និងអវត្តមាននៃការហាមឃាត់ច្បាស់លាស់លើការប្រើប្រាស់កម្លាំង ចាំបាច់ត្រូវតែមានការកែលម្អបន្ថែមទៀត ដើម្បីធានានូវភាពសមាមាត្រ និងការអនុលោមតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ |
| ១.៣០<br>ប្រព័ន្ធកត់ត្រាការប្រាស្រ័យទាក់ទងដើម្បីឃ្លាំមើល បញ្ហា អ្នកទទួលខុសត្រូវលើការបញ្ហា និងអ្នកអនុវត្តបញ្ហាជាកាតព្វកិច្ច | កម្រិតនៃ ប្រព័ន្ធកត់ត្រាការប្រាស្រ័យទាក់ទងត្រូវបានបង្កើតឡើងដោយក្របខ័ណ្ឌច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី មិនចែងពីប្រព័ន្ធកំណត់ត្រាការប្រាស្រ័យទាក់ទងនោះទេ តែមាត្រា ១៩ ចែងថា "អាជ្ញាធរ ដែលត្រូវបានចាត់ឱ្យរក្សាសន្តិសុខសុវត្ថិភាពនិងសណ្តាប់ធ្នាប់សាធារណៈនៅកន្លែងបាតុកម្មប្រជុំដោយសន្តិវិធី ត្រូវពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ ព្រមទាំងមានស្លាកឈ្មោះនិងអត្តលេខសម្គាល់ខ្លួននៅផ្នែកខាងមុខ ដែលលើកកម្ពស់គណនេយ្យភាពនិងសម្របសម្រួលការកំណត់អត្តសញ្ញាណអ្នកធ្វើខុស"។ ខណៈពេលដែលមាត្រា១៩ កំណត់ការកំណត់អត្តសញ្ញាណជាក់លាក់សម្រាប់បុគ្គលិកដើម្បីរក្សាសន្តិសុខក្នុងអំឡុងពេលជួបប្រជុំ គឺខ្វះនូវតម្រូវការជាក់លាក់សម្រាប់ប្រព័ន្ធកត់ត្រាទំនាក់ទំនងដ៏ទូលំទូលាយមួយ។ អវត្តមាននៃប្រព័ន្ធបែបនេះរារាំងតម្លាភាព និងគណនេយ្យភាព រវាងអាជ្ញាធរ និងអ្នករៀបចំការជួបប្រជុំ។ ការបង្កើត និងរក្សាប្រព័ន្ធកំណត់ត្រាទំនាក់ទំនងនឹងផ្តល់នូវឧបករណ៍សំខាន់មួយសម្រាប់សកម្មភាព ត្រួតពិនិត្យ ដោយការដោះស្រាយវិវាទដែលអាចកើតមាន និងធានាការប្រកាន់ខ្ជាប់នូវគោលការណ៍សិទ្ធិមនុស្សក្នុងអំឡុងពេលជួបប្រជុំ។ ដូច្នេះ ក្របខណ្ឌច្បាប់របស់កម្ពុជាបច្ចុប្បន្ននៅខ្វះការការពារជាចាំបាច់នៅក្នុងចំណុចនេះ ហើយវិធានការច្បាប់បន្ថែមទៀតគឺចាំបាច់ដើម្បីអនុវត្តប្រព័ន្ធកត់ត្រាទំនាក់ទំនងនិងលើកកម្ពស់ការអនុលោមតាមស្តង់ដារអន្តរជាតិ។ |
| ១.៣១<br>ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងកូដកម្មស្របតាមស្តង់ដារអន្តរជាតិ | កម្រិតក្របខ័ណ្ឌច្បាប់ទាក់ទងនឹងកូដកម្មស្របតាមស្តង់ដារអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | កម្ពុជាមិនបានបំពេញតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិសម្រាប់កូដកម្មនោះទេ។ រដ្ឋធម្មនុញ្ញចែងពីសិទ្ធិធ្វើបាតុកម្មនៅមាត្រា ៣៧ មាត្រា ៤១ និង ៤២ និងបន្តការពារសិទ្ធិជួបប្រជុំនិងសិទ្ធិចូលរួម "ក្នុងអង្គការមហាជន" ដែលទាំងពីរនេះការពារដល់សិទ្ធិធ្វើកូដកម្ម។ ទោះយ៉ាងណាជំពូកទី៣ នៃរដ្ឋធម្មនុញ្ញអនុវត្តតែចំពោះ "ប្រជាពលរដ្ឋខ្មែរ" ជំនួសឱ្យសិទ្ធិទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ប្រទេសកម្ពុជា។ ដូចនេះការការពារសិទ្ធិធ្វើកូដកម្មនៅក្នុងរដ្ឋធម្មនុញ្ញគឺមិនគ្រប់គ្រាន់ទេសម្រាប់ពលរដ្ឋដែលមិនមែនជាពលរដ្ឋរស់នៅក្នុងប្រទេសកម្ពុជាដូចជាជនចំណាកស្រុកនិងជនភៀសខ្លួនជាដើម។ សិទ្ធិធ្វើកូដកម្មក្នុងជំពូកទី១៣ នៃច្បាប់ស្តីពីការងារ[152] មាត្រា៣២០ បានចែងថាសិទ្ធិក្នុងការធ្វើកូដកម្ម "អាចអនុវត្តក្នុងលក្ខណៈទូទៅដើម្បីការពារផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គមរបស់កម្មករ"[153] ទោះយ៉ាងណាមាត្រា៣២៤ តម្រូវឱ្យ មានកូដកម្មជាច្រើនរួមទាំងការជូនដំណឹងជាមុន ៧ ថ្ងៃនៃថ្ងៃធ្វើការដល់សហគ្រាស ឬគ្រឹះស្ថានសមាគមនិយោជកដែលដូចគ្នានឹង |

[148] ផ្នែកទី២ នៃចំនុច ៣.៦.៤ នៃសៀវភៅណែនាំការអនុវត្ត។

[149] ផ្នែកទី២ នៃចំនុច ៣.៦.៥ នៃសៀវភៅណែនាំការអនុវត្ត។

[150] មាត្រា២០(២) ២៣ ដល់២៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី

[151] ចំនុច ៣.៦.៥ នៃសៀវភៅណែនាំការអនុវត្ត

[152] មាត្រា ៣១៩ នៃច្បាប់ស្តីពីការងារ។

[153] មាត្រា ៣២០ នៃច្បាប់ស្តីពីការងារ។

| | | | | |
|---|---|---|---|---|
| | | | | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការជូនដំណឹងមុនត្រូវបានបន្ថែមរហូតដល់១៥ថ្ងៃ នៃថ្ងៃធ្វើការតាមរយៈមាត្រា៣២៧ ក្នុងករណីដែលកូដកម្ម នោះប៉ះពាល់ដល់ផ្នែក សំខាន់ៗ។ ការជូនដំណឹងមុនត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវការទាមទារដែលជាមូលហេតុ នៃកូដកម្ម។ ខណៈពេលដែលនីតិវិធីនៃការជូនដំណឹងជាមុនមិនមានការរំលោភបំពានដោយផ្ទាល់ នៃស្តង់ដារអន្តរជាតិ រយៈពេលនៃការជូនដំណឹងមិនមែនជាហេតុផលសមរម្យនោះទេ[154]។គណៈកម្មាធិការខាងសេរីភាពខាងសមាគមបានកំណត់ថាការជូនដំណឹងជាមុន ៤៨ ម៉ោងគឺសមហេតុផលដូចជាការជូនដំណឹងជាមុន ២០ ថ្ងៃសម្រាប់សេវាកម្មផលប្រយោជន៍សាធារណៈ[155]។ ព័ត៌មានដែលបានស្នើសុំនៅក្នុងសេចក្តីជូនដំណឹងស្តីពីកូដកម្មគួរតែសមហេតុផលឬបកស្រាយក្នុងលក្ខណៈសមហេតុផលហើយការកាត់សេចក្តីជាលទ្ធផលមិនគួរត្រូវបានប្រើក្នុងលក្ខណៈដូចជាដើម្បីបង្ហាញសកម្មភាពសហជីពស្របច្បាប់ដែលស្ទើរតែមិនអាចធ្វើអ្វីបាននោះទេ[156]។ ដូច្នេះការជូនដំណឹងជាមុនដែលមានចែងក្នុងច្បាប់ស្តីពីការងារនឹងរំលោភលើស្តង់ដារអន្តរជាតិប្រសិនបើត្រូវអនុវត្តតាមទាំងបំពាន។ លើសពីនេះទៅទៀត នៅពេលដែលស្តង់ដារអន្តរជាតិអនុញ្ញាតឱ្យមានសិទ្ធិធ្វើកូដកម្ម ការកំណត់បែបនេះអាចទទួលយកបានលុះត្រាតែការពឹងផ្អែកលើអាជ្ញាកណ្តាលមិនមានកាតព្វកិច្ចហើយក្នុងករណីដែលការកំណត់នេះមិនអនុវត្តជាក់ស្តែងរារាំងការអំពាវនាវឱ្យធ្វើកូដកម្ម[157]។ មាត្រា ៣២០ នៃច្បាប់ស្តីពីការងារកម្រិតលើសិទ្ធិក្នុងការធ្វើកូដកម្មនៅស្ថានភាព ដែល “រាល់វិធីសាស្ត្រដោះស្រាយដោយសន្តិវិធី ប្រើប្រាស់ក្នុងការដោះស្រាយវិវាទជាមួយនិយោជក”។ បទប្បញ្ញត្តិនេះមិនអនុលោមតាមស្តង់ដារអន្តរជាតិដែលថាការចូលរួមក្នុងការដោះស្រាយវិវាទ គួរតែជាការស្ម័គ្រចិត្ត។ បទប្បញ្ញត្តិនេះមិនបានអនុលោមតាមតាមស្តង់ដារអន្តរជាតិ ដែលការចូលរួមក្នុងការដោះស្រាយវិវាទគួរតែជាការស្ម័គ្រចិត្ត។ លើសពីនេះទៀតដោយកំណត់សិទ្ធិធ្វើកូដកម្មទៅនឹងស្ថានភាពដែលវិធីសាស្ត្រទាំងអស់ត្រូវបានប្រើប្រាស់ ដោយសន្តិវិធីច្បាប់ការងារមិនអនុលោមតាមស្តង់ដារអន្តរជាតិនោះទេ។ វាបង្កើតការរឹតត្បិតទូលំទូលាយទៅវិញ[158]។ លើសពីនេះទៀតមាត្រា ១៣ នៃច្បាប់សហជីពបានចែងថាលក្ខន្តិកៈសហជីពទាំងអស់រួមមាន “លក្ខន្តិកៈដែលសន្លឹកឆ្នោតសំងាត់ត្រូវបានបោះឆ្នោតដោយយ៉ាងហោចណាស់៥០ភាគរយបូក១នៃសមាជិកសរុបដែលចូលរួមក្នុងការប្រជុំធ្វើសេចក្តីសម្រេចចិត្តធ្វើកូដកម្ម”។ ហើយនេះជាការរឹតត្បិតហួសហេតុ ដែលជាចំនួនកំណត់សិទ្ធិធ្វើកូដកម្មបានបន្ថយការការពារកូដកម្មនៅកម្ពុជា។ |
| ១.៣២<br><br>ការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិផ្អែកតាមលក្ខខណ្ឌ ៣ ចំណុចយោងតាមមាត្រា ១៩ នៃ ក.អ.ន.ព.ស | កម្រិតនៃ ច្បាប់ដែលប៉ះពាល់សេរីភាពខាងការ បញ្ចេញមតិ ផ្អែកតាមលក្ខខណ្ឌ ៣ ចំណុចពី មាត្រា ១៩ នៃ ក.អ.ស.ព.ន | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | ច្បាប់សំខាន់ៗរបស់កម្ពុជាបានរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិដែលមិនអនុលោមទៅតាមលក្ខខណ្ឌបីចំណុចនៃមាត្រា១៩ នៃកន.ព.ស.អ.។ ដូច្នេះកម្ពុជាពុំបានបំពេញសូចនាករមួយនេះឡើយ[159]។ ជាពិសេស ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការបរិហារកេរ្តិ៍ ការប្រមាថ ញុះញង់ និងកាលពីខែកុម្ភៈ ឆ្នាំ២០១៨ នៅបទល្មើសប្រមាថអង្គព្រះមហាក្សត្រ) ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ច្បាប់ស្តីពីទូរគមនាគមន៍ ច្បាប់ស្តីពីការអប់រំ ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីរបបសារព័ត៌មាន និងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅឆ្នាំ២០១៨ ដែលមិនអនុលោមតាមលក្ខខណ្ឌបីចំនុចនៃមាត្រា១៩ (៣) នៃ ក.អ.ស.ព.ន[160]។ លើសពីនេះទៀត ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និង បណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអិនធឺណិតរឹតត្បិតលើសិទ្ធិសេរីភាពបញ្ចេញមតិ។ ការហាមឃាត់នៅក្នុងប្រកាសអន្តរក្រសួងគឺមានលក្ខណៈទូលំទូលាយពេកនិងមិនច្បាស់លាស់សម្រាប់ប្រជាពលរដ្ឋដើម្បីកំណត់ថាតើខ្លឹមសារណាមួយដែលអនុញ្ញាតឬមិនអនុញ្ញាត។ លើសពីនេះទៅទៀតគោលបំណងនៃប្រកាសនេះមិនបានការពារសិទ្ធិនិងកេរ្តិ៍ឈ្មោះរបស់នរណាម្នាក់ឡើយឬដើម្បីការពារសន្តិសុខសណ្តាប់ ធ្នាប់សាធារណៈឬសុខភាពសាធារណៈនិងសីលធម៌។ ចុងក្រោយមានការផ្តន្ទាទោសសម្រាប់ការផ្សព្វផ្សាយ រួមមានបិទគេហទំព័រនិងចំណាត់ការផ្លូវច្បាប់ចំពោះបុគ្គលនិងនីតិបុគ្គល[161]។ ការផ្តន្ទាទោសទាំងនេះមិនមែនជាមធ្យោបាយរឹតត្បិតដែលចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងនៃប្រកាសនេះ[162]។មាត្រា៥ (១១)នៃច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នផ្តល់អំណាចទៅរាជរដ្ឋាភិបាលក្នុងការហាមឃាត់ការនិយាយស្តីឬបញ្ចេញមតិដែលនាំឱ្យមាន “ភ័យស្លន់ស្លោឬវឹកវរឬនាំឱ្យខូចខាតដល់សន្តិសុខជាតិ” ឬអាច "បង្កការភាន់ច្រឡំ" ក្នុងចំណោមសាធារណជន។ ប្រភេទនៃការនិយាយទាំងនេះគឺមិនច្បាស់លាស់គ្មានការកំណត់និងរំលោភបំពាន។ ស្ទើរតែគ្រប់ប្រភេទនៃការបញ្ចេញមតិអំពីស្ថានភាពអាសន្ន អាចត្រូវបានបកស្រាយថាជា “បង្កឱ្យមានការភ័ន្តច្រឡំ”។ ការហាមឃាត់រាល់និយាយដែលអាចបង្ក “ភាពច្របូកច្របល់” ឬ “ភាពវឹកវរ” មិនអាចត្រូវបានគេចាត់ទុកថាចាំបាច់នៅក្នុងភាពអាសន្នណាមួយឡើយ។ មាត្រា ៥ (១១) ដូច្នេះច្បាប់នេះនឹងស្របនឹងគោលការណ៍ សមាមាត្រនៃ ក.អ.ស.ព.ន ឡើយ។ មាត្រា ១ នៃ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ អនុញ្ញាតឱ្យបង្កើតរចនាសម្ព័ន្ធ ដែលអាចនាំឱ្យមានការរំលោភបំពានឯកជនភាព និងសេរីភាពខាងការបញ្ចេញមតិ។ មាត្រា១ដដែលមិនមានភាពច្បាស់លាស់ ដែលអនុញ្ញាតការរឹតត្បិតទៅលើសេរីភាពខាងការបញ្ចេញមតិ មិនមានគោលបំណងស្របច្បាប់និងមិនសមាមាត្រ។ មាត្រា៦ នៃអនុក្រឹត្យនេះបានអនុញ្ញាតឱ្យអាជ្ញាធរអាចតាមដានទំនាក់ទំនងតាមអនឡាញ ក្នុងករណីមានការសង្ស័យថាមាតិកានោះអាច “ប៉ះពាល់ដល់សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ភាពថ្លៃថ្នូរ វប្បធម៌ ទំនៀមទំលាប់ប្រពៃណី“។ ការអនុញ្ញាតឱ្យមានការរាំងខ្ទប់មាតិកាប្រឆាំងនឹងគោលដៅ ដែលមិនបានកំណត់ជាក់លាក់ ដែលលើសពីភាព |

[154] អង្គការពលកម្មអន្តរជាតិ, សេរីភាពខាងសមាគម: សេចក្តីសម្រេចរួមរបស់គណកម្មការធិការខាងសេរីភាពខាងសមាគម (បោះពុម្ពលើទី៦ការិយាល័យពលកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ ឆ្នាំ២០១៨) កថាខណ្ឌ៧៩៩ , “កាតព្វកិច្ចផ្តល់ការជូនដំណឹងមុនទៅនិយោជកមុនពេលរៀបចំកូដកម្មត្រូវបានពិចារណានិងទទួលយករហូតដល់មានហេតុផលសមរម្យ”។

[155] ដូចខាងលើ កថាខណ្ឌ៨០០ និង៨០១។

[156] ដូចខាងលើ កថាខណ្ឌ៨០៣។

[157] អង្គការពលកម្មអន្តរជាតិ, សេរីភាពខាងសមាគម: សេចក្តីសម្រេចរួមរបស់គណកម្មការធិការខាងសេរីភាពខាងសមាគម (ឆ្នាំ២០១៨) កថាខណ្ឌ៧៩៣។

[158] អង្គការពលកម្មអន្តរជាតិ, សេរីភាពខាងសមាគម: សេចក្តីសម្រេចនិងគោលការណ៍របស់គណៈកម្មាធិការខាងសេរីភាពខាងសមាគមនៃគណៈ អង្គការពលកម្មអន្តរជាតិ។ (បោះពុម្ពលើទី៥ការិយាល័យពលកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ ឆ្នាំ២០០៦) កថាខណ្ឌ៥៤៧។

[159] មាត្រា២(១) នៃក.អ.ស.ព.ន តម្រូវឱ្យរដ្ឋភាគី ការគោរពនិងដើម្បីធានាដល់បុគ្គលទាំងអស់នៅក្នុងទឹកដីនិងក្រោមយុត្តាធិការរបស់ខ្លួននូវសិទ្ធិដែលបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ។ លើសពីនេះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាថ្ងៃទី១០ខែកក្កដាឆ្នាំ ២០០៧ បានបកស្រាយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញថាសន្ធិសញ្ញាអន្តរជាតិដែលបានផ្តល់សច្ចាប័នដោយកម្ពុជារួមមានអ.ស.ព.ន ត្រូវបានអនុវត្តនៅក្នុងច្បាប់ជាតិ។ សូមមើលសេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញលេខ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

[160] សូមអានសូមមើល "របាយការណ៍ប្រចាំឆ្នាំលើកទី១ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែសីហា ឆ្នាំ២០១៧) ទំព័រ ៧-៨ ដែលអាចរកបាន៖ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf និងសូមអានសូមមើល "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ ២០១៨) ទំព័រ ៤ ដែលអាចរកបាន៖ https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=128&id=5

[161] សូមអាន អាយ. ស៊ី .អិន.អិល "ការវិភាគប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ិនធឺណិត" ខែកក្កដា ឆ្នាំ២០១៨ ដែលអាចរកបាន៖ http://sithi.org/judicial/docs/ICNL-Analysis-Prakas-on-Websites-and-Social-Media_July-2018.pdf

[162] ដូចខាងលើ។ ទំព័រ៥ ដល់ទី៨ ។

| | | | | |
|---|---|---|---|---|
| | | | | ចាំបាច់។ ការរឹតត្បិតមកលើសេរីភាពខាងការបញ្ចេញមតិក្រោមអនុក្រឹត្យនេះ មិនបានអនុវត្តតាមលក្ខខណ្ឌ៣ចំណុចនៃ ក.អ.ស.ន.ពនោះទេ។ [163] |
| ១.៣៣<br><br>ការនិយាយបង្ខូចកេរ្តិ៍មិនត្រូវមានទោស ព្រហ្មទណ្ឌទេ | កម្រិតនៃការបង្ខូចកេរ្តិ៍មិនត្រូវជាប់ទោស ព្រហ្មទណ្ឌទេ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ ដូចមាត្រា៣០៥ និង៣០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមានបទបរិហាកេរ្តិ៍និងការប្រមាថ។ ការបរិហារកេរ្តិ៍ត្រូវបានកំណត់ថា គ្រប់ការអះអាងបំផ្លើសឬ ទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសឬកិត្តិស័ព្ទនៃបុគ្គលឬស្ថាប័ន។ ការប្រមាថមានន័យថាពាក្យមើល ងាយឬគ្រប់ពាក្យត្រគោះដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយគឺជាការប្រមាថ។ ការដាក់ទោសនៃការបរិហារកេរ្តិ៍នៅក្នុងច្បាប់ជាតិគឺមានបញ្ហាពីព្រោះនិយមន័យមិនច្បាស់លាស់ដោយមិនតម្រូវចាំឱ្យមានគ្រោះថ្នាក់ណាមួយកើតឡើងឡើយ។ ការដាក់ទោសនេះមិនបានការពារអំពីការពិតឬផលប្រយោជន៍សាធារណៈតម្រូវដោយច្បាប់និងបទដ្ឋានអន្តរជាតិនោះដែរ[164]។ លើសពីនេះទៀតក្នុងការអនុវត្ត ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ព្រហ្មទណ្ឌអាចប្រើលើបុគ្គល "ស្ថាប័ន"<br><br>ដែលមិនបានគោរពតាមច្បាប់អន្តរជាតិ។ ខណៈដែលការពិន័យចំពោះការបរិហារកេរ្តិ៍ឬការជេរប្រមាថមិនបានបញ្ចូលទោសជាប់ពន្ធនាគារប៉ុន្តែបទល្មើសទាំងនេះត្រូវផ្តន្ទាទោសដោយការផាកពិន័យក្នុងក្រមព្រហ្មទណ្ឌ[165]។ លើសពីនេះនៅខែកុម្ភៈ ឆ្នាំ២០១៨ ការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌរួមទាំងមាត្រា ៤៣៧ស្ទួន "បទប្រមាថអង្គព្រះមហាក្សត្រ"។ បទល្មើសនេះផ្ទុយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលចែងច្បាស់ថាបុគ្គលសាធារណៈ ត្រូវតែប្រឈមនឹងការរិះគន់កម្រិតខ្ពស់ដោយគ្រាន់តែថាទម្រង់នៃការបញ្ចេញមតិបែបនេះត្រូវបានគេចាត់ទុកថាជាការប្រមាថដល់បុគ្គលសា ធារណៈដែលគួរនឹងមានការដាក់ទណ្ឌកម្មនោះទេ[166]។ ការបំពានមាត្រានេះ នាំឱ្យមានការពិន័យមិនស្មើគ្នាពោលគឺត្រូវជាប់ពន្ធនាគារពី ១ ឆ្នាំទៅ ៥ ឆ្នាំនិងពិន័យជាប្រាក់ពី ២ ទៅ ១០ លានរៀល។ មាត្រា ៧១ នៃ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា និងមាត្រា ៧១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏មានទោសព្រហ្មទណ្ឌចំពោះការបរិហារកេរ្តិ៍ដោយការរឹតត្បិតលើគណបក្សនយោបាយនិងបេក្ខជនឬអ្នកគាំទ្រនៅពេលថ្លែងដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរថាបានប្រើពាក្យ "អសីលធម៌" ឬ "ប្រមាថ" ក្នុងអំឡុងពេលឃោសនាបោះឆ្នោត[167]។ ខណៈដែលច្បាប់អន្តរជាតិអនុញ្ញាតឱ្យមានការរឹតត្បិតក្នុងការប្រើប្រាស់ពាក្យពេចន៍ក្នុងពេលបោះឆ្នោត លក្ខណៈមិនច្បាស់នៃបទប្បញ្ញត្តិនេះមិនត្រូវបានគោរពតាមស្តង់ដារអន្តរជាតិនោះទេពីព្រោះច្បាប់នេះផ្តល់ឱកាសឱ្យមានការរំលោភបំពាន-ការមិនយល់ស្របជាមួយគណបក្សនយោបាយអាចត្រូវបានកំណត់ថាជា"អំពើអសីលធម៌ឬប្រមាថ"[168]។ មាត្រា ៧១ បានចែងទាំងការពិន័យជាប្រាក់និងការលុបបេក្ខភាព។ ការពិនិត្យឡើងវិញនៃសូចនាករនេះត្រូវបានធ្វើនៅក្នុងឆ្នាំ២០២០ ហើយខណៈពេលដែលគ្មានការវិវឌ្ឍផ្នែកច្បាប់ពិន្ទុនេះត្រូវបានទម្លាក់មកត្រឹម ១ ពិន្ទុនៅពេលធ្វើការវាយតម្លៃឡើងវិញ។ នេះត្រូវបានគេរកឃើញពិន្ទុចំនួន ២ ដោយសារបទបរិហារកេរ្តិ៍មិនអនុវត្តទោសជាប់ពន្ធនាគារតាមក្រមព្រហ្មទណ្ឌទោះយ៉ាងណាសេចក្តីផ្តើមនៃការប្រព្រឹត្តបទល្មើស "ច្បាប់ប្រមាថអង្គព្រះមហាក្សត្រ" ក្នុងឆ្នាំទី៣ ផ្តន្ទាទោសដាក់ពន្ធនាគារជាការដាក់ទោសចំពោះទិដ្ឋភាពនៃបទបរិហារកេរ្តិ៍នេះ។ |
| ១.៣៤ ច្បាប់ការពារប្រឆាំងនឹងបណ្តឹងយុទ្ធិសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ | កម្រិតក្របខណ្ឌច្បាប់ដែលការពារប្រឆាំងនឹងបណ្តឹងយុទ្ធិសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | ប្រទេសកម្ពុជាបង្ហាញនូវចំណុចខ្វះខាតសំខាន់ៗក្នុងការអនុលោមតាមស្តង់ដារអន្តរជាតិទាក់ទងនឹងការហាមឃាត់ការប្រើប្រាស់យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ។ អវត្តមាននៃច្បាប់បទប្បញ្ញត្តិ ឬគោលនយោបាយជាក់លាក់ដែលហាមប្រាមយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ ជាគម្លាតដ៏សំខាន់នៅក្នុងក្របខ័ណ្ឌច្បាប់។ លើសពីនេះ កង្វះការផាកពិន័យចំពោះបុគ្គល ឬស្ថាប័នដែលដាក់ពាក្យបណ្តឹងបែបនេះ រឹតតែពង្រឹងការខ្វះខាតការការពារផ្លូវច្បាប់ប្រឆាំងនឹងការអនុវត្តបែបនេះ។<br><br>លើសពីនេះ វត្តមាននៃបទល្មើសដែលបានកំណត់យ៉ាងច្បាស់លាស់ជាច្រើននៅក្នុងក្រមព្រហ្មទណ្ឌ (ឧ. ការបរិហារកេរ្តិ៍ ការប្រមាថជាសាធារណៈ ការប្រមាថតាមសារព័ត៌មាន) បង្កើតលក្ខខណ្ឌអំណោយផលដល់ការប្រើប្រាស់យន្តការផ្លូវច្បាប់ខុស ដើម្បីបំបិទមាត់អ្នករិះគន់ ឬគាបសង្កត់ការបញ្ចេញមតិស្របច្បាប់។ បទល្មើសទាំងនេះដោយសារតែលក្ខណៈមិនច្បាស់លាស់ដែលមានចែង មិនបានគោរពតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងជួយសម្រួលដល់ធម្យោបាយនៃបណ្តឹងប្រឆាំងនឹងបុគ្គល និងអង្គភាពដែលចូលរួមក្នុងការចូលរួមជាសាធារណៈ។ |
| ១.៣៥<br><br>ការតាមដានមកលើការប្រាស្រ័យទាក់ទងអាចធ្វើបានក្រោយពេលមានការត្រួតពិនិ | កម្រិតនៃក្របខ័ណ្ឌច្បាប់ធានាថាការតា ដានមកលើការប្រាស្រ័យទាក់ទងអាច បានក្រោយពេល មានការត្រួតពិនិត្យពី តុលាការតែប៉ុណ្ណោះ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | ច្បាប់កម្ពុជាពុំបានបំពេញតាមចំណុចនេះទេ។ ច្បាប់ស្តីពីទូរគមនាគមន៍ដែលបានប្រកាសឱ្យប្រើនៅឆ្នាំ២០១៦ បានផ្តល់អំណាចទូលាយឱ្យរដ្ឋាភិបាលនូវក្នុងការតាមដានទូរគមនាគមន៍ដោយគ្មានការត្រួត ពិនិត្យពីប្រព័ន្ធតុលាការឬស្ថាប័នឯករាជ្យផ្សេងទៀត។ មាត្រា ៦ ចែងថា "ប្រតិបត្តិករទូរគមនាគមន៍និងអ្នកដែលពាក់ព័ន្ធនឹងវិស័យទូរគមានគមន៍ត្រូវផ្តល់ឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នូវទិន្នន័យសេវាកម្មបច្ចេកវិជ្ជាទូរគមនាគមន៍និងទិន្នន័យសេវាទូរគមនាគមន៍"។ យោងតាមបទបញ្ញត្តិនេះប្រតិបត្តិករទូរគមនាគមន៍មិនចាំបាច់ត្រូវឆ្លងការពិនិត្យពីតុលាការឬស្ថាប័នឯករាជ្យឡើយ។ ពាក្យថា "ទិន្នន័យសេវា" មិនត្រូវបានកំណត់នៅក្នុងច្បាប់ទេហើយអាចត្រូវបានបកស្រាយគ្រប់ប្រព័ន្ធបញ្ចូលការកំណត់ត្រាទំនាក់ទំនងអ្នកប្រើទាំងអស់ ប្រវត្តិស្វែងរក និងព័ត៌មានសម្ងាត់ផ្សេងទៀត។ នេះក៏រំលោភលើមាត្រា៤០ នៃរដ្ឋធម្មនុញ្ញដែលធានានូវសិទ្ធិរក្សាការសម្ងាត់។ មាត្រា៩៧ ច្បាប់ស្តីពីទូរគមនាគមន៍ចែងអំពីការលួចស្តាប់ ថតសម្លេងការ |

[163] សូមមើលចំណុចគន្លឹះទី១។

[164] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ អនុសាសន៍ទូទៅលេខ៣៤ UN Doc. CCPR/C/GC/34, (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១), កថាខណ្ឌ៤៧, <https://www2.ohchr.org/english/bodies/hrc/docs/gc34.pdfhttps://bit.ly/1xmySgV>.

[165] សូមអាន "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និង អាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៨ ដែលអាចរកបាន៖ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

[166] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'អនុសាសន៍ទូទៅលេខ៣៤' , UN Doc. CCPR/C/GC/៣៤, (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១), កថាខណ្ឌ៣៨ <https://www2.ohchr.org/english/bodies/hrc/docs/gc34.pdfhttps://bit.ly/1xmySgV>

[167] យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល២១ថ្ងៃ (មាត្រា៧២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា) និងរយៈពេល១៤ថ្ងៃសំរាប់ការបោះឆ្នោតឃុំ-សង្កាត់ (មាត្រា៧០នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់)។

[168] សហភាពអឺរ៉ុប, របាយការណ៍បញ្ចប់បេសកកម្មការត្រួតពិនិត្យនៅកម្ពុជា ឆ្នាំ២០១៥ <https://eeas.europa.eu/sites/eeas/files/efm_cambodia_2015_final_report_publ.pdf>

| | | | | |
|---|---|---|---|---|
| ត្បពីតុលាការតែប៉ុណ្ណោះ | | | | សន្ធនាបានលុះត្រាតែមានការអនុញ្ញាតពី“អាជ្ញាធរជម្មានរូប” ហើយការផ្សព្វផ្សាយពីកិច្ចសន្ធនាទាំងនោះក៏ចាំបាច់មានត្រូវមានការអនុញ្ញាតពី“អាជ្ញាធរជម្មានរូប”។ បទបញ្ញត្តិទាំងនេះមានលក្ខណៈទូលាយងាយស្រួលក្នុងការបំពានព្រោះពួកគេអនុញ្ញាតឱ្យមានការឃ្លាំមើលដោយគ្មានគណនេយ្យភាពសាធារណៈឬការការពារសុវត្ថិភាព។ ស្រដៀងគ្នានេះច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយឆ្នាំ២០១០ បានផ្តល់អំណាចដល់អង្គភាពដោយមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់តុលាការ[169]។ មាត្រា២៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយត្រូវបានអនុញ្ញាតឱ្យ “ឃ្លាំមើល ត្រួតត្រា ស្តាប់សម្លេង ថតចម្លងនិងថតរូបនិងថតសម្លេងទូរស័ព្ទ” ដែលមានព័ត៌មានច្បាស់លាស់នៃអំពើពុករលួយ។ ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សាយតាមគេហទំព័រនិងបណ្តាញសង្គមបានបរាជ័យនៅក្នុងសូចនាករនេះដោយសារការបង្កើត “ក្រុមការងារតាមដាន” រួមគ្នាជាមួយតំណាងក្រសួងដើម្បី “ត្រួតពិនិត្យ” និងចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងការផ្សព្វផ្សាយខុសច្បាប់នៅលើគេហទំព័រនិងប្រព័ន្ធផ្សព្វផ្សាយសង្គម។ មិនមានការនិយាយពីការត្រួតពិនិត្យតាមនីតិវិធីតុលាការឡើយ[170]។ មាត្រា ១ នៃ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិអនុញ្ញាតឱ្យបង្កើតរចនាសម្ព័ន្ធដែលជួយសម្រួលដល់ការតាមដានលើការចែករំលែកព័ត៌មានឬសកម្មភាពតាមអនឡាញ រួមទាំងទំនាក់ទំនងឯកជន ដោយមិនមានការដីកាពីតុលាការ។<br>លើសពីនេះ អនុក្រឹត្យចំនួនពីរបានចូលជាធរមានក្នុងឆ្នាំ២០២៣ បង្កើនការព្រួយបារម្ភទាក់ទងនឹងឯកជនភាពឌីជីថល និងសេរីភាពខាងការបញ្ចេញមតិ។ អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ( verify.gov.kh ) ខ្វះភាពច្បាស់លាស់អំពីរបៀបដែលអាជ្ញាធរនឹងការពារឯកជនភាពរបស់អ្នកប្រើប្រាស់ ជាពិសេសទាក់ទងនឹងលទ្ធភាពទទួលបានព័ត៌មានឯកជនរបស់រដ្ឋាភិបាល និងការកំណត់គោលដៅនៃក្រុមជាក់លាក់ ដូចជាសកម្មជន និងអ្នកសារព័ត៌មានជាដើម។ ភាពមិនច្បាស់លាស់នេះជួយសម្រួលដល់ការឃ្លាំមើលរបស់រដ្ឋ និងបង្កើតឥទ្ធិពលដល់ការបែកធ្លាយព័ត៌មាន។ អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ខ្វះគោលបំណង និងភស្តុតាងច្បាស់លាស់នៃប្រសិទ្ធភាព ការមិនបង្ហាញពីរបៀបដែលការចុះឈ្មោះការពារសុខុមាលភាពសាធារណៈ លើកកម្ពស់ការប្រកួតប្រជែងដោយយុត្តិធម៌ ឬរារាំងការប្រើប្រាស់ស៊ីមដែលមិនមានការអនុញ្ញាត ខណៈពេលដែលបង្កើនការព្រួយបារម្ភអំពីការឃ្លាំមើលដ៏មានសក្តានុពលរបស់រដ្ឋាភិបាល និងកង្វះនៃការរក្សាការសម្ងាត់ទិន្នន័យ ជាពិសេសសម្រាប់បុគ្គលដែលចូលរួមក្នុងសកម្មភាពសំខាន់ៗ។ ភាពខ្វះខាតទាំងនេះទាមទារឱ្យមានកំណែទម្រង់ផ្លូវច្បាប់ ដើម្បីធានាបាននូវការការពារឯកជនភាពដ៏រឹងមាំ ហេតុផលច្បាស់លាស់សម្រាប់ការប្រមូលទិន្នន័យ និងយន្តការត្រួតពិនិត្យឯករាជ្យដើម្បីការពារសិទ្ធិមនុស្សក្នុងវិស័យឌីជីថល។ |
| ១.៣៦<br>សិទ្ធិទទួលព័ត៌មានត្រូវបានការពារ និងលើកកម្ពស់ | ក្របខណ្ឌច្បាប់ ការពារ និងលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ ពីព្រោះសិទ្ធិទទួលព័ត៌មានមិនត្រូវបានការពារដោយច្បាប់ឡើយ[171]។ ទោះយ៉ាងណា រដ្ឋាភិបាលកំពុងធ្វើការលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ ច្បាប់ជាច្រើនមានឥទ្ធិពលទៅលើសិទ្ធិទទួលព័ត៌មានរួមមានច្បាប់ស្តីពីរបបសារព័ត៌មាននិងក្រមព្រហ្មទណ្ឌ។ ច្បាប់ស្តីពីរបបសារព័ត៌មានហាមឃាត់និងផ្តន្ទាទោសការបោះពុម្ពផ្សាយនូវការបញ្ចេញមតិជាច្រើន។ មាត្រា ១២ នៃច្បាប់នេះបង្កើតឱ្យមានការរឹតត្បិតលើរាល់ព័ត៌មាន ដែលអាចប៉ះពាល់ដល់សន្តិសុខជាតិនិងស្ថេរភាពនយោបាយ តែមិនតម្រូវថាទាល់តែមានទំនាក់ទំនងរវាងការបោះពុម្ពផ្សាយ និងហានិភ័យនៃគ្រោះថ្នាក់ឡើយ។ នេះបង្ហាញពីការខកខានក្នុងការការពារសិទ្ធិទទួលព័ត៌មាន។ បទល្មើសនៃការ “ក្លែងព័ត៌មាន” ក្រោមមាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌ កម្ពុជាបានដាក់ជាបទល្មើសព្រហ្មទណ្ឌនូវអំពើដែល ផ្តល់ឬបើកកកាយព័ត៌មានក្លែងដើម្បីធ្វើឱ្យជឿថា នឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូតខាត ប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស។ ការប្រើប្រាស់ពាក្យដែលមានន័យទូលំទូលាយ មិនច្បាស់លាស់នៃបទល្មើសបែបនេះ បណ្តាលឱ្យមានការអនុវត្តប្រឬកប្របល់ ដល់ការបញ្ចេញមតិដែលមិនមែនក្លែងក្លាយ ឬ ព័ត៌មានដែលជាមតិយោបល់។ នេះនឹងបង្កើនវិសាលភាពច្បាប់លើសពីកម្រិតនៃការរឹតត្បិតលើសេរីភាពនៃការបញ្ចេញមតិដែលត្រូវបានអនុញ្ញាត។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ ឆ្នាំទៅ ២ ឆ្នាំនិងពិន័យជាប្រាក់ពី ២ ទៅ ៤ លាន រៀល ការពិន័យនេះមើលទៅដូចជាមិនសមាមាត្រចំពោះសកម្មភាពព្រហ្មទណ្ឌទាល់តែសោះ។ ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នផ្តល់អំណាចដល់រាជរដ្ឋាភិបាល ក្នុងការហាមឃាត់ឬរឹតត្បិតការចែករំលែកឬប្រព័ន្ធផ្សព្វផ្សាយ[172] ដែលរារាំងសិទ្ធិក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មានក្នុងពេលមានអាសន្ន។ ច្បាប់នេះអនុញ្ញាតឱ្យរាជរដ្ឋាភិបាលដាក់រឹតត្បិតលើព័ត៌មាន ដែលអាចរារាំងដល់ការរាយការណ៍ប្រកបដោយតម្លាភាព ធ្វើឱ្យខូចខាតដល់ប្រជាពលរដ្ឋ ។ មាត្រា៦ នៃ អនុក្រឹត្យស្តីពី ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិអនុញ្ញាតឱ្យមានការបិទខ្ទប់ និងផ្តាច់មាតិកាអនឡាញទាំងឡាយណាដែលអាជ្ញាធរគិតថាប៉ះពាល់ដល់ “សុវត្ថិភាព ចំណូលរបស់រដ្ឋ សណ្តាប់ធ្នាប់សាធារណៈ ភាពថ្លៃថ្នូរ វប្បធម៌ ទំនៀមទំលាប់ប្រពៃណី” ដែលនេះនាំឱ្យមានការរឹតត្បិតមកលើមាតិកាទាំងនោះ រួមទាំងមាតិកាដែលមិនមានកំហុសដែលចាត់ទុកថាជំទាស់នឹងគោលបំណងទាំងនេះ។ [173] |

[169] សូមអាន "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៤ ដែលអាចរកបាន៖ https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=128&id=5

[170] ប្រកាសអន្តរ, ចំណុចទី៤ សូមមើល កាន់ វិច្ឆិកា, 'កម្ពុជាបង្កើតក្រុមការងារតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយតាមប្រព័ន្ធផ្សព្វផ្សាយនិងបណ្តាញសង្គម' (វីអូអេ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨), <https://www.voacambodia.com/a/cambodia-forms-task-force-to-monitor-fake-news-on-social-media/4425534.html>

[171] ខែមីនា ឆ្នាំ២០១៨ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានបញ្ជាក់ថាសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។ សូមមើល ខ្មែរថាមស៍ 'ការត្រៀមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន', )ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ដោយ តាំងវីដា ( https://www.khmertimeskh.com/50577422/access-to-information-draft-law-ready/ ។ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន អាចរកបាននៅ https://www.phnompenhpost.com/Assets/doc/Doc-Jan-31-2018-15-30-en.pdf

[172] មាត្រា ៥ (១១) នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។

[173] សូមមើលចំណុចគន្លឹះទី១។

| | | | | |
|---|---|---|---|---|
| ១.៣៧<br><br>សិទ្ធិប្រើប្រាស់អ៊ិនធឺណិតមិនអាចត្រូវបានកាត់ផ្តាច់តាមអំពើចិត្តនោះទេ | កម្រិតនៃសិទ្ធិប្រើប្រាស់អ៊ិនធឺណិតត្រូវបានធានាដោយច្បាប់ និងការពារពីការរឹតត្បិតតាមអំពើចិត្ត | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ។ ខណៈដែលគ្មានបទប្បញ្ញត្តិផ្តល់អំណាចដល់រដ្ឋាភិបាលអាចបិទប្រព័ន្ធអ៊ិនធើណិត មាត្រា៧ នៃច្បាប់ស្តីពីទូរគមនាគមន៍អាចនាំឱ្យមានអនុវត្តតាមអំពើចិត្តដើម្បីបិទអ៊ីនធឺណិតបាន។ មាត្រា៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ចែងថា "ក្នុងករណីដែលមានភាពមិនប្រក្រតី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រសួងឬស្ថាប័នដែលមានសមត្ថកិច្ចអាចបញ្ជាឱ្យប្រតិ បត្តិករទូរគមនាគមន៍ពាក់ព័ន្ធចាត់វិធានការចាំបាច់ដោយផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល"។<br>បន្ថែមពីលើនេះក៏បានផ្តល់ឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក្រោមមាត្រា២៤ ដែលចែងថា "រចនាសម្ព័ន្ធទូរគមនាគមន៍ និងបណ្តាញទូរគមនាគមន៍ និងរចនាសម្ព័ន្ធគាំទ្រដល់ទូរគមនាគមន៍នឹងស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងប្រៃសនីយ៍និងទូរ គមនាគមន៍"។ ក្រោមបទប្បញ្ញត្តិទាំងនេះរដ្ឋាភិបាលទំនងជាទទួលបានការត្រួតពិនិត្យគ្រប់ឧស្សា ហកម្មទូរគមនាគមន៍រួមមានសកម្មភាពនិងហេដ្ឋារចនាសម្ព័ន្ធ។ ក្រុមការងារពិសេសដែលបង្កើតឡើងដោយប្រកាសអន្តរក្រសួងក៏មានអំណាចផ្តាច់សេវាប្រព័ន្ធអ៊ីនធឺណិតដោយមិនចាំបាច់មានការត្រួតពិនិត្យពីតុលាការដើម្បីទប់ស្កាត់ការអនុវត្តន៍តាមអំពើចិត្តឡើយ[174]។ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិត ជាតិ អនុញ្ញាតឱ្យមានការបង្កើតរចនាសម្ព័ន្ធដែលប្រមូលផ្តុំការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិត របស់រាជរដ្ឋា ភិបាល[175]។ ហើយនេះ ក៏បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការកាត់ផ្តាច់អ៊ីនធឺណិត។[176] |
| **ចំណុចគន្លឹះទី២៖ ក្របខណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិត្រូវបានអនុវត្តនិងប្រត្តិបត្តិតាមត្រឹមត្រូវឬទេ ?** | | | | |
| ធាតុផ្សំ | សូចនាករ | ប្រភពទិន្នន័យ | ២០២៣ | *កំណត់សម្គាល់* |
| ២.១<br><br>ស្ថាប័នរដ្ឋាភិបាលយល់ពីសិទ្ធិ និងកាតព្វកិច្ចទាក់ទិននឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | %នៃការថ្លែងតាមប្រព័ន្ធផ្សព្វផ្សាយបង្ហាញឱ្យឃើញពីកង្វះការយល់ដឹង ឬការបកស្រាយមិនត្រឹមត្រូវអំពីសេរីភាពខាងការបង្កើតសមាគមជួបប្រជុំ និងបញ្ចេញមតិ របស់តំណាងរដ្ឋាភិបាល | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ១០% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាការថ្លែង២៦២ ករណី ក្នុងចំណោមនោះការថ្លែងចំនួន២៤ របស់មន្ត្រីរដ្ឋាភិបាលបង្ហាញពីកង្វះការយល់ដឹង ឬបកស្រាយមិនត្រឹមត្រូវអំពីសេរីភាពមូលដ្ឋាន។ |
| ២.២<br><br>អាជ្ញាធរ និងភាគីទីបីទទួលខុសត្រូវចំពោះការរំលោភច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | # របាការណ៍បន្ថែមឱ្យឃើញថាអាជ្ញាធរ និងភាគីទីបីទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា២៦២ករណី ដោយ១ករណី អាជ្ញាធរឬភាគីទីបីដែលត្រូវទទួលខុសត្រូវចំពោះការរំលោភបំពាន។ |
| | # របាការណ៍បន្ថែមឱ្យឃើញថាអាជ្ញាធរ និងភាគីទីបីទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | ២ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា៣៧១ ករណី ដែល២ករណី អាជ្ញាធរឬភាគីទីបីដែលត្រូវទទួលខុសត្រូវចំពោះការរំលោភបំពាន ។ |

[174] ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ប្រការ ៤ ។

[175] មាត្រា១នៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ។

[176] សូមមើលចំណុចគន្លឹះទី១។

| | | | | |
|---|---|---|---|---|
| ២.៣ សេរីភាពអាចអនុវត្តដោយគ្មានជ្រៀតជ្រែកនិងគំរាមកំហែង | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានកោះហៅសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៦៩ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាមនុស្ស ៦៩ នាក់នៃការកោះហៅ។ |
| | # នៃបុគ្គលម្នាក់ៗត្រូវបានកោះហៅសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងនិងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | ២៩ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា២៩នាក់ដែលត្រូវបានកោះហៅ។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានសាកសួរសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៨៧ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាមនុស្ស ៨៧ នាក់ដែលត្រូវបានសាកសួរ។ |
| | # នៃបុគ្គលម្នាក់ៗត្រូវបានសាកសួរសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | ១៩ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រាមនុស្ស ១៩ នាក់ដែលត្រូវបានសាកសួរ។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានឃាត់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៩៥ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាមនុស្ស៩៥ នាក់ដែលត្រូវបានឃុំខ្លួន។ |

| | | | | |
|---|---|---|---|---|
| | # នៃបុគ្គលម្នាក់ៗបានឃាត់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | ៤ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រាមនុស្ស ៤ នាក់ដែលត្រូវបានឃុំខ្លួន។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវធ្វើសេចក្តីយល់ព្រមដោយរដ្ឋាភិបាលដើម្បីចុះហត្ថលេខា និងផ្តិតមេដៃលើលិខិតយល់ព្រមសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ២៥ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានកត់ត្រាមនុស្ស ២៥ នាក់ដែលត្រូវបានធ្វើសេចក្តីយល់ព្រម ចុះហត្ថលេខា និងផ្តិតមេដៃ។ |
| | # នៃបុគ្គលម្នាក់ៗត្រូវធ្វើសេចក្តីយល់ព្រមដោយរដ្ឋាភិបាលដើម្បីចុះហត្ថលេខា និងផ្តិតមេដៃលើលិខិតយល់ព្រមសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | ៥ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រាមនុស្ស៥ នាក់ដែលត្រូវធ្វើសេចក្តីយល់ព្រមចុះហត្ថលេខា និងផ្តិតមេដៃ។ |
| | # នៃបុគ្គលម្នាក់ៗនិងអង្គភាពបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានកាត់ទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ១០០ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាមនុស្សចំនួន ១០០នាក់ ដែលបានកាត់ទោស។ |

| | | | | |
|---|---|---|---|---|
| | # នៃបុគ្គលម្នាក់ៗនិងអង្គភាពត្រូវបានកាត់ទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | ២ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រាមនុស្ស២នាក់ ដែលបានកាត់ទោស។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានចាប់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ១០៥ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាមនុស្ស ១០៥ នាក់ បានចាប់ខ្លួន។ |
| | # នៃបុគ្គលម្នាក់ៗត្រូវបានចាប់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | ២ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រាមនុស្ស២នាក់ដែលត្រូវបានចាប់ខ្លួន។ |
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពដែលរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ សេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៩១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាមនុស្ស ៩១នាក់ដែលត្រូវបានផ្តន្ទាទោស។ |

| | | | | |
|---|---|---|---|---|
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពដែលផ្តន្ទាទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ សេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | ២ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រាមនុស្ស២នាក់ដែលត្រូវបានផ្តន្ទាទោស។ |
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពដែលរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាលសម្រាប់ការអនុវត្តសេរីភាពខាងការបង្កើតសមាគម សេរីភាពខាងជួបប្រជុំ សេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៤៣ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា៤៣ ករណី បុគ្គលឬអង្គភាពណាមួយដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាល។ |
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពណាមួយដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាលក្នុងការអនុវត្តសេរីភាពខាងការបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | ១ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ១ ករណី អំពីបុគ្គលឬអង្គភាពដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាល។ |
| ២.៤ ស្ថាប័នរដ្ឋាភិបាលគោរពសិទ្ធិកាតព្វកិច្ច និងការប្រើប្រាស់សេរីភាពខាងការបង្កើតសមាគម | # រាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដែលបង្ហាញថារដ្ឋាភិបាល គោរពសិទ្ធិ កាតព្វកិច្ចនិងការប្រើប្រាស់ សេរីភាពខាងការបង្កើតសមាគម | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ០ | ការតាមដានប្រព័ន្ធផ្សព្វផ្សាយមិនបាន់កត់ត្រាករណីណាមួយដែររដ្ឋាភិបាលការពារសេរីភាពខាងសមាគម។ |
| | # ករណីរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយដែលរដ្ឋាភិបាល រំលោភលើសេរីភាពខាងការ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៧១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៧១ ករណីនៃហេតុការណ៍ដែលស្ថាប័នរដ្ឋាភិបាលបានរំលោភលើសេរីភាពខាងសមាគម។ |

| | | | | |
|---|---|---|---|---|
| | # ចំនួនហេតុការណ៍ ដែល រដ្ឋាភិបាល រំលោភលើសេរីភាពខាង ការបង្កើតសមាគម | ការរាយការណ៍ពី ហេតុការណ៍ | ៩០ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ៩០ ករណីនៃហេតុការណ៍ដែលស្ថាប័នរដ្ឋាភិបាលបានរំលោភលើសេរីភាពខាងសមាគម។ |
| ២.៥<br>ការចុះបញ្ជីសមាគម ត្រូវបានអនុវត្តដោយ យុត្តិធម៌ និងតម្លាភាព | កម្រិតនៃ ដំណើរការចុះបញ្ជី សមាគមត្រូវបានអនុវត្តដោយ យុត្តិធម៌និងតម្លាភាព | ការតាមដានពី នីតិវិធីចុះបញ្ជី អង្គការសមាគម | 0 | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាថាពុំមានករណីណាមួយដែលលិខិតចុះបញ្ជីត្រូវបានបដិសេធដោយសារតែមាន សមាគមជាច្រើនដែលមានរូចស្រាប់ដែលមានគោលដៅស្រដៀងៗគ្នា។ |
| ២.៦<br>មានសមាគមច្រើន ដែល គោលបំណង ស្រដៀងគ្នា | # ពាក្យសុំចុះបញ្ជីត្រូវបានបដិសេធ ដោយសារតែមានសមាគមច្រើនដែលមាន គោលបំណងស្រដៀងគ្នា | ការរាយការណ៍ ពីហេតុការណ៍ | 0 | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រាថាពុំមានករណីណាមួយដែលលិខិតចុះបញ្ជីត្រូវបានបដិសេធដោយសារតែមានសមាគមជា ច្រើនដែលមានរួចស្រាប់ដែលមានគោលដៅស្រដៀងៗគ្នា។ |
| | | ការតាមដានពី នីតិវិធីចុះបញ្ជី អង្គការសមាគម | 0 | ឧបករណ៍វាយតម្លៃការចុះបញ្ជីអង្គការសមាគមមិនបានកត់ត្រាករណីបដិសេធចុះបញ្ជីដោយសារមូលហេតុបែបនេះទេ។ |
| ២.៧<br>សមាគមអាច បង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬ ប្រភេទផ្សេងទៀត នៃសហជីព ដោយ សេរី | % នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ អំពីការ ជ្រៀតជ្រែក មកលើគោលបំណង បង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីព | ការស្ទង់មតិថ្នាក់ ដឹកនាំអង្គការ សង្គមស៊ីវិលនិង សហជីព | ៣១% | សូមមើលសំណួរ៤.១ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # ហេតុការណ៍ ដែលមានការ ជ្រៀតជ្រែកមកលើ គោល បំណង សមាគមក្នុងការបង្កើតបណ្តាញ ស ម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀត | ការរាយការណ៍ពី ហេតុការណ៍ | ២ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា២ ករណីនៃការជ្រៀតជ្រែកដែលសមាគមប៉ុនប៉ង់ដើម្បីបង្កើតបណ្តាញសម្ព័ន្ធ សហព័ន្ធ សហជីព ឬប្រភេទផ្សេងទៀតនៃសហជីព។ |
| ២.៨<br>សមាជិកនៃអង្គការ សមាគម សម្ព័ន្ធ សហព័ន្ធ មានសិទ្ធិ ដកខ្លួនចេញបាន | % នៃថ្នាក់ដឹកនាំសមាគមបាន រាយការណ៍អំពីសិទ្ធិខ្លួនដក ខ្លួនចេញពីសមាជិក | ការស្ទង់មតិថ្នាក់ ដឹកនាំអង្គការ សង្គមស៊ីវិលនិង សហជីព | ៥១% | សូមមើលសំណួរ៤.៣.១ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |

| | | | | |
|---|---|---|---|---|
| ២.៩<br>សមាគមដំណើរការដោយពុំមានការជ្រៀត ជ្រៀកពីរដ្ឋាភិបាល | % នៃថ្នាក់ដឹកនាំសមាគមបានរាយការណ៍អំពីការជ្រៀតជ្រែងលើសលុបពីសំណាក់រដ្ឋាភិបាលក្នុងឆ្នាំមុន | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៥៨% | សូមមើលសំណួរ៤.៥ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # ហេតុការណ៍ដែលរដ្ឋាភិបាលជ្រៀតជ្រែកមកលើសមាគម រំលោភលើបទដ្ឋានអន្តរជាតិបង្ហាញក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៧០ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា៧០ ករណី នៃការត្រួតត្រារបស់រដ្ឋាភិបាលលើសមាគមដែលជាការរំលោភលើស្តង់ដារអន្តរជាតិ។ |
| | # ហេតុការណ៍ដែលរដ្ឋាភិបាលជ្រៀតជ្រែកមកលើសមាគម រំលោភលើបទដ្ឋានអន្តរជាតិបង្ហាញក្នុងការរាយការណ៍ហេតុការណ៍ | ការរាយការណ៍ពីហេតុការណ៍ | ៩១ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ៩១ ករណី នៃការត្រួតត្រារបស់រដ្ឋាភិបាលលើសមាគមដែលជាការរំលោភលើស្តង់ដារអន្តរជាតិ។ |
| ២.១០<br>បុគ្គលពុំបានក្លាយជាគោលដៅដោយសារតែការចូលរួមជាមួយសមាគមនោះទេ។ | %នៃបុគ្គលដែលរាយការណ៍អំពីការក្លាយជាជនរងគ្រោះដោយសារតែការចូលរួមជាមួយសមាគម | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៣០% | សូមមើលសំណួរ៥.៦ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | %នៃបុគ្គលដែលរាយការណ៍អំពីការក្លាយជាជនរងគ្រោះដោយសារតែការចូលរួមជាមួយសមាគម | ការស្ទង់មតិជាសាធារណៈ | ២២% | សូមមើលសំណួរ៣.៤ នៃការស្ទង់មតិសាធារណៈ។ |
| ២.១១<br>សមាគមត្រូវបានការពារពីការជ្រៀតជ្រែករបស់ភាគីទីបី។ | % នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ការជ្រៀតជ្រែកពីភាគីទីបី | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ២៧% | សូមមើលសំណួរ៤.៧ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # នៃហេតុការណ៍របស់ជនទីបីបានជ្រៀតជ្រែកសមាគម | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៤៨ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៤៨ ករណី ដែលបង្ហាញថាសមាគមត្រូវបានរំខានធ្វើទុក្ខបុកម្នេញដោយ ភាគីទីបី។ |

| | | | | |
|---|---|---|---|---|
| | | | | |
| | # នៃហេតុការណ៍របស់ជនទីបីបានជ្រៀតជ្រែកសមាគម | ការរាយការណ៍ពីហេតុការណ៍ | ៧៣ | ការរាយការណ៍ហេតុការណ៍បានកត់ត្រា ៧៣ ករណី ដែលបង្ហាញថាថ្នាក់ដឹកនាំសមាគមត្រូវបានរំខានធ្វើទុក្ខបុកម្នេញដោយភាគីទីបី។ |
| ២.១២<br><br>សមាគមមិនប្រឈមនឹងលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលជាបន្ទុក និងស្មុគស្មាញ | % នៃថ្នាក់ដឹកនាំសមាគមដែលប្រឈមនឹងលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលជាបន្ទុក និងស្មុគស្មាញ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៤៥% | សូមមើលសំណួរ៤.១២ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| ២១.៣<br><br>ការដាក់ទណ្ឌកម្មលើសមាគមត្រូវបានអនុវត្តស្របតាមច្បាប់របស់<br><br>កម្ពុជា | # ការរាយការណ៍ហេតុការណ៍ដែលការដាក់ទោសដោយពុំបានអនុវត្តស្របទៅតាមច្បាប់របស់កម្ពុជា | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ១ ករណីនៃការដាក់ទណ្ឌកម្មលើសមាគមណាមួយដែលមិនត្រូវបានអនុវត្តស្របតាមច្បាប់កម្ពុជាឡើយ។ |
| | # ការរាយការណ៍ហេតុការណ៍ដែលការទណ្ឌកម្មដោយពុំបានអនុវត្តស្របទៅតាមច្បាប់របស់កម្ពុជា | ការរាយការណ៍ពីហេតុការណ៍ | ០ | ការរាយការណ៍ពីហេតុការណ៍ពុំបានកត់ត្រាករណី នៃការដាក់ទណ្ឌកម្មលើស្ថាប័ន សមាគម ដោយពុំបានអនុវត្តស្របទៅតាមច្បាប់របស់កម្ពុជា។ |
| ២១.៤<br><br>សមាគមបានឧបាស្រ័យ ប្រសិនបើពួកគេត្រូវបានដាក់ទោស | % នៃថ្នាក់ដឹកនាំសមាគមរាយការណ៍ថាអាចទទួលបានគ្រាំទ្រ និងជំនួយផ្នែកច្បាប់ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៤៧% | សូមមើលសំណួរ៤.១៩ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។<br><br>ចំនួនឆ្លើយតបតិចតួចចំពោះសំណួរនេះមានន័យថាមានភាពប្រសើរឡើងពី១ឆ្នាំទៅ១ឆ្នាំ។ សំណួរនេះបានផ្លាស់ទៅ ៤.១៦.១ ក្នុងកម្រងសំណួរឆ្នាំ២០២២។ |
| ២១.៥<br><br>ការរំលាយសមាគម ធ្វើបានក្រោយពេលមធ្យោបាយ ផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់ | # ហេតុការណ៍រាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយនៃការរំលាយណាមួយក្រោយពេលមធ្យោបាយផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយពុំបានកត់ត្រាករណីនៃការរំលាយសមាគមដោយមិនស្ម័គ្រចិត្ត។ |

| | | | | |
|---|---|---|---|---|
